# មាតិកា

## ជំពូក១៖ ស្ថានភាពរួម


១- សេចក្តីសង្ខេប ៖ 3
២- សេចក្តីផ្តើម 6
៣- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ 7
៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy) 7
៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ 8
៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ 11
៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក 13
៤- កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ 14
៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ 14
៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១១ 15
៤.៣-ការអភិវឌ្ឍន៍ផលិតកម្មកសិកម្មរយៈពេល ៥ឆ្នាំ 18


## ជំពូក២៖ លទ្ធផលនិងទិសដៅ


៥-លទ្ធផលឆ្នាំ២០១១-២០១២និងទិសដៅឆ្នាំ២០១២-២០១៣ 28
៥.១- ផលិតកម្មដំណាំស្រូវនិងដំណាំផ្សេងៗ (ឧបសម្ព័ន្ធទី១- ៩) 28
៥.២. ការងារកសិកម្ម 29
៥.២.១. លទ្ធផល 29
៥.២.២. វាយតម្លៃនិងសន្និដ្ឋាន 35
៥.២.៣. វិធានការនិងទិសដៅ 36
៥.៣- ផលិតកម្មនិងបសុព្យាបាល (ឧបសម្ព័ន្ធទី១០-១២) 37
៥.៣.១-លទ្ធផល 37
៥.៣.២-វាយតម្លៃនិងសន្និដ្ឋាន 48
៥.៣.៣-វិធានការនិងទិសដៅ 49
៥.៤-ផលិតផលដំណាំកៅស៊ូ (ឧបសម្ព័ន្ធទី១៣-១៥) 49
៥.៤.១-លទ្ធផល 50
៥.៤.២-វាយតម្លៃនិងសន្និដ្ឋាន 51
៥.៤.៣-វិធានការនិងទិសដៅ 52
៥.៥- លទ្ធផលការងាររុក្ខកម្ម 53
៥.៥.១-លទ្ធផល 53

៥.៥.២. វាយតម្លៃនិងសន្និដ្ឋាន ..... 59

៥.៥.៣. វិធានការនិងទិសដៅ ..... 59

**៥.៦- ការងារជលផល** (ឧបសម្ព័ន្ធទី១៦-១៨) ..... 60

៥.៦.១- លទ្ធផល ..... 60

៥.៦.២- វាយតម្លៃនិងសន្និដ្ឋាន ..... 62

៥.៦.៣. វិធានការ ..... 63

**៥.៧- ការងារសេវាកម្មនិងការគាំទ្រ** ..... 63

៥.៧.១-ការងារគោលនយោបាយផែនការ និងវិនិយោគ ..... 63

៥.៧.២-ការងារសហប្រតិបត្តិការអន្តរជាតិ ..... 69

៥.៧.៣-ការងារកិច្ចការរដ្ឋបាល ..... 73

៥.៧.៤-ការងារនីតិកម្មកសិកម្ម ..... 74

៥.៧.៥-ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង ..... 77

៥.៧.៦-ការងារស្រាវជ្រាវកសិកម្ម ..... 79

៥.៧.៧- ការងារកសិ-ឧស្សាហកម្ម ..... 85

៥.៧.៨- ការងារយេនឌ័រ ..... 86

**៥.៨- ធនធានមនុស្សនិងថវិកា** ..... 88

៥.៨.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ..... 88

៥.៨.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ ..... 90

៥.៨.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ ..... 98

**៥.៩- កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍** ..... 103


## ជំពូក១៖ វាយតម្លៃនិងសន្និដ្ឋាន


**៦-វាយតម្លៃរួម** ..... 109

**៧-ទិសដៅរួម** ..... 110

**៨. វាយតម្លៃ និង សន្និដ្ឋាន** ..... 115

# ជំពូក ១
# ស្ថានភាពរួម

## ១- សេចក្តីសង្ខេប ៖

ឆ្នាំ២០១១ គឺជាឆ្នាំទី៤ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ មុតមាំ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

មកទល់ពេលនេះ ការងារបង្កបង្កើនផលរដូវវស្សានិងរដូវប្រាំង ត្រូវបានបញ្ចប់ការដាំដុះជាស្ថាពរ និងជាការឈានដល់ពេលកំណត់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រារព្ធធ្វើសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១១-២០១២ និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំ២០១២-២០១៣ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីសមិទ្ធផល ដែលសម្រេចបានជាវិជ្ជមាន ក៏ដូចជាការប្រមូលផ្តុំនូវមតិយោបល់ ទស្សនៈទៅលើបញ្ហាប្រឈមទាំងឡាយ និងការវិភាគចែករំលែកលើបទពិសោធន៍ល្អៗ ជាពិសេសការផ្តល់អនុសាសន៍គន្លឹះដ៏មានតម្លៃរបស់**សម្តេចនាយករដ្ឋមន្ត្រី** ដើម្បីជាត្រីវិស័យក្នុងការរៀបចំជាចក្ខុវិស័យ ជាយុទ្ធសាស្ត្រ និងលើកទិសដៅអនុវត្តបន្តនៅឆ្នាំបន្ទាប់ ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា។

នារយៈពេលមួយឆ្នាំកន្លងមកនេះ បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ ពិសេសគ្រោះទឹកជំនន់បង្កដោយជំនន់ទឹកភ្លៀងចុងរដូវវស្សា (ចាប់ពីពាក់កណ្តាលខែតុលាដល់ពាក់កណ្តាលខែវិច្ឆិកា) ព្រមទាំងភាពស្ថិតនៅក្រោមការស្តារផលប៉ះពាល់ដោយវិបត្តិកលយុគ្គសេដ្ឋកិច្ចពិភពលោក តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្ម នៅតែមានការកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែងស្រូវរដូវវស្សាឆ្នាំ២០១១នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃគ្រោះធម្មជាតិ ក៏ស្ថានភាពផលិតកម្មកសិកម្ម ជារួមមានកម្រិត ល្អទូទាំងប្រទេស។ យើងបានដាំដុះស្រូវរដូវវស្សាលើផ្ទៃដីសរុប ២,៥០លានហត ដែលមានទិន្នផលជាមធ្យមចំនួន ២,៩២ត/ហត ដោយទទួលបរិមាណផលសរុបប្រមាណ ៦,៧លានតោន និងស្រូវរដូវប្រាំងឆ្នាំ២០១១-២០១២ លើផ្ទៃដីជាង០,៤៧លានហិកតា ដែលមានទិន្នផលជាមធ្យម៤,៤ត/ហត ដោយទទួលបានបរិមាណផលសរុប ២,០៨លានតោន។ សរុបទាំងរដូវវស្សានិងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុប២,៩៧លានហត ដោយទទួលបរិមាណផលសរុបប្រមាណ ៨,៧៨លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ៣,១៧ត/ហត។ ដូច្នេះតុល្យភាពស្បៀងនៅសល់ជាង ២,៧៨លានតោនអង្ករ គិតជាស្រូវជាង ៤,៣៤លានតោន លើសឆ្នាំមុន ០,៤លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំកន្លងមកប្រមាណ១,៣លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំណាស់។ ការពិសាធន៍ស្រាវជ្រាវដំណាំ ការស្វែងរកបច្ចេកទេស សមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំ កំពុងត្រូវបានដំណើរការយ៉ាងផុសផុល ពិសេសការបានអនុវត្តការងារពិសោធន៍ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅតាមកសិដ្ឋានស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្ម និងស្រែកសិករ មានជាអាទិ៍ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធិភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សាំពូជ និងការពិសោធន៍អំពីវិធីសាស្ត្រដាំដុះដំណាំផ្សេងៗទៀត។ ការធ្វើបង្ហាញទិវាស្រែ និងការរៀបចំទស្សនៈកិច្ចសិក្សា ដោយមានកសិករចូលរួមត្រូវបានអនុវត្តយ៉ាងសកម្ម។

ចំពោះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុន។ ជារួមឈានមកដល់ពេលបច្ចុប្បន្នការងារបង្កបង្កើនផលដំណាំឆ្នាំ២០១១-២០១២នេះ ទទួលបានផលយ៉ាងល្អប្រសើរ។

ដោយឡែកផលិតកម្មសត្វនៅកម្ពុជាជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍ជាវិជ្ជមានគួរកត់សម្គាល់ ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុកនិងគោ-ក្របី ត្រូវបាននាំចេញទៅបរទេសមួយចំនួនផងដែរ។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១១ ឃើញថាផលិតកម្មគោកើនប្រមាណ ១,១% ក្របីថយចុះ ១,៧៤%។ ការចិញ្ចឹមបក្សីពីឆ្នាំ២០០៧ ដល់ ២០១១ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៧% គឺពី ១៥លានក្បាល ដល់ ២១,៦លានក្បាល។

ចំពោះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែផ្សេងៗ និងចំការ។ល។ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សម្គាល់ថា មកដល់ឆ្នាំ២០១១ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសមានចំនួន ២១៣.១០៤ហត គឺកើនឡើង ១៧,៥% ប្រៀបធៀបទៅនឹងឆ្នាំ២០១០ ក្នុងនោះ ការអភិវឌ្ឍវិស័យកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

វិស័យព្រៃឈើកំពុងតែត្រូវធានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ។ មកទល់នឹងឆ្នាំ២០១១នេះ សកម្មភាពដាំឈើជាចំការសម្រេចបានសរុបចំនួន ៣៣.៥៤០ហត ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបានចំនួន ១.៨២០ហត ក្រុមហ៊ុនវិនិយោគឯកជនដាំដុះបានចំនួន ៣០.៣៦៥ ហត គ្រួសារឯកជនខ្នាតតូចដាំបាន ១.៣៥៥ ហត។ ទន្ទឹមនឹងនោះ សហគមន៍ព្រៃឈើសរុបចំនួន ៥៦១ សហគមន៍ត្រូវបានបង្កើតឡើង ហើយគ្រប់គ្រងលើផ្ទៃដីសរុបចំនួន ៤៨១.៧៧៩ហត។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង ១០% គឺពី ៤០៥ពាន់តោននៅឆ្នាំ២០១០ ដល់ ៤៤៥ពាន់តោននៅឆ្នាំ២០១១ ហើយអាជីវកម្មនេសាទសមុទ្រសម្រេចបាន ៩១ពាន់តោន កើនលើសឆ្នាំមុន ៧%។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើ សម្រេចបាន ៧២ពាន់តោន កើនបាន ២០% និងសហគមន៍នេសាទមានចំនួន ៤៦៩សហគមន៍ ដែលបានចុះបញ្ជីការធ្វើអាជីវកម្មនេសាទចំនួន៣២៤សហគមន៍រួចហើយ។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្ម និងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ដូចជាការងារវិនិយោគសាធារណៈ ការរៀបចំគម្រោងសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការកើនឡើង ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្មកាន់តែទូលំទូលាយ កិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានធ្វើកាន់តែច្រើនផងដែរ។

តាមការរៀបរាប់ខាងលើ យើងអាចវាយតម្លៃបានថា បរិមាណផលិតកម្មស្រូវមានការកើនឡើង បើប្រៀបធៀបនឹងឆ្នាំកន្លងមក ជារួមការងារបង្កបង្កើនផលកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំកំពុងវិវឌ្ឍន៍ល្អ និងមានការចាប់អារម្មណ៍ខ្ពស់ពីប្រជាកសិកររបស់យើង។

នេះជារបត់មួយដែលកសិករយើងកំពុងកែទម្លាប់ពីកសិកម្មបុរាណ ដោយផ្អែកតាមយថាផលមកជាកសិកម្មលក្ខណៈជឿនលឿន និងស៊ីជម្រៅ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថា ការដាំដុះដំណាំរួមផ្សំផ្សេងទៀត ដោយមិនពឹងផ្អែកតែលើស្រូវតែមួយមុខ ក៏បាននិងកំពុងទទួលការយកចិត្តទុកដាក់ផងដែរ។ ជារួមចំពោះមុខនិងទៅអនាគត យើងជឿជាក់ថា ការងារបង្កបង្កើនផលកសិកម្មនៅតែមានសក្តានុពល និងមានការវិវឌ្ឍន៍រីកចម្រើនច្រើន ដែលជាប្រភពជំរុញកំណើនសេដ្ឋកិច្ច នៅជនបទដ៏មានស្ថេរភាព។ សម្រាប់អនាគត ការអភិវឌ្ឍន៍ផលិតកម្មកសិកម្ម គឺទាមទារការជំរុញខ្លាំងលើការអភិវឌ្ឍផ្នែកគុណភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ជាងបរិមាណផលិតផល និងតម្រង់ទិសទៅរកការធ្វើកសិពាណិជ្ជកម្ម។

ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លំអិតនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋផងដែរ។

ជាសន្និដ្ឋាន កសិកម្មកម្ពុជាសម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយសារការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងយុទ្ធសាស្ត្រ ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ២- សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្មនៅឡើយ ហើយមានប្រជាពលរដ្ឋប្រមាណ៨០%រស់នៅជនបទ ហើយដែលក្នុងនោះភាគច្រើនលើសលុប ប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងចាត់ទុកថាកសិកម្ម គឺជាវិស័យមួយដែលមានអាទិភាពខ្ពស់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិ។

ដោយយោងលើសារៈសំខាន់នៃវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្មនិងជនបទ ការកាត់បន្ថយភាពក្រីក្រឱ្យបានក្នុងកម្រិតមួយសមស្រប (ជាង១%ក្នុងមួយឆ្នាំ) តាមរយៈការបង្កើនផលិតភាពកសិកម្មធានានូវសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលប្រចាំគ្រួសារកសិករ ហើយដែលថ្មីៗកន្លងមកនេះ វិស័យនេះអាចធានាបាននូវអតិរេកនៃផលិតផលកសិកម្មបម្រើឱ្យការនាំចេញទៀតផង។ យើងបានពិនិត្យឃើញថា កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាទាំងនេះ បានឆ្លុះបញ្ចាំងតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ដែលត្រូវបានរៀបចំឡើង និងឆ្លើយតបនូវទិសដៅគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ នៃរាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ននេះ។

ជាការពិតឆ្នាំ២០១១ គឺជាឆ្នាំទី៤ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃមោះមុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលក្នុងនោះការលើកស្ទួយវិស័យកសិកម្មគឺជាមុំមួយដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ការកែទម្រង់ដីធ្លីនិងបោសសំអាតមីន ការកែទម្រង់វិស័យជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូលដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំ និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជំនះដោះស្រាយបាននូវការលំបាកផ្សេងៗ ដែលរួមមានកត្តាអវិជ្ជមាននៃធម្មជាតិ ពិសេសគ្រោះទឹកជំនន់នារដូវវស្សាឆ្នាំ២០១១ ដែលបានបំផ្លិចបំផ្លាញផលដំណាំស្រូវនិងដំណាំផ្សេងៗជាង២៦ម៉ឺនហត រួមនឹងមានភាពរាំងស្ងួតនិងសត្វល្អិតបំផ្លាញនៅតំបន់មួយចំនួនទៀត។ សភាពការណ៍នេះ បានធ្វើឱ្យកំណើនក្នុងវិស័យកសិកម្មធ្លាក់ចុះត្រឹមតែ ៣,៣%នាឆ្នាំ២០១១នេះ ទាបជាងឆ្នាំ២០១០ ដែលអត្រាកំណើនមានចំនួន ៤% និងសង្ឃឹមថាកំណើនវិស័យនេះអាចនឹងមានការកើនឡើងក្នុងឆ្នាំ២០១២ និងក្នុងរយៈពេលមធ្យមខាងមុខ។

ទប់ទល់នឹងស្ថានភាពនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំជំរុញផលិតកម្មកសិកម្មលើគ្រប់មុខព្រួញ ជាពិសេសការបង្កបង្កើនផលដំណាំជាយុទ្ធសាស្ត្រជាអាទិ៍ ដំណាំស្រូវ កៅស៊ូ និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុក និងនៅសល់ស្បៀងសម្រាប់នាំចេញ ជាក់ស្តែងកម្ពុជាអាចនៅសល់ស្រូវជាង៤,៣៤លានតោន សម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្មអាហារក្នុងស្រុក និងការនាំចេញ។ នៅពេលដែលពិភពលោកកំពុងជួបប្រទះវិបត្តិស្បៀង និងការធ្លាក់រួញចុះនៃសេដ្ឋកិច្ច កម្ពុជាបានខិតខំបង្កើននូវផលិតកម្មដំណាំស្បៀង សំដៅរួមចំណែកដោះស្រាយបញ្ហានេះ ដោយសារយើងមានសក្តានុពល អំណោយផលយ៉ាងធំធេងរបស់វិស័យកសិកម្មនេះ ជាពិសេសផលិតកម្មដំណាំស្រូវអាចពង្រីកសក្តានុពលផលិតកម្ម និងជំរុញការនាំចេញលើកស្ទួយជីវភាពប្រជាពលរដ្ឋតាមជនបទ និងបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

ប្រជាពលរដ្ឋគ្រប់តំបន់និងទីប្រជុំជន បានខិតខំប្រកបមុខរបរយ៉ាងមមាញឹក ប្រកបដោយលក្ខណៈប្រកួតប្រជែងក្នុងបរិបទនៃពាណិជ្ជូបនីយកម្មកសិកម្ម ដែលធ្វើឱ្យវិស័យកសិកម្មកាន់តែមានសភាពសកម្ម និងមានសារៈសំខាន់ក្នុងជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងរាជរដ្ឋាភិបាលបាននិងកំពុងបង្កើនផ្តោតការយកចិត្តទុកដាក់ និងវិនិយោគកាន់តែខ្លាំងក្លាលើវិស័យកសិកម្មនេះ។

ការរីកចម្រើននៃវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលរួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ដំណើរការអភិវឌ្ឍគ្រប់ផ្នែកក្នុងវិស័យកសិកម្ម ការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ការធ្វើកំណែទម្រង់ស៊ីជម្រៅឡើងនេសាទ និងកំណែទម្រង់ព្រៃឈើ រួមនឹងការខិតខំដោះស្រាយនូវរាល់បញ្ហាដែលកើតមានចំពោះមុខ និងការទប់ស្កាត់សកម្មភាពរំលោភបំពានយកដីដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នៃប្រទេសអ្នកផ្តល់ជំនួយ ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក សំដៅជំរុញលើកកំពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ធានាសន្តិសុខស្បៀង និងទីផ្សារក្នុង-ក្រៅប្រទេស។ គ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបានពង្រឹងពីមួយថ្ងៃទៅមួយថ្ងៃ តាមរយៈកម្មវិធីកែទម្រង់ និងការពង្រឹងអភិបាលកិច្ចល្អ។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាននិងកំពុងស្រូបទាញបាននូវទុនវិនិយោគ ទាំងពីអ្នកវិនិយោគក្នុងនិងក្រៅប្រទេស កាន់តែធំឡើងជាលំដាប់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ជារួមផ្នែកផលិតកម្មកសិកម្មអាចវាយតម្លៃបានថាទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ពិសេសលើបរិមាណផលិតផលស្រូវបានកើនប្រមាណ ៥,៧% លើសឆ្នាំមុន ទន្ទឹមនឹងការកែទម្រង់លើវិស័យព្រៃឈើ និងជលផល បានដំណើរការទៅមុខប្រកបដោយលទ្ធផលជាទីមោទនៈ គួបផ្សំនឹងការផ្តល់សេវាកម្មគាំទ្រ និងការផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យា មានសភាពកាន់តែសកម្ម ចូលជ្រៅដល់មជ្ឈដ្ឋានប្រជាកសិករ។ ទោះជាយ៉ាងណាក្តី ការរីកចំរើនក្នុងវិស័យកសិកម្ម ក៏មិនអាចកាត់ផ្តាច់បានពីការរួមចំណែកឧបត្ថម្ភពីបណ្តាដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានដែរ ជាពិសេសការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញប្បទានដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីចូលរួមជំរុញវិស័យនេះ។

ក្រោយពីរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលជាកត្តាសំខាន់មួយថ្មីថែមទៀតក្នុងការជំរុញផលិតកម្មស្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយនេះ ហើយគ្រប់អង្គភាពដែលពាក់ព័ន្ធក្នុងផលិតកម្មស្រូវបានខិតខំអនុវត្ត គួបផ្សំនឹងការចូលរួមចំណែកទាំងផ្នែកបច្ចេកទេស និងធនធានថវិកា សម្រាប់អនុវត្តការងារនេះឱ្យសម្រេចបានលទ្ធផល តាមការគ្រោងទុក។ ក្នុងការនាំចេញផលិតផលកសិកម្មរបស់កម្ពុជា អង្ករ កៅស៊ូ និងដំឡូងមី បានឈរក្នុងលំដាប់នៃការនាំចេញដែលអាចសន្និដ្ឋានបានថាផលិតផលកសិកម្មសម្រាប់ការនាំចេញមានបីមុខសំខាន់កំពុងលេចធ្លោនាពេលបច្ចុប្បន្ននេះ។

ជាការសន្និដ្ឋាន វិស័យកសិកម្មបច្ចុប្បន្ននេះ មានការអភិវឌ្ឍប្រកបដោយមោទនភាព ជាពិសេសផលិតកម្មកសិកម្មកម្ពុជានៅតែបន្តឈានចូលដល់ដំណាក់កាលល្អបំផុត ក្នុងប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា។

## ៣- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy)

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លាសវៃរបស់ *សម្តេចអគ្គមហាសេនាបតីតេជោ* **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់ការលើកកំពស់វិស័យកសិកម្ម សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតសំខាន់ទៅលើការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ។

ចតុកោណយុទ្ធសាស្ត្រទាំងបួនសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចគឺ÷ ១-ការលើស្ទួយវិស័យកសិកម្ម ២-ការអភិវឌ្ឍផ្នែកឯកជននិងការងារ ៣-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៤-ការកសាងសមត្ថភាពនិងអភិវឌ្ឍន៍ធនធានមនុស្ស។

ការលើកស្ទួយវិស័យកសិកម្មរួមមាន: (ទី១)-ការលើកកំពស់ផលិតភាពនិងពិពិធកម្មកសិកម្ម (ទី២)-កំណែទម្រង់ដីធ្លីនិងការបោសសំអាតមីន (ទី៣)-កំណែទម្រង់ជលផល និង (ទី៤)-កំណែទម្រង់ព្រៃឈើ។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់វិស័យកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុករួមជាមួយធនធានថវិកា និងជំនួយបច្ចេកទេស

ពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្លូវថ្នល់ ធារាសាស្ត្រ និងអគ្គិសនី ព្រមទាំងឥណទានទីផ្សារ និងការកែច្នៃកសិផលជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

## ៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ត្រូវបានរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ក៏បានរៀបចំធ្វើឱ្យមានសង្គតិភាព រវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់និងជំរុញការអភិវឌ្ឍកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ បានកំណត់ចក្ខុវិស័យដើម្បីធានា “ភាពមានស្បៀងគ្រប់គ្រាន់ និងប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដោយជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព”។

ដើម្បីសម្រេចបាននូវទស្សនវិស័យនេះ សកម្មភាពគាំទ្រជាច្រើនត្រូវបានផ្តល់ រួមជាមួយនូវធាតុចូលសំខាន់ៗ សំដៅជំរុញដល់ការលូតលាស់សេដ្ឋកិច្ច ដូចជាការផ្តល់សេវាកម្មមានគុណភាពខ្ពស់ ដែលនាំដល់ការផ្គត់ផ្គង់ស្បៀងប្រកបដោយសុវត្ថិភាព បង្កើនផលិតភាពកសិកម្មនិងតម្លៃបន្ថែម ដោយផ្អែកទៅលើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពតម្លៃចំពោះវិស័យ ដែលពឹងផ្អែកលើផលិតកម្មកសិកម្ម នេសាទ និងរុក្ខាប្រមាញ់។

ទិសដៅគោលនយោបាយរួមត្រូវបានកំណត់សំដៅ "<u>លើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជកម្មកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រនិងជំរុញកំណើនសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព</u>"។

ដើម្បីសំរេចបានគោលដៅជាយុទ្ធសាស្ត្រចំបងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តកំណត់នូវទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រតាមវិស័យអនុវិស័យដែលមានស្រាប់ដូចខាងក្រោម ÷

*ទិសដៅគោលនយោបាយទី-១៖ សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្មកសិកម្ម*

*ទិសដៅគោលនយោបាយទី-២៖ ពង្រីកទីផ្សារសម្រាប់ផលិតផលកសិកម្ម*

*ទិសដៅគោលនយោបាយទី-៣៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ស្ថាប័ននិងបញ្ញត្តិច្បាប់*

*ទិសដៅគោលនយោបាយទី-៤៖ កំណែទម្រង់ជលផល*

*ទិសដៅគោលនយោបាយទី-៥៖ កំណែទម្រង់ព្រៃឈើ*

**<u>គោលបំណងគោលនយោបាយ</u>៖** (Policy Objectives)

*ទី-១÷ បង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ដោយធានាឱ្យបាននូវកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងកម្រិតប្រមាណជា ១០% ផលិតកម្មសត្វ ៣% ក្នុងមួយឆ្នាំ លើមូលដ្ឋាននៃការបង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្មទូលាយជាងមុន និងការទប់ស្កាត់ជំងឺឆ្លងសត្វកាន់តែមានប្រសិទ្ធភាព។*

*ទី-២÷ ធានារក្សាឱ្យបាននូវផ្ទៃដែននេសាទសម្រាប់សហគមន៍នេសាទ បង្កើនការការពារធនធានជលផល ការទប់ស្កាត់បទល្មើសនេសាទ ពិសេសតំបន់ជុំវិញបឹងទន្លេសាប និងការជំរុញវារីវប្បកម្មក្នុងកំរិត ១៥% ក្នុងមួយឆ្នាំ រួមនឹងការពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យកាន់តែប្រសើរឡើង ។*

*ទី-៣÷ រក្សាបាននូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ៦០% នៅឆ្នាំ២០១៥ ដោយត្រូវបង្កើនការការពារធនធានព្រៃឈើ ពិសេសការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឡើងវិញឱ្យបានខ្លាំងក្លា និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ លើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង។*

ដើម្បីសម្រេចបានគោលដៅនៃយុទ្ធសាស្ត្រទាំងប្រាំ និងគោលបំណងគោលនយោបាយខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី ដោយរួមបញ្ចូលនូវប្រភពធនធានថវិកាខាងក្រៅផងដែរ។ កម្មវិធីទាំងនោះរួមមាន ÷

*កម្មវិធីទី ១ ៖ បង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម*

*កម្មវិធីទី ២ ៖ ជំរុញការចូលទីផ្សារ នៃផលិតផលកសិកម្ម*

*កម្មវិធីទី ៣ ៖ ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់និងអភិវឌ្ឍន៍ធនធានមនុស្ស*

*កម្មវិធីទី ៤ ៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព*

*កម្មវិធីទី ៥ ៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃ ប្រកបដោយនិរន្តរភាព*

ក្នុងគោលដៅសម្រាប់ជំរុញការលើកកម្ពស់ផលិតភាពនិងពិពិធកម្មកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំ និងយកចិត្តទុកដាក់ជាសំខាន់នូវយុទ្ធវិធីមានលក្ខណៈជាអភិក្រមមួយចំនួនដូចខាងក្រោម÷

- ផ្តល់អាទិភាពខ្ពស់ទៅលើការបង្កើនផលិតភាពកសិកម្ម និងការធ្វើពិពិធភាវូបនីយកម្មក្នុងវិស័យកសិកម្ម ព្រមទាំងការជំរុញកសិឧស្សាហកម្មឱ្យបានខ្លាំងក្លា ដោយត្រូវយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែរទិសដៅពីការអភិវឌ្ឍតាមបែប "**វិបុលកម្ម**" ទៅកាន់ការអភិវឌ្ឍតាមបែប "**ប្រពលវប្បកម្ម**" ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ ធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផលជាពិសេសកសិផលសម្រេច ។
- ពង្រឹងនិងពង្រីក "*សេវាផ្សព្វផ្សាយកសិកម្ម*" ដោយជំរុញការផ្តល់សេវានេះ ឱ្យទៅដល់ថ្នាក់មូលដ្ឋាន ពិសេសការពង្រឹងសេវាថ្នាក់ស្រុក ឃុំ និងត្រូវតម្រង់ទិសជ្រើសរើសក្រុមគោលដៅដែលត្រូវទទួលផល ជាពិសេសការយកចិត្តទុកដាក់ដល់ក្រុមកសិករ ដែលជាសមាជិកសហគមន៍អភិវឌ្ឍន៍កសិកម្ម ឬសហករណ៍កសិកម្ម និងផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្តថ្នាក់ឃុំ-ភូមិ (ផ្តោតលើការពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិឱ្យក្លាយជាអ្នកផ្សព្វផ្សាយកសិកម្មភូមិ) ព្រមទាំងធានាស្ថេរភាពនៃប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម ដែលបាននិងកំពុងអនុវត្ត។ យកចិត្តទុកដាក់លើអន្តរាគមន៍ សំដៅជួយដល់ការបង្កើនផលិតកម្មកសិកម្ម តាមរយៈការសិក្សាពិសោធន៍ស្រាវជ្រាវកសិកម្ម សំដៅជំរុញការអភិវឌ្ឍផលិតកម្មកសិកម្ម។
- បន្តពង្រឹងនិងពង្រីកសមត្ថភាពពិសោធន៍ វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកា ដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យគ្រប់គ្រាន់សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធូបទកម្ម លើផលិតផលនិងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងធានាសុខភាពសាធារណៈ។
- ជំរុញការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឱ្យការងារពិសោធន៍ស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្របលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្តើរៗនូវគោលដៅនៃគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

- ជំរុញនិងបង្កើតបរិយាកាសអនុគ្រោះឱ្យកាន់តែប្រសើរឡើងថែមទៀត សម្រាប់ទាក់ទាញវិនិយោគទុនឯកជនទាំងក្នុង និងក្រៅប្រទេសឱ្យចូលរួមក្នុងផលិតកម្មកសិកម្ម ពិសេសផលិតកម្មដំណាំកសិឧស្សាហកម្ម និងស្វាគមន៍ចំពោះការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើននិងធានាឱ្យបាននូវការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដល់កសិករក្នុងការដាំដុះនិងចិញ្ចឹមសត្វ។
- ផ្សារភ្ជាប់កសិករទៅនឹងសង្វាក់ផ្គត់ផ្គង់កសិផលទីផ្សារក្នុងស្រុក ដោយយកចិត្តទុកដាក់លើការអនុវត្តប្រព័ន្ធ *"ផលិតកម្មកសិកម្មតាមកិច្ចសន្យា"* និងជំរុញការឈានចូលទីផ្សារពិភពលោក តាមរយៈការខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពកសិផលឱ្យស្របតាមស្តង់ដារអន្តរជាតិ យកចិត្តទុកដាក់ដល់ការអនុវត្តល្អក្នុងផលិតកម្មកសិកម្ម និងការផ្តល់សេវាព័ត៌មានទីផ្សារកសិកម្ម។
- ជំរុញបន្ថែមការអភិវឌ្ឍលើវិស័យចិញ្ចឹមសត្វគ្រប់ប្រភេទ ដោយសង្កត់លើការកែលម្អពូជ ចំណីសត្វ បញ្ជ្រាបបច្ចេកវិជ្ជាទំនើបក្នុងការចិញ្ចឹមសត្វដល់ស្រទាប់កសិករ និងឡជីវឧស្ម័នក្នុងគោលដៅបង្កើនផលិតភាពសត្វទាំងបរិមាណ និងគុណភាព។ ពង្រឹងនិងពង្រីកការងារត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ឬពីតំបន់មួយទៅតំបន់មួយទៀត តាមរយៈការបង្កើនកម្មវិធីយុទ្ធនាការចាក់ថ្នាំការពារសត្វ ជីវសុវត្ថិភាព ពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ និងការពិនិត្យចលនាសត្វឱ្យបានត្រឹមត្រូវ។ ជំរុញការងារសុខភាពសាធារណៈ ដោយផ្តោតជាសំខាន់លើការគ្រប់គ្រងសត្តឃាតដ្ឋាន ការពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសាច់ នៅតាមសត្តឃាតដ្ឋាននិងទីផ្សារ ក្នុងទិសដៅកាត់បន្ថយលុបបំបាត់ជំងឺឆ្លងតាមរយៈសាច់ និងផលិតផលសាច់ ដើម្បីធានាសុវត្ថិភាពចំណីអាហារដល់ប្រជាពលរដ្ឋ។
- ជំរុញការដាំដុះដំណាំកៅស៊ូតាមគ្រប់រូបភាព ទាំងការពង្រីកចម្ការកៅស៊ូមានស្រាប់ ចម្ការកៅស៊ូវិនិយោគឯកជន និងពិសេសបង្កើនផ្ទៃដីដាំដុះកៅស៊ូគ្រួសារ។ រៀបចំច្បាប់កៅស៊ូពាក់ពន្ធ័នឹងការដាំដុះ ការប្រមូលផល ការកែច្នៃ ការដឹកជញ្ជូន និងការនាំចេញ ជាពិសេសការធ្វើសហប្រតិបត្តិការ និងចូលរួមជាមួយបណ្ឌាវិទ្យាស្ថាន និងអង្គការកៅស៊ូអន្តរជាតិនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍បច្ចេកវិទ្យា និងចំណេះដឹងទូទៅលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដោយជំរុញការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូដល់បណ្តារោងចក្រផលិតជ័រកៅស៊ូ និងខិតខំកៀងគររកប្រភពទុនពីស្ថាប័នភ្នាក់ងារហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស។
- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្ម រួមមាន៖ ច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ ច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។ល។ រៀបចំគោលនយោបាយជាតិសម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម គោលនយោបាយនិងយុទ្ធសាស្ត្រវិស័យផលិតកម្មនិងបសុព្យាបាល អនុក្រឹត្យស្តីពីការគ្រប់គ្រងរោងជាងផលិត កែច្នៃ តម្លើង និងរោងជាងជួសជុលគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម អនុក្រឹត្យនិងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ ប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកម្ចាត់សមាសភាពចង្រៃ ប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ វិសោធនកម្មលើប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យជាដើម។ល។
- ជំរុញការអភិវឌ្ឍធនធានមនុស្ស ដោយរៀបចំបណ្តុះបណ្តាលលើមុខជំនាញបច្ចេកទេសជលផល ដោយរួមទាំងអ្នកនេសាទ សហគមន៍នេសាទនិងកសិករចិញ្ចឹមត្រីផង និងបន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីកិច្ចអភិវឌ្ឍវិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល។

- បង្កើនលែងប្រភេទពូជត្រីក្នុងស្រុកចូលតំបន់ទឹកធម្មជាតិឱ្យបានគ្រប់ស្រុក ដើម្បីបង្កើនផលស្តុកមច្ឆជាតិ បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ និងជំរុញការទាញយកផលពីធនធានទឹកតាមរយៈការពង្រីកតំបន់អភិវឌ្ឍន៍វារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីក្នុងស្រែ។
- ជំរុញបង្កើនទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធនិងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី និងធ្វើការអភិរក្សផ្សោតទន្លេមេគង្គនៅខេត្តក្រចេះនិងស្ទឹងត្រែង ដោយសិក្សាស្រាវជ្រាវផ្សព្វផ្សាយ អភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់។
- ខិតខំបន្តអនុវត្តអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី "**ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ**" និងបង្កើនប្រព័ន្ធត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលជលផល ជាពិសេសបង្កើនសកម្មភាពត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផលតាមបណ្តាខេត្តឱ្យកាន់តែកាន់ខ្លាំងក្លា។
- ពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ជា បទប្បញ្ញត្តិ លិខិតបទដ្ឋានពាក់ព័ន្ធនិងវិស័យព្រៃឈើ ពិសេសច្បាប់ស្តីពីព្រៃឈើ ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាតទប់ស្កាត់និងបង្ក្រាបបទល្មើសឱ្យបានទាន់ពេលវេលា ទន្ទឹមនឹងការពង្រឹងវិន័យការងារចំពោះមន្ត្រីមានសមត្ថកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មសាធារណៈ និងអភិបាលកិច្ចល្អនៃវិស័យព្រៃឈើ។
- រៀបចំធនធានមនុស្សនិងលិខិតបទដ្ឋានក្រោមច្បាប់ ដើម្បីអនុវត្តរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើតាម អនុក្រឹត្យកំណត់ និងបន្តសហការជាមួយស្ថាប័នពាក់ពន្ធ័ និងអាជ្ញាធរដែនដីចុះបោះបង្គោល ដើម្បីកំណត់ព្រំប្រទល់ដែនព្រៃឈើច្បាស់លាស់ និងអនុវត្តបន្តកម្មវិធីសហគមន៍ព្រៃឈើជាតិ ។
- ជំរុញការដាំព្រៃឈើសម្រាប់បម្រើដល់ពហុប្រយោជន៍នៃសេដ្ឋកិច្ចសង្គមនិងសេវាបរិស្ថាន និងបណ្តុះកូនឈើចែកចាយជូនប្រជាពលរដ្ឋដាំឱ្យបាន១០លានដើមជារៀងរាល់ឆ្នាំ និងរៀបចំបុណ្យរុក្ខទិវាដាំដើមឈើ។ សហការជាមួយដៃគូអភិវឌ្ឍន៍រៀបចំបង្កើតប្រពន្ធ័គណនេយ្យឥណទានកាបូនព្រៃឈើ (Forest Carbon Accounting System) ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើលើបញ្ហាថ្មីៗ នៃឥណទានកាបូនព្រៃឈើ។

### ៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ

ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ កន្លងទៅនេះ ដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ហើយដែលគ្រប់ភាគីដែលពាក់ព័ន្ធក្នុងកិច្ចការនេះ ត្រូវតែរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវទិសដៅធ្វើយ៉ាងណាឱ្យកម្ពុជាមានផលិតផលស្រូវ ដែលផលិតលើសប្រមាណជាង ៤លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការជាង ១លានតោន នៅឆ្នាំ២០១៥ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលម្អិតរបស់ខ្លួន សំដៅឆ្លើយតបនិងសម្រេចបាននូវចំណុចទិសដៅគោលនយោបាយដែលបានកំណត់នេះ។ ឯកសារគោលនយោបាយស្តីពី ការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ បានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយសំខាន់ៗ ទៅតាមដំណាក់កាលនីមួយៗគឺៈ (ទី១) វិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងផលិតកម្ម (ទី២) ពាក់ព័ន្ធនឹងការប្រមូលទិញ និងការកែច្នៃ (ទី៣) ពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញ និង (ទី៤) គឺវិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ។

ដើម្បីឆ្លើយតបបាននូវទិសដៅគោលនយោបាយ ដែលបានដាក់ឱ្យអនុវត្តនេះ "*ការបង្កើនផលិតភាព ពិសេសប្រពលវប្បកម្មដំណាំស្រូវ និងពិពិធភាវូបនីយកម្ម*" គឺជាចំណុចគន្លឹះ ដែលនឹងត្រូវយកចិត្តទុកដាក់និងត្រូវផ្តោតទៅលើការបង្កើនសេវាកម្មនិងអន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី កត្តាអាកាសធាតុ និងពិសេសការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារចង់បាន។ល។ ម្យ៉ាងទៀត ការសម្របសម្រួលនិងគាំទ្រវិស័យឯកជនក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ តម្រូវតាមស្តង់ដារទីផ្សារអន្តរជាតិ គឺជាការចាំបាច់ និងត្រូវតែគាំទ្រឱ្យបានខ្លាំងក្លា។

ដោយឡែក ការប្រមូលផ្តុំផលិតកម្ម ក៏ជាចំណុចគន្លឹះមួយសំខាន់ផងដែរ ពោលគឺសំដៅសម្រួលដល់ការផ្គត់ផ្គង់ និងប្រមូលទិញជាលក្ខណៈទ្រង់ទ្រាយធំតាមរយៈ "*សហគមន៍កសិកម្ម ឬសហករណ៍កសិកម្ម*" ព្រោះប្រសិនបើផលិតផលស្រូវនៅរាយប៉ាយគ្រប់ទីកន្លែង និងចម្រុះទៅដោយប្រភេទពូជច្រើនមុខនោះ គុណភាពស្រូវពិតជាមិនអាចឆ្លើយតបបាន ទៅនឹងសេចក្តីត្រូវការបានឡើយ។ ដូចនេះ ទាមទារឱ្យមានការប្រមូលផ្តុំផលិតកម្មជាចាំបាច់ ហើយសហគមន៍កសិកម្មគឺជាមជ្ឈមណ្ឌលផលិតនិងផ្គត់ផ្គង់ដ៏សំខាន់នាពេលអនាគត។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវតម្រង់ទិសនៃការធ្វើអន្តរាគមន៍ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម ដើម្បីផលិតក្នុងទ្រង់ទ្រាយធំនាពេលខាងមុខ។ ម្យ៉ាងវិញទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងត្រូវយកចិត្តទុកដាក់ខ្លាំងក្លាដល់ផ្នែកឯកជន ពិសេសបណ្តាក្រុមហ៊ុនដែលចូលរួមក្នុងការធ្វើផលិតកម្មកសិកម្មនៅកម្ពុជាផងដែរ។

ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិត និងអ្នកប្រមូលទិញ តាមយន្តការ «*ផលិតកម្មកសិកម្មតាម កិច្ចសន្យា*» គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ ក្នុងការសម្រេចបាននូវទិសដៅគោលនយោបាយនេះ។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានអំពីទីផ្សារស្រូវអង្ករ ក៏ជាមធ្យោបាយដ៏សំខាន់មួយដើម្បីឱ្យកសិករ ពាណិជ្ជករ មានទំនាក់ទំនងគ្នាក្នុងពាណិជ្ជកម្មកសិកម្មនេះ។ លើសពីនេះទៀតនោះ ការសម្រួលពាណិជ្ជកម្ម និងការនាំចេញតាមរយៈសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការសម្រួលបែបបទលិខិតបទដ្ឋានក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មម រុក្ខាប្រមាញ់ និងនេសាទ គឺជាវិធានការចាំបាច់និងត្រូវពង្រឹងបន្ថែមទៀត។

ផ្អែកលើសារសំខាន់នេះនិងភាពចាំបាច់នៃឯកសារគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំនូវផែនការសកម្មភាពរបស់ខ្លួនដោយបានលំអិតនូវអ្វីដែលជាសកម្មភាព និងភារកិច្ចត្រូវអនុវត្ត និងបានដាក់ចុះជាសកម្មភាពជាក់ស្តែងនានាដល់អង្គភាពជំនាញដែលពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តវិធានការគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

មកទល់នឹងពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានកំណត់រួចហើយនូវប្រភេទពូជស្រូវសំខាន់ៗ ចំនួន ១០ ប្រភេទ សម្រាប់ជំរុញផលិតកម្ម រួមមាន÷

- ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន ៣ ពូជៈ ពូជសែនពិដោរ ពូជជលសារ និង ពូជ IR66
- ពូជស្រូវកណ្តាលចំនួន ៤ ពូជៈ ពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាច័ន្ទសែនស
- ពូជស្រូវធ្ងន់ចំនួន ៣ ពូជៈ ពូជរាំងជ័យ ពូជខា៤ និង ពូជខា៦ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តនូវបណ្តាសកម្មភាពធំៗមួយចំនួន ដូចជា÷

(ទ-១) វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវៈ ធ្វើការសម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ជី ធាតុចូលកសិកម្មផ្សេងៗទៀត ជាមួយនឹងច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានអនុវត្តច្បាប់រួចហើយ បានពង្រឹងនិងពង្រីកសមត្ថភាព CARDI ស្ថានីយ៍ពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម ពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ពង្រីករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្ម រៀបចំគម្រោងផែនការដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធ និងពង្រឹងតួនាទីរបស់អង្គការកសិករ ពិសេសការលើកកម្ពស់សមត្ថភាពរបស់កសិករ និងសហគមន៍កសិកម្ម ក្នុងការខ្ចីនិងការប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។ ការរៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកំពុងត្រូវបានគិតគូរនិងស្វះស្វែងរកធនធានដើម្បីអនុវត្ត និងផ្សព្វផ្សាយឲ្យបានទូលាយ។ ការរៀបចំកសាងច្បាប់ស្តីពី ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ការរៀបចំច្បាប់ស្តីពីសហគមន៍កសិកម្មកំពុងដំណើរការយ៉ាងសកម្ម។ អនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានអនុម័ត និងកំពុងរៀបចំអនុវត្ត ។

(ទ-២) **វិធានការពាក់ពន្ធ័នឹងការប្រមូលទិញនិងការកែច្នៃស្រូវៈ** ក្រសួងបានយកចិត្តទុកដាក់ដល់ការពង្រឹងសហគមន៍កសិកម្ម ដោយបានផ្តោតលើសកម្មភាព÷ ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ការផ្សារភ្ជាប់ទីផ្សារកសិផល ពង្រឹងសមត្ថភាពគ្រប់គ្រង និងកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរួបវន្តដល់សហគមន៍កសិកម្ម។

(ទ-៣) **វិធានការពាក់ពន្ធ័នឹងប្រពន្ធ័សម្រួលការនាំចេញអង្ករៈ** ក្រសួងបាននិងកំពុងរៀបចំចងក្រងនិងផ្សព្វផ្សាយ

ឯកសារស្តីពីនីតិវិធីនៃការនាំចេញទំនិញជាកម្មវត្ថុការត្រួតពិនិត្យភូតគាមអនាម័យ ស្វែងរកធនធានដើម្បីសិក្សាពីសមាសភាពចង្រៃលើអង្ករនៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសមាសភាពចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រងនិងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសមាសភាពចង្រៃលើអង្ករ រៀបចំតំបន់គ្មានសមាសភាពចង្រៃ សម្រាប់ផលិតកម្មដំណាំស្រូវ ដើម្បីនាំចេញទៅតាមតម្រូវការរបស់ប្រទេសនាំចូល ដោយផ្អែកលើស្តង់ដារអន្តរជាតិស្តីពីវិធានភូតគាមអនាម័យ ខិតខំពង្រឹងសមត្ថភាពបច្ចេកទេស ដើម្បីជំរុញការអនុវត្តការងារធ្វូបទកម្ម រួមសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីកំណត់ស្តង់ដារគុណភាពអង្ករកម្ពុជាឲ្យស្របតាមស្តង់ដារអន្តរជាតិ និងបានជំរុញការរៀបចំច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ។ ហើយថ្មីៗនេះ ក្រសួងបានចាត់មន្ត្រីជំនាញជាន់ខ្ពស់ ដើម្បីប្រចាំការនៅច្រកចេញចូលតែសម្រាប់ធ្វើសេវាបំពេញបែបបទនាំអង្ករនូវក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

(ទី-៤) **វិធានការស្វែងរកទីផ្សារៈ** ក្រសួងបានផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុក និងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និងចរាចរស្រូវ-អង្ករ និងវិភាគអំពីស្ថានការទីផ្សារតំបន់ និងអន្តរជាតិ ។

## ៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក

យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក មានទស្សនៈវិស័យ “ធានាឱ្យមានស្បៀងនិងទឹកគ្រប់គ្រាន់ មានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូបភាពក្រីក្រត្រូវបានកាត់បន្ថយ រួមចំណែកក្នុងការលូតលាស់សេដ្ឋកិច្ចជាតិ (បង្កើនផលិតផលសរុបក្នុងស្រុកសម្រាប់ប្រជាជនម្នាក់ៗ) និងធានាឱ្យបាននូវចីរភាពធនធានធម្មជាតិ”។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការដើម្បីគៀងគរជំនួយនិងធនធានសំរាប់អនុវត្ត ជាពិសេសអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក តាមរយៈយន្តការសហប្រតិបត្តិការទ្វេភាគីពហុភាគី ជំនួយអភិវឌ្ឍន៍ផ្លូវការ និងយន្តការក្រុមការងារបច្ចេកទេសនានា។ ទស្សនៈវិស័យ ទិសដៅនិងកម្មវិធីរបស់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនិងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ គឺសមស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ហើយក៏ស្របតាមដំណើរការវិវឌ្ឍន៍ និងនិន្នាការប្រកួតប្រជែងនៅលើទីផ្សារនៅក្នុងតំបន់និងលើសកលលោក និងតាមតម្រូវការសេដ្ឋកិច្ចទីផ្សារសេរី។ ប្រការទាំងអស់នេះហើយ ដែលធ្វើឱ្យដៃគូអភិវឌ្ឍន៍នានាមានការចូលរួមយ៉ាងពេញទំហឹងក្នុងការកសាងយុទ្ធសាស្ត្រនេះ បានផ្តល់ជំនួយទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្រសកម្មភាពទាំងឡាយដែលមានចែងក្នុងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ ។

ផ្អែកលើទស្សនៈវិស័យរយៈពេលវែង យុទ្ធសាស្ត្រនេះមានគោលដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ធានាបាននូវសន្តិសុខស្បៀង និងការលូតលាស់សេដ្ឋកិច្ច តាមរយៈការបង្កើននូវផលិតភាពនិងពិពិធកម្មកសិកម្ម បង្កើនការអភិវឌ្ឍនិងគ្រប់គ្រងធនធានទឹក។ ដើម្បីសម្រេចបាននូវគោលដៅនេះ យុទ្ធសាស្ត្របានកំណត់នូវកម្មវិធីសំខាន់ចំនួន៥គឺៈ ទី(១) កម្មវិធីគាំទ្រដល់ការពង្រឹងសមត្ថភាពនិងគ្រប់គ្រងស្ថាប័នសម្រាប់វិស័យកសិកម្មនិងទឹកៈ ទី(២) កម្មវិធីគាំទ្រសន្តិសុខស្បៀង ទី(៣) កម្មវិធីគាំទ្រកសិកម្មនិងកសិពាណិជ្ជកម្ម ទី(៤) កម្មវិធីគ្រប់គ្រងធនធានទឹក ការស្រោចស្រពនិងដីធ្លី ទី(៥) កម្មវិធីស្រាវជ្រាវអប់រំនិងផ្សព្វផ្សាយសម្រាប់កសិកម្មនិងធនធានទឹក។

ដោយផ្អែកលើទិសដៅនេះ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយមនាំមុខ និងដោយមានការសម្របសម្រួលគាំទ្រពីដៃគូអភិវឌ្ឍន៍ បានកំណត់រៀបចំកម្មវិធីទាំង៥រួចជាស្ថាពរ ។ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដោយមានការជួយឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ បានពិនិត្យនិងរៀបចំធ្វើសុខុដុមនីយកម្មកម្មវិធីទាំង៥នេះ ក្នុងគោលបំណងដើម្បីកំណត់អាទិភាពកម្មវិធីទាំងអស់ឱ្យមានលក្ខណៈស្របគ្នាទាក់ទងគ្នានិងតាមលំដាប់។ ជាលទ្ធផលការធ្វើសុខុដុមនីយកម្មកម្មវិធីនេះកំណត់បាននូវផ្នែក (Component) ចំនួន ០៦ ដែលរួមមាន ផ្នែកទី១: គោលនយោបាយ និងបទប្បញ្ញត្តិ ផ្នែកទី២: ការកសាងសមត្ថភាព ស្ថាប័ននិងការអភិវឌ្ឍធនធានមនុស្ស ផ្នែកទី៣: ការស្រាវជ្រាវ និងការអប់រំ ផ្នែកទី៤: សន្តិសុខស្បៀង ផ្នែកទី៥: ការគ្រប់គ្រងធនធានទឹកនិង

ដីកសិកម្ម និងផ្នែកទី៦: កសិពាណិជ្ជកម្មនិងទីផ្សារ។ ផ្នែកទាំង៦នៃកម្មវិធីនេះ គ្រោងនឹងប្រើប្រាស់ថវិកាសរុបប្រមាណ ៥០១ លានដុល្លារអាមេរិក សម្រាប់អនុវត្តរយៈពេល០៥ឆ្នាំខាងមុខ។

ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក បាននិងកំពុងដំណើរការការងាររៀបចំបង្កើតផែនទីបង្ហាញផ្លូវ ក្នុងគោលបំណង (១) សិក្សាវាយតម្លៃលើកាលានុវត្តភាព ឧបសគ្គ និងបញ្ហាប្រឈមនានា ដែលទាក់ទងទៅនឹងការបង្កើតអភិក្រមផ្នែកលើកម្មវិធីរួមមួយក្នុងវិស័យកសិកម្មនិងទឹក និង (២) ដើម្បីសម្រេចបាននូវការធ្វើសុខដុមនីយកម្ម និងការតម្រឹមការរៀបចំផែនការសម្រាប់កម្មវិធី ការអនុវត្ត និងការតាមដាននិងវាយតម្លៃ ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ ។

បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក តាមរយៈទីប្រឹក្សាជាតិនិងអន្តរជាតិ បាននិងកំពុងសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គភាពថ្នាក់ក្រោមជាតិមួយចំនួន ក្នុងកិច្ចពិគ្រោះយោបល់ ដែលទាក់ទងទៅនឹងកិច្ចដំណើរការនិងការអនុវត្តអភិក្រមផ្អែកលើកម្មវិធី (PBAs)។

## ៤- កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មមានសារៈសំខាន់បំផុតក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះវិស័យនេះ អាចផ្តល់នូវប្រភពស្បៀងអាហារ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិឧស្សាហកម្មនិងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារអន្តជាតិ។ នេះគឺជាចំណុចគន្លឹះចំបងបំផុតដែលអាចបញ្ជាក់បានថា វិស័យកសិកម្មមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច។

សេដ្ឋកិច្ចកម្ពុជាបានងើបចេញពីវិបត្តិហិរញ្ញវត្ថុសាកល និងមានសន្ទុះកំណើនឡើងវិញប្រកបដោយចិរភាព។ កំណើនសេដ្ឋកិច្ចឆ្នាំ២០១១ ត្រូវបានប៉ាន់ប្រមាណថាទទួលបានប្រហែល ៦,៩%។ ជាមួយគ្នានេះ ដោយសារកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មផ្ទៃក្នុងតំបន់កំពុងកើនឡើង និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងតំបន់អាស៊ី ទីផ្សារអាស៊ីអាចផ្តល់ក្តីសង្ឃឹមច្រើនសម្រាប់ការនាំចេញ និងកំណើនប្រាក់ចំណូលសម្រាប់កម្ពុជា។ កម្ពុជានឹងត្រូវធ្វើពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ដោយមិនត្រូវផ្តោតតែចំពោះទីផ្សារសហរដ្ឋអាមេរិក និងអឺរ៉ុបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវផ្តោតទៅលើទីផ្សារអាស៊ីផងដែរ។ តម្លៃទំនិញនិងប្រេងអន្តរជាតិ បន្តកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ២០១១ ដោយសារតម្រូវការខ្លាំងក្លារបស់ពិភពលោក និងស្ថានការណ៍នៅអាស៊ីបូព៌ា និងការប្រែប្រួលតម្លៃឆាប់រហ័សចំពោះទំនិញមួយចំនួនទៀត។ ទោះជាយ៉ាងនេះក្តី កម្ពុជាអាចរក្សាអតិផរណាជាមធ្យមប្រចាំឆ្នាំក្នុងកម្រិត ៥,៥% ក្នុងឆ្នាំ២០១១ កន្លងទៅនេះ។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ កម្ពុជាចាំបាច់ត្រូវពិនិត្យតាមដានអតិផរណាដោយប្រុងប្រយ័ត្ន ពីព្រោះកំណើននៃគំនាបដ៏ខ្លាំងក្លានៃអតិផរណាក្នុងតំបន់ គួបផ្សំនឹងការកើនឡើងតម្លៃប្រេងនិងចំណីអាហារ អាចជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ចក្នុងស្រុក ដែលអាចរំខានដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

តម្រូវការផលិតផលកសិកម្មសម្រាប់អាស៊ីមានការកើនឡើងយ៉ាងឆាប់រហ័ស។ ការកើនឡើងនេះ គឺធ្វើឱ្យកើនឡើងតម្លៃចំណីអាហារ និងការព្រួយបារម្ភចំពោះសុវត្ថិភាពស្បៀងដែលកំពុងបន្តកើតមាន។ តម្លៃវត្ថុធាតុដើមសម្រាប់ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ដូចជាជ័រកៅស៊ូ រំពឹងថានឹងកើនឡើង ស្របគ្នានឹងនិន្នាការកើនឡើងនៃតម្លៃប្រេងផងដែរ។ ស្ថានភាពសេដ្ឋកិច្ចដែលប្រែប្រួល និងសូចនាករនៃការផ្គត់ផ្គង់ចំណីអាហារអាចបង្កើនតម្រូវការផលិតផលកសិកម្ម។ ដោយគិតគូរពីកត្តាទាំងអស់នេះ វិស័យកសិកម្មត្រូវបានព្យាករណ៍ថា នឹងរក្សាបានការអនុវត្តល្អប្រសើរក្នុងឆ្នាំ២០១២ និងក្នុងរយៈពេលមធ្យមខាងមុខ។ ការនាំចេញផលិតផលកសិកម្ម ពិសេសការនាំចេញអង្ករ រំពឹងថានឹងកើនឡើងដោយសាររាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់វិស័យនេះ ។

### ៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ពោលគឺវិស័យ

កសិកម្មអាចដោះស្រាយបាននូវការងារធ្វើរបស់ប្រជាជនរហូតដល់ប្រមាណជិត៧០%  និងអាចចូលរួមមួយចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើផលិតកម្មកសិកម្មនេះ។

ការខិតខំប្រឹងប្រែងកន្លងមករបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជំរុញការអភិវឌ្ឍវិស័យកសិកម្ម បានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ជាក់ស្តែងភាពក្រីក្របានថយចុះពីកម្រិត៤៧% នៅឆ្នាំ១៩៩៤មកត្រឹម៣៤,៧% នៅឆ្នាំ២០០៤ អាត្រានៃភាពក្រីក្រនេះបានថយចុះមកនៅ៣០,១% នៅឆ្នាំ២០០៧ ហើយតាមការប៉ាន់ស្មានថ្មីៗនេះបានបង្ហាញថាអាត្រានេះបានថយមកត្រឹមតែ២៦,១%នាំឆ្នាំ២០១០។ ដូចនេះយើងអាចវាយតម្លៃបានថា ជាមធ្យមភាគភាពក្រីក្របានថយចុះជាង ១% ក្នុងមួយឆ្នាំៗ។

សន្តិភាព ការបង្រួបបង្រួមជាតិ និងស្ថេរភាពសង្គមគឺជាកត្តាគន្លឹះសម្រាប់ការកសាងប្រទេស ពិសេសការអភិវឌ្ឍវិស័យកសិកម្មនេះ។ គោលនយោបាយគាំទ្រដល់ការរីកលូតលាស់នៃវិស័យកសិកម្ម ក៏ជាកត្តាជំរុញមួយទៀតយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យនេះ ដែលធ្វើឱ្យសហគមន៍ផ្តល់ជំនួយនានា យកចិត្តទុកដាក់ជួយគាំទ្រយ៉ាងខ្លាំងក្លា។ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញការអនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្ម ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ធានាសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋទូទៅ។ ម្យ៉ាងវិញទៀត សក្តានុពលភាពសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មដូចជា កត្តាដីកសិកម្មដែលអាចពង្រីកផលិតកម្មកសិកម្ម លទ្ធភាពបង្កើនទិន្នផលដំណាំ ប្រភពធនធានទឹកនិងការស្រោចស្រព កម្លាំងពលកម្មកសិកម្ម។ល។ នឹងអាចរុញការរីកលូតលាស់សេដ្ឋកិច្ចជនបទ និងអាចធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនបន្ថែមទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ជំរុញផលិតភាពកសិកម្ម ដោយខិតខំពង្រឹងថែមទៀតនូវប្រសិទ្ធភាពសេវាកម្មគាំទ្រដូចជាៈ ការងារស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍន៍ទីផ្សារកសិកម្មនិងបទដ្ឋានគតិយុត្តនានា ក៏បានកែលម្អបំពេញបន្ថែមនិងកសាងថ្មី ដែលបានជួយឱ្យការងារដឹកនាំអនុវត្តសកម្មភាពនានា មានលក្ខណៈប្រសើរនិងមានប្រសិទ្ធភាព ។

## ៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១១

### ៤.២.១- ការចូលរួមចំណែកនៃវិស័យសេដ្ឋកិច្ចសំខាន់ៗក្នុង GDP ឆ្នាំ ២០១១




__*ប្រភពទិន្នន័យ:*__ តួលេខប៉ាន់ស្មានរបស់ក្រសួងផែនការខែមីនា ឆ្នាំ២០១២

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល ២៨,៤%នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១១នេះ។ ដោយឡែកវិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ ៣០,៥% និងវិស័យសេវាកម្មប្រហែល ៤១,១%។ ការកើននូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺបានកើនឡើងដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានសភាពទ្រឹងនិងមានសន្ទុះថយចុះក្នុងអំឡុងឆ្នាំ២០០៨ និង២០០៩ កន្លងទៅនេះ ដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។ ប៉ុន្តែចាប់ពីឆ្នាំ២០១០ និង២០១១ វិស័យឧស្សាហកម្ម និងវិស័យសេវាកម្មមានសន្ទុះរីកលូតលាស់ឡើងវិញជាបណ្តើរៗ។

### ៤.២.២-ការចូលរួមចំណែកជា%ផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ ២០០២-២០១១




គួរកត់សម្គាល់ដែរថា ការចូលរួមចំណែកជា%នៃផ្នែកកសិកម្មក្នុង GDP (គិតតាមថ្លៃស្ថេរឆ្នាំ២០០០) ជារួមមាននិន្នាការថយចុះពី ៣១,៥% នាឆ្នាំ២០០២ មកនៅត្រឹម ២៦,៧% នៅឆ្នាំ២០០៧ និងកើនឡើងវិញប្រមាណពី ២៦,៨% នៅឆ្នាំ២០០៨ ដល់២៩% នៅឆ្នាំ២០១០។ សភាពការណ៍នេះ បានបង្ហាញអំពីភាពប្រកួតប្រជែងរីកចំរើនរួមនៃវិស័យសេដ្ឋកិច្ចទាំងបីរបស់កម្ពុជា ហើយក្នុងនោះវិស័យកសិកម្មនៅតែបន្តរីកចម្រើនទាំងបរិមាណនិងគុណភាព។ ឆ្នាំ២០១១កន្លងទៅនេះ ការចូលរួមចំណែករបស់កសិកម្មក្នុង GDP ត្រូវបានប៉ាន់ស្មានសម្រេចបានប្រហែល២៨,៤% (តាមការប៉ាន់ស្មានជំហ៊ានដំបូង របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ)។

### ៤.២.៣-តម្លៃបន្ថែមសរុប (GVA) ផ្នែកកសិកម្មចាប់ពីឆ្នាំ ២០០២-២០១១




ការធ្លាក់ចុះនូវចំណែក (%) របស់វិស័យកសិកម្មក្នុង GDP រយៈពេល៦ឆ្នាំកន្លងមក (២០០២-២០០៧) មិនមែនមានន័យថាផលិតកម្មកសិកម្មធ្លាក់ចុះនោះទេ។ ផ្ទុយទៅវិញ តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្ម (Gross Value Added-GVA) បានកើនឡើងពី ៥.១០៨ ពាន់លានរៀលនៅឆ្នាំ២០០២ រហូតដល់ ៧.១៧៤ ពាន់លានរៀល នៅឆ្នាំ២០០៧ (កើនប្រហែលជាង ៤០%) និងបានបន្តកើនថែមទៀតដល់ ៨.៥៨៧ ពាន់លានរៀលឆ្នាំ ២០១១ នេះ (តម្លៃគិតតាមថ្លៃស្ថេរឆ្នាំ២០០០)។

### ៤.២.៤-កំណើន ( %) នៃវិស័យកសិកម្មចាប់ពីឆ្នាំ ២០០១-២០១១




ជារួមកំណើន (%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណជាពី៤ទៅ៥% (២០០៦-២០១០) កំណើនមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ដូចដែលបានបង្ហាញតាមក្រាហ្វិកខាងលើ ហើយការប្រែប្រួលនេះមានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗ។ ដូចនេះ វិស័យកសិកម្មគឺពឹងផ្អែកច្រើននៅឡើយលើកត្តាធម្មជាតិ ដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។

នៅឆ្នាំ២០០១ កំណើននៃវិស័យកសិកម្មនេះ មានប្រមាណ៣,៣% ប៉ុណ្ណោះ។ នាឆ្នាំ២០០៣ វិស័យកសិកម្មកើនក្នុងរង្វង់ប្រហែល ១០,៥% និងនៅឆ្នាំ ២០០៥ កើនខ្លាំងរហូតដល់ ១៥,៧% (អាស្រ័យដោយភាពអនុគ្រោះខ្លាំងពីធម្មជាតិ ពិសេសកត្តាទឹកភ្លៀង និងមិនមានបញ្ហាសត្វល្អិតបំផ្លាញ)។ នៅឆ្នាំ២០០៦ វិស័យកសិកម្មបានកើនប្រមាណ ៥,៥% និងឆ្នាំ២០០៩ មានកំណើនប្រហែល ៥,៤% និងឆ្នាំ២០១០ កំណើនមានត្រឹមតែ៤%។ ដោយឡែក ឆ្នាំ២០១១នេះ កំណើនបានធ្លាក់ចុះប្រហែលជាង ៣,៣% (តាមការប៉ាន់ស្មានដំបូងរបស់វិទ្យាស្ថានជាតិស្ថិតិ) ដែលនេះគឺជាឥទ្ធិពលនៃគ្រោះទឹកជំនន់ធ្ងន់ធ្ងរនៅរដូវវស្សាឆ្នាំ២០១១កន្លងទៅ។ គួរកត់សម្គាល់ដែរថា នៅឆ្នាំ២០០២និង២០០៤ កំណើនផ្នែកកសិកម្មជាចំនួនអវិជ្ជមាននេះ គឺអាស្រ័យដោយការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិ ដែលរួមមាន ទឹកជំនន់ រាំងស្ងួត និងការបំផ្លាញដំណាំដោយសត្វចង្រៃ។

### ៤.២.៥-សមាសភាពនៃអនុវិស័យក្នុងវិស័យកសិកម្ម ឆ្នាំ២០១១




ពិនិត្យជារួមយើងសង្កេតឃើញថា នៅក្នុងវិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជា (%) របស់ផលិតកម្មដំណាំគ្រប់ប្រភេទនាឆ្នាំ២០១១ មានចំនួនជាងពាក់កណ្ដាល ពោលគឺកើនដល់៥៤% នៃផលិតផលសរុបរបស់

វិស័យកសិកម្ម។ ផលិតកម្មនេសាទ បានចូលរួមចំណែកច្រើនបង្គួរបន្ទាប់ពីដំណាំ គឺមានប្រមាណ២៥% ផលិតកម្មសត្វបាន ចូលរួម ១៥% និងអាជីវកម្មព្រៃឈើមានត្រឹមតែ ៦%ប៉ុណ្ណោះ។

ផលិតកម្មដំណាំ ពិសេសស្រូវនៅតែជាមុខដំណាំសំខាន់សម្រាប់ការរកចំណូលរបស់កសិករ។ មុខរបរអាជីវកម្មបន្ទាប់ គឺអាចសន្និដ្ឋានថាអាជីវកម្មនេសាទ (មានសមាសភាគប្រមាណ ២៥-២៧%) និងផលិតកម្មសត្វមានការចូលរួមតិចជាងអាជីវកម្មនេសាទ (១២,៨-១៥,៦% ក្នុងកំឡុងពេល៥ឆ្នាំកន្លងទៅនេះ ២០០៧-២០១១)។ ដោយឡែក អាជីវកម្មព្រៃឈើមាននិន្នាការថយចុះជាបន្តបន្ទាប់ (សមាសភាគចូលរួមក្នុងវិស័យកសិកម្មមានត្រឹមតែប្រមាណ ៦% នាឆ្នាំ២០១១)។

### ៤.២.៦-សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម




ការបង្ហាញតាមក្រាហ្វិកឃើញថា ផ្នែកដំណាំមានការកើនឡើងយ៉ាងខ្លាំង ដែលសមាសភាគរបស់ផ្នែកនេះមានចំនួន ៥២,២% នៅឆ្នាំ ២០០៧ និងមាននិន្នាការកើនឡើងដល់ ៥៣,៨% នៅឆ្នាំ២០១០ និងកើនឡើងរហូតដល់ ៥៤% នៅឆ្នាំ២០១១។ សមាសភាគនៃផ្នែកផលិតកម្មដំណាំនេះបានកើនប្រហែល១,៨% បើប្រៀបធៀបនឹងឆ្នាំ២០០៧។ ចំពោះសមាសភាគផ្នែកជលផលមានការប្រែប្រួលពី២៤,៨%នៅឆ្នាំ២០០៧ (ផ្នែកនេះបានទទួលរងនូវកត្តាជះឥទ្ធិពលទឹកទន្លេ) កើនរហូតដល់២៥%នាឆ្នាំ២០១១។ ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើ មានការថយចុះជាបន្តបន្ទាប់បើធៀបនិងឆ្នាំ២០០៧ ពី ៧,៣%មកត្រឹមតែ ៦% នៅឆ្នាំ២០១១។ រីឯសមាសភាគផ្នែកផលិតកម្មសត្វមានការប្រែប្រួលនិងថយចុះបើធៀបរយៈពេលឆ្នាំ៥កន្លងទៅនេះ (១៥,៦%ឆ្នាំ២០០៧ ថយមកត្រឹម ១៥,៣% ឆ្នាំ២០០៩ និង ១៥%ឆ្នាំ២០១១)។

## ៤.៣-ការវិវឌ្ឍនៃផលិតកម្មកសិកម្មរយៈពេល ៥ ឆ្នាំ

### ៤.៣.១-ការវិវឌ្ឍផលិតកម្មដំណាំស្រូវ

ផលិតកម្មស្រូវ នៅតែជាផលិតកម្មចម្បងមួយសម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅជនបទស្ទើរតែទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលកន្លងមកនេះ ក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិសរបស់រាជរដ្ឋាភិបាល ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្មមានការវិវឌ្ឍន៍រីកចម្រើនឡើងគួរឱ្យកត់សម្គាល់។

ជាក់ស្តែងផលិតកម្មស្រូវប្រចាំឆ្នាំ២០១១នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃបាតុភូតធម្មជាតិ ពិសេសគ្រោះទឹកជំនន់ក៏ស្ថានភាពផលិតកម្មកសិកម្ម ជារួមមានកម្រិតល្អប្រសើរទូទាំងប្រទេស។ ផលិតកម្មដំណាំស្រូវអនុវត្តបានសរុបចំនួន**២,៩៧** លានហត ផ្ទៃដីអាចប្រមូលផលបានមានចំនួន**២,៧៧**លានហត និងទិន្នផលមធ្យមប្រចាំឆ្នាំទទួលបានចំនួន**៣,១៧៣ត/ហត**។ ផ្ទៃដីចំនួន២៦៧.២៣៧ហត ត្រូវបានទទួលរងដោយគ្រោះធម្មជាតិនាឆ្នាំ២០១១កន្លងទៅនេះ ពិសេសគ្រោះទឹកជំនន់ទន្លេមេគង្គបំផ្លាញ។ តែទោះជាយ៉ាងណាក្តី កម្ពុជាអាចទទួលបានបរិមាណផលស្រូវជាង**៨,៧៨**លានតោននិងអាចសល់ស្បៀង (អង្ករ) សរុបជាង២,៧៨លានតោន (បរិមាណស្បៀងសល់គិតជាស្រូវនៅសល់ប្រមាណជាង**៤,៣៤**លានតោន)។ ផលិតផលស្រូវដែល

ទទួលបាននេះ ខ្ពស់ជាងមធ្យមភាគ១០ឆ្នាំកន្លងមក ប្រមាណ២លានតោនស្រូវស្មើនឹង១,៣លានតោនអង្ករ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។

**តារាង÷ ប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ២០០៧-២០១១**

| បរិយាយ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ប្រៀបធៀបកំណើន ២០១១/២០១០ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហត) | 2,585,905 | 2,615,741 | 2,719,080 | 2,795,892 | 2,968,529 | 6.17% |
| ផ្ទៃដីប្រមូលផល (ហត) | 2,566,952 | 2,613,363 | 2,674,603 | 2,777,323 | 2,766,617 | -0.39% |
| ទិន្នផល (ត/ហត) | 2.621 | 2.746 | 2.836 | 2.970 | 3.173 | 6.85% |
| បរិមាណផល (ត) | 6,727,127 | 7,175,473 | 7,585,870 | 8,249,452 | 8,779,365 | 6.42% |
| សៀងសល់ (អង្ករ) | 1,649,640 | 2,025,033 | 2,244,598 | 2,516,752 | 2,780,328 | 10.47% |
| សៀងសល់ (ស្រូវ) | 2,577,562 | 3,164,114 | 3,507,185 | 3,932,425 | 4,344,263 | 10.47% |

**ក្រាហ្វិកទី ១ ÷ បង្ហាញសមាសភាគចូលរួមនៃផ្ទៃដីដាំដុះស្រូវវស្សាតាមប្រភេទឆ្នាំ២០១១**




ជារួមពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីអនុវត្ត ផ្ទៃដីប្រមូលផល និងបរិមាណផល មានការវិវឌ្ឍឈានឡើងជាលំដាប់ សមិទ្ធផលទទួលបានទាំងនេះ ក៏ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ជាពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករ បានជួយធ្វើឱ្យវិស័យកសិកម្មមានដំណើរការលូតលាស់ ទាំងការងារគ្រប់គ្រងទាំងបច្ចេកទេសដាំដុះ ដោយបានបង្កើនការអប់រំណែនាំដល់ប្រជាកសិករឱ្យកែប្រែទន្លាប់ចាស់បង្កើនចំណេះដឹងក្នុងផលិតកម្ម និងបច្ចេកទេសកែច្នៃផលិតផលកាន់តែប្រសើរឡើង។

ផ្ទៃដីដាំដុះប្រភេទស្រូវកណ្ដាលមានប្រមាណ៤៨% (ប្រជាកសិករទទួលយកនូវបច្ចេកទេសសម្រាប់ដាំដុះប្រភេទស្រូវនេះច្រើន) ប្រភេទស្រូវស្រាលមានប្រមាណ២៥% និងស្រូវធ្ងន់មានប្រហែល២១%។ ដោយឡែកស្រូវចំការនិង ស្រូវឡើងទឹកមានសមាសភាគតិចតួច (ស្រូវចំការ ២% និងស្រូវឡើងទឹក ៤%)។

**ក្រាហ្វិកទី ២ ÷ បង្ហាញការវិវត្តន៍នៃផ្ទៃដីដាំដុះនិងផ្ទៃដីប្រមូលផលចាប់ពីឆ្នាំ២០០២-២០១១ (រយៈពេល ១០ ឆ្នាំ)**




ផលិតកម្មស្រូវរដូវវស្សាមានចំណែកប្រមាណជាង ៨៤% នៃផ្ទៃដីផលិតកម្មស្រូវទូទាំងប្រទេស។ ប្រទេសកម្ពុជាទទួលរងនូវគ្រោះទឹកជំនន់ទន្លេមេគង្គពាក់កណ្តាលរដូវនៅតាមបណ្តារាជធានីខេត្តចំនួន១៧នៃទូទាំងប្រទេស បានធ្វើឱ្យផ្ទៃដីប្រមូលផលថយចុះ ប៉ុន្តែបរិមាណស្រូវនៅតែបន្តកើនឡើង។ ផ្ទៃដីដាំដុះស្រូវរដូវវស្សាឆ្នាំ២០១១ សម្រេចបានប្រមាណ**២,៥០**លានហតដែលមានទិន្នផលជាមធ្យមចំនួន**២,៩២**ត/ហត ដោយទទួលបរិមាណផលសរុបប្រមាណជាង**៦,៧**លានតោន និងស្រូវរដូវប្រាំង២០១១-២០១២ សម្រេចបានលើផ្ទៃដីដាំដុះជាង**០,៤៧**លានហិកតា ទទួលបានទិន្នផលជាមធ្យម**៤,៤**ត/ហត ដោយទទួលបានបរិមាណផលសរុបជាង**២**លានតោន។

**ក្រាហ្វិកទី ៣ ÷ បង្ហាញការវិវត្តន៍នៃបរិមាណផលស្រូវរដូវវស្សា ប្រាំង និងប្រចាំឆ្នាំ២០០២-២០១១**




ក្នុងរយៈពេល៦ឆ្នាំចុងក្រោយពីឆ្នាំ២០០៦ដល់ឆ្នាំ២០១១យើងពិនិត្យឃើញថា បរិមាណផលសរុបប្រចាំឆ្នាំ ក៏ដូចជាបរិមាណផលស្រូវរដូវវស្សានិងស្រូវរដូវប្រាំង មានការកើនឡើងជាលំដាប់ ទោះបីជួបប្រទះនូវគ្រោះធម្មជាតិដូចជា: ទឹកជំនន់ រាំងស្ងួត និងសត្វល្អិតបំផ្លាញខ្លះៗក៏ដោយ។ នៅឆ្នាំ២០១១នេះ បរិមាណផលសរុបកើនឡើងជាងឆ្នាំ២០១០ប្រមាណ ៥២៩.៩១៣តោន ស្មើនឹង៦,៤២% ដោយសារការខិតខំស្តារឡើងវិញនូវផ្ទៃដីដែលបានខូចខាត និងម្យ៉ាងទៀតគឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចំការ ការផ្លាស់ប្តូរបច្ចេកទេស និងការមានផ្លាស់ប្តូរពូជដែលមានទិន្នផលខ្ពស់។

ក្រាហ្វិកទី ៤ ÷ បង្ហាញអំពីកំណើនផលិតកម្មស្រូវពីឆ្នាំ ២០០៧-២០១១




កំណើននៃផលិតកម្មដំណាំស្រូវមានការប្រែប្រួលតាមឆ្នាំនីមួយៗ អាស្រ័យដោយលក្ខខណ្ឌនិងភាពអនុគ្រោះនៃកត្តាទឹកនិងសមត្ថភាពទប់ទល់ស្ការពីការខូចខាត។ ទន្ទឹមនឹងនោះ បើប្រៀបធៀបទៅនឹងឆ្នាំ២០១០ ផ្ទៃដីអនុវត្តដាំដុះបានកើនប្រហែល ៦,១៧% តែផ្ទៃដីប្រមូលផលថយចុះ០,៣៩% (ខូចខាតដោយទឹកជំនន់ទន្លេមេគង្គស្មើ១០,៧%នៃផ្ទៃដីអនុវត្ត២,៥លានហត) និងបរិមាណផលកើន៦,៤២%។ ជារួមផលិតផលស្រូវបានកើនឡើងធៀបនឹងឆ្នាំកន្លងមកដែលទាំងអស់នេះ គឺដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានជំរុញឱ្យវិស័យកសិកម្មមានដំណើរការល្វតលាស់ទាំងបរិមាណនិងគុណភាព ពិសេសការគ្រប់គ្រងទាំងផ្នែកបច្ចេកទេសដាំដុះ និងការកែច្នៃផលិតផលកាន់តែប្រសើរឡើង។

**៤.៣.២- ការវិវឌ្ឍន៍ដំណាំកសិកម្ម ៤ មុខពីឆ្នាំ២០០២-២០១១**

ក្រាហ្វិកទី ៥ ÷ បង្ហាញអំពីផ្ទៃដីដំណាំ ៤ មុខ ឆ្នាំ ២០០២-២០១១ (ពោត ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀង)




តារាង: ផ្ទៃដីដាំដុះដំណាំរដូវសំខាន់ៗ៤មុខ៖ (ឯកតា: គិតជាហត)

| មុខដំណាំ | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត | 80,470 | 93,362 | 91,203 | 90,732 | 108,836 | 142,391 | 163,106 | 206,058 | 213,622 | 174,257 |
| ដំឡូងមី | 19,563 | 25,740 | 22,749 | 30,032 | 97,918 | 108,122 | 179,945 | 160,326 | 206,226 | 391,714 |
| សណ្តែកបាយ | 39,802 | 44,940 | 39,089 | 60,570 | 85,140 | 65,261 | 45,605 | 49,599 | 69,206 | 68,111 |
| សណ្តែកសៀង | 33,438 | 53,064 | 84,886 | 118,760 | 75,053 | 76,981 | 74,413 | 96,388 | 103,198 | 70,584 |
| សរុបដំណាំ៤មុខ | **173,273** | **217,106** | **237,927** | **300,094** | **366,947** | **392,755** | **463,069** | **512,371** | **592,252** | **704,666** |

ជារួមផ្ទៃដីដាំដុះដំណាំរដូវ មានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗ ហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិងទីផ្សារ។ ផ្ទៃដីដាំដុះដំណាំសំខាន់ៗ (ពោត ដំឡូងមី សណ្ដែកបាយ សណ្ដែកសៀង) មានទិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនឡើងបានពី ៥៩២.២៥២ហត (ឆ្នាំ២០១០) ដល់ ៧០៤.៦៦៦ហត (ឆ្នាំ២០១១) ពោលគឺកើនប្រហែល ១៨,៩៨%។

ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម សរុបទូទាំងប្រទេសសម្រាប់ឆ្នាំ២០១១ សម្រេចបានប្រមាណ ៨៥៦.៧៧៧ហត កើនលើសឆ្នាំមុន ១៣,៨៤% និងបរិមាណផលសរុបនៃដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មប្រចាំឆ្នាំ ក៏មានការកើនឡើងដែរ គឺបានកើនពី ៦,១លានតោន ឆ្នាំ២០១០ ដល់ ៩,៩៣លានតោន ឆ្នាំ២០១១ (កើនប្រមាណ ៦១.៧១%)។ ទន្ទឹមនឹងនោះ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ អនុវត្តបានសរុបចំនួន ១៦៤.៨៤០ហត តិចជាងឆ្នាំមុន ១៣,២៤ %។ ដូចនេះ ផ្ទៃដីដាំដុះដំណាំទូទាំងប្រទេសសម្រេចបាន ៣,៩២លានហត (ផ្ទៃដីដាំដុះដំណាំស្រូវចំនួន២,៩៧លានហត ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មចំនួន ០,៧៩ លានហត និងផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ចំនួន ០,១៦ លានហត។

### ៤.៣.៣- ការវិវឌ្ឍវិស័យបសុសត្វ

**ក្រាហ្វិកទី ៦ ÷ បង្ហាញអំពីការវិវត្តន៍សត្វនៅកម្ពុជាពីឆ្នាំ២០០៧-២០១១**




ជារួមផលិតកម្មសត្វនៅកម្ពុជា ជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍គួរកត់សម្គាល់ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះ អាចធានាការផ្គត់ផ្គង់សេចក្ដីត្រូវការក្នុងស្រុកនិងកន្លងមកគោ ក្របី មួយចំនួនត្រូវបាននាំចេញទៅបរទេស។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វរយៈពេល៥ឆ្នាំ (២០០៧-២០១១) ឃើញថា ផលិតកម្មគោកើនបានចំនួន១.១១%។ ដោយឡែក បើប្រៀបធៀបនឹងឆ្នាំ២០១០ ការចិញ្ចឹមគោបានថយចុះពី៣,៤៨លានក្បាល មកត្រឹម ៣,៤០លានក្បាល ថយចុះប្រមាណ២,២៦% រីឯក្របីសរុបមានចំនួនជាង៦៨៩ពាន់ក្បាល ថយចុះ១,៧៤% និងជ្រូកចិញ្ចឹមបានជាង២លានក្បាល កើនប្រមាណ១,៨៩%។ ការថយចុះចំពោះសត្វគោក្របីនេះ គឺមូលហេតុបណ្ដាលមកពីជំងឺឆ្លងសត្វ (ពិសេសជំងឺសារទឹក ជំងឺអុតក្ដាម និងជំងឺជ្រូកត្រចៀកខៀវ) ចលនាពាណិជ្ជកម្មសត្វនាំចូល-ចេញមិនផ្លូវការ។ល។ ជាពិសេសប្រជាកសិករ ភាគច្រើនប្រើប្រាស់ត្រាក់ទ័រនិងគោយន្ត។

**ក្រាហ្វិកទី ៧ ÷ បង្ហាញអំពីបម្រែបម្រួលលស្ថិតិសត្វស្លាប (មាន់ទា) នៅកម្ពុជាពីឆ្នាំ២០០៧-២០១១**



ការចិញ្ចឹមសត្វស្លាបពីឆ្នាំ២០០៧ដល់២០១១ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់៣៦.៦% គឺពីជាង១៥លានក្បាល ដល់ ២១,៦១លានក្បាល ជាមួយនោះ ឆ្នាំ២០១១ សត្វស្លាបមានការកើនឡើងចំនួន៤,៦៤% បើប្រៀបធៀបនឹងឆ្នាំ២០១០ នេះបញ្ជាក់ឱ្យឃើញថា ប្រជាកសិករយល់ដឹងជាបណ្តើរៗ នូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ជាពិសេសការផ្សព្វផ្សាយទូលំទូលាយក្នុងជួរកសិករ ដែលជាលទ្ធផលចំនួនសត្វស្លាបមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ ស៊ុត នៅក្នុងប្រទេស និងកសិកដ្ឋានផលិតកម្មមានលក្ខណៈស្របច្បាប់ជាបណ្តើរៗដែរ។ គួរកត់សម្គាល់ថា មានករណីជម្ងឺកើតសត្វស្លាបកើតមាននៅតំបន់មួយចំនួន ប៉ុន្តែត្រូវបានការពារបានយ៉ាងមានប្រសិទ្ធភាព ទន្ទឹមនោះ ពាក់ព័ន្ធនឹងការងារផលិតកម្ម និងបសុព្យាបាលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចុះនូវវិធានការមួយចំនួន ដើម្បីជំរុញការចិញ្ចឹមសត្វស្លាបទាំងកម្រិតគ្រួសារ និងកម្រិតកសិដ្ឋាន ក៏ដូចជាបានលើកទឹកចិត្តវិនិយោគលើការចិញ្ចឹមមាន់សាច់ និងស៊ុត។

ជារួមការចិញ្ចឹមសត្វមានសន្ទុះធ្លាក់ចុះបន្តិចតាមបែបគ្រួសារនិងបែបពាណិជ្ជកម្ម បើធៀបនឹងឆ្នាំ២០១០លើកលែងការចិញ្ចឹមសត្វស្លាប។ ប៉ុន្តែចំពោះការកែលម្អពូជសត្វ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរផងដែរ ព្រោះប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើស ពូជសត្វជាកត្តាសំខាន់ ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារបានឆាប់ទៀតផង។ ចំណែកឯចំណីសត្វ និងដំណាំចំណីសត្វ ប្រជាកសិករមានការចូលរួមយ៉ាងសកម្ម និងយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចក្នុងស្រុកយ៉ាងផុសផុល។

### ៤.៣.៤- ការវិវឌ្ឍវិស័យកៅស៊ូ

កៅស៊ូធម្មជាតិគឺជាប្រភេទដំណាំឧស្សាហកម្មមួយយ៉ាងសំខាន់ ដែលបានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមដល់អ្នកដាំ និងដែលបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការការពារបរិស្ថានធម្មជាតិប្រកបដោយចីរភាព។

នៅក្នុងឆ្នាំ២០១១ បរិមាណផលិតផលកៅស៊ូធម្មជាតិនៅក្នុងពិភពលោក ផលិតបានបរិមាណចំនួន ១០,១០លានតោន គឺកើនឡើង ៦,៤% បើប្រៀបធៀបជាមួយផលិតផលឆ្នាំ២០១០ ដែលមានចំនួន ៩,៤៩លានតោន។ ជាមួយគ្នានេះ ការប្រើប្រាស់កៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១១ មានបរិមាណចំនួន ១០,៤៩លានតោន គឺបានកើនឡើងចំនួន៣% បើប្រៀបធៀបជាមួយការប្រើប្រាស់ឆ្នាំ២០១០ ដែលមានចំនួន១០,១៨លានតោន។ ដូច្នេះសន្និធិប្រចាំឆ្នាំនៅតាមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ គឺមានតិចតួចណាស់។ កត្តានេះ បានធ្វើឲ្យតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិ មានសន្ទុះកើនឡើងនាពេលបច្ចុប្បន្ន ក៏ដូចជាទៅថ្ងៃអនាគតផងដែរ ។

នៅឆ្នាំ២០១១ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនដល់ចំនួន២១៣.១០៤ហត គឺកើនឡើង១៧,៥% បើប្រៀបធៀបទៅនឹងឆ្នាំ២០១០ (ផ្ទៃដីដាំកៅស៊ូឆ្នាំ ២០១០ មានចំនួន១៨១.៤៣០ហត) ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្មមានស្រាប់ចំនួន៥០.៧១៥ហត ផ្ទៃដីវិនិយោគថ្មីស្ថិតនៅលើដីសម្បទានសេដ្ឋកិច្ចមានចំនួន៦៦.៤៥៩ហត និងផ្ទៃដីកៅស៊ូគ្រួសារមានចំនួន ៩៥.៩៣០ ហត។

**ក្រាហ្វិកទី ៨: ផ្ទៃដីដាំដុះកៅស៊ូតាមប្រភេទឆ្នាំ២០១១**



សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជា មានការកើនឡើងជាលំដាប់ អាស្រ័យដោយសារតម្លៃកៅស៊ូបានឡើងខ្ពស់ គួបផ្សំស្ថានភាពនយោបាយសន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយសេរីភាវូបនីយកម្ម លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក ជាពិសេសមានការចូលរួមពីផ្នែកឯកជន ដែលបានធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដោយបានធ្វើឲ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរជាទីមោទនៈ។

ដោយឡែក ចំពោះចម្ការកៅស៊ូកសិ-ឧស្សាហកម្មមានស្រាប់ ពុំមានការកើនឡើងផ្ទៃដីដាំដុះថ្មីគួរឲ្យកត់សម្គាល់ទេ គឺធ្វើការដាំដុះតែលើផ្ទៃដីកៅស៊ូចាស់ កាប់ និងដាំឡើងវិញតែប៉ុណ្ណោះ ។

**ក្រាហ្វិកទី ៩ ÷ ការវិវត្តន៍នៅក្នុងការដាំដុះកៅស៊ូឆ្នាំ២០០៧-២០១១**




## ៤.៣.៥- ការអភិវឌ្ឍវិស័យរុក្ខកម្ម

នៅឆ្នាំ២០១១នេះ បញ្ហាលេចធ្លោសំខាន់ៗមួយចំនួនក្នុងវិស័យព្រៃឈើនៅកម្ពុជាមានដូចជា បញ្ហាប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD) យន្តការអភិវឌ្ឍន៍ស្អាត (CDM) កម្មវិធីព្រៃឈើជាតិ (NFP)។

ដើម្បីពង្រឹងការគ្រប់គ្រងវិស័យព្រៃឈើ មន្ត្រីជំនាញរបស់រដ្ឋបាលព្រៃឈើចំនួន២.១២៣នាក់បានទទួលវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងវែងនៅក្នុងនិងក្រៅប្រទេស ដោយផ្តោតលើការពង្រឹងសមត្ថភាពមន្ត្រីលើការងារគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យព្រៃឈើនិងសត្វព្រៃ។

កម្មវិធីព្រៃឈើត្រូវបានរៀបចំនិងអនុវត្តប្រកបដោយប្រសិទ្ធភាព ពិសេសការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍គ្របដណ្តប់នៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើ កំពត កណ្តាល ក្រចេះ រតនគិរី មណ្ឌលគិរី និងព្រះវិហារ។

ក្នុងក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិ ក្រសួងបានរៀបចំបោះពុម្ពសៀវភៅបម្រែបម្រួលគម្របព្រៃឈើឆ្នាំ២០១០ជាភាសាជាតិនិងភាសាអង់គ្លេស ដើម្បីវាយតម្លៃការប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និង២០១០ នៅទូទាំងប្រទេស និងវាយតម្លៃការប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និង ២០១០ ក្នុងព្រៃសហគមន៍ចំនួន៨៨ ក្នុងខេត្តចំនួន១៦។ កិច្ចសហប្រតិបត្តិការជប៉ុនស្តីពីគម្រោងប្រព័ន្ធតាមដានការប្រែប្រួលគម្របព្រៃឈើ REL/MRV តាមគោលការណ៍ Cambodia REDD Road Map ត្រូវបានអនុវត្ត។ ចំពោះការផ្គត់ផ្គង់តម្រូវការឈើប្រើប្រាស់ក្នុងស្រុក ក្រសួងបាននិងកំពុងផ្តល់សេវាផ្គត់ផ្គង់ផល អនុផលព្រៃឈើដែលមានប្រភពពីបណ្តាក្រុមហ៊ុនគម្រោងវារីអគ្គិសនី ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។ ចំពោះការប្រើប្រាស់ផល អនុផលព្រៃឈើរបស់សហគមន៍ព្រៃឈើរាជរដ្ឋាភិបាលពុំយកសួយសារនិងបុព្វលាភ។ ទន្ទឹមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍បានចំនួន៥១កន្លែងលើផ្ទៃដី១៣.៨៩៥ហាតដូចជាខេត្ត ពោធិសាត់ចំនួន៣៨កន្លែង ឧត្តរមានជ័យចំនួន០២កន្លែង កំពតចំនួន០១កន្លែង និងតាកែវចំនួន០៦កន្លែង។

**ក្រាហ្វិកទី ១០÷ បង្ហាញអំពីសហគមន៍ព្រៃឈើពីឆ្នាំ២០០៧-២០១១**




ដើម្បីបង្កើនការងារគ្រប់គ្រងព្រៃឈើ ក្រសួងបានព្រាងច្បាប់ស្តីពីសត្វព្រៃ និងជីវចម្រុះ និងព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃបៃតងជានិច្ចក្នុងទីទំនាបក្នុងខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ និងស្ទឹងត្រែង។ ក្នុងកិច្ចការពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមរយៈរដ្ឋបាលព្រៃឈើបានបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃនិងបទល្មើសកាប់រានដីព្រៃ ការទន្ទ្រានដីព្រៃសរុបចំនួន១.៧៩០ករណី (កើនឡើងចំនួន២៨៣ករណីធៀបទៅនឹងឆ្នាំ២០១០ ដែលមានចំនួន១.៥០៧ករណី)។

ក្នុងក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិក៏ដូចកម្មវិធីទី៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់រដ្ឋបាលព្រៃឈើ ការដាំដើមឈើនិងបណ្តុះកូនឈើនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន០៧ របស់រដ្ឋបាលព្រៃឈើត្រូវបានជំរុញនិងអនុវត្តប្រកបដោយលទ្ធផលផ្លែផ្កាគួរជាទីពេញចិត្ត។ ការដាំដុះដំណាំកោះស៊ូនិងដាំឈើព្រៃ ដើម្បីបង្កើនគម្របព្រៃតាមផែនការកំណត់ ត្រូវបានអនុវត្តយ៉ាងសស្រាក់សស្រាំពិសេសការចូលរួមពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងគ្រួសារឯកជន (ទិន្នន័យលម្អិតមានក្នុងជំពូក២)។

**ក្រាហ្វិកទី ១១ ÷ បង្ហាញអំពីការដាំដុះឈើពីឆ្នាំ ២០០៧-២០១១**




### ៤.៣.៦- ការវិវឌ្ឍវិស័យជលផល

នៅក្នុងឆ្នាំ២០១១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការបង្កើតស្រះជម្រកត្រីសហគមន៍ ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស ការលុបបំបាត់បទល្មើសនេសាទ និងការផ្សព្វផ្សាយពង្រឹងការអនុវត្តច្បាប់ជាដើម។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងបទដ្ឋានបច្ចេកទេសមួយចំនួនទៀត ដែលបានរៀបចំត្រូវបានពិនិត្យកែសម្រួលនិងអនុម័ត ដើម្បីដាក់ឲ្យអនុវត្តធានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។

ជាមួយការរីកចម្រើននេះដែរ ក្នុងឱកាសប្រារព្ធទិវាមច្ឆជាតិ ១កក្កដា ជារៀងរាល់ឆ្នាំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តែងតែបានផ្តល់អនុសាសន៍ដ៏ថ្លៃថ្លា ពាក់ព័ន្ធដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផលដែលទាក់ទងដល់ការលុបបំបាត់បទល្មើស ការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុង ឧបករណ៍ឆក់ត្រី ការបង្កើតកន្លែងអភិរក្សធនធានជលផល ការរៀបចំនិងគ្រប់គ្រងពង្រឹងសហគមន៍នេសាទ ជំរុញការអភិវឌ្ឍន៍វារីវប្បកម្ម ការថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងជាដើម ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំអនុវត្តយ៉ាងសកម្ម ដើម្បីសម្រេចបាននូវទិសដៅដាក់ចុះនេះ។ ជាក់ស្តែងសមិទ្ធិផលធំៗបានទទួលមានដូចខាងក្រោម÷

-អាជីវកម្មនេសាទទឹកសាបៈ អាជីវកម្មទឹកសាបឆ្នាំ២០១១ អនុវត្តបានចំនួន៤៤៥.០០០តោន កើនលើសឆ្នាំមុនប្រមាណ ៤០.០០០តោន និងមានកំណើនប្រមាណ៣,២៤% រយៈពេល៥ឆ្នាំ (ឆ្នាំ២០០៧ ដល់ឆ្នាំ២០១១)

-អាជីវកម្មនេសាទសមុទ្រៈ ការធ្វើអាជីវកម្មនេសាទសមុទ្រឆ្នាំ២០១១ អនុវត្តបាន៩១.០០០តោន ស្មើ១១៣,៧៥% នៃផែនការ៨០.០០០តោន និងមានកំណើនប្រមាណ៩,៥០% រយៈពេល៥ឆ្នាំ (២០០៧-២០១១)

-ការអភិវឌ្ឍវារីវប្បកម្មៈ ការចិញ្ចឹមត្រី បង្គាឆ្នាំ២០១១ អនុវត្តបានចំនួន៧២.០០០តោន ស្មើ១២០% នៃផែនការ ៦០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១២.០០០តោន ឬកំណើន២០%ប្រចាំឆ្នាំ។ ជាមួយគ្នានេះដែរការចិញ្ចឹមក្រពើអនុវត្តបាន២៣០.០០០ក្បាល ស្មើ១១៥% នៃផែនការ២០០.០០០ក្បាល និងការភ្ញាស់កូនត្រីនៅទូទាំងប្រទេសអនុវត្តបានចំនួន២៨០កន្លែង ក្នុងនោះមាន២៦៧កន្លែងជារបស់កសិករ តាមរយៈការផ្តល់បច្ចេកទេសពីរដ្ឋបាលជលផល និងបានបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន៧៣៨កន្លែង ដែលនៅក្នុងខេត្តកំពង់ស្ពឺច្រើនជាងគេចំនួន១៧៣កន្លែង និងខេត្តសៀមរាបចំនួន៩០កន្លែង។ ជាមួយគ្នានោះកន្លែងដែលបានរៀបចំហើយធ្វើឲ្យផលត្រីតាមវាលស្រែកើនពី៤-៦ដងជាមធ្យម នេះអាចបញ្ជាក់ថាប្រជាកសិករនិងប្រជានេសាទបានទទួលយកនូវបច្ចេកទេសវារីវប្បកម្ម ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តកន្លងមក។

-ក្នុងការអនុវត្តវិធានការកែទម្រង់វិស័យជលផលរហូតដល់សព្វថ្ងៃនេះ ឡូត៍នេសាទដែលបានលុបទាំងអស់ត្រូវរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារនិងធ្វើជាកន្លែងអភិរក្សជលផល និងរៀបចំបង្កើតសហគមន៍នេសាទ សរុបបានចំនួន**៤៦៩សហគមន៍** ដែលបានចុះបញ្ជីជាផ្លូវការបានចំនួន៣២៤សហគមន៍រួចហើយ។

-ចំណូលវិស័យជលផលៈ ចំណូលពីការធ្វើអាជីវកម្មនេសាទឆ្នាំ២០១១ អនុវត្តបានចំនួន៧.៤១៨.៧៤៣.៥៥០រៀល ស្មើ៨១,៤២% នៃផែនការ៩.១១២.០០០.០០០រៀល។

**ក្រាហ្វិកទី១២÷ បង្ហាញអំពីផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ**




លទ្ធផលដែលទទួលបានក្នុងវិស័យជលផលបានដាក់ចេញនូវវិធានការឲ្យគ្រប់អធិការដ្ឋាន និងខណ្ឌរដ្ឋបាលជលផលទាំងអស់អនុវត្តតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ**

**ព្រះរាជាណាចក្រកម្ពុជា** ឃើញថាសកម្មភាពទាំអស់នេះ មានការរីវឌ្ឍន៏រីកចម្រើនគួរជាទីមោទនៈ។ ជាមួយគ្នានេះដែរ រដ្ឋបាលជលផលក៏បានសហការជាមួយដៃគូអភិវឌ្ឍនិងប្រទេសផ្តល់ជំនួយនានា ក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយពង្រីកវារីវប្បកម្មនិងការអភិរក្ស ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល ដើម្បីកិច្ចអភិវឌ្ឍន៏វិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព។

ម្យ៉ាងវិញទៀត ការជំរុញបង្កើនការទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធនិងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំគ្រប់គ្រងនិងការអភិវឌ្ឍសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី បានជួយជំរុញថែមទៀតដល់ការលើកស្ទួយវិស័យជលផលនេះ និងបានជួយដល់ការអភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ជនបទ ឲ្យមានភាពរីវឌ្ឍឈានឡើងជាលំដាប់នាពេលកន្លងមក។ ពិសេសការខិតខំអនុវត្តអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ***"ធ្វើឲ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ"*** បានធ្វើឲ្យវិស័យជលផលមានការរីកចម្រើន គួរជាទីមោទនៈ និងបន្តអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល ក្នុងការលុបបំបាត់បទល្មើសនេសាទជាពិសេសក្នុងតំបន់បឹងទន្លេសាប។

ក្នុងទិសដៅជំរុញការងារគ្រប់គ្រងវិស័យជលផលឲ្យកាន់តែមានភាពប្រសើរជាងមុន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងត្រូវផ្តោតជាសំខាន់លើការអនុវត្តតាមគោលការណ៍មួយចំនួនរួមមាន÷ បន្តសហការជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ឲ្យទាន់ពេលវេលានូវការកាប់បំផ្លាញព្រៃលិចទឹកនៅតំន់ហាមឃាត់ ដូចជាតំបន់៣នៅជុំវិញបឹងទន្លេសាបនិងព្រៃកោងកាងតំបន់សមុទ្រ ហើយនឹងមានវិធានការជាក់ស្តែងជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ឲ្យបានជាដាច់ខាតនូវការរំលោភយកដីព្រៃលិចទឹកនិងព្រៃកោងកាងធ្វើជាដីកម្មសិទ្ធិ។

ភារកិច្ចសំខាន់និងបន្ទាន់ចំពោះមុខគឺចុះរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស និងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងពង្រឹងសកម្មភាពគ្រប់គ្រងកន្លែងអភិរក្សជលផលប្រកបដោយប្រសិទ្ធភាព។ បន្តយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍន៍វារីវប្បកម្មគ្រប់ប្រភេទដូចជា ចិញ្ចឹមក្នុងស្រះ ក្នុងស្រែ និងក្នុងបែរទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសតំបន់ដែលខ្សត់ទឹកខ្វះខាតត្រី ដោយលើកទឹកចិត្តនិងជំរុញការចិញ្ចឹមត្រីខ្នាតតូចជាលក្ខណៈគ្រួសារ ព្រមទាំងទាក់ទាញវិនិយោគិន ចូលរួមក្នុងវិស័យវារីវប្បកម្មឲ្យបានខ្លាំងក្លាដើម្បីឲ្យវិស័យឯកជននេះជួយអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម។

ទន្ទឹមនឹងនេះ រដ្ឋបាលជលផលថ្នាក់មូលដ្ឋាននឹងបង្កើនសកម្មភាពត្រួតពិនិត្យនិងលុបបំបាត់បទល្មើសជលផលគ្រប់រូបភាពតាមបណ្តាខេត្ត និងការពារឱ្យកាន់តែខ្លាំងក្លា ជាពិសេសបទល្មើសអាគុយឆក់ត្រីនិងស្បៃមុង។

# ជំពូក ២
# លទ្ធផលនិងទិសដៅ

## ៥-លទ្ធផលឆ្នាំ២០១១-២០១២និងទិសដៅឆ្នាំ២០១២-២០១៣

### ៥.១- ផលិតកម្មដំណាំស្រូវនិងដំណាំផ្សេងៗ (ឧបសម្ព័ន្ធទី១-៨)

ជារួមទូទាំងប្រទេសសភាពការណ៍អាកាសធាតុ ពិសេសស្ថានភាពទឹកភ្លៀងនៅរដូវវស្សាឆ្នាំ២០១១ មានអំណោយផលល្អចាប់ពីដើមរដូវរហូតដល់ចុងរដូវ ជាមួយនោះទទួលរងនូវគ្រោះធម្មជាតិដោយជំនន់ទឹកភ្លៀងនៅពាក់កណ្តាលខែសីហា និងទឹកទន្លេមេគង្គមានការកើនឡើងជាបន្តបន្ទាប់រហូតដល់មានការជន់លិច ចាប់ពីចុងខែកញ្ញានិងបន្តជន់លិចធ្ងន់ធ្ងររហូតដល់ពាក់កណ្តាលខែវិច្ឆិកា។

បណ្តាខេត្តដែលជួបនឹងគ្រោះធម្មជាតិទឹកជំនន់ទន្លេមេគង្គនិងទឹកភ្លៀងដូចជាមាន÷កំពង់ធំ ព្រៃវែង កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ សៀមរាប កំពង់ឆ្នាំង ស្វាយរៀង កណ្តាល តាកែវ ក្រចេះ កំពត ព្រះវិហារ ស្ទឹងត្រែង រាជធានីភ្នំពេញ ឧត្តរមានជ័យនិងប៉ៃលិន។

សភាពការណ៍ផ្សេងៗទៀត លើការងារបង្កបង្កើនផលដំណាំស្រូវទទួលរងនូវគ្រោះរាំងស្ងួតនៅបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ស្ពឺ ស្វាយរៀងនិងតាកែវ ព្រមទាំងទទួលរងនូវសត្វល្អិតបំផ្លាញនៅខេត្តកោះកុង។

ឆ្នាំ២០១១នេះ ទោះបីជួបប្រទះគ្រោះធម្មជាតិ (ទឹកជំនន់ រាំងស្ងួត សត្វល្អិត) លើផលិតផលដំណាំក៏ដោយ ក៏យើងខិតខំយ៉ាងសកម្មយកអស់កម្លាំងកាយចិត្តជំរុញការងារផលិតកម្មទទួលបានជោគជ័យគួរជាទីមោទនៈ។

**ក-ដំណាំស្រូវ ៖**

-ផ្ទៃដីអនុវត្តសរុបទូទាំងឆ្នាំ**២.៩៦៨.៥២៩ហត**លើសឆ្នាំមុន១៧២.៦៣៧ហតក្នុងនោះរដូវវស្សាអនុវត្តបាន**២.៤៩៦.៥៦៩ហត** លើសឆ្នាំមុនចំនួន ១០៥.៥៥៣ហត និងរដូវប្រាំងសរុបចំនួន**៤៧១.៩៦០ហត** លើសឆ្នាំមុន៦៧.០៨៤ ហត

-ផ្ទៃដីខូចខាតសរុបចំនួន**២៦៧.៣៦៤ហត**ជាផ្ទៃដីដំណាំស្រូវរដូវវស្សា តែស្តារបានវិញ**៦៥.៤៥២ហត** រីឯដំណាំស្រូវរដូវប្រាំងពុំមានទទួលរងការខូចខាតឡើយ។

-ផ្ទៃដីប្រមូលផលសរុប**២.៧៦៦.៦១៧ហត**តិចជាងឆ្នាំមុន១០.៧០៦ហត ក្នុងនោះរដូវវស្សា**២.២៩៤.៧៨៤ហត** តិចជាងឆ្នាំមុនចំនួន៧៧.៧៣៥ហត និងរដូវប្រាំងសរុបចំនួន**៤៧១.៨៣៣ហត** លើសឆ្នាំមុនចំនួន៦៧.០២៩ហត

-ទិន្នផលមធ្យមប្រចាំឆ្នាំ**៣,១៧៣ត/ហត**លើសឆ្នាំមុន០,២០៣ត/ហត ក្នុងនោះរដូវវស្សា**២,៩២០ត/ហត** (លើស ឆ្នាំមុន ០,១៦០ត/ហត) និងរដូវប្រាំង**៤,៤០៦ត/ហត** (លើសឆ្នាំមុន០,២០៥ត/ហត)

-បរិមាណផលទទួលបានសរុប**៨.៧៧៩.៣៦៥តោន**លើសឆ្នាំមុន៥២៩.៩១៣តោន ក្នុងនោះរដូវវស្សា៦.៧០០.៤៣៩តោន លើសឆ្នាំមុន១៥១.៧៣០តោននិងរដូវប្រាំងឆ្នាំ២០១១-២០១២ចំនួន២.០៧៨.៩២៦តោនលើសឆ្នាំមុនចំនួន៣៧៨.១៨៣តោន

-តុល្យភាពស្បៀងសល់**២.៧៨០.៣២៨តោនអង្ករ** គិតជាស្រូវ**៤.៣៤៤.២៦៣តោន**លើសឆ្នាំមុនចំនួន៤១១.៨៣៨តោន។

**ខ-ដំណាំកសិកម្មរួមផ្សំ**

***ខ.១- ដំណាំរួមផ្សំ÷***

ដំណាំរួមផ្សំអនុវត្តបានសរុប ៦៩៦.០៤៣ហត កើនលើសឆ្នាំមុន ១៤២.៨០៥ហត និងបរិមាណផលសរុប ៩.២៧៣.៩២៣តោន លើសឆ្នាំមុន ៣.៧២៤.២៩៤តោន។

***ខ.២- ដំណាំឧស្សាហកម្ម÷***

ដំណាំឧស្សាកម្មអនុវត្តបានសរុប ១៦០.៧៣៤ហត តិចជាងឆ្នាំមុន ៣៨.៦៦៧ហត និងបរិមាណផលសរុប ៦៥២.៨២០ តោន កើនលើសឆ្នាំមុន ៦៣.៩១៧ តោន។

ពិនិត្យជារួមលទ្ធផលដំណាំកសិកម្មបានអភិវឌ្ឍជាប្រវត្តិសាស្ត្រដ៏ល្អប្រសើរ ដែលកន្លងមកប្រទេសកម្ពុជាពុំធ្លាប់ជួប

ប្រទះនូវសមិទ្ធផលនៃវិស័យកសិកម្មមានការរីកចម្រើនដូចពេលនេះ ពិសេសដំណាំស្រូវបានកើនឡើងលើសផែនការដែលបានគ្រោងទុក។

**គ-ដំណាំអចិន្ត្រៃយ៍**

ដំណាំឈើហូបផ្លែ និងដំណាំអចិន្ត្រៃយ៍ ក៏មានការអភិវឌ្ឍកើនឡើងជាបន្តបន្ទាប់។ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍អនុវត្តបានក្នុងឆ្នាំ២០១១ មានសរុបចំនួន១៦៤.៨៤០ហត តិចជាងឆ្នាំមុន១៣,២៤%។ ដោយឡែក ចំពោះទិន្នផលដំណាំអចិន្ត្រៃយ៍មួយចំនួនដូចជា មៀនសរុបចំនួន ៨,៥៧៧/ហត ស្វាយសរុបចំនួន ២១,៩៣តោន ធូរេនសរុបចំនួន ១៥,១១តោន និងក្រូចសរុបចំនួន ៨,៥២តោន។

## ៥.២. ការងារកសិកម្ម

### ៥.២.១. លទ្ធផល

អគ្គនាយកដ្ឋានកសិកម្មមានបេសកកម្មដឹកនាំគ្រប់គ្រង និងធ្វើសកម្មភាពជំរុញការអភិវឌ្ឍវិស័យផលិតកម្មដំណាំកសិកម្ម ដើម្បីចូលរួមចំណែក(១) ធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ(២) គ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល(៣) ជំរុញកំណើនផលិតភាពកសិកម្មតាមរយៈពិពិធកម្មកសិកម្ម(៤) កាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនចំណូលដល់កសិករដោយតម្លៃបន្ថែមលើកសិផល និង(៥) ធានាទីផ្សារកសិផល ។

អគ្គនាយកដ្ឋានកសិកម្ម បាននិងកំពុងអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដោយផ្តោតលើការងារស្រាវជ្រាវ និងអភិវឌ្ឍស្នូលសំខាន់ៗមួយចំនួនមានជាអាទិ(១) ការគ្រប់គ្រងធនធានដីកសិកម្ម(២) ការអភិវឌ្ឍដំណាំកសិកម្មគ្រប់ប្រភេទ(៣) ការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ (៤) ការស្រាវជ្រាវអភិវឌ្ឍនិងជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម (៥) ការផ្សព្វផ្សាយកសិកម្ម និង(៦) ការត្រួតពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ ។

ក្នុងឆ្នាំ២០១១ កន្លងមកនេះ ដោយមានការគាំទ្រទាំងផ្នែកស្មារតី និងសម្ភារថវិកាពីថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កិច្ចចូលរួមសហការនិងការគាំពារពីដៃគូអភិវឌ្ឍនានា ការចូលរួមសហការស្និតរមួតពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់និងជាពិសេសការចូលរួមរបស់ប្រជាកសិករ ជាមួយគ្នានោះ បាននិងកំពុងប្រែក្លាយនូវបេសកកម្មដ៏ធំធេងនេះ ឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ក្នុងការចូលរួមចំណែកក្នុងការជំរុញការអភិវឌ្ឍនិងកំណើនវិស័យផលិតកម្មដំណាំកសិកម្ម ដោយសម្រេចបានសមិទ្ធផលសំខាន់ៗគួរជាទីមោទន។

ជាក់ស្តែង ផលិតកម្មដំណាំស្រូវដែលជា "មាស ស" របស់កម្ពុជា និងជាផ្នែកមួយដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជនបទ ចូលរួមទ្រទ្រង់ជីវភាពប្រជាជនកម្ពុជាទាំងនៅទីជនបទ និងទីក្រុង សមិទ្ធិផលសម្រេចបានដ៏ត្រចះត្រចង់នេះពិតជាមិនអាចកាត់ផ្តាច់បានពីការអនុវត្តការងារដ៏សកម្មរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការអគ្គនាយកដ្ឋានកសិកម្មតាមជំនាញដូចខាងក្រោមបានឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តួចផ្តើមរៀបចំសន្និបាតកសិករទូទាំងប្រទេស ដោយឈរលើទស្សនៈបំផុសនូវគំនិតច្នៃប្រឌិត ផ្លាស់ប្តូរបទពិសោធន៍ និងគំនិតបង្កើតថ្មីដល់កសិករ។ ក្នុងន័យនេះ កាលពីថ្ងៃទី០១-០២ ខែមិនា ឆ្នាំ២០១២ កន្លងទៅនេះ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសន្និបាតកសិករទូទាំងប្រទេសលើកទី៣ ដើម្បីធ្វើការប្រឡងប្រជែងជ្រើសរើសកសិករឆ្នើមដែលមានស្នាដៃឯក លើប្រធានបទចំនួន៧ គឺ៖

- **ប្រពលវប្បកម្មដំណាំស្រូវ**
- **ប្រព័ន្ធកសិកម្មចម្រុះ**
- **ការចិញ្ចឹមសត្វ**
- **ការចិញ្ចឹមត្រី**
- **ការកែច្នៃគ្រឿងយន្តនិងឧបករណ៍កសិកម្ម**
- **ការកែច្នៃផលិតផលកសិកម្មនិងជលផល**
- **សកម្មភាពការងាររបស់សហគមន៍ព្រៃឈើ**

សន្និបាតកសិករឆ្នាំនេះ ប្រព្រឹត្តទៅប្រកបដោយមោទនភាព និងទទួលបានលទ្ធផលដ៏ល្អប្រសើរ ដោយមានសមាជិក-សមាជិកា ចូលរួមសរុបចំនួន៣១៥ នាក់ ក្នុងនោះ មានថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពក្រោមឱវាទ មន្ទីរកសិកម្មរាជធានី ខេត្ត អង្គការជាដៃគូរ និងកសិករជាបេក្ខភាពប្រឡងប្រណាំងគ្រប់រាជធានី ខេត្ត ទាំង ២៤ ទូទាំងប្រទេស។ នីតិវិធីនៃការប្រឡងជ្រើសរើសមាន៣ដំណាក់កាលគឺ ទី១ ការវាយតម្លៃលើចំណេះដឹងបច្ចេកទេសនៃការអនុវត្តន៍ និងទេពកោសល្យនៃការពន្យល់បកស្រាយ។ ដំណាក់កាលទី២ គឺចុះវាយតម្លៃការអនុវត្តផ្ទាល់ដោយផ្អែកលើផ្ទៃដីអនុវត្តពិតប្រាកដ និងលទ្ធផលនៃការទទួលយកនូវគំនិតថ្មីនិងការច្នៃប្រឌិត ការផ្សព្វផ្សាយដល់អ្នកជិតខាង និងភាពឧស្សាហ៍ព្យាយាមក្នុងការងារផលិតកម្មនៅមូលដ្ឋាន។ ដំណាក់កាលទី៣ គឺការធ្វើបទបង្ហាញនៅក្នុងអង្គសន្និបាតកសិករទូទាំងប្រទេសនាថ្ងៃទី០១-០២ ខែមីនា ឆ្នាំ២០១២។

បន្ទាប់ពីធ្វើការវាយតម្លៃ គណៈមេប្រយោគបានធ្វើការចម្រាញ់ជ្រើសរើសយកកសិករឆ្នើមចំនួន៥នាក់ ដែលត្រូវទទួលជ័យលាភីពីលេខ១ ដល់លេខ៥ សម្រាប់ប្រធានបទនីមួយៗ ដែលមានចំនួនសរុប៣៥នាក់ មកពីខេត្តចំនួន១៥ គឺខេត្ត កំពង់ចាម តាកែវ កណ្តាល កំពង់ឆ្នាំង សៀមរាប ពោធិសាត់ ស្វាយរៀង ព្រះសីហនុ បាត់ដំបង ព្រៃវែង បន្ទាយមានជ័យ កោះកុង ឧត្តរមានជ័យ កំពង់ស្ពឺ និងកំពង់ធំ ។

### ៥.២.១.១. ការស្រាវជ្រាវនិងអភិវឌ្ឍដំណាំស្រូវ

ការស្រាវជ្រាវដំណាំស្រូវ គឺផ្តោតលើស្វែងរកបច្ចេកទេសមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវ។ ក្នុងឆ្នាំ២០១១កន្លងមកនេះ អគ្គនាយកដ្ឋានកសិកម្ម ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងថវិកាជំនួយពីដៃគូរអភិវឌ្ឍមួយចំនួន បានអនុវត្តការងារពិសោធន៍ ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅតាមកសិដ្ឋាន ស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្ម និងស្រែកសិករ មានជាអាទិ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សាំពូជ និងការពិសោធន៍អំពីវិធីសាស្ត្រដាំដុះដំណាំស្រូវផ្សេងៗទៀត មានចំនួនសរុប៧០ ពិសោធន៍ ការធ្វើបង្ហាញសរុបចំនួន១០០ស្រែបង្ហាញ ធ្វើទិវាស្រែសរុបចំនួន៦៩កន្លែង និងរៀបចំទស្សនៈកិច្ចសិក្សា៣៩លើក ដោយមានកសិករចូលរួមសរុប២.៤៧០នាក់ ។

ក្នុងគោលបំណងផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ពូជសុទ្ធល្អ និងបានដំណើរការផលិតកម្មពូជ អគ្គនាយកដ្ឋានកសិកម្ម បានប្រើប្រាស់ថវិការាជរដ្ឋាភិបាលនិងថវិកាពីដៃគូរអភិវឌ្ឍ ផលិតពូជសុទ្ធល្អបានចំនួន៩៧៥តោន និងពូជសុទ្ធទទួលស្គាល់ចំនួន១០តោន ដើម្បីផ្សព្វផ្សាយជូនប្រជាកសិករ។

ដោយឡែក ការលើកកម្ពស់ និងការទទួលយកបច្ចេកវិជ្ជាផលិតកម្មដំណាំស្រូវ សម្រាប់ដំណើរការជំរុញប្រពលវប្បកម្ម និងបង្កើនផលិតភាពប្រព័ន្ធកសិកម្មមានដំណាំស្រូវជាមូលដ្ឋាន បានដំណើរការការធ្វើស្រែបង្ហាញ ការរៀបចំកម្មវិធីទស្សនកិច្ច ការបណ្តុះបណ្តាល ដែលមានកសិករចូលរួមសរុបចំនួន ៦.១៤៦នាក់ ក្នុងនោះកសិករចំនួន៣០៩នាក់ បានធ្វើការបណ្តុះបណ្តាលក្លាយជាគ្រូបង្គោល។ លេខាធិការដ្ឋាន ប.វ.ស ដែលជាសេនាធិការ បានសហការជាមួយអង្គការ CAVAC និងអង្គការ HARVEST បានបោះពុម្ភសៀវភៅបង្កិបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវបានចំនួន២០.៥០០ក្បាល ខិតប័ណ្ណផ្សព្វផ្សាយ ២០.១០០សន្លឹក និងផ្ទាំងរូបភាពចំនួន២០.១០០សន្លឹក។

### ៥.២.១.២. ការស្រាវជ្រាវនិងអភិវឌ្ឍដំណាំសាកវប្បកម្ម

ការអភិវឌ្ឍអនុវិស័យស្រាវជ្រាវ និងអភិវឌ្ឍសាកវប្បកម្ម និងដំណាំរួមផ្សំនេះ សម្រេចបានសមិទ្ធផល ៖

-បានផលិតពូជបន្លែសរុប៤០តោន រួមមានពូជ ប៉េងបោះ សណ្តែកកួរ ត្រប់វែង ផ្ទីស ពោតដំណើប ពោតផ្អែម ល្ពៅ និង ត្រឡាច ដោយមានការគាំទ្រថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

-បានដំណើរការពិសោធន៍ជ្រើសរើសពូជដំណាំហូបផ្លែ និងរុក្ខជាតិលំអចំនួន៥០ពិសោធន៍ មានកសិករចូលរួមចំនួន ២៤៥នាក់។ តាមរយៈការងារស្រាវជ្រាវនេះ ពូជដំណាំចំនួន០៥ពូជ ត្រូវបានពង្រីករួមមាន ពូជដំណាំស្រការនាគចំនួន៣០០ដើម ពូជផ្កាកូឡាបចំនួន៦០០ដើម ពូជផ្កាត្រីហ្សង់តែមចំនួន ៦០០ដើម ពូជផ្កាចំបីក្រហមចំនួន ៦០០ដើម ពូជផ្កាស្បៃរឿងចំនួន១០០០ដើម ។

-បានធ្វើពិសោធន៍ ពូជប៉េងប៉ោះ ពូជពោត ពូជសណ្តែកបាយ ពូជម្ទេស ពូជត្រសក់ ពូជខាត់ណា ពូជសណ្តែកគួរ ពូជត្រប់ និងពូជសណ្តែកសៀង លើផ្ទៃដីសរុបចំនួន៧.៥០០ម២

-បានស្រាវជ្រាវអភិរក្ស និងបន្សុទ្ធពូជដំណាំបន្លែចំនួន ០៣ពូជ និងដំណាំរួមផ្សំដ៏ទៃទៀតបានចំនួន ០៩ពូជ

-បានចងក្រងឯកសារស្តីពីឈើហូបផ្លែនៅតំបន់ពាយ័ព្យចំនួន១៣៩ឃុំ នៅក្នុងខេត្ត កំពង់ឆ្នាំង ពោធិសាត់ និងឧត្តរមានជ័យ

- បានពង្រឹង និងពង្រីកជំនាញស្តីពីផលិតកម្មដំណាំរួមផ្សំ និងបច្ចេកទេសដាំដុះផ្សិតចំបើង និងផ្សិតអំបោះតាមរយៈការបណ្តុះបណ្តាល ការធ្វើបង្ហាញ និងរៀបចំទិវាស្រែ ដល់កសិករសរុបចំនួន២.៣០០នាក់។

### ៤.២.១.៣. ការស្រាវជ្រាវនិងអភិវឌ្ឍសាកវប្បកម្មដំណាំឧស្សាហកម្ម

សមិទ្ធផលការងារសំខាន់ៗពាក់ព័ន្ធនឹងផ្នែកនេះ បានផ្តោតជាសំខាន់ទៅលើការអភិរក្ស និងអភិវឌ្ឍពូជដំណាំមួយចំនួនដូចជា ដំណាំពោត ដំណាំមន ដំណាំសណ្តែក ដំណាំម្រេច និងរុក្ខជាតិគម្របដី លទ្ធផលសម្រេចបានដូចជា÷

-បានផលិតពូជដំណាំឧស្សាហកម្មលើផ្ទៃដីចំនួន ៥០ ហត ទទួលបានបរិមាណផលចំនួន៥៩តោន

-បានធ្វើសម្ងហកម្មពូជចំនួន៥៣៩ពូជ ដែលប្រមូលពីបណ្តាមូលដ្ឋាននានាក្នុងប្រទេស និងនាំចូលពីក្រៅប្រទេស (ប្រទេសម៉ាឡេស៊ី កូរ៉េ នេប៉ាល់ ចិន និងវៀតណាម) រួមមានពូជពោតចំណីសត្វចំនួន៤៨០ពូជ ពោតផ្អែមចំនួន៣២ពូជ និងពោតសចំនួន២៧ពូជ

-បានពិសោធន៍សិរិតសំរាំងពូជពោតចំនួន២១ពូជ (ពោតសម្រាប់ចំណីសត្វ១០ពូជ ពោតផ្អែម៦ពូជ ពោតស ៥ពូជ) ពូជសណ្តែកសៀង PDN និងពូជសណ្តែកបាយ SB50G

-បានដំណើរការស្រែពិសោធន៍ស្រាវជ្រាវស្តីពីការជ្រើសរើសពូជដំណាំឧស្សាហកម្មនិងបច្ចេកទេសដាំដុះសមស្របតាមប្រព័ន្ធក្បេត្របរិស្ថានចំនួន១៣ពិសោធន៍

-បានដំណើរការស្រែបង្ហាញ និងទិវាស្រែស្តីពីការដាំដុះដំណាំឧស្សាហកម្មចំនួន១០០ស្រែបង្ហាញ មានកសិករចូលរួមសរុបចំនួន៤៧០នាក់

-បានបណ្តុះបណ្តាលកសិករស្តីពីផលិតកម្មពូជ ការបន្សុទ្ធពូជ និងបច្ចេកទេសក្រោយពេលប្រមូល ផលដំណាំឧស្សាហកម្ម មានកសិករចូលរួមសរុបចំនួន៧២០នាក់។

### ៤.២.១.៤. ការស្រាវជ្រាវនិងអភិវឌ្ឍធនធានដីកសិកម្ម

ជាក់ស្តែងក្នុងឆ្នាំ២០១១ ការងារគ្រប់គ្រងធនធានដីកសិកម្ម បាននិងកំពុងទទួលបានការយកចិត្តទុកដាក់និងលើកកម្ពស់ទាំងការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសគ្រប់គ្រងជីជាតិដីល្អៗ ជូនដល់ស្រទាប់ប្រជាកសិករ សម្រាប់ការកសាងផែនការការប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយចីរភាព សម្រេចបានលទ្ធផលសំខាន់ៗ÷

-បានចងក្រងឯកសារបច្ចេកទេសស្តីពីការកំណត់តំបន់ដាំដុះសម្រាប់ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដែលពិពណ៌នាអំពីលក្ខណៈរបស់ដី និងចំណាត់ថ្នាក់ដី និងបានរៀបចំផែនទីការប្រើប្រាស់ដីកសិកម្ម និងស្ថិតិការប្រើប្រាស់ដីកសិកម្មជាក់ស្តែងតាមប្រភេទដំណាំទូទាំងខេត្តស្វាយរៀង ។

-បានដំណើរការស្រែបង្ហាញអំពី ប្រសិទ្ធភាពជីគីមីលាយជីធម្មជាតិចំនួន៤០០កន្លែង តាមតំបន់គោលដៅចំនួន១៣ខេត្ត ដោយមានកសិករចំនួន៤០០គ្រួសារ ចូលរួមអនុវត្តផ្ទាល់។ លទ្ធផលនៃស្រែបង្ហាញនេះបញ្ជាក់ថា ជារួមទិន្នផលស្រូវមានភាពឆ្លើយតបខ្ពស់ទៅនឹងការប្រើប្រាស់ជីកំប៉ុស្តជាងការប្រើប្រាស់ជីគីមី ។ ដូច្នេះជាសរុបមក ការប្រើជីគីមីកន្លះកំរិតណែនាំនិងថែមជីកំប៉ុស្តចំនួន ១៥តោន នោះកសិករទទួលបានទិន្នផលខ្ពស់ ជាករណីបណ្តាអ្នកស្រាវជ្រាវ និងអ្នកផ្សព្វផ្សាយត្រូវតែជំរុញឲ្យកសិករចេះប្រើប្រាស់ជីគីមីលាយជីធម្មជាតិ ឲ្យសមស្របតាមលក្ខណៈបច្ចេកទេស ដែលជាកត្តាមួយប្រសើរបំផុតក្នុងការកែលំអជីជាតិដី រក្សាតុល្យភាពជីជាតិដី និងបង្កើនទិន្នផលដំណាំ

- បានដំណើរការបើកសាលារៀនស្រែកសិករអំពីបច្ចេកទេសធ្វើជីកំប៉ុស្តចំនួន៤០កន្លែង មានកសិករចូលរួមសរុបចំនួន១២០០នាក់ និងមានកសិករចំនួន៦០០គ្រួសារបានសាងសង់រោងជីកំប៉ុស្ត

- បានចូលរួមចុះសិក្សា និងវាយតំលៃដីសម្បទានសេដ្ឋកិច្ចបានចំនួន៣៧ក្រុមហ៊ុន នៅតាមបណ្តាខេត្តចំនួន១៥ខេត្ត

- បាននិងកំពុងអនុវត្តគម្រោង "ពិពិធកម្មកសិកម្មនៅកម្ពុជា-PADAC" ដោយអនុវត្ត ច្ចេកទេសដាំដោយផ្ទាល់លើដំណាំគម្រប និងបានពង្រីកសកម្មភាពតាមតំបន់គោលដៅក្នុង ខេត្តកំពង់ចាម បាត់ដំបង និងប៉ៃលិន ក្នុងគោលបំណងរក្សា និងបង្កើនឡើងវិញនូវផលិតភាព ដីដែលកំពុងទទួលរងការបាត់បង់ជីជាតិ។

### ៥.២.១.៥. ការអភិវឌ្ឍបច្ចេកទេសការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

ក្នុងឆ្នាំ២០១១ ក្រៅពីការងារចុះពិនិត្យតាមដានសភាពការណ៍នៃការរាតត្បាតរបស់សមាសភាពចង្រៃ និងដឹកនាំកិច្ចអន្តរាគមន៍កំចាត់សមាសភាពចង្រៃនៅទូទាំងប្រទេស ក៏បានអនុវត្តសកម្មភាពមួយចំនួន ដោយទទួលបានលទ្ធផលដូចខាងក្រោម÷

- បានចងក្រងបញ្ជីឈ្មោះសមាសភាពចង្រៃលើដំណាំដំឡូងមី

-បានចងក្រងទិន្នន័យគ្រឹះសមាសភាពចង្រៃក្នុងប្រព័ន្ធកុំព្យូទ័រសម្រាប់ដំណាំស្រូវ ដំណាំប៉េងប៉ោះ ដំណាំសណ្តែក ដំណាំដំឡូង ដំណាំកៅស៊ូ និងដំណាំតែ

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មល្អ ដើម្បីបង្កើនគុណភាពផលិតផល និងសុវត្ថិភាពចំណីអាហារ ចំនួន៤២វគ្គ មានកសិករចូលរួមចំនួន១៤៧០នាក់

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្មចំនួន៣៦វគ្គ មានកសិករចូលរួមចំនួន១២៦០នាក់

-បានដំណើរការវគ្គបណ្តុះបណ្តាលស្តីពីវិធានការកំចាត់សត្វល្អិតចង្រៃលើដំណាំបន្លែចំនួន៤២វគ្គ មានកសិករចូលរួមចំនួន ១៤៧០នាក់

-បានដំណើរការស្រែពិសោធន៍ស្តីពីការប្រើប្រាស់ថ្នាំកំចាត់សត្វល្អិតផ្សំពីរុក្ខជាតិលើដំណាំចំនួន ១៤៤ពិសោធន៍

-បានធ្វើអង្កេតរុយចោះផ្លែលើដំណាំស្វាយនៅខេត្ត កំពង់ស្ពឺ កំពត ព្រះសីហនុ កំពង់ចាម កណ្តាល និងបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពអំពីការអង្កេត និងកំចាត់រុយចោះផ្លែមន្ត្រីបច្ចេកទេសមកពីមន្ទីរកសិកម្មនៃខេត្ត ទាំង ០៥ ចំនួន ៧០នាក់

ទាក់ទងនឹងការជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារបរទេសនៅឆ្នាំ២០១១កន្លងមកនេះ បានចាត់បញ្ជូនមន្ត្រីបច្ចេកទេសភូតគាមអនាម័យចុះធ្វើការត្រួតពិនិត្យ ផលិតនាំចេញ និងផ្តល់វិញ្ញាបនប័ត្រភូតគាមអនាម័យចំនួន១.៦៧៩ ច្បាប់ សម្រួលដល់ការនាំចេញផលិតផលកសិកម្មចំនួន១៧មុខទំនិញ មានបរិមាណសរុបចំនួន៤៨៧.៣២៧តោន ក្នុងនោះមុខទំនិញសំខាន់ៗរួមមាន÷ អង្ករចំនួន ២០១.៨៩៩តោន ដំឡូងមីចំនួន ២០៣.០០៤តោន ចំណិតឈើអាកាស្យាចំនួន ៥២.៦៧៥តោន ប្រេងដូងឆៅចំនួន ៦.២០២តោន សន្លឹកថ្នាំជក់ចំនួន ៣.១៧៣តោន ឈើកែឆ្នៃចំនួន ១.៩៨៣តោន ម្សៅដំឡូងមីចំនួន១.៧៥៧តោន ស្វាយចន្ទីចំនួន១.២៣៨តោន គ្រាប់ដូងប្រេងចំនួន៩៦៩តោន សណ្តែកសៀងចំនួន២៩២តោន កៅស៊ូក្រែបចំនួន ២១៧តោន បន្ទះក្តាកុងផ្លាកេចំនួន ២៣៤តោន ម្រេចចំនួន ១៨៤តោន សណ្តែកដីចំនួន ១៨០តោន ល្ងខ្មៅចំនួន ៥៦តោន និងបន្លែគ្រប់មុខ ២៩តោន។

### ៥.២.១.៦. ការពង្រឹងការត្រួតពិនិត្យគុណភាពក្នុងមន្ទីរពិសោធន៍

មន្ទីរពិសោធន៍ជាតិកសិកម្មក្នុងឆ្នាំ២០១១នេះ សម្រេចបានសមិទ្ធិផល សំខាន់ៗដូចខាងក្រោម÷

-បានបើកវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពបច្ចេកទេស មន្ត្រីរាជការមន្ទីរពិសោធន៍ជាតិ ចំនួន ០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន១៥នាក់។ វគ្គបណ្តុះបណ្តាលបានផ្តោតលើការវិភាគគុណភាពទឹក វិធីសាស្ត្រយកសំណាកដី ជី ថ្នាំកសិកម្ម និងរុក្ខជាតិ ការប្រើប្រាស់ឧបករណ៍ GPS ការវិភាគគុណភាពថ្នាំកសិកម្ម និងវិធីសាស្ត្របកស្រាយលទ្ធផលវិភាគដី

-បានផ្តល់សេវាពិសោធន៍វិភាគដី ជី ថ្នាំកសិកម្ម និងទឹក បានចំនួនសរុប៦៩៧សំណាក ក្នុងនោះ ដីចំនួន៣៧១សំណាក ដីចំនួន២១២សំណាក ថ្នាំកសិកម្មចំនួន៨៩សំណាក និងទឹកកសិកម្មចំនួន២៥សំណាក

-បានចុះប្រមូលសំណាកដី ជី ថ្នាំកសិកម្ម និងរុក្ខជាតិយកមកធ្វើការវិភាគ និងកត់ត្រាទិន្នន័យបានចំនួន២២៥សំណាក។

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់សេវាកម្មវិភាគថ្នាំកសិកម្ម និងកាកសំណល់គីមី មន្ទីរពិសោធន៍ជាតិកសិកម្ម បាន

រៀបចំជាវិធីសាស្ត្រវិភាគបានចំនួន៣៧សាធាតុសកម្ម និងក្រោមក្របខណ្ឌសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន មន្ទីរពិសោធន៍ជាតិបាននិងកំពុងបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីបច្ចេកទេសអំពី វិធីសាស្ត្រវិភាគដី និងថ្នាំកសិកម្មដោយប្រើឧបករណ៍វិភាគទំនើប។

### ៤.២.១.៧. ការងារផ្សព្វផ្សាយកសិកម្មនិងពង្រឹងសហគមន៍កសិកម្មឆ្នាំ២០១១

ការងារផ្សព្វផ្សាយកសិកម្មបានដឹកនាំសម្របសម្រួលការសកម្មភាពការងារផ្សព្វផ្សាយកសិកម្មនៅក្នុង រាជធានី-ខេត្តទាំង២៤ និងសហការជាមួយអង្គភាពជំនាញនានា មន្ទីរកសិកម្មរាជធានី ខេត្ត គម្រោង/កម្មវិធីនានា និងភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន (NGOs) និងរដ្ឋអំណាចមូលដ្ឋានក្នុងការផ្សព្វផ្សាយ ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មលើសកម្មភាពសំខាន់ៗដែលរួមមាន (១).ការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយកសិកម្ម និងកសិករ (២).ការអភិវឌ្ឍប្រព័ន្ធកសិកម្ម (៣).ការរៀបចំនិងពង្រឹងអង្គការកសិករ និងសហគមន៍កសិកម្ម (៤).ការអប់រំនិងផ្សព្វផ្សាយព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម និង៥).ចូលរួមការកែលំអផលិតកម្មស្បៀង និងរកចំណូលជាលក្ខណៈគ្រួសារ។ ជាលទ្ធផលនៅឆ្នាំ២០១១នេះសម្រេចបាន÷

-បានសិក្សាវាយតម្លៃពីស្ថានភាពប្រព័ន្ធ និងសេវាផ្សព្វផ្សាយកសិកម្មដែលទទួលបានលទ្ធផលដូចខាងក្រោម÷

- សិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវក្របខ័ណ្ឌសេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានដំណើរការក្នុងរយៈពេលពីរថ្ងៃ ពីថ្ងៃទី ២០ ដល់ ទី២១ខែធ្នូ ឆ្នាំ២០១១ ដែលមានអ្នកចូលរួមចំនួន ១៧០ នាក់មានស្ត្រី ២៤នាក់
- ប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជាមាននៅថ្នាក់ជាតិមានភារកិច្ចសម្របសម្រួល នៅថ្នាក់ក្រោមជាតិមានមន្ទីរកសិកម្មខេត្តជាអ្នកដឹកនាំអនុវត្ត និងចាត់ចែងការងារ និងមន្ត្រីផ្សព្វផ្សាយកសិកម្ម និងកសិកម្មស្រុក ជាអ្នកផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងសេវាគាំទ្រ ដល់អង្គការកសិករនានា និងសហគមន៍កសិកម្ម ដូចជានៅថ្នាក់មូលដ្ឋានមានអ្នកផ្សព្វផ្សាយកសិកម្មឃុំ (នៅតែឃុំគោលដៅរបស់គម្រោងគាំទ្រដោយអ៊ីហ្វាតខេត្តស្វាយរៀង ព្រៃវែង ក្រចេះ រតនគីរី និងខេត្តព្រះវិហារ) និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ជាភ្នាក់ងារផ្តល់សេវាស្ម័គ្រចិត្តសេវាផ្សព្វផ្សាយកសិកម្មជាទូទៅនៅមូលដ្ឋានភូមិ ឃុំ អនុវត្តដោយមន្ត្រីកសិកម្មរបស់រាជរដ្ឋាភិបាល (មន្ត្រីកសិកម្មខេត្តនិងស្រុក) ក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- មន្ត្រីដែលអនុវត្ត និងសម្របសម្របសម្រួលការងារផ្សព្វផ្សាយកសិកម្មនៅកម្ពុជាមាន÷មន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់កណ្តាលមាន៧៤នាក់ នៅថ្នាក់ខេត្ត ២៦៣នាក់និងថ្នាក់ស្រុក៩៥៩នាក់ (ទិន្នន័យនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០១១) និង ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ៣៥០នាក់និងភូមិ ៧,៣៣៦នាក់។

-បានបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្ម ខេត្ត និងស្រុកបានចំនួន៤៥៧ នាក់ក្នុងនោះមានស្ត្រីចំនួន៦១នាក់

-បានបានបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ១,២៧០នាក់ ហើយមកដល់ឆ្នាំ២០១១នេះចំនួនអ្នកផ្សព្វផ្សាយកសិកម្មភូមិចំនួន ៧,៣៣៦នាក់ ក្នុងនោះមានស្ត្រីចំនួន ៦៦៨នាក់

-បណ្តុះបណ្តាលពីការប្រើប្រាស់ឯកសារវិភាគប្រព័ន្ធក្សេត្របរិស្ថានដល់មន្ត្រីផ្សព្វផ្សាយកសិកម្ម និងក្រុមប្រឹក្សាឃុំបានចំនួន៧វគ្គ ដែលមានអ្នកចូលរួមចំនួន១៩៥នាក់មានស្ត្រី៤៤នាក់ ដូចជាខេត្តស្វាយរៀង ឧត្តរមានជ័យ ព្រះហារ និងស្ទឹងត្រែង

-ការសិក្សាការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថានឃុំចំនួន២៦ឃុំ ហើយមកដល់ពេលនេះ បានវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសរុបចំនួន៦១២ ឃុំ

-ការអប់រំនិងផ្សព្វផ្សាយកសិកម្ម មានគោលដៅជួយដល់កសិករនិងសហគមន៍កសិករ ក្នុងការបង្កើននូវបរិមាណនិងគុណភាពផលិតផលកសិកម្ម តាមរយៈបង្កើនការយល់ដឹង និងការទទួលបាននូវចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម ពីផលិតកម្មដំណាំ ដំណាំកៅស៊ូ ការចិញ្ចឹមសត្វ វារីវប្បកម្ម ក្សេត្រ-រុក្ខកម្ម ប្រព័ន្ធកសិកម្មចំរុះ ការគ្រប់គ្រងធនធានធម្មជាតិ ដី ធនធានជលផល និងព្រៃឈើ)។ល។ តាមរយៈអប់រំ និងផ្សព្វផ្សាយនាទីកសិកម្មតាមទូរទស្សន៍ជាតិ វិទ្យុជាតិ នាទីចុះ ស្រែជាមួយកសិករ នាទីស្វែងយល់ពីកសិកម្ម ការតាំងពិព័រណផលិតផលកសិកម្ម សេវានិងឯកសារកសិកម្ម ទិវាបណ្តាញកសិករ និងសន្និបាតកសិករជាដើម

-បានចងក្រងសហគមន៍កសិកម្មចំនួន៣២ និងបានចុះបញ្ជីទទួលស្គាល់ផ្លូវការ ហើយមកដល់ឆ្នាំ២០១១ នេះមានសហគមន៍កសិកម្មសរុបចំនួន២៧៣សហគមន៍

-បានបើកវគ្គបណ្តុះបណ្តាលពីការគ្រប់គ្រងបញ្ជីគណនេយ្យ÷ ចំនួន៤៨វគ្គមាន អ្នកដឹកនាំនិងបេឡា សហគមន៍កសិកម្ម ១២០០នាក់ចូលរួមមានស្ត្រី៣៦៥នាក់

-បានបើកវគ្គបណ្តុះបណ្តាលពីគោលគំនិតសហគមន៍កសិកម្មដល់មន្ត្រីផ្សព្វផ្សាយកសិកម្មចំនួន ៣០០នាក់ស្ត្រី៩៤នាក់

-បានអនុវត្តកម្មវិធី និងគម្រោងនានាទាក់ទងនឹងផលិតកម្មស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ដើម្បីកែលំអសន្តិសុខស្បៀងគ្រួសារ ជីវភាពរស់នៅ និងប្រាក់ចំណូលគ្រួសារនៅជនបទ តាមរយៈការផ្ទេរ និងផ្សព្វផ្សាយបច្ចេកទេស និងព័ត៌មានកសិកម្ម ដោយជំរុញផលិតកម្មកសិកម្មនិងពិពិធកម្មកសិកម្មតាមគ្រួសារកសិករមាន÷ ការធ្វើប្រពលវប្បកម្មដំណាំស្រូវនិងពិពិធកម្មដំណាំរួមផ្សំ ដំណាំបន្លែ ដំណាំឈើហូបផ្លែ ការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈគ្រួសារនិងប្រព័ន្ធកសិកម្មចំរុះ ការរៀបចំនិងពង្រឹងក្រុមកសិករជួយខ្លួនឯង (មានក្រុមសន្សំប្រាក់ក្រុមផលិតស្បៀងធនាគារស្រូវ ធនាគារជី។ល។) និងការអនុវត្តគម្រោងសហគមន៍ខ្នាតតូច និងជំនួញខ្នាតតូច។

**៤.២.១.៨. ការងារគ្រឿងយន្តកសិកម្ម ឆ្នាំ២០១១** (ឧបសម្ព័ន្ធទី១៩-២០)

ក្នុងឆ្នាំ២០១១ ដោយការគាំទ្រពង្រឹងសេវាកម្ម គ្រឿងយន្តកសិកម្មចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងដំណើរការប្រពលវប្បកម្មឆ្ពោះទៅបង្កើនផលិតភាព គុណភាពកសិកម្ម និងកាត់បន្ថយការបាត់បង់។ នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានិយមការប្រើប្រាស់គ្រឿងយន្តកសិកម្ម កំពុងមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា។ ជាលទ្ធផលការងារគ្រឿងយន្តកសិកម្មសម្រេចបាន÷

**ក- ស្ថានភាពគ្រឿងយន្តកសិកម្ម ÷**

ក្នុងឆ្នាំ២០១១នេះ ស្ថិតិគ្រឿងយន្តកសិកម្ម សរុបបានបង្ហាញថា នៅទូទាំងប្រទេសកម្ពុជាមាន ដូចខាងក្រោម÷

-ត្រាក់ទ័រចំនួន៦.៧៨៦គ្រឿង កើនលើសឆ្នាំ២០១០ចំនួន៥៨៦គ្រឿង

-គោយន្តចំនួន៧៧.៤២១គ្រឿង កើនលើសឆ្នាំ២០១០ ចំនួន១០.៨៧៣គ្រឿង

-ម៉ាស៊ីនបូមទឹកចំនួន ១៨៣.៥០២គ្រឿង កើនលើសឆ្នាំ ២០១០ចំនួន១៦.៨៦៩គ្រឿង

-ម៉ាស៊ីនច្រូតចំនួន១.៥៤៨គ្រឿង ម៉ាស៊ីនបោក និងបូតស្រូវចំនួន១៥.២១០គ្រឿង

-ម៉ាស៊ីនកិនស្រូវចំនួន៤៨.៧៥៣ គ្រឿង កើនលើសឆ្នាំ ២០១០ចំនួន៥៣៦គ្រឿង។

-ឧបករណ៍បំពាក់ត្រាក់ទ័រៈនង្គ័ល៥.៦៧៩គ្រឿង រនាស់៣.៦៥០គ្រឿង រ៉ឺម៉ក៣.០៤៤គ្រឿង អង្កប់១.០៣១គ្រឿង

-ឧបករណ៍បំពាក់គោយន្តៈនង្គ័ល៦៨.៧៧៩គ្រឿង រនាស់៦៥.១៧៩គ្រឿង រ៉ឺម៉ក៦០.២០៧គ្រឿង អង្កប់១៨០គ្រឿង

-ឧបករណ៍កសិកម្ម÷ ឧបករណ៍ដាំស្រូវ ២៩គ្រឿង ឧបករណ៍ជ្រួយដីសម្អាតស្មៅ៥៩ គ្រឿង។

-ឧបករណ៍បុរាណមាននង្គ័ល៨៤៣.២១១គ្រឿង រនាស់៧១០.០០៣គ្រឿង រទេះ៥១៨.២១៧គ្រឿង អង្កប់វាយដីចំនួន១៤.៩៣១គ្រឿង រហាត់ចំនួន២.២៨៣គ្រឿង ស្នាចថ្លឹង៣៩.៦២៤គ្រឿង ត្បាល់បក់ ចំនួន៧.៤៩៥គ្រឿង។

**ខ. ការផ្ទេរបច្ចេកវិទ្យាគ្រឿងយន្តកសិកម្ម**

-បានអនុវត្តភ្ជួរបង្ហាញដោយត្រាក់ទ័រពីបច្ចេកទេសភ្ជួរលុបគល់ជញ្ជ្រាំងនៅខេត្តស្វាយរៀង និងបង្ហាញការប្រមូលផលដោយម៉ាស៊ីនច្រូតស្រូវ "កំបៃ" ជូនកសិករនៅស្រុកថ្មគោល ខេត្តបាត់ដំបងបានចុះអន្តរាគមន៍ភ្ជួរលុបគល់ជញ្ជ្រាំងជូនគ្រួសារយុទ្ធជន ស្ត្រីមេម៉ាយ យោធិនពិការក្នុងខេត្តព្រៃវែង ពោធិសាត់ កណ្តាលនិងនៅមជ្ឈមណ្ឌល បំប៉នសុខភាពលេខ៣១៧ (តាកែនកោះស្លា) សរុបចំនួន៥១៦ហ.ត

-បានបញ្ចុះម៉ាស៊ីនបូមទឹកចំនួន០២គ្រឿងអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ នៅមជ្ឈមណ្ឌលវិស្វកម្មកសិកម្មទួលសំរោង ខេត្តបាត់ដំបង ដែលជួបគ្រោះទឹកជំនន់

-បានសហការជាមួយក្រុមហ៊ុនមេគង្គអេហ្គ្រីខលឈ័រត្រេកធ័រ ចុះអនុវត្តបង្ហាញការភ្ជួររាស់ដោយត្រាក់ទ័រ Ma-hindra បំពាក់ជាមួយនិងឧបករណ៍ (អង្កប់) វាយដីនៅខេត្ត ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ

-បានចុះអន្តរាគមន៍ភ្ជួររាស់ដោយគោយន្ត និងអនុវត្តបង្ហាញការដាំស្រូវជាជួរដោយឧបករណ៍ដាំស្រូវ (Drum seeder) នៅភូមិត្រែង ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត

-បានចុះអន្តរាគមន៍ភ្នំរាស់ដោយគោយន្ត និងអនុវត្តបង្ហាញការដាំស្រូវជាជួរដោយឧបករណ៍ដាំស្រូវ (Drum seeder) នៅភូមិត្រែង ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត

-បានដំណើរការបើកវគ្គបំពាក់បំប៉នអំពី ការប្រើប្រាស់ ថែទាំ និងជួសជុល ការបាត់បង់ក្រោយប្រមូលផល ការធ្វើបង្ហាញអំពីការរៀបចំដី និងប្រមូលផលបានចំនួន២៥វគ្គ មានកសិករចូលរួមសរុបចំនួន៧៥០នាក់។

### ៥.២.១.៩. ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

-បាននិងកំពុងពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពី "ការការពារដំណាំ និងភូតគាមអនាម័យ"

-បាននិងកំពុងព្រាងសេចក្តីព្រាងច្បាប់ស្តីពីសហករណ៍កសិកម្ម"និងបានឆ្លងកិច្ចប្រជុំអចិន្ត្រៃយ៍ក្រសួងរួចហើយ

-បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី "ការគ្រប់គ្រងរោងជាងផលិត កែច្នៃ ដំឡើង និងរោងជាងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម" ដោយបានឆ្លងការប្រជុំអចិន្ត្រៃយ៍ក្រសួងរួចហើយ ហើយកំពុងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី

-បានរៀបចំប្រកាសស្តីពី "បទបញ្ជាផ្ទៃក្នុងគំរូរបស់បុរេសហគមន៍អភិវឌ្ឍកសិកម្ម"

-បានរៀបចំប្រកាសស្តីពី "បញ្ជីឈ្មោះសមាសភាពចង្រៃភូតគាមអនាម័យ និងបង្កគ្រោះថ្នាក់ដែលត្រូវហាមឃាត់ចូលព្រះរាជាណាចក្រកម្ពុជា"

-ប្រកាសស្តីពី "នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ"

-ប្រកាសស្តីពី "ការដាក់ឲ្យប្រើប្រាស់នូវវិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់"

-បានរៀបចំសេចក្តីព្រាងប្រកាសរួមស្តីពី "សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកំចាត់សមាសភាពចង្រៃ"

-បាននិងកំពុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការគ្រប់គ្រងដីកសិកម្ម" ដោយបានរៀបចំការប្រជុំពិគ្រោះយោបល់ផ្ទៃក្នុងបានចំនួន ០៥លើក បានប្រជុំពិគ្រោះយោបល់ជាមួយទីប្រឹក្សាបច្ចេកទេសរបស់អង្គការ FAO ចំនួន ០៣លើក និង បើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើឯកសារពង្រាងច្បាប់ដី កសិកម្មនៅរាជធានីភ្នំពេញ។

### ៥.២.១.១០. បញ្ហាប្រឈម

-ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍកសិកម្មនូវមានការខ្វះខាត (ប្រព័ន្ធស្រោចស្រោចស្រព អគារបណ្តុះបណ្តាល ផ្លូវថ្នល់...)ខ្វះឧបករណ៍ សម្ភារៈ និងមធ្យោបាយផលិតកម្ម នៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍកសិកម្ម

-ការរក្សាពូជដំណាំបានជួបប្រទះបញ្ហាប្រឈម ដោយសារឃ្លាំងទុកដាក់មិនបានសមស្របតាមបទដ្ឋានបច្ចេកទេស ដែលធ្វើឲ្យមានបញ្ហាប្រឈម នៅតាមមូលដ្ឋានខ្លះៗក្នុងពេលកន្លងមក

-ថវិកាសំរាប់ការងារស្រាវជ្រាវ និងអភិវឌ្ឍវិស័យកសិកម្មនៅមានកម្រិត ពិសេសការងារអនុវត្តសកម្មភាពសម្រាប់គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-ខ្វះធនធាន (ធនធានមនុស្ស និងធនធានសម្ភារៈ) ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

-ខ្វះការវិនិយោគពីវិស័យឯកជនពាក់ព័ន្ធនឹងវិស័យកសិកម្ម

-ចំណេះដឹងកសិករនៅមូលដ្ឋាននៅមានកម្រិត ធ្វើឲ្យមានការលំបាកក្នុងការបញ្ជ្រាបបច្ចេកទេសកសិកម្មថ្មី និងងាយរងគ្រោះពីការឆបោកឈ្មួញទុច្ចរិត។

### ៥.២.២. វាយតម្លៃនិងសន្និដ្ឋាន

ក្នុងឆ្នាំ២០១១ នៃអាណត្តិទី៤ នៃរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** អគ្គនាយកដ្ឋានកសិកម្មសូមធ្វើការវាយតម្លៃនិងសន្និដ្ឋានដោយមោទនភាពថា ទោះបីស្ថិតនៅក្នុងដំណាក់កាលពឹងផ្អែកលើធម្មជាតិនិងជាញឹកញាប់បានទទួលរងការគំរាមកំហែងពីគ្រោះមហន្តរាយធម្មជាតិជាបន្តបន្ទាប់ក្តីវិស័យកសិកម្ម កម្ពុជាបាននិងកំពុងមានការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយក្តីសង្ឃឹមថាវិស័យនេះពិតជានឹងក្លាយជាឆ្អឹងខ្នងយ៉ាងរឹងមាំសម្រាប់ការពន្លឿន និងការពង្រីកមូលដ្ឋានអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជាបន្តចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស្វាហាប់និងចីរភាព។ ការសម្រេចបាននូវកំណើនផលិតកម្មស្រូវក្នុងឆ្នាំ២០១១កន្លងមកនេះ ជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលធំៗជាច្រើនជាមូលដ្ឋានគាំទ្រដល់ក្តីសង្ឃឹម និងលទ្ធ

ភាពនៃការសម្រេចបាននូវចក្ខុវិស័យ ស្តីពីការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសនាំចេញមាសស (អង្ករ) ដ៏សំខាន់មួយក្នុងចំណោមប្រទេសនាំចេញអង្ករក្នុងពិភពលោក ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ដូចដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៤នៅក្នុងឯកសារគោលនយោបាយស្តីពី "ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ"។ និយាយជារួមវិស័យកសិកម្មកម្ពុជាកំពុងតែមានការវិវត្តប្រកបដោយអត្ថន័យទាំងបរិមាណនិងគុណភាព។ ប្រជាកសិករកាន់តែមានសមត្ថភាពធានាបាននូវភាពម្ចាស់ការនៅក្នុងដំណើរការផលិតកម្មដោយសារការខិតខំរបស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងធ្វើឱ្យមានការរីកចម្រើនជាបណ្តើរៗនូវមូលដ្ឋានបម្រើឱ្យផលិតកម្ម និងពាណិជ្ជកម្ម កសិកម្ម ពិសេសការរីកចម្រើនខាងប្រព័ន្ធធារាសាស្ត្រយន្តូបនីយកម្មកសិកម្មពូជដំណាំមានគុណភាព បច្ចេកទេសដាំដុះនិងថែទាំដំណាំថ្មីៗនិងយន្តការសម្របសម្រួលទីផ្សារផលិតផលកសិកម្ម។ល។ ព្រមជាមួយគ្នានេះ ប្រជាកសិករក៏កំពុងតែមានការកែប្រែទម្លាប់និងផ្នត់គំនិតជាបណ្តើរៗក្នុងការចាប់យកទៅអនុវត្តនូវបច្ចេកទេសប្រពលវប្បកម្មនិងពិពិធកម្មដំណាំត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស ដែលជាផ្លែផ្កាកើតចេញពីការបំពេញការងារមិនចេះនឿយហត់ និងប្រកបដោយស្មារតីទទួលខុសត្រូវនិងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកសិកម្មនិងអ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ក្រោមការជួយឧបត្ថម្ភគាំទ្រទាំងស្មារតី សម្ភារៈថវិកានិងការដឹកនាំចង្អុលបង្ហាញប្រកបដោយប្រសិទ្ធភាពរបស់ថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ជាន់ថ្នាក់ ពិសេស**ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**៥.២.៣. វិធានការនិងទិសដៅ**

- ពង្រឹងការងារគ្រប់គ្រងនិងដឹកនាំអង្គភាពតាមរយៈការកសាងនិងរក្សានូវបរិយាកាសការងារប្រកបដោយស្មារតីឯកភាពផ្ទៃក្នុង គោរពតាមឋានានុក្រម សហការចូលរួម មានគំនិតផ្តួចផ្តើម និងទទួលខុសត្រូវខ្ពស់
- កសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាពិសេសការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងប្រតិបត្តិការរបស់មន្ទីរពិសោធន៍ជាតិកសិកម្ម
- កសាងទំនាក់ទំនងសហប្រតិបត្តិការល្អជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ សំដៅគៀងគរជំនួយឧបត្ថម្ភគ្រប់ប្រភេទសម្រាប់ការស្តារនិងកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមបណ្តាកសិដ្ឋាន ស្ថានីយ៍ ដើម្បីពង្រឹងនិងពង្រីកសមត្ថភាពស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសដល់កសិករ ក៏ដូចជាដើម្បីអនុវត្តផែនការសកម្មភាពការងារពាក់ព័ន្ធនឹងឯសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ
- ផ្អែកលើផែនការយុទ្ធសាស្ត្រឆ្នាំ២០០៩-២០១៣ នឹងជំរុញការរៀបចំកសាងជាផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ផលិតកម្មដំណាំ
- ធ្វើឱ្យកាន់តែប្រសើរសមត្ថភាពរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ក្រោមក្របខ័ណ្ឌថវិកាតាមកម្មវិធី ដោយធ្វើយ៉ាងណាឱ្យមានសង្គតភាពជាមួយនឹងគោលនយោបាយយុទ្ធសាស្ត្ររបស់អនុវិស័យនិងដោយមានការកំណត់នូវសូចនាករឱ្យបានសមស្រប
- ដំណើរការប្រឡងប្រណាំងក្នុងចំណោមកសិករឆ្នើម តាមរយៈការរៀបចំវេទិកានានាដែលមានការចូលរួមពីសំណាក់ប្រជាកសិកររួមមាន÷ ដំណើរការរៀបចំសន្និបាតកសិករទូទាំងប្រទេសនិងសន្និបាតសហគមន៍កសិកម្មទូទាំងប្រទេស
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ សំដៅធានាការផ្គត់ផ្គង់សម្ភារៈនិងធាតុចូលបានទាន់ពេលវេលារដូវកាលដាំដុះនិងពិសោធន៍ស្រាវជ្រាវ
- អនុវត្តយ៉ាងខ្លាំងក្លានូវសកម្មភាពការងារពាក់ព័ន្ធនឹងឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា
- ខិតខំតម្រែតម្រង់ទិសនិងជំរុញការអនុវត្តផែនការជាយុទ្ធសាស្ត្រ២០០៩-២០១៣ របស់អគ្គនាយកដ្ឋានកសិកម្មឱ្យសម្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម។

## ៥.៣- ផលិតកម្មនិងបសុព្យាបាល (ឧបសម្ព័ន្ធទី១០-១២)

នាពេលបច្ចុប្បន្ននេះ ការងារផលិតកម្មសត្វ និងសុខភាពសត្វ ជាវិស័យមួយយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសបាននិងកំពុងបន្តបំពេញការអនុវត្តការងារ និងភារកិច្ចរបស់ខ្លួនយ៉ាងមមាញឹកបំផុត និងធ្វើឲ្យសម្រេចសមិទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់ប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់។

វិស័យនេះ បានបង្កើតការងារ និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករនៅតាមជនបទ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងកំណើនជីវភាពគ្រួសារឲ្យមានភាពធូរធា និងសេដ្ឋកិច្ចរុងរឿង ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ វិស័យផលិតកម្មសត្វ និងសុខភាពសត្វ បានរួមចំណែកប្រមាណ ១២.៨%នៃផលិតផលសរុបរបស់វិស័យកសិកម្ម និងប្រមាណ៦.១%នៃផលទុនជាតិសរុប។ ដើម្បីសម្រេចគោលដៅ និងគោលបំណងខាងលើ វិស័យនេះបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបន្តការគាំទ្រ និងពង្រឹងសន្តិសុខស្បៀង ផ្តល់អាហាររូបត្ថម្ភគ្រប់គ្រាន់ និងសុវត្ថិភាពម្ហូបអាហារសម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ។ ក្នុងឆ្នាំ២០១១កន្លងទៅនេះ ក៏ដូចជារយៈពេលឆ្នាំបន្តបន្ទាប់ទៀត សកម្មភាពជាច្រើនត្រូវបានអនុវត្តនៅក្នុងរាជធានី ខេត្តទាំង២៤ ដោយមានការសម្របសម្រួល និងសហការជាមួយអង្គភាពជំនាញ មន្ទីរកសិកម្មរាជធានី ខេត្ត គម្រោងកម្មវិធីនានា ព្រមទាំងជាមួយភ្នាក់ងារប្រតិបត្តិមួយចំនួននៅតាមមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល បណ្តាប្រទេសជាមិត្ត អាជ្ញាធរមូលដ្ឋាន និងផ្នែកឯកជន សំដៅជួយក្នុងការអភិវឌ្ឍន៍លើការងារផលិតកម្ម និងសុខភាពសត្វនេះយ៉ាងសកម្មបំផុត។

ជារួមវិស័យផលិតកម្មនិងបសុព្យាបាល នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជាជំងឺឆ្លងរាលដាលសត្វ គោក្របីខ្វះខាតចំណីអាហារ ការយល់ដឹងរបស់កសិករលើបច្ចេកទេស និងការផ្សព្វផ្សាយបច្ចេកទេសនៅមានកំរិត ថ្លៃដើមផលិតកម្មខ្ពស់ និងវិនិយោគទុនលើវិស័យចិញ្ចឹមសត្វនៅមានសន្ទុះយឺត។ល។

នៅក្នុងឆ្នាំ២០១១កន្លងទៅនេះ ជំងឺឆ្លងសត្វ នៅជាបញ្ហាប្រឈមសំខាន់បំផុត ដែលវិស័យផលិតកម្មនិងបសុព្យាបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការប្រយុទ្ធប្រឆាំង ជាពិសេសជំងឺផ្តាសាយបក្សី ដែលបានផ្ទុះឡើងចំនួន០៦ ករណី នៅខេត្តកណ្តាល តាកែវ បាត់ដំបង និង បន្ទាយមានជ័យ(៣ ករណី) ក្នុងនោះសម្លាប់ជីវិតមនុស្ស ចំនួន០៨ ករណី នៅរាជធានីភ្នំពេញ ព្រៃវែង(២) កំពង់ចាម(២) និងបន្ទាយមានជ័យ(៣)។ បន្ថែមលើសពីនេះ ស្ថានភាពជំងឺដទៃផ្សេងទៀតរួមមាន ជំងឺជ្រុកត្រចៀកខៀវ ជំងឺសារទឹក និងជំងឺអុតក្តាម គឺមានការផ្ទុះរាលដាលនៅតំបន់មួយចំនួន ដែលបង្កឲ្យមានការប៉ះពាល់ដល់ផលិតកម្មសត្វ។

លទ្ធផលដែលសម្រេចបានទាំងនេះ ក៏ដោយសារមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ជាពិសេសក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការខិតខំប្រឹងប្រែងយក ចិត្តទុកដាក់ពីមន្ត្រីនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្មខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ ប្រជាកសិករម្ចាស់សត្វ ជាពិសេសម្ចាស់ជំនួយពីអង្គការជាតិ និងអន្តរជាតិនានា ។

### ៥.៣.១-លទ្ធផល

#### ៥.៣.១.១-តាមគោលដៅនិងយុទ្ធសាស្ត្រសំខាន់ៗ

នៅក្នុងឆ្នាំ២០១១នេះ អនុវិស័យផលិតកម្ម និងបសុព្យាបាល បានកំណត់គោលដៅគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដើម្បីបង្កើននូវផលិតភាពសត្វ ដោយធានាបាននូវកំលាំងអូសទាញ ការពារ និងទប់ស្កាត់ជំងឺឆ្លងសត្វ សុខភាពសាធារណៈ ម្ហូបអាហារ និងការនាំចេញសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីប្តូរជារូបិយបណ្ណ៍ សម្រាប់ជាចំណូលគ្រួសារ និងសេដ្ឋកិច្ចជាតិ ក្នុងការអនុវត្តការងារលើអនុវិស័យនេះ ប្រកបដោយប្រសិទ្ធភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យរយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងសកម្មភាព កម្មវិធី ជាអទិភាពសម្រាប់ការអនុវត្តឱ្យស្របតាមគោលនយោបាយជាតិ រួមមាន ÷

- កសាងច្បាប់និងអភិវឌ្ឍធនធានមនុស្ស
- ការកាត់បន្ថយអត្រាសត្វឈឺនិងងាប់ តាមរយៈការត្រួតពិនិត្យជំងឺសត្វ

- ការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពម្ហូបអាហារមានប្រភពពីសត្វនិងសុខភាពសាធារណៈ ពិសេសការទប់ស្កាត់ជំងឺឆ្លងពីសត្វទៅមនុស្ស
- ជំរុញធ្វើឱ្យប្រសើរឡើងនូវផលិតកម្មចំណីសត្វនិងធ្វើឱ្យប្រសើរឡើងនូវពូជសត្វ
- ជំរុញការគ្រប់គ្រងកាកសំណល់សត្វ តាមរយៈការសាងសង់ឡជីវឧស្ម័ន
- ជំរុញការកែទម្លាប់ការចិញ្ចឹមសត្វរបស់កសិករបែបយថាផលនិងការចិញ្ចឹមសត្វ សម្រាប់ផ្គត់ផ្គង់គ្រួសារទៅជាការចិញ្ចឹមសត្វតាមបច្ចេកទេស ទៅជាបែបពាណិជ្ជកម្ម ដោយមានជីវសុវត្ថិភាព
- បង្កើននិងពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយលើការងារផលិតកម្មសត្វនិងសុខភាពសត្វ
- ជំរុញឱ្យប្រសើរឡើងនូវឥណទានក្នុងការសាងសង់ឡជីវឧស្ម័ននិងការចិញ្ចឹមសត្វ
- លើកទឹកចិត្តការវិនិយោគលើការចិញ្ចឹមសត្វ សេវាកម្មសុខភាពសត្វ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារសត្វ និងផលិតផលមានដើមកំណើតពីសត្វ

## ៤.៣.១.២. សកម្មភាពនិងលទ្ធផលសម្រេចបានឆ្នាំ២០១១

## ១. លទ្ធផលសំខាន់ៗឆ្នាំ២០១១

ការអនុវត្តការងារអនុវិស័យនេះ ក្នុងរយៈមួយឆ្នាំកន្លងទៅនេះ ទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម÷

-ស្ថិតិសត្វ បានកត់សម្គាល់ថា គោ ក្របីសរុប **៤.០៩៦.៤០១** ក្បាល ថយចុះចំនួន **២,១៥%** ក្នុងនោះ គោសរុបចំនួន **៣.៤០៦.៩៧២**ក្បាល ថយចុះ **២,២៣%** និងក្របីសរុបចំនួន **៦៩២.៦១១** ក្បាល ថយចុះ **១,៣៥%** ធៀបឆ្នាំ២០១០។ សត្វស្លាប កើន **៥,៧៧%** និងជ្រូក កើនឡើងចុះ **២,០៤%** ធៀបទៅ នឹងឆ្នាំ ២០១០

-កសិដ្ឋាននិងកន្លែងចិញ្ចឹមសត្វសរុប **២.០៥៩** កន្លែង ដែលមានសត្វសរុបចំនួន **៣.៩២៥.២០៩** ក្បាល ក្នុងនោះ កសិដ្ឋានមាន់ពង មាន់សាច់-៥៨០កសិដ្ឋាន ទា-៩៨៣កសិដ្ឋាន គ្រួច៤កសិដ្ឋាន ជ្រូក-៣៦៤កសិដ្ឋាន គោ-៣០កន្លែង គោទឹកដោះ ១កន្លែង ក្របី១ សេះ១ និងកសិដ្ឋានពពែចៀមចំនួន៩៥កន្លែង

-ស្ថានីយមានជ្រូកពូជសរុបចំនួន**១៥៩**ក្បាល ក្នុងនោះមេពូជមានចំនួន **១៤១** ក្បាល និងបាពូជមានចំនួន**១៨**ក្បាល។ ឆ្នាំ២០១១ ស្ថានីយ ផលិតបានកូនជ្រូកពូជចំនួន **៩២៦** ក្បាល ដែលបានលក់ចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ កសិករពីខេត្តចំនួន **១១** រួមមាន ខេត្តកណ្តាល ព្រះវិហារ តាកែវ ព្រះសីហនុ សៀមរាប ព្រៃវែង តាកែវ កំពង់ចាម រាជធានីភ្នំពេញ ពោធិសាត់ និងរតនៈគីរី បានទទួលទិញជ្រូកពូជពីស្ថានីយ ដើម្បីចិញ្ចឹមផ្សព្វផ្សាយពូជបន្ត

-ស្ថានីយមានចំនួនគោសរុប **២០៧** ក្បាល ក្នុងនោះមានគោពូជកំផែងសែន ចំនួន **៣៧** ក្បាល ជាអំណោយដ៏ថ្លៃថ្លារបស់**ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកន្លែងដាំ និងផ្សព្វផ្សាយដំណាំចំណីសត្វផងដែរ។ ឆ្នាំ២០១១ ស្ថានីយបានចែកពូជស្មៅឃីងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មុលឡាតូ ប៉ាស្ពាឡូម និងស៊ីម្ហូងដល់បណ្តាខេត្តមួយចំនួន ហើយស្ថានីយក៏បានផ្តល់ស្មៅដល់កសិករ ដែល រងគ្រោះដោយទឹកជំនន់

-ការកែលំអរពូជសត្វ និងការដាំដំណាំចំណីសត្វ កំពុងតែមានការរីកចម្រើនល្អប្រសើរ និងពង្រីកការផ្សព្វផ្សាយពូជសត្វ និងពូជស្មៅជាបន្តទៅតំបន់ផ្សេងៗ ទូទាំងប្រទេសយ៉ាងផុសផុល

-គម្រោងសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ÷ ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១១ ការកសាងឡជីវឧស្ម័ន បានអនុវត្តក្នុងខេត្តចំនួន ១៤ សរុបមានចំនួន ១៤.៩៧២ ឡ ដែលក្នុងនោះ នៅឆ្នាំ ២០១១ ឡជីឧស្ម័ន បានសាងសង់ចំនួន ៤.៨២៦ ឡ

-ព័ត៌មានទីផ្សារសត្វនិងផលិតផលសត្វ មានតួនាទីយ៉ាងសំខាន់ ដើម្បីផ្សព្វផ្សាយពីតំលៃសត្វ និងផលិតផលសត្វដល់ប្រជាកសិករនៅតាមមូលដ្ឋាន សម្រាប់ជាមូលដ្ឋានក្នុងការលក់ដូរសត្វរបស់កសិករ

-ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្ត នៅទូទាំងប្រទេស ដោយមានការសហការជាមួយអង្គការជាដៃគូ និងផ្នែកឯកជន គឺមានការអនុវត្តបានល្អប្រសើរជាងឆ្នាំមុនៗ

-ជំងឺអុតក្តាម សារទឹក បូសខ្យល់ ជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀត គឺត្រូវបានចាត់ទុកថា ជាជំងឺឆ្លងដ៏សំខាន់ដែលនៅតែបន្តការបង្កនូវភាពស្មុគ្រស្មាញ បំផ្លិចបំផ្លាញ និងគ្រោះមហន្តរាយដល់អាយុជីវិតមនុស្ស សត្វ

-ជំងឺផ្តាសាយបក្សី គឺនៅជាបញ្ហាចំបង ហើយនាដើមឆ្នាំ២០១១ ជំងឺផ្តាសាយបក្សីនេះ បានផ្ទុះឡើងចំនួន០៦ករណី នៅខេត្តកណ្តាល តាកែវ បាត់ដំបង និងបន្ទាយមានជ័យ (៣ករណី) ក្នុងនោះសម្លាប់ជីវិតមនុស្ស ចំនួន០៨ករណី នៅរាជធានីភ្នំពេញ ព្រៃវែង ២ កំពង់ចាម ២ និងបន្ទាយមានជ័យ ៣។ បន្ថែមលើសពីនេះ ស្ថានភាពជំងឺដទៃផ្សេងទៀត រួមមាន ជំងឺជ្រូកត្រចៀកខៀវ ជំងឺសារទឹក និងជំងឺអុតក្តាម គឺមានការផ្ទុះរាលដាលនៅតំបន់មួយចំនួន ដែលបង្កឲ្យមានការប៉ះពាល់ដល់ផលិតកម្មសត្វ

-ជាលទ្ធផលនៅទូទាំងប្រទេសសត្វបានទទួលការចាក់ថ្នាំការពារ÷សារទឹកគោក្របីបានចំនួន១.៦៧០.៥០៣ក្បាល អុតក្តាមគោក្របីបានចំនួន៨៥.៦៤០ក្បាល បូសខ្យល់ចំនួន២៤.៧៧០ក្បាល សារទឹកជ្រូកចំនួន១៦៩.៥៣០ក្បាល ប៉េស្តជ្រូកចំនួន២៩៨.០៣៨ក្បាល សាល់ម៉ូជ្រូកចំនួន១៣១.០៨៦ក្បាល អុតក្តាមជ្រូកចំនួន២៨.១៤១ក្បាល អូហ្សេស្គីជ្រូកចំនួន១២.៧៣១ក្បាល រាគកូនជ្រូកចំនួន៣៥.៧៥១ក្បាល កញ្ជ្រឹលជ្រូកចំនួន២៧.៧៤១ក្បាល ញូវកាសបក្សីចំនួន ៨៥៥.៤៨០ ក្បាល អាសន្នរោគមាន់ចំនួន៧០២.៨៦៣ក្បាល អុតបក្សីចំនួន ៣០៤.១១៦ ក្បាល អាសន្នរោគទាចំនួន ៨៧.៧៥៩ក្បាល និងប៉េស្តទាចំនួន១០៧.៨៨១ក្បាល

-ការទប់ស្កាត់ជំងឺឆ្លងសត្វៈ បានពង្រឹងការត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ពង្រឹងការស្រាវជ្រាវ យកវត្ថុវិភាគ ធ្វើការផ្សព្វផ្សាយជាប្រចាំនូវផលប៉ះពាល់នៃជំងឺឆ្លង វិធានការការពារ និង ជីវសុវត្ថិភាពក្នុងការចិញ្ចឹមសត្វនៅតាមផ្ទះ ក៏ដូចជានៅតាមកសិដ្ឋាន ចុះស្រាវជ្រាវ និងទប់ស្កាត់តាមគ្រប់ច្រកនាំចូល ពិសេសបណ្តាខេត្តតាមព្រំដែន រាយការណ៍ជាប្រចាំពីស្ថានភាពវិវត្តន៍នៃជំងឺឆ្លង និងលទ្ធផលនៃការអនុវត្តវិធានការទាំងឡាយ

-ការទប់ស្កាត់បទល្មើសៈ ការឃាត់ចាប់ និងដុតកំទេចចោលតាមវិធានបសុពេទ្យផលិតផលសត្វខុសច្បាប់នាំមកពីប្រទេសជិតខាង មានចំនួន ៤៨ ករណី

-ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វៈ ការនាំចេញសត្វគោ ក្របីក្នុងស្រុក គោឆ្លងកាត់ ការនាំចូលជ្រូក ព្រមទាំងបាននាំចេញ-ចូលសត្វ និងផលិតផលមានដើមកំណើតសត្វប្រភេទផ្សេងទៀត

-ភ្នាក់ងារសុខភាពសត្វភូមិសរុបមានចំនួន១៤.៥៦៣នាក់ ក្នុងនោះបានធ្វើការបណ្តុះបណ្តាលថ្មីចំនួន១.៧០៣នាក់ ដើម្បីជំនួសភ្នាក់ងារសុខភាពសត្វភូមិ ដែលបានបោះ បង់អាជីពរបស់ខ្លួន

-សត្តឃាតដ្ឋានទាំងប្រភេទ “ក ”និង “ខ ” ដែលមានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រង សត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ មានចំនួនសរុប**៩៦**កន្លែង ក្នុងនោះ នៅរាជធានីភ្នំពេញ**១២**កន្លែង ខេត្តកណ្តាល**១៨**កន្លែង កំពង់ឆ្នាំង **១០**កន្លែង បន្ទាយមានជ័យ**០៩**កន្លែង បាត់ដំបង**១៣**កន្លែង សៀមរាប**០៦**កន្លែង ព្រះសីហនុ**០២**កន្លែង ព្រៃវែង**០៣**កន្លែង កំពង់ស្ពឺ**១០**កន្លែង មណ្ឌលគិរី**០២**កន្លែង រតនៈគិរី**០២**កន្លែង ស្ទឹងត្រែង**០១**កន្លែង កំពត**០៤**កន្លែង ក្រចេះ**០២**កន្លែង កោះកុង**០១**កន្លែង និងខេត្តកែប**០១**កន្លែង

-វត្ថុវិភាគ ដែលបានធ្វើវិភាគរកវត្តមានមេរោគបង្កជំងឺ មានចំនួនសរុប **១៣.១៧២** វត្ថុវិភាគ ក្នុងនោះ ប៉ារ៉ាស៊ីតសាស្រ្តចំនួន**២.២៩៤**បាក់តេរីសាស្រ្តចំនួន**២.៣៧៧** លោហិតសាស្រ្តចំនួន**២.២៤២** សេរ៉ូមសាស្រ្តចំនួន**៦.១៨២** និងសរីរៈរោគសាស្រ្ត**៧៧**វត្ថុវិភាគ។ តាមការវិភាគនេះ វិទ្យាស្ថានជាតិ បានរកឃើញពពួកប៉ារ៉ាស៊ីត វីរុស (ផ្តាសាយ បក្សី ញូកាស អុតក្តាម ប៉េស្តជ្រូក ត្រចៀកខៀវ) និងបាក់តេរី (សារទឹក និងអ៊ីកូលី)

-អង្កេតតាមដាន និងស្រាវជ្រាវជំងឺសត្វ រួមមានសិក្សាស្រាវជ្រាវកន្លែងផ្ទុះជំងឺសារទឹក ជំងឺអុតក្តាម និងជំងឺប៉េស្តជ្រូក នៅតាមបណ្តារាជធានី ខេត្ត និងតាមដានឃ្លាំមើលពីស្ថានភាពជំងឺផ្តាសាយបក្សី នៅតាមបណ្តាភូមិនៅទូទាំងប្រទេស ដោយប្រើប្រាស់ភ្នាក់ងារសុខភាពសត្វភូមិ ព្រមទាំងនៅតាមទីផ្សារលក់បក្សីរស់រាជធានី ខេត្តផងដែរ

-ប្រពន្ធ័ពត៌មានជំងឺសត្វ មានការរៀបចំជាលក្ខណៈប្រព័ន្ធបានល្អប្រសើរពីមូលដ្ឋានរហូតដល់ថ្នាក់ជាតិ គឺរាជធានី ខេត្ត បានរាយការណ៍ជាប្រចាំមកនាយកដ្ឋាន ហើយនាយកដ្ឋាន បានរាយការណ៍បន្តជូនក្រសួង ប្រទេសជិតខាង អង្គការអន្តរជាតិនានា ពិសេសអង្គការ OIE, FAO តាមរយៈ ARAHIS និង WAHIS និងអ្នកពាក់ព័ន្ធដទៃទៀត។ ចំពោះព័ត៌មានទាន់ហេតុការណ៍នៅក្នុងប្រទេស វិទ្យាស្ថានជាតិ បានទទួលទូរសព្ទ័ហៅចូលចំនួន១៣៤ ដែលមកពីរាជធានីភ្នំពេញ កណ្តាល

ក្រចេះ ព្រៃវែង កំពង់ចាម កំពង់ស្ពឺ តាកែវ ក្រចេះ សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពត កំពង់ឆ្នាំង កំពង់ធំ និងក្រសួងសុខាភិបាល ដែលរាយការណ៍ពីសត្វឈឺ ងាប់ សាកសួរពីរោគសញ្ញា និងវិធានការការពារជំងឺសត្វ

-កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកផលិតកម្ម និងបសុព្យាបាល បានទទួលលទ្ធផលល្អគួរឱ្យកត់សំគាល់ ដូចជា ការកសាងលិខិតបទដ្ឋានគតិយុត្តនៃអនុក្រឹត្យលេខ១៦ និង១០៨ អនក្រ.បក បានបញ្ចប់សព្វគ្រប់ទាំងស្រុង។ ទន្ទឹមនឹងនោះ បានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វរួចហើយ។ សេចក្តីព្រាងច្បាប់នេះ មានចំនួន ១៩ ជំពូក និង១៣៦ មាត្រា។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដាក់ប្រជុំអចិន្ត្រៃយ៍

-ការផ្សព្វផ្សាយបច្ចេកទេស គឺកំពុងតែមានការចាប់អារម្មណ៍និងមានការគាំទ្រពីគ្រប់ជំនាញ អង្គការជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយជាច្រើន ហើយបាននិងកំពុងតែអនុវត្តយ៉ាងសកម្ម នៅតាមមូលដ្ឋានរាជធានី ខេត្តទូទាំងប្រទេស។ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលបានយកចិត្តទុកដាក់ប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ តាមវិទ្យុ ទូរទស្ស ទស្សនាវដ្តី បទសំភាសន៍ ឯកសារបច្ចេកទេស ការតាំងពិព័ណ៌ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការឃោសនាផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងទស្សនកិច្ចសិក្សា។ល។ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាអទិភាពដូចជាបញ្ហាជំងឺឆ្លង អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ បច្ចេកទេសចិញ្ចឹម ពូជនិងបច្ចេកទេសជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជតាមបែបសិប្បនិមិត្ត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផលិតកម្ម និងបសុព្យាបាល ។ល។

-សហការជាមួយដៃគូរអភិវឌ្ឍន៍មួយចំនួនដូចជា: OIE, SEAFMD, FAO, WHO, SLPP, WB, USDA, USAID, JICA, ACIAR, IPC និង SNV ។ល។

## ២. ការងារផលិតកម្មសត្វ

សមិទ្ធផលផ្នែកផលិតកម្មសត្វឆ្នាំ២០១១ មានការវិវត្តន៍ជាបន្តបន្ទាប់និងគួរឱ្យកត់សម្គាល់ដែលក្នុងនោះ÷

### *២.១. ការចិញ្ចឹមសត្វតាមលក្ខណៈគ្រួសារ*

**តារាងប្រៀបធៀបស្ថិតិសត្វ**

| ប្រភេទសត្វ | ចំនួនសត្វសរុប (ក្បាល) | | ប្រៀបធៀបឆ្នាំ២០១១/២០១០ | |
|---|---|---|---|---|
| | ឆ្នាំ ២០១០ | ឆ្នាំ ២០១១ | ចំនួនសត្វកើន ឬថយ (ក្បាល) | ភាគរយ (%) |
| គោ | ៣.៤៨៤.៦០១ | ៣.៤០៦.៩៧២ | -៧៧.៦២៩ | ២,២៣ |
| ក្របី | ៧០២.០៧៤ | ៦៨៩.៨២៩ | -១២.២៤៥ | ១,៧៧ |
| គោ-ក្របី | ៤.១៨៦.៦៧៥ | ៤.០៩៦.៨០១ | -៨៩.៨៧៤ | ២,១៥ |
| កំលាំងអូសទាញ | ១.៦២៦.២៤៣ | ១.៥៧៤.២៩៦ | -៥១.៩៤៧ | ៣,១៩ |
| ជ្រូក | ២.០៥៧.៤៣១ | ២.០៩៩.៣៣២ | ៤១.៩០១ | ២,០៤ |
| សត្វស្លាប | ២០.៨៣៤.២៩៥ | ២២.០៣៦.៧៥៥ | ១.២០២.៤៦០ | ៥,៧៧ |

ឆ្នាំ២០១១ ចំនួនគោក្របីមានការថយចុះប្រមាណ២,១៥% ដោយឡែកជ្រូក និងបក្សីមានការកើនឡើង ២,០៤% និង ៥,៧៧% (ធៀបនឹងឆ្នាំ ២០១០)។

-ការថយចុះគោ ក្របី គឺបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន រួមមានកំណើននៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម ការបម្រែបម្រួលអាកាសធាតុការកើនឡើងនៃផ្ទៃដីកសិកម្ម និងកំណើននៃតម្រូវការសាច់ជាម្ហូបអាហារក្នុងស្រុកនិងទីផ្សារនាំចេញគោរស់ទៅប្រទេសជិតខាង

-ការចិញ្ចឹមជ្រូក មានការកើនឡើង ដោយសារមានតម្រូវការទីផ្សារខ្ពស់ ផ្តល់នូវប្រាក់ចំណូល មានវដ្តផលិតកម្មខ្លី និងការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ និងមានការចូលរួមពីផ្នែកឯកជន

-ការចិញ្ចឹមបក្សី ក៏នៅតែមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារការចិញ្ចឹមជាលក្ខណៈគ្រួសារមានការរីកចម្រើន ជាពិសេសសន្ទុះកើនឡើងនៃការវិនិយោគផ្នែកឯកជន និងមានកំណើនតម្រូវការទីផ្សារខ្ពស់។

## ២.២ កសិដ្ឋានចិញ្ចឹមសត្វឯកជន

ស្ថិតិកសិដ្ឋាននិងចំនួនសត្វចិញ្ចឹមបែបពាក់កណ្ដាលឧស្សាហកម្ម និងឧស្សាហកម្មឆ្នាំ២០១០-២០១១

| ប្រភេទកសិដ្ឋាន ចិញ្ចឹមសត្វ | ចំនួនកសិដ្ឋាន | | ចំនួនសត្វសរុប (ក្បាល) | | ការប្រៀបធៀបចំនួនសត្វសរុបឆ្នាំ ២០១១/២០១០ | |
|---|---|---|---|---|---|---|
| | ២០១០ | ២០១១ | ២០១០ | ២០១១ | កើនឬថយ (ក្បាល) | ភាគរយ (%) |
| មាន់សាច់ និង ស៊ុត | ៣០៧ | ៥៨០ | ១.៥៣៥.៥០៥ | ១.៨៩៦.៦៩០ | ៣៦១.១៨៥ | ២៣,៥២ |
| ទាសាច់ និងស៊ុត | ៥៦៨ | ៩៨៣ | ៩០៧.២៧៩ | ១.៨៤៣.៩២១ | ៩៣៦.៦៤២ | ១០៣,២៤ |
| ក្រួច | ១២ | ៤ | ៤.៥០៩ | ១៧.០០០ | ១២.៤៩១ | ២៧៧ |
| ជ្រូកសាច់ និងជ្រូកពូជ | ៣.០៩៥ | ៣៦៤ | ១៥៩.៤៥០ | ១៦៤៤៤៨ | ៤៩៩៨ | ៣,១៣ |
| គោ | ៦៣ | ៣0 | ៣.៩៤២ | ៤.៧៧0 | ៨២៨ | ២១ |
| គោទឹកដោះ | ១ | ១ | ៨០ | ៩៥ | ១៥ | ១៨,៧៥ |
| ក្របី | ១ | ១ | ៤៨ | ៨៤ | ៣៦ | ៧៥ |
| សេះ | ១ | ១ | ៤១ | ៤៣ | ២ | ៤,៨៨ |
| ចៀម | ២ | ៣ | ៤០ | ៤០៣ | ៣៦៣ | ៩០៧,០៧ |
| ពពែ | ៦៥ | ៩២ | ១.៥៦៩ | ២.៥២៥ | ៩៥៦ | ៦០,៩៣ |

## ២.៣ ស្ថានីយចិញ្ចឹមសត្វរដ្ឋ

### ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន

ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិននៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការឧបត្ថម្ភគាំទ្ររបស់សាធារណរដ្ឋប្រជាមានិតចិន និងរាជរដ្ឋាភិបាលកម្ពុជា។ ចុងឆ្នាំ២០១១ ស្ថានីយ៍ មានជ្រូកពូជសរុបចំនួន **១៥៩**ក្បាល ក្នុងនោះមេពូជមានចំនួន **១៤១**ក្បាល និងបាពូជមានចំនួន**១៨**ក្បាល។ ឆ្នាំ២០១១ ស្ថានីយ៍ផលិតបានកូនជ្រូកពូជចំនួន **៩២៦** ក្បាល ដែលបានលក់ចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ កសិករពីខេត្តចំនួន **១១** រួមមាន ខេត្តកណ្ដាល ព្រះវិហារ តាកែវ ព្រះសីហនុ សៀមរាប ព្រៃវែង តាកែវ កំពង់ចាម រាជធានីភ្នំពេញ ពោធិសាត់ និងរតនៈគីរី បានទទួលទិញជ្រូកពូជពីស្ថានីយ ដើម្បីចិញ្ចឹមផ្សព្វផ្សាយពូជបន្ត។

### ស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅ

នាឆ្នាំ២០១១ ស្ថានីយមានចំនួនគោសរុប ២០៧ ក្បាល ក្នុងនោះមានគោពូជកំផែងសែន ចំនួន ៣៧ ក្បាល ជាអំណោយដ៏ថ្លៃថ្លារបស់**ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកន្លែងដាំនិងផ្សព្វផ្សាយដំណាំចំណីសត្វផងដែរ។ ឆ្នាំ២០១១ ស្ថានីយ បានចែកពូជស្មៅឃើងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មុលឡាតូ ប៉ាស្ពាឡូម និងស៊ីមូងដល់បណ្ដាខេត្តមួយចំនួន ហើយស្ថានីយ៍ក៏បានផ្ដល់ស្មៅដល់កសិករ ដែលរងគ្រោះ ដោយទឹកជំនន់។

## ២.៤ ការកែលម្អពូជសត្វ

ការកែលំអពូជសត្វ បានអភិវឌ្ឍន៍ជាជំហានៗតាមគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យផលិតកម្មនិងបសុព្យាបាល ដូចជា ការនាំចូលរូបធាតុសេនេទិកសត្វពូជសត្វ ការជ្រើសរើសពូជសត្វ ក្នុងស្រុក ដែលមានផលិតភាពខ្ពស់ ដើម្បីយកមកបង្កាត់និងផ្សព្វផ្សាយពូជទាំងក្នុងជួរកសិករ ក៏ដូចជាតាមបណ្ដាកសិដ្ឋានចិញ្ចឹមសត្វឯកជននៅក្នុងប្រទេសកម្ពុជា។ ពូជសត្វសំខាន់ៗ ដែលត្រូវបានយកមកបង្កាត់ និងផ្សព្វផ្សាយពូជ មានដូចជា÷

-ពូជកំផែងសែន និងពូជប្រាមាន់ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ

-ការនាំចូលស្ពែមពូជគោស៊ីមប្រា និងសាន់តា ដែលត្រូវបានធ្វើការបង្កាត់សិប្បនិម្មិតជាមួយគោ ក្នុងស្រុកតាមបណ្ដាខេត្តមួយចំនួនដូចជា ខេត្តពោធិសាត់ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង សៀមរាប និងខេត្តតាកែវ ដែលចំនួនបង្កាត់ ស៊ីមប្រា ចំនួន ២៩៨ ក្បាល

-ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន ធ្វើការបង្កាត់ និងផ្សព្វផ្សាយពូជជ្រូក ឡែនដ្រេស យ៉កសៀ និងឌុយរ៉ុក

-ការបង្កាត់មាន់យកសាច់ ស៊ុត ពូជKI (ពូជមាន់ខ្មែរបង្កាត់ជាមួយអ៊ីសាប្រោន)នៅខេត្តសៀមរាប

-ការចិញ្ចឹមគោយកទឹកដោះ ក្រោមគម្រោងកិច្ចសហប្រតិបត្តិជប៉ុន (JLTA) អនុវត្តនៅភូមិកោះក្របី ឃុំព្រែកថ្មី ខណ្ឌមានជ័យរាជធានីភ្នំពេញ និងឃុំជ្រោយអំបិល ស្រុកកៀនស្វាយ

-វិស័យឯកជន បាននឹងកំពុងបង្កាត់និងផ្សព្វផ្សាយលក់ពូជសត្វគ្រប់ប្រភេទ ដែលធ្វើឲ្យមានការផ្លាស់ប្តូរពូជសត្វគួរឲ្យកត់សម្គាល់។

## ២.៥ ការកែលំអចំណីសត្វ

អនុវិស័យផលិតកម្មនិងបសុពេទ្យបាល បាននឹងកំពុងជំរុញការដាំដំណាំចំណីសត្វ ផ្តល់ពូជ និងផ្សព្វផ្សាយពូជស្មៅ បច្ចេកទេសដាំដំណាំចំណីសត្វ ព្រមទាំងជំរុញការអនុវត្ត សាកល្បងពិសោធន៍ ផ្សព្វផ្សាយពីវិធីសាស្ត្រ និងបច្ចេកទេសកែច្នៃ និងផ្ទុំចំណីសត្វដល់ការិយាល័យផលិតកម្ម និងបសុពេទ្យបាលរាជធានី ខេត្ត និងកសិករតាមបណ្តាខេត្តនានានៅទូទាំងប្រទេស។

ពូជដំណាំចំណីសត្វ ដែលបានផ្សព្វផ្សាយដល់កសិករនាពេលបច្ចុប្បន្ន រួមមាន÷ Simung, Mulato, Paspalum, Stylo184, Marandu, Ruzi, Elephant grass, King grass កន្ធឹថេត ទ្រីចាន់ធារ៉ា ។ល។ បច្ចេកទេសកែច្នៃ និងផ្ទុំចំណីសត្វរួមមាន÷ ការធ្វើចំបើងផ្អាប់ជាមួយជីអ៊ុយរេ ផ្ទុកស្មៅ ស្លឹក ដំឡូងមីផ្អាប់។ល។

ខេត្តកំពង់ចាម តាកែវ ពោធិ៍សាត់ និងខេត្តកណ្តាល គឺជាខេត្តគំរូ ដែលទទួលបានជោគជ័យក្នុងការដាំដំណាំចំណីសត្វ និងបានអនុវត្តការកែច្នៃផ្ទុំចំណីសត្វ និងផ្សព្វផ្សាយពូជ បច្ចេកទេសដាំដុះ បច្ចេកទេសកែច្នៃផ្ទុំ ដល់កសិករក្នុងខេត្តរបស់ខ្លួន និងខេត្តដទៃផ្សេងទៀត ។

## ២.៦ ការអភិវឌ្ឍនកម្មវិធីឡជីវឧស្ម័ន

ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ ការកសាងឡជីវឧស្ម័នបានអនុវត្តក្នុងខេត្តចំនួន ១៤ សរុបមានចំនួន១៤.៩៧២ឡ ដែលក្នុងនោះ នៅឆ្នាំ ២០១១ ឡជីឧស្ម័ន បានសាងសង់ចំនួន៤.៨២៦ ឡ ។

**តារាងចំនួនឡជីវឧស្ម័ននៅកម្ពុជាចាប់ពីឆ្នាំ២០០៦-២០១១**

| ខេត្ត | ឡជីវឧស្ម័នដែលបានសាងសង់ | | | | | | |
|---|---|---|---|---|---|---|---|
| | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | សរុបរួម |
| កំពង់ចាម | ១១៣ | ២៥០ | ៤០០ | ៤៩៧ | ៤៨៤ | ៤៥០ | **២.១៩៤** |
| កណ្តាល | ៨៧ | ៨១ | ១០០ | ១៣៣ | ២៨១ | ២២២ | **៩០៤** |
| ស្វាយរៀង | ៦១ | ១៣៦ | ៣៣២ | ៥២៥ | ៥២២ | ៥៥២ | **២.១២៨** |
| តាកែវ | ៣១ | ៤៥០ | ៦៨៦ | ៤០៥ | ៦១៩ | ៦៤០ | **២.៨៣១** |
| កំពង់ស្ពឺ | ៤ | ២៣២ | ២៨៩ | ២៣៥ | ៣៦២ | ៤៣៤ | **១.៥៥៦** |
| កំពង់ឆ្នាំង | ០ | ០ | ១៥៥ | ១៩៨ | ១៦៨ | ២៣៨ | **៧៥៩** |
| កំពត | ០ | ១ | ៣៥៧ | ៣៧៧ | ៦៩៦ | ១.០៣៤ | **២.៤៦៥** |
| ព្រៃវែង | ០ | ០ | ២១ | ២៤៦ | ៤៣៨ | ៦៥៣ | **១.៣៥៨** |
| សៀមរាប | ០ | ០ | ០ | ០ | ៦៧ | ១០៧ | **១៧៤** |
| ពោធិ៍សាត់ | ០ | ០ | ០ | ០ | ៧៤ | ១១៦ | **១៩០** |
| បាត់ដំបង | ០ | ០ | ០ | ០ | ២២ | ៥៦ | **៧៨** |
| កំពង់ធំ | ០ | ០ | ០ | ០ | ១១ | ២៦១ | **២៧១** |
| កែប | ០ | ០ | ០ | ០ | ០ | ៦២ | **៦២** |
| ព្រះសីហនុ | ០ | ០ | ០ | ០ | ០ | ១ | **១** |
| **សរុបរួម** | **២៩៦** | **១.១៥០** | **២.៣៤០** | **២.៦១៦** | **៣.៧៤៤** | **៤.៨២៦** | **១៤.៩៧២** |

ក្រាហ្វិកបង្ហាញចំនួនឡជីវឧស្ម័នដែលបានសាងសង់នៅតាមខែនៃឆ្នាំ២០១១




## ២.៧ ពត៌មានទីផ្សារសត្វ និង ផលិតផលសត្វ

ព័ត៌មានទីផ្សារសត្វនិងផលិតផលសត្វ មានតួនាទីយ៉ាងសំខាន់ ដើម្បីផ្សព្វផ្សាយពីតម្លៃសត្វនិងផលិតផលសត្វដល់ប្រជាកសិករនៅតាមមូលដ្ឋាន សម្រាប់ជាមូលដ្ឋានក្នុងការលក់ដូរសត្វរបស់កសិករ។ នៅឆ្នាំ២០១១ អនុវិស័យនេះបានបន្តការងារប្រមូលទិន្នន័យទីផ្សារសត្វ និងផលិតផលសត្វនៅតាមទីផ្សារមួយចំនួនក្នុងរាជធានី ខេត្ត។

ក្រាហ្វិកបង្ហាញ ទិន្នន័យតម្លៃសត្វនិងផលិតផលសត្វនៅឆ្នាំ ២០១១




## ២.៨ ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋានរបស់រាជធានី ខេត្ត

នៅឆ្នាំ២០១១នេះ ការអភិវឌ្ឍការចិញ្ចឹមសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្តនៅទូទាំងប្រទេស ដោយមានការសហការជាមួយអង្គការជាដៃគូ និងផ្នែកឯកជន គឺមានការធ្លាក់ចុះបន្តិចដោយសារមានកត្តាជាច្រើន ដែលបង្កឱ្យមានបញ្ហាប្រឈមក្នុងកិច្ចដំណើរការការងារចិញ្ចឹមសត្វនេះ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក្រសួងបាននឹងកំពុងខិតខំប្រឹងប្រែងស្វែងរកគ្រប់មធ្យោបាយ និងវិធីសាស្ត្រសំខាន់ៗគ្រប់បែបយ៉ាង ដើម្បីដោះស្រាយរាល់បញ្ហាទាំងអស់នេះ ដោយមានការចុះណែនាំដល់អ្នកចិញ្ចឹមសត្វពីរបៀបចិញ្ចឹមសត្វ ការបង្កើតសហគមន៍ចិញ្ចឹមសត្វ ការផ្តល់ឥណទានសម្រាប់ ចិញ្ចឹមសត្វ និងកម្មវិធីដទៃផ្សេងៗទៀត។

# ៣. ការងារសុខភាពសត្វ

## ៣.១ ស្ថានភាពជំងឺឆ្លងសត្វ

ជារៀងរាល់ឆ្នាំ ជំងឺឆ្លងសត្វច្រើនប្រភេទ បានបង្កឱ្យសត្វឈឺ និងងាប់ នឹងបណ្តាលឱ្យមានការខាតបង់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិផងដែរ។ មិនតែប៉ុណ្ណោះ ជួនពេលខ្លះ ជំងឺទាំងនេះក៏អាចឆ្លងរាលដាលដល់មនុស្សនិងបង្កឱ្យមាន

គ្រោះថ្នាក់ ដល់ជីវិតមនុស្សស្លាប់ថែមទៀតផង។ នៅឆ្នាំ២០១១ កន្លងទៅនេះ សភាពការណ៍នៃជំងឺឆ្លងសត្វ មានសភាពរាលដាលមិនសូវខ្លាំងក្លាគួរឱ្យកត់សម្គាល់ទេ ប៉ុន្តែតាមការសង្កេតជារួម ទិន្នន័យនៃស្ថានភាពជំងឺឆ្លងសំខាន់ៗ ដែលបង្កឱ្យមានមហន្តរាយដល់ជីវិតមនុស្សសត្វ និងសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិរួមមាន ÷

**ជំងឺអុតក្តាម÷** មានការផ្ទុះឡើងចំនួន៩៧កន្លែង ក្នុងនោះមាន០៦កន្លែង ដូចជាខេត្តកំពត០៦កន្លែង កណ្តាល០២កន្លែង កែប០៨កន្លែង កំពង់ស្ពឺ០១កន្លែង កំពង់ឆ្នាំង០៤កន្លែង កំពង់ធំ១០កន្លែង តាកែវ១២កន្លែង ព្រៃវែង០៨កន្លែង ស្វាយរៀង ០៣កន្លែង ក្រចេះ០៧កន្លែង រតនគិរី០៥កន្លែង បាត់ដំបង០៤កន្លែង បន្ទាយមានជ័យ០៣កន្លែង សៀមរាប០១កន្លែង ឧត្តមានជ័យ ០២កន្លែង ប៉ៃលិន០១កន្លែង ព្រះសីហនុ០៣កន្លែង ព្រះវិហារ និង០៧កន្លែងនៅខេត្តកំពង់ចាម។

**ជំងឺសារទឹក÷** មានការផ្ទុះឡើងចំនួនចំនួន ៦៤ កន្លែងគឺ÷ ដូចជាខេត្តកំពត០៦ កន្លែង កំពង់ស្ពឺ០៨កន្លែង កណ្តាល ០៦កន្លែង បន្ទាយមានជ័យ០៤កន្លែង ព្រះវិហារ០៣កន្លែង រតនគិរី០៧កន្លែង ស្ទឹងត្រែង០២កន្លែង កំពង់ចាម០២កន្លែង កែប០២កន្លែង កំពង់ធំ០៤កន្លែង ព្រៃវែង១២កន្លែង ស្វាយរៀង០៨កន្លែង ដែលបណ្តាលឱ្យគោឈឺចំនួន៩២៧ក្បាល ក្នុងនោះងាប់ចំនួន១០៨ក្បាល និងក្របីឈឺចំនួន៧៨៤ក្បាល ក្នុងនោះ ងាប់ចំនួន៩៣ក្បាល ។

**ជំងឺបូសខ្យល់÷** បានផ្ទុះឡើងចំនួន០១កន្លែង គឺនៅក្នុងខេត្តមណ្ឌលគិរី ដែលមានគោឈឺចំនួន ៣៦ ក្បាល និង ងាប់ ០២ ក្បាល ។

**ជំងឺបូសប៉េស្តជ្រូក÷** បានផ្ទុះឡើងចំនួន០៨កន្លែង គឺ០៣កន្លែងក្នុងកំពង់ស្ពឺ ០៣ កន្លែងក្នុងខេត្តក្រចេះ និង ០២ កន្លែងក្នុងកំពង់ចាម ដែលបណ្តាលឱ្យជ្រូកឈឺចំនួន៤.៨១៤ក្បាល និងងាប់ចំនួន២១១ក្បាល។

**ជំងឺផ្តាសាយបក្សី÷** បាញ់ថ្នាំរំងាប់មេរោគដោយថ្នាំ TH4 នៅជុំវិញភូមិ ឃុំ ស្រុកដែលរកឃើញវត្តមានជំងឺផ្តាសាយបក្សីនិងសម្លាប់បក្សីដែលឈឺ និងសង្ស័យមានជំងឺនៅភូមិ ឃុំ ស្រុកដែលបក្សីមាន ជំងឺនោះដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ ។

## *៣.២ ការបង្ក្រាបបទល្មើស និងការទប់ស្កាត់ជំងឺឆ្លងសត្វ*

ផ្អែកលើវិធានបច្ចេកទេសនិងវិធានច្បាប់ បានទប់ស្កាត់និងបង្ក្រាបបទល្មើស ដែលទទួលបានលទ្ធផលដូចខាងក្រោម÷

**<u>នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល÷</u>** បានត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ជាលទ្ធផលបានរកឃើញ និងបង្ក្រាបបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន**២៣**ករណី ក្នុងនោះមានគោ-ក្របីចំនួន **៣២២**ក្បាល និងជ្រូកចំនួន **៩១** ក្បាល ពពែចំនួន **១៣៤** ក្បាល និងស៊ុតមាន់-ទាចំនួន **១៦៧.៥០០** គ្រាប់ និងបានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន ៦១.០០០.០០០ រៀល។

**<u>ការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត</u>÷** បានត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ជាលទ្ធផលបានរកឃើញ និងបង្ក្រាបបទល្មើសដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វ បានចំនួន **២៥** ករណីៈ គោក្របីចំនួន **៣០**ក្បាល ជ្រូកចំនួន **៩៨** ក្បាល មាន់-ទាចំនួន **២.៥៥៩** ក្បាល ស៊ុតបក្សី **៨.៤០២** គ្រាប់ ពពែចំនួន**៤៦**ក្បាល និងផលិតផលសត្វចំនួន**១០.៥៨១**គីឡូក្រាម និងបានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន ១០.០០០.០០០ រៀល។

## *៣.៣ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ*

ជាលទ្ធផល នៅទូទាំងប្រទេស សត្វបានទទួលការចាក់ថ្នាំការពារ រួមមាន÷ សារទឹកគោក្របីបានចំនួន ១.៦៧០.៥០៣ ក្បាល អុតក្តាមគោក្របី បានចំនួន ៨៥.៦៤០ក្បាល បូសខ្យល់ ចំនួន ២៤.៧៧០ក្បាល ចាក់វ៉ាកសាំងឆ្កែចំនួន ៣.៨៦១ក្បាល សារទឹកជ្រូកចំនួន ១៦៩.៥៣០ក្បាល ប៉េស្តជ្រូកចំនួន ២៩៨.០៣៨ក្បាល សាល់ម៉ូជ្រូកចំនួន ១៣១.០៤៦ក្បាល អុតក្តាមជ្រូកចំនួន ២៨.១៤១ក្បាល អូហ្យេស្គីជ្រូកចំនួន ១២.៧៣១ក្បាល រាគកូនជ្រូកចំនួន ៣៥.៧៥១ក្បាល កញ្ជ្រឹលជ្រូកចំនួន ២៧.៧៤១ក្បាល ញូវកាសបក្សីចំនួន ៨៥៥.៤៨០ក្បាល អាសន្នរោគមាន់ចំនួន ៧០២.៤៦៣ក្បាល អុតបក្សីចំនួន ៣០៤.១១៦ក្បាល អាសន្នរោគទាចំនួន ៨៧.៧៥៩ក្បាល និងប៉េស្តទាចំនួន ១០៧.៨៨១ក្បាល។

## *៣.៤ ការងារត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ*

នៅក្នុងឆ្នាំ២០១១ ការត្រួតពិនិត្យសត្វ និងផលិតមានដើមកំណើតពីសត្វ ដែលបាននាំចេញ នាំចូល និងនាំឆ្លង

កាត់ព្រះរាជាណាចក្រកម្ពុជាមានដូចតទៅៈ ការនាំសត្វគោ-ក្របីក្នុងស្រុកចេញក្រៅប្រទេសចំនួន **៣.៤៨៨**ក្បាល ការនាំសត្វគោពីប្រទេសថៃឆ្លងកាត់សរុប ចំនួន **១៣២.៨២៥**ក្បាល នាំចូលគោពូជយកទឹកដោះ **១០០**ក្បាល ពពែ និងចៀមនាំចូល **១.១៧០**ក្បាល ការនាំជ្រូកចូលចំនួន**៣៩៤.៧៦០**ក្បាលៈ ជ្រូកសាច់ចំនួន**៣០៣.៤០៦**ក្បាល ជ្រូកពូជចំនួន**១៦.៧៧៨**ក្បាល (មេ បាពូជ និងកូន) ជ្រូកឆ្លងកាត់**១១.១០០**ក្បាល កូនមាន់ពូជនាំចូល **៣៤៤.៣៨៩**ក្បាល ពងមាន់**២.៥០០.០០**គ្រាប់ សាច់គោនាំចូល**២៥៤.៣៨៦**គ.ក្រ នាំស្វាចេញក្រៅប្រទេសចំនួន**៧.៦៦៦**ក្បាល ការនាំស្បែកគោ-ក្របីក្នុងស្រុកចេញក្រៅប្រទេសចំនួន **១.៤៧៦.១១៨**គក្រ ចំណីផ្អែនាំចេញ**៥៨៨.៦៧៥**គ.ក្រ និងសាច់មាន់ធ្វើចំណីផ្អែ**៣៦១.៤១៩**ក្បាល។

### *៣.៥ ភ្នាក់ងារសុខភាពសត្វភូមិ*

ភ្នាក់ងារសុខភាពសត្វភូមិសរុបមានចំនួន **១៤.៥៦៣នាក់** ក្នុងនោះបានធ្វើការបណ្តុះបណ្តាលថ្មីចំនួន **១.៧០៣**នាក់ ដើម្បីជំនួសភ្នាក់ងារសុខភាពសត្វភូមិ ដែលបានបោះបង់អាជីពរបស់ខ្លួន។

## ៤. ការងារសុខភាពសាធារណៈ

ការងារសុខភាពសាធារណៈ ក៏ជាផ្នែកមួយដ៏សំខាន់នៃវិស័យផលិតកម្មនិងបសុព្យាបាល ដែលចូលរួមក្នុងការទប់ស្កាត់ជំងឺឆ្លងពីសត្វទៅសត្វ និងពីសត្វទៅមនុស្ស តាមរយៈការគ្រប់គ្រង និងការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតសត្វនៅតាមសត្តឃាតដ្ឋាន និងកន្លែងតាំងលក់ ។

សត្តឃាតដ្ឋានទាំងប្រភេទ “ក” និង “ខ” ដែលមានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វមានចំនួនសរុប **៩៦**កន្លែង ក្នុងនោះ នៅរាជធានីភ្នំពេញ ១២កន្លែង ខេត្តកណ្តាល ១៨កន្លែង កំពង់ឆ្នាំង ១០កន្លែង បន្ទាយមានជ័យ ០៩កន្លែង បាត់ដំបង ១៣កន្លែង សៀមរាប ០៦កន្លែង ព្រះសីហនុ ០២កន្លែង ព្រៃវែង ០៣កន្លែង កំពង់ស្ពឺ ១០កន្លែង មណ្ឌលគិរី ០២កន្លែង រតនៈគិរី ០២កន្លែង ស្ទឹងត្រែង ០១កន្លែង កំពត ០៤កន្លែង ក្រចេះ ០២កន្លែង កោះកុង ០១កន្លែង និងកែប ០១កន្លែង។

ចំនួនសត្វពិឃាតនៅទទាំងប្រទេសឆ្នាំ២០១១ សរុបមាន÷ គោ ១១៥.៩៧៣ក្បាល ក្របី៣.៤៦៧ក្បាល និងជ្រូក ៧៧៤.៣៨៨ក្បាល។

## ៥. ការងារវិទ្យាស្ថានជាតិស្រាវស្រាវបសុព្យាបាល

នាពេលបច្ចុប្បន្ននេះ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអង្កេតតាមដានឃ្លាំមើល សិក្សាស្រាវជ្រាវ វិភាគរកមេរោគ និងធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងសម្រេចបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាក្នុងការឆ្លើយតបជាបន្ទាន់ នៅគ្រប់រូបភាព និងស្ថានភាពទាន់ហេតុការណ៍នានានៃជំងឺសត្វ ដែលបង្កឡើងដោយមេរោគគ្រប់ប្រភេទ។ លទ្ធផលដែលទទួលបានមានដូចខាងក្រោម÷

-ផ្នែកសេរ៉ូមសាស្ត្រ/វីរុសសាស្ត្រៈ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួនរួមមានៈ ជំងឺផ្តាសាយបក្សី ញ៉ូវកាស មីកូប្លាស្មា ប៉េស្តជ្រូក ប្រ៊ុយសែលឡូស សារទឹក អុតក្តាម សាល់ម៉ូណែលឡូស ឆ្កែឆ្កួត ត្រចៀកខៀវជ្រូក និងជំងឺស្វា (SRV STLV CHV) ។ល។

-ផ្នែកបាក់តេរីសាស្ត្រៈ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួនរួមមានៈ ជំងឺសារទឹក បួសខ្យល់ ឈាមខ្មៅ ស្តាហ្វីឡូកុកកូស ស្ត្រិបតូកុកកូស សាល់ម៉ូណែលឡូស អ៊ីកូលី ស៊ីយ៉ែលឡា និងវិភាគរកមេរោគក្នុងចំណីសត្វ និងជំងឺស្វា (Shigella Salmonella)

-ផ្នែកប៉ារ៉ាស៊ីតៈ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន រួមមាន : Floatation, Sedimentation, Fasciola egg Counting, Mc master egg Counting, Scraping examination និង Blood smear examination ។ល។

-ផ្នែកលោហិតសាស្ត្រៈ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួនរួមមានៈ អេម៉ូក្រាមប៉ារ៉ាស៊ីតក្នុងឈាម និងប្រូតេអ៊ីន

-ផ្នែកសរីរៈរោគសាស្ត្រៈ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន រួមមានៈ វះពិនិត្យប្រភេទសត្វតូច (ជ្រូក ចៀម ពពែ និងបក្សី) និងអ៊ីស្តូក្រាម (ការដាក់ពណ៌ និងពិនិត្យនៅលើកញ្ចក់ឡាម)

-ផ្នែកអេពីដេមីសាស្ត្រៈ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន រួមមានៈ តាមដានឃ្លាំមើលជំងឺសត្វ ស្រាវជ្រាវរកប្រភពជំងឺសត្វ អង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺ គ្រប់គ្រងទិន្នន័យជំងឺសត្វ វិភាគទិន្នន័យនិងបកស្រាយលទ្ធផលនៃការអង្កេតស្រាវជ្រាវ ឬ ការសិក្សាជាដើម។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលដោយសហការជាមួយមន្ត្រីពាក់ព័ន្ធ បានចុះស្រាវជ្រាវអង្កេតតាមដានជំងឺសត្វសំខាន់ៗនៅទូទាំងប្រទេសរួមមាន ជំងឺសារទឹក អុតក្តាម បូសខ្យល់ ញ្ញកាស បេស្តជ្រូក និងផ្តាសាយបក្សី។ល។ និងបានចុះយកវត្ថុវិភាគ ដើម្បីធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺ។ ចំនួនវត្ថុវិភាគ ដែលបានធ្វើវិភាគរកវត្តមានមេរោគបង្កជំងឺ មានចំនួនសរុប **១៣១៧២** វត្ថុវិភាគ ក្នុងនោះ ប៉ារ៉ាស៊ីតសាស្ត្រចំនួន **២.២៩៤** បាក់តេរីសាស្ត្រចំនួន**២.៣៧៧** លោហិតសាស្ត្រចំនួន **២.២៤២** ស៊េរ៉ូមសាស្ត្រចំនួន **៦.១៨២** និងសរីរៈរោគសាស្ត្រ **៧៧** វត្ថុវិភាគ។ តាមការវិភាគនេះ វិទ្យាស្ថានជាតិបានរកឃើញពពួកប៉ារ៉ាស៊ីត វីរុស (ផ្តាសាយបក្សី ញ្ញកាស អុតក្តាម ប៉េស្តជ្រូក ត្រចៀកខៀវ) និងបាក់តេរី (សារទឹក និងអ៊ិកូលី)។

ព័ត៌មានស្តីពីស្ថានភាពជំងឺសត្វនៅក្នុប្រទេសកម្ពុជា ត្រូវបានរាយការណ៍ជាប្រចាំទៅប្រទេសអាស៊ាននិងអង្គការសុខភាពសត្វពិភពលោកតាមរយៈប្រព័ន្ធព័ត៌មានពីរ÷ (១) ប្រព័ន្ធពត៌មានសុខភាពសត្វ នៅក្នុងតំបន់អាស៊ាន (ARAHIS) និង(២) ប្រពន្ធ័ពត៌មានសុខភាពសត្វពិភពលោក (WAHIS)។ តាមរយៈប្រព័ន្ធព័ត៌មានសុខភាពសត្វទាំងពីរនេះ អនុវិស័យទទួលបានមកវិញនូវព័ត៌មានស្តីពីស្ថានភាពជំងឺសត្វរបស់ប្រទេសក្នុងតំបន់ និងពីបណ្តាប្រទេសជាសមាជិកអង្គការសុខភាពសត្វពិភពលោក។ ដោយឡែក ចំពោះព័ត៌មានទាន់ហេតុការណ៍នៅក្នុងប្រទេស វិទ្យាស្ថានជាតិ បានទទួលទូរសព្ទ័ហៅចូលចំនួន **១៣៤** ដែលមកពីរាជធានីភ្នំពេញ កណ្តាល ក្រចេះ ព្រៃវែង កំពង់ចាម កំពង់ស្ពឺ តាកែវ ក្រចេះ សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពត កំពង់ឆ្នាំង កំពង់ធំ និងក្រសួងសុខាភិបាល ដែលរាយការណ៍ពីសត្វឈឺ ងាប់ សាកសួរពីរោគសញ្ញា និងវិធានការការពារជំងឺសត្វ។

ឆ្នាំ២០១១ ជំងឺផ្តាសាយបក្សីផ្ទុះឡើងលើបក្សីចំនួន៦ កន្លែង រួមមាន÷ភូមិព្រៃកដូង ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ភូមិក្បាលអូរ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម សួនសត្វភ្នំតាម៉ៅភូមិត្រពាំងសាប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ភូមិចករស្មី និងភូមិព្រៃកសំរោង ឃុំរហាត់ទឹក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ភូមិតាស្រី ឃុំតាផូ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ និងភូមិអូរពងមាន់ ឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល បានសហការជាមួយវិទ្យាស្ថានជាតិប៉ាស្ទ័រ (PIC) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) និងដៃគូរផ្សេងៗ បានសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយចំនួន ហើយលទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងនេះ បានចងក្រងជាឯកសារនិងមានដំកល់ទុក នៅក្នុងបណ្ណាល័យរបស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល។

កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ បានទទួលលទ្ធផលល្អ គួរឱ្យកត់សំគាល់ ដូចជា

-ការងារកសាងសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ÷ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វរួចហើយ។សេចក្តីព្រាងច្បាប់នេះ មានចំនួន **១៩ ជំពូក** និង**១៣៦ មាត្រា**។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដាក់ប្រជុំអចិន្ត្រៃយ៍

-ប្រកាសលេខ១៣៧ ប្រក.កសក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ ស្តីពីការបង្កើតវិទ្យាស្ថានជាតិស្រាវជ្រាវផលិតកម្មសត្វ

-សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រង និងការដាក់ឲ្យប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទៈ សេចក្តីព្រាងប្រកាសនេះ បានទទួលការអនុម័តពីអង្គប្រជុំអចិន្ត្រៃយ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ

-សេចក្តីព្រាងប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវបានកែសម្រួល និងសុំការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រកាសរួមស្ដីពីការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ត្រូវបានកែសម្រួល និងសុំការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សេចក្ដីព្រាងប្រកាសស្ដីពីការគ្រប់គ្រងកសិដ្ឋានៈ កំពុងរៀបចំ។

ការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍវិស័យផលិតកម្ម និងបសុព្យាបាល ជាមធ្យោបាយសម្រាប់ផ្ទេរចំណេះដឹងថ្មីៗតាមបែបវិទ្យាសាស្ត្រក្នុងការចិញ្ចឹមសត្វ វាគឺជាចលករដ៏សំខាន់ក្នុងការធ្វើឱ្យមានការផ្លាស់ប្ដូរឥរិយាបទរបស់កសិករក្នុងការចិញ្ចឹមសត្វតាមបែបយថាផលទៅជាការចិញ្ចឹមតាមបែបបច្ចេកទេស ការចិញ្ចឹមសត្វសម្រាប់តែតម្រូវការហូបចុកក្នុងគ្រួសារទៅជាការចិញ្ចឹមសម្រាប់ធ្វើពាណិជ្ជកម្ម។ ដោយយល់ឃើញពីសារៈសំខាន់នៃការងារផ្សព្វផ្សាយ និងបានយកចិត្តទុកដាក់ប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ តាមវិទ្យុ ទូរទស្ស ទស្សនាវដ្ដី បទសម្ភាសន៍ ឯកសារបច្ចេកទេស ការតាំងពិព័ណ៌ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការឃោសនាផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងទស្សនកិច្ចសិក្សា។ល។ ដោយផ្ដោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាអទិភាពដូចជាបញ្ហាជំងឺឆ្លង អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ បច្ចេកទេសចិញ្ចឹម ពូជនិងបច្ចេកទេសជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជតាមបែបសិប្បនិមិត្ត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុតពាក់ព័ន្ធនឹងវិស័យ ផលិតកម្ម និងបសុព្យាបាល ។ល។

គម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍ ÷ ដើម្បីធានាសុវត្ថិភាព និងការអភិវឌ្ឍន៍អនុវស័យផលិតកម្មសត្វ និងសុខភាពសត្វប្រកបដោយចីរភាព និងភាពរីកចម្រើន អនុវិស័យមានកិច្ចសហការយ៉ាងជិតស្និតជាមួយអង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ជាច្រើនផ្សេងទៀត និងផ្នែកឯកជននានា ដូចជា OIE, FAO, EU, JICA, WB, ACIAR, USAID, CP ដែលជាប្រភពធនធានយ៉ាងសំខាន់ ក្នុងការផ្ដល់នូវការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកា សម្រាប់ជួយដំណើរការនៃការអនុវត្តសកម្មភាពការងារក្នុងអនុវិស័យនេះ។

កិច្ចសហប្រតិបត្តិការទ្វេភាគី÷ មកទល់ពេលនេះ អនុវិស័យមានកិច្ចសហប្រតិបត្តិការទ្វេភាគីលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម សាធារណៈរដ្ឋប្រជាមានិតចិន ថៃឡង់ដ៍ ជប៉ុន និងកូរ៉េក្រោមកិច្ចព្រមព្រៀង MOU។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយភាគីវៀតណាម ជារៀងរាល់ឆ្នាំ ភាគីទាំងពីរមានការជួបប្រជុំគ្នា ដើម្បីជជែកពិភាក្សាគ្នាស្ដីពីកិច្ចសហការលើសុខភាពសត្វនៃប្រទេសទាំងពីរ ដោះស្រាយរាល់ប្រឈម ការផ្លាស់ប្ដូរបច្ចេកទេស ការផ្ដល់ជំនួយជាសម្ភារបរិក្ខារ វគ្គបណ្ដុះបណ្ដាល និងទស្សនកិច្ចសិក្សា។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយភាគីចិន ក្រោមកិច្ចព្រមព្រៀង MOU ភាគីទាំងពីរ បានបង្កើតស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា ចិន ដោយមានការគាំទ្រទាំងបច្ចេកទេស ថវិកា និងពូជជ្រូក ដល់ភាគីកម្ពុជា។ ក្រៅពីនេះ ភាគីចិនមានការបន្តផ្ដល់ជំនួយឡជីវឧស្ម័នចំនួនប្រមាណ ៣០០ឡ សម្រាប់ប្រជាកសិករកម្ពុជា នៅតាមជនបទ។ ចំពោះកិច្ចហសប្រតិបត្តិការទ្វេភាគីកម្ពុជា ជប៉ុន ភាគីទាំងពីរ បានផ្ដោតលើការចិញ្ចឹមគោយកទឹកដោះនៅតាមសហគមន៍អ្នកចិញ្ចឹមសត្វ ដោយភាគីជប៉ុន បានផ្ដល់ជំនួយផ្នែកបច្ចេកទេស ឧបករណ៍សម្ភារបរិក្ខារ និងថវិកាមួយចំនួន សម្រាប់គាំទ្រគម្រោងនេះ។ ចំពោះកិច្ចសហការជាមួយកូរ៉េ ភាគីទាំងពីរ បានសង្កត់លើការងារមន្ទីរពិសោធន៍ និងផ្នែកសុខភាពសត្វ ដោយផ្ដល់នូវសម្ភារបរិក្ខារ និងផ្លាស់ប្ដូរបទពិសោធន៍បច្ចេកទេសជំនាញតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចសិក្សានៃមន្ត្រីជំនាញរវាងប្រទេសទាំងពីរ។

ការផ្គត់ផ្គង់ និងបើកផ្ដល់ថ្នាំការពារ សម្ភារបរិក្ខារបសុពេទ្យ និងសម្ភារផ្សេងទៀត÷ នាឆ្នាំ២០១១នេះ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល បានធ្វើការផ្គត់ផ្គង់សម្ភារបរិក្ខារការិយាល័យ និងប្រេងជូនដល់ការិយាល័យជំនាញ សម្រាប់កិច្ចដំណើការការិយាល័យរបស់ខ្លួន និងចុះបំពេញការងារនៅតាមមូលដ្ឋាន។ ក្រៅពីនេះ បានធ្វើការបែងចែកថ្នាំការពារព្យាបាល និងសម្ភារបរិក្ខារបសុពេទ្យជូនការិយាល័យ ផ.បរាជធានី ខេត្ត និងស្ថានីយចិញ្ចឹមសត្វទាំងពីររួមមាន÷ វ៉ាក់សារទឹកចំនួន ១.៧១៩.០០០ កំរិត វ៉ាក់សាំងអុតក្ដាមចំនួន ៦៨.៦៥៥ កំរិត បូសខ្យល់ចំនួន ៣៦.៤១០កំរិត ស៊ីរាំង ១០ និង ២០ មមចំនួន ៤០៤ គ្រឿង ម្ជុលចំនួន ៨៤៩ ប្រអប់ ដង្កៀបចំនួន ៩៧ គ្រឿង ទែម៉ូម៉ែតចំនួន ១៦៥ គ្រឿង ថ្នាំព្យាបាល ០៨ មុខចំនួន ៩៩២ ដប ប្លីមេទីឡែនចំនួន ៥៩ គ.ក្រ អាកុលចំនួន ៨៦ លីត្រ សំឡីចំនួន ៨៣ គក្រ អាវអៀមចំនួន ១០០ អាវ កាបូបពេទ្យសត្វចំនួន ២២កាបូប និងធុងទឹកកកចំនួន ១០ គ្រឿង។

ការអង្កេតតាមដាននិងការវាយតម្លៃលើការងារពាក់ព័ន្ធ÷ អនុវិស័យនេះ បានចុះអនុវត្តត្រួតពិនិត្យ តាមដានលើការអនុវត្តគម្រោងតាមកម្មវិធី និងការប្រមូលចំណូល តាមរយៈរាជធានី ខេត្ត។ ក្រៅពីនេះ ជារៀងរាល់ឆ្នាំ តែងតែធ្វើការគ្រើនរំលឹក និងចេញសេចក្តីណែនាំស្តីពីការប្រមូលចំណូលនេះ ជាហូរហែផងដែរ។

**៩.៣.២-វាយតម្លៃនិងសន្និដ្ឋាន**

វិស័យផលិតកម្មនិងបសុព្យាបាល កាន់តែមានសារៈសំខាន់ក្នុងវិស័យសេដ្ឋកិច្ចជាតិ និងមានតួនាទីសំខាន់ក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងក្នុងតំបន់ ដូចជាការផ្តល់នូវកំលាំងអូសទាញផ្តល់សាច់ ស៊ុត វត្ថុធាតុដើម ចំណូលគ្រួសារ និងចំណូលសេដ្ឋកិច្ចជាតិ។

ឆ្នាំ២០១១ ផលិតកម្មគោ ក្របី មានការថយចុះចំនួន២.១៥ភាគរយ ធៀបនឹងស្ថិតិសត្វឆ្នាំ ២០១០។ ការថយចុះគោក្របី គឺបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន រួមមានកំណើននៃ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម ការបំរែបំរួលអាកាសធាតុ ការកើនឡើងនៃផ្ទៃដីកសិកម្ម និងកំណើននៃតម្រូវការសាច់ជាម្ហូបអាហារក្នុងស្រុកនិងទីផ្សារនាំចេញគោរស់ទៅប្រទេសជិតខាង។ ប៉ុន្តែផ្ទុយទៅវិញ ជ្រូកបានកើនឡើងចំនួន**២.០៤ភាគរយ** និងចំនួនសត្វស្លាបមានការកើនឡើងចំនួន **៥.៧៧ភាគរយ** បើធៀបនឹងស្ថិតិឆ្នាំ២០១០។ មូលហេតុនៃការកើនឡើងនេះ គឺបណ្តាលមកពីមានកំណើនតម្រូវការទីផ្សារខ្ពស់ ផ្តល់នូវប្រាក់ចំណូលមានវដ្តផលិតកម្មខ្លី និងការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ និងការចិញ្ចឹមជាលក្ខណៈគ្រួសារមានការរីកចំរើន ជាពិសេសសន្ទុះកើនឡើងនៃការវិនិយោគផ្នែកឯកជន។ ការវិនិយោគក្នុងការផលិតចំណីសត្វ មានការរីកចម្រើនគួរឲ្យកត់សំគាល់ ដោយសារមានការបង្កើតឡើងនូវរោងចក្រចំណីសត្វគ្រប់ប្រភេទពីសំណាក់វិនិយោគិនក្នុងស្រុក និងវិនិយោគិនពីបរទេស ដូចជាក្រុមហ៊ុន ស៊ី ភី ខេមបូឌា ក្រុមហ៊ុន អេស ស៊ី អេហ្វ ក្រុមហ៊ុនអេហ្វ្រិគម៉ាស្ទ័រ ក្រុមហ៊ុនម៉ុង ឬទ្ធី គ្រុប ក្រុមហ៊ុន ហ្វ្រីគនហ្វិត។ល។ សម្រាប់ផលិតចែកចាយក្នុងស្រុក និងក្រុមហ៊ុនជីហ្វែ ផលិតចំណីសត្វសម្រាប់នាំចេញទៅក្រៅប្រទេស ។

ការកែលំអរពូជសត្វ មានការបន្តសកម្មភាពរបស់ខ្លួនខ្លាំងក្លា ដោយបានបង្កាត់ និងផ្សព្វផ្សាយពូជសត្វ ដូចជានៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា-ចិន និងមជ្ឈមណ្ឌលបង្កាត់ពូជគោសាន់តា និងស៊ីមប្រា ដោយសិប្បនិម្មិតនៅខេត្តពោធិសាត់ មជ្ឈមណ្ឌលបង្កាត់ជ្រូកពូជ ដោយសិប្បនិម្មិតនៅខេត្តតាកែវ និងការបង្កាត់ពូជមាន់ KI នៅខេត្តសៀមរាប ហើយផ្សព្វផ្សាយពូជបន្តដល់ខេត្តផ្សេៗទៀត។

ដំណាំចំណីសត្វ កាន់តែមានការពង្រីកសកម្មភាពរបស់ខ្លួនខ្លាំងក្លាផងដែរ នៅគ្រប់រាជធានី ខេត្តទូទាំងប្រទេសដោយស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ជាកន្លែងផ្សព្វផ្សាយ ពូជស្មៅ និងចែកចាយពូជទៅតាមបណ្តាខេត្ត និងគម្រោង ACIAR គាំទ្រហិរញ្ញប្បទានដោយរដ្ឋាភិបាលអូស្រ្តាលី ជាពិសេសនៅមានស្រុកព្រៃឈរខេត្តកំពង់ចាម និងស្រុកត្រាំកក់ ខេត្តតាកែវ ប្រជាជនដាំស្មៅទទួលបានជោគជ័យ និងផ្សព្វផ្សាយដល់ខេត្តផ្សេងៗទៀត។ ក្រៅពីនេះ ក៏នៅមានការដាំស្មៅបង្ហាញនៅតាមខេត្ត ស្រុកមួយចំនួនទៀតផងដែរ។

ការគ្រប់គ្រងកាកសំណល់សត្វ តាមរយៈការសាងសង់ឡជីវឧស្ម័នសរុប ដែលបានសាងសង់ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១១ គឺមានចំនួន **១៤.៩៧២ឡ** ដែលក្នុងនោះសម្រាប់ឆ្នាំ ២០១១ ឡជីឧស្ម័នមានចំនួន **៤.៨២៦ឡ** ។ ថ្វីបើនៅឆ្នាំ ២០១១ នេះ បានទទួលរងនូវគ្រោះមហន្តរាយយ៉ាងធំធេង ដោយសារទឹកជំនន់ ប៉ុន្តែសភាពការណ៍ និងស្ថានភាពជំងឺសត្វ ពុំបានបង្កការឆ្លងរាលដាល និងប៉ះពាល់ខ្លាំងក្លាដល់ជីវិតមនុស្សសត្វអ្វីឡើយ។ នេះបញ្ជាក់ឲ្យឃើញថា នាយកដ្ឋានផ.ប និងការិយាល័យផ.ប បានរៀបចំផែនការគ្រប់គ្រងការត្រួតពិនិត្យបានគ្រប់ជ្រុងជ្រោយ និងចាត់វិធានបសុពេទ្យ ដើម្បីទប់ស្កាត់ជំងឺសត្វបានល្អប្រសើរ និងទាន់ពេលវេលា។

ការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុតនានាទាក់ទងវិស័យផលិតកម្ម និងបសុព្យាបាល បាននឹងកំពុងដំណើរការប្រកបដោផ្លែផ្កា ជាពិសេសបានបញ្ចប់សេចក្តីព្រៀងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។

សមិទ្ធផលទាំងអស់នេះ សម្រេចបានដោយសារមានការគាំទ្រពីរាជរដ្ឋាភិបាលពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសពីសំណាក់**ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការខិតខំប្រឹងប្រែងចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ព្រម

ទាំងមានការចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរកសិកម្មរាជធានី-ខេត្ត មន្ត្រីរាជការការិយាល័យផលិតកម្ម និងបសុព្យាបាល រាជធានី-ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ និងដោយមានកិច្ចសហប្រតិបត្តិការ និងជំនួយឧបត្ថម្ភពីបណ្តាប្រទេសនានាក្នុងតំបន់ ភ្នាក់ងារផ្តល់ជំនួយអង្គការជាតិ អង្គការអន្តរជាតិនានា និងផ្នែកឯកជនជាដើម ។

**៥.៣.៣-វិធានការនិងទិសដៅ**

នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មានទិសដៅច្បាស់លាស់ សម្រាប់អនុវត្តសកម្មភាពរបស់ខ្លួនក្នុងឆ្នាំ២០១២ ដូចខាងក្រោម ÷

-បន្តពង្រឹង និងគ្រប់គ្រងអង្គភាព សម្រាប់អនុវត្តការងារវិស័យប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់

-រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ផែនការសកម្មភាព កម្មវិធី និងគម្រោងសកម្មភាពអាទិភាពលើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ

- រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ លើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ

-ពង្រឹងសមត្ថភាពមន្ត្រីរាជការផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ ដើម្បីបង្កើនសមត្ថភាពបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព និងជម្រុញការអភិវឌ្ឍន៍លើផ្នែកចិញ្ចឹមសត្វគ្រប់ប្រភេទ ដោយផ្តោតលើការកែលំអរពូជសត្វ បង្កាត់ពូជសត្វ ចំណីសត្វ សុខភាពសត្វ បញ្ហាបច្ចេកវិជ្ជា និងបច្ចេកទេសជំនាញក្នុងការចិញ្ចឹម ការថែទាំសត្វ ការធ្វើអនាម័យ ដល់ប្រជាកសិករអ្នកចិញ្ចឹមសត្វ ក្នុងគោលដៅបង្កើនផលិតភាពសត្វទាំងបរិមាណ និងគុណភាព

-ជំរុញបន្ថែមទៀតលើការសាងសង់ឡជីវឧស្ម័ន ដោយធ្វើការកែទម្លាប់កសិករពីការចិញ្ចឹមសត្វការលែងមកការចិញ្ចឹមសត្វដាក់ទ្រុង

-ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ឬពីតំបន់មួយទៅតំបន់មួយទៀត តាមរយៈការអនុវត្តវិធានបសុពេទ្យរួមមានៈ ការចាក់ថ្នាំការពារសត្វ ការព្យាបាលសត្វ ការគ្រប់គ្រងជីវសុវត្ថិភាព ការធ្វើអនាម័យ និងការត្រួតពិនិត្យចលនាសត្វចេញ-ចូល និងឆ្លងកាត់ក្នុងព្រះរាជាណាចក្រកម្ពុជា។ល។

-ពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ តាមរយៈការបណ្តុះបណ្តាល និងការបំពាក់បំប៉នបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ និងខិតខំធ្វើយ៉ាងណាឱ្យមាននិរន្តរភាពភ្នាក់ងារសុខភាពសត្វភូមិ

-ពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ គឺសំដៅលើការជំរុញឱ្យអាជីវករយល់ដឹងពីការអនុវត្តច្បាប់ការត្រួតពិនិត្យអនាម័យសាច់ដើម្បីធានាសុខភាពសាធារណៈ

-ជំរុញនិងបង្កើនការងារស្រាវជ្រាវ អង្កេតតាមដាន ឃ្លាំមើលលើសុខភាពសត្វ និងជំងឺឆ្លងសត្វ ដើម្បីបង្កើនសមត្ថភាពត្រួតពិនិត្យ និងទប់ស្កាត់ការរាលដាលជំងឺឆ្លងសត្វ

-ជំរុញនិងបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងសុខភាពសត្វ តាមរយៈការបណ្តុះបណ្តាល អប់រំផ្សព្វផ្សាយ និងការធ្វើបង្ហាញ ចងក្រង បោះពុម្ពឯកសារបច្ចេកទេស ផលិតកម្ម និងបសុព្យាបាល

-ជំរុញការលើកទឹកចិត្តដល់ផ្នែកឯកជន និងអ្នកវិនិយោគលើវិស័យចិញ្ចឹមសត្វ និងសេវាកម្មសុខភាពសត្វ និងជួយស្វែងរកទីផ្សារសត្វឲ្យប្រជាកសិករចិញ្ចឹមសត្វ ដោយយកចិត្តទុកដាក់បំផុត

-ចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វ និងភ្នាក់ងារសុខភាពសត្វភូមិ

-បន្តនិងធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យផលិតកម្ម និងបសុព្យាបាល ជាមួយបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ពន្ធ័ និងកិច្ចសហការជាមួយផ្នែកឯកជន។

**៥.៤-ផលិតផលដំណាំកៅស៊ូ** (ឧបសម្ព័ន្ធទី១៣-១៥)

កៅស៊ូជាដំណាំកសិ-ឧស្សាហកម្មរយៈពេលវែង ដែលបានបំពេញតួនាទីយ៉ាងសំខាន់ជួយទ្រទ្រង់ដល់សង្គម-សេដ្ឋកិច្ចជាតិតាមរយៈនីហរ័ណកម្មផលិតផលជ័រ និងឈើកៅស៊ូ ដែលជាចំណែកមួយក្នុង យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ បង្កើតការងារនៅជនបទ បង្កើនប្រាក់ចំណូល និងទប់ស្កាត់ធ្វើចំណាក ស្រុករបស់កសិករ។ ម្យ៉ាងវិញទៀតដំណាំកៅស៊ូក៏បានចូលរួមការពារបរិស្ថាន ដោយបង្កើតជាគម្រប បៃតង រក្សាលំនឹងធម្មជាតិ និងការពារហូរច្រោះដី ។

នៅក្នុងឆ្នាំ ២០១១ បរិមាណផលិតផលកៅស៊ូធម្មជាតិនៅក្នុងពិភពលោក ផលិតបានមានចំនួន ១០.១០០.០០០ តោន គឺកើនឡើង ៦.៤% បើប្រៀបធៀបជាមួយផលិតផលឆ្នាំ ២០១០ ដែលមានចំនួន ៩.៤៩.000 តោន។ កត្តាដែលរួមចំណែកជំរុញឲ្យមានការកើនឡើងនូវផលិតផលនេះ ដោយសារ÷ (១) តម្លៃជ័រកៅស៊ូយ៉ាងខ្ពស់ខុសពីធម្មតា បានលើកទឹកចិត្តដល់កសិករ ធ្វើឲ្យការប្រមូល ផលជ័រពីដើមកៅស៊ូ ប្រកបដោយប្រសិទ្ធិភាពសេដ្ឋកិច្ច (២) ផ្ទៃដីដាំដុះឆ្នាំ ២០០៣ និង ២០០៥ ក្នុងបណ្តាប្រទេសផលិតកៅស៊ូ ធម្មជាតិបានមកដល់បក្កភាពបើកចៀរជ័របានហើយ (៣) កសិករបានប្រើប្រាស់មធ្យោបាយផ្សេងៗយ៉ាង ច្រើនក្នុងការប្រមូលផលដូចជា ការប្រើថ្នាំរំញោច ការបង្កើនចង្វាក់ ចៀរជ័រ និងដាក់ក្បាំងគម្របការពារ ទឹកភ្លៀង(៤) រក្សា និងការពន្យាពេលក្នុងការកាប់ដើមកៅស៊ូចាស់ៗ សម្រាប់ដាំឡើងវិញ ទុកធ្វើការ ប្រមូលផលសិន។

ជាមួយគ្នានេះ ការប្រើប្រាស់កៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ ២០១១ មានបរិមាណចំនួន ១០,៤៩ លានតោន គឺបានកើនឡើងចំនួន ៣% បើប្រៀបធៀបជាមួយការប្រើប្រាស់ឆ្នាំ ២០១០ ដែលមានចំនួន ១០,១៨ លានតោន ។ ដូច្នេះសន្និធិប្រចាំឆ្នាំនៅតាមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ គឺមានតិចតួចណាស់។ កត្តានេះ បានធ្វើឲ្យតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិ មានសន្ទុះកើនឡើងនាពេលបច្ចុប្បន្ន ក៏ដូចថ្ងៃអនាគតផងដែរ ។

**៥.៤.១-លទ្ធផល**

នៅឆ្នាំ ២០១១ ចំការកៅស៊ូកសិ-ឧស្សាហកម្មមានស្រាប់ និងចម្ការកៅស៊ូគ្រួសារ ព្រមទាំង វិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា បានដំណើរការអនុវត្តទៅតាមផែនការរៀងៗខ្លួន ក្នុងនោះ មុខព្រួញសំខាន់ៗរួមមានការធ្វើអាជីវកម្ម ផលិតកម្ម នីហ័រណកម្ម ការកាប់ដើមកៅស៊ូចាស់ៗ និងការដាំកៅស៊ូឡើងវិញ ដោយ ទទួលបានលទ្ធផលដូចខាងក្រោមនេះ ÷

៥.៣.១.១- **ការងារអាជីវកម្មផលិតកម្ម និងការអភិវឌ្ឍន៍ដំណាំកៅស៊ូ**

**ក- ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ**

- ផ្ទៃដីចៀរជ័រ ៤៥.១៦២ ហត ក្នុងនោះ ផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារ ចំនួន ២១.៩៨៦ ហត
- ផលិតផលកៅស៊ូស្ងួត ៥១.៣៣៩តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ២៥.២៨៤តោន
- ការនាំចេញកៅស៊ូស្ងួត ៤៤.៩៦៩តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ២៥.០០០តោន
- កូនកៅស៊ូកំពុងថែទាំសរុបចំនួន ១៦៧.៩៤១ហត ក្នុងនោះ កៅស៊ូកសិ-ឧស្សាហកម្មសរុបចំនួន ៩៣.៩៩៧ហត និងកៅស៊ូគ្រួសារចំនួន ៧៣.៩៤៤ហត។

**ក្រាហ្វិកបង្ហាញពីផលិតផល និងការនាំចេញកៅស៊ូឆ្នាំ ២០០៧-២០១១**




**ខ- ក្របខណ្ឌច្បាប់**

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី អគ្គនាយកដ្ឋានកៅស៊ូ បាននិងកំពុងរៀបចំសេចក្តី ព្រាងច្បាប់ស្តីពីកៅស៊ូ ដែលបានបញ្ចប់នាចុងឆ្នាំ ២០១១ នេះក្នុងកម្រិតក្រុមការងារតាក់តែងច្បាប់នៃអគ្គនាយកដ្ឋានកៅស៊ូ។

ជារួមអនុវិស័យកៅស៊ូបានកសាងយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជារយៈពេល១០ឆ្នាំ (២០១១-២០២០) មួយផងដែរ។

### គ- ការងារស្រង់ស្ថិតិកៅស៊ូគ្រួសារ

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី អគ្គនាយកដ្ឋានកៅស៊ូ បានចុះស្រង់ស្ថិតិចម្ការ កៅស៊ូ នៅខេត្តគោលដៅមួយចំនួន។ នៅឆ្នាំ២០១០ ក្រុមអនុវត្តគម្រោងរបស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ ដោយមានកិច្ចសហការល្អជាមួយមន្ទីរកសិកម្មខេត្ត និងរដ្ឋអំណាចមូលដ្ឋាន បានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារនៅក្នុងខេត្ត៤រួមមានៈ ខេត្តរតនគីរី ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តមណ្ឌលគីរី។ នៅឆ្នាំ២០១១ ក្រុមអនុវត្តគម្រោងបានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារក្នុងខេត្ត៥បន្ថែមទៀត គឺខេត្តបាត់ដំបង ប៉ៃលិន កំពង់ធំ ព្រះវិហារ និងខេត្តកំពង់ចាម។ ជាសរុប គម្រោងបានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារនៅក្នុងខេត្តចំនួន៩ ដែលមានផ្ទៃដីចំនួន៩៥.០០១ហត គឺស្មើនឹង១៨.៥០៨គ្រួសារ ។

### ឃ- ការចូលរួមសន្និសីទនិងសន្និបាតអន្តរជាតិ

ក្នុងឋានៈជាសមាជិកពេញសិទ្ធិ នៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ និងក្រុមប្រឹក្សា អភិវឌ្ឍន៍កៅស៊ូអន្តរជាតិ អគ្គនាយកដ្ឋានកៅស៊ូ តែងបានចូលរួមប្រជុំសន្និសីទនៃអង្គការទាំងពីរនេះ នៅប្រទេសសាធារណរដ្ឋប្រជាមានិតចិន និងប្រទេសថៃ ព្រមទាំងបានធ្វើការទំនាក់ទំនងជាប្រចាំជាក្រុមសិក្សាកៅស៊ូ អន្តរជាតិផងដែរ។

### ង- ការអភិវឌ្ឍដំណាំកៅស៊ូជាលក្ខណៈគ្រួសារ

ចាប់តាំងពីឆ្នាំពី២០០៣មក ការដាំដុះកៅស៊ូលក្ខណៈគ្រួសារ-ឯកជន ដែលប្រើប្រាស់ទុនខ្លួនឯងផ្ទាល់មានការរីកលូតលាស់យ៉ាងខ្លាំងក្លាទាំងតំបន់ប្រពៃណី និងតំបន់មិនប្រពៃណីដែលពីមុនជាតំបន់មិនធ្លាប់ដាំកៅស៊ូក៏ដោយ។ គិតមកត្រឹមឆ្នាំ២០១១នេះ ផ្ទៃដីចំការកៅស៊ូគ្រួសារនៅទូទាំងប្រទេស សរុបមានចំនួន ៩៥.៩៣០ហត។

### ៥.៤.២-វាយតម្លៃនិងសន្និដ្ឋាន

ក្រោយពីរាជរដ្ឋាភិបាលបានធ្វើអវិនិយោគចំការកៅស៊ូរដ្ឋទាំង៧ និងបានកែសម្រួលអគ្គនាយកដ្ឋានកៅស៊ូ ជាអង្គភាពរដ្ឋបាលថ្នាក់កណ្តាល តែពុំមានរចនាសម្ព័ន្ធដល់ថ្នាក់មូលដ្ឋាន និងដោយថវិកា មធ្យោបាយធ្វើដំណើរ មធ្យោបាយបម្រើការងារ និងធនធានមនុស្សនៅមានកម្រិត។ ដើម្បីគ្រប់គ្រងវិស័យកៅស៊ូ ធានាទទួលបានប្រសិទ្ធិភាពខ្ពស់ និងប្រកបដោយចីរភាព គឺត្រូវមានការ គាំទ្រពីថ្នាក់ដឹកនាំ និងមានការចូលរួមទទួលខុសត្រូវរបស់មន្ត្រីជំនាញ ស្ថាប័នពាក់ព័ន្ធ និងពីគ្រប់ប្រតិបត្តករកៅស៊ូទាំងអស់ផងដែរ។ សំណូមពរដូចខាងក្រោម÷

-ជួយអន្តរាគមន៍ទៅនាយកដ្ឋាននីតិកម្មកសិកម្ម ដើម្បីជួយពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូឱ្យបានឆាប់ និងជួយអន្តរាគមន៍ដល់ក្រុមហ៊ុនទទួលដីសម្បទានសេដ្ឋកិច្ចលើដំណាំកៅស៊ូទាំងអស់ ឱ្យសហការជាមួយមន្ត្រីជំនាញក្នុងការផ្តល់ទិន្នន័យ និងការអភិវឌ្ឍក្នុងការធ្វើផែនការគោលនយោបាយវិស័យកៅស៊ូ

-ផ្តល់សេចក្តីចម្លងឯកសារ ទាក់ទងដល់ការងារវិនិយោគដំណាំកៅស៊ូលើដីសម្បទានសេដ្ឋកិច្ចទាំងអស់ ដើម្បីជាមូលដ្ឋានក្នុងការតាមដាន និងវាយតម្លៃឱ្យបានត្រឹមត្រូវ

-អនុញ្ញាតឱ្យមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានកៅស៊ូ បានចូលរួមផ្តល់យោបល់បច្ចេកទេស លើការផ្តល់ដីសម្បទានសេដ្ឋកិច្ច ឬសង្គមកិច្ចសម្រាប់ដំណាំកៅស៊ូ និងរុក្ខសម្ភារកៅស៊ូដែលនាំចូល

-ជួយជំរុញការចេញប្រកាសសមាសភាពការិយាល័យបច្ចេកទេសដំណាំកៅស៊ូនៅតាមបណ្តាខេត្ត ដើម្បីងាយស្រួលក្នុងការចាត់ចែងអនុវត្តការងារបន្ត

-ផ្តល់ការយល់ព្រមលើគម្រោងថវិកាតាមកម្មវិធីនិងផ្តល់សម្ភារការិយាល័យ ប្រេងឥន្ធនៈ និងថវិកា ជាពិសេសមធ្យោបាយធ្វើដំណើរឲ្យបានសមស្រប និងទាន់ពេលវេលា ដើម្បីចាត់ចែងការងារឱ្យមានលទ្ធភាព និងចុះបំពេញភារកិច្ចឲ្យបានសម្រេចតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជាឆ្នាំ២០១១-២០២០

-អនុញ្ញាតឱ្យមន្ត្រីជំនាញកៅស៊ូ បានចូលរួមផ្តល់យោបល់បច្ចេកទេស លើការបង្កើតរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូ

-ផ្តល់ទីតាំងដីសម្រាប់បង្កើតស្ថានីយ ឬអនុស្ថានីយពិសោធន៍តាមតំបន់ ដែលមានសក្តានុពលដល់ការអភិវឌ្ឍដំណាំកៅស៊ូ

-ជួយអន្តរាគមន៍ទៅស្ថាប័នពាក់ព័ន្ធ ក្នុងការទប់ស្កាត់ការនាំចេញផលិតផលជ័រកៅស៊ូដែលគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាព

-ជួយអន្តរាគមន៍ទៅក្រុមហ៊ុនកៅស៊ូ (អតីតចម្ការកៅស៊ូរដ្ឋ) និងចម្ការកៅស៊ូឯកជន ដែលមានរោងចក្រកែច្នៃកៅស៊ូ CSR ឲ្យមកបំពេញបែបបទតាមបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធដល់ការចេញវិញ្ញាបនបត្របញ្ជាក់គុណភាព

-ជួយអន្តរាគមន៍ទៅក្រុមហ៊ុនកៅស៊ូ (អតីតចម្ការកៅស៊ូរដ្ឋ) ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រ ក្នុងការបង្កើតនិងដាក់ឲ្យដំណើរការឡើងវិញនូវមន្ទីរពិសោធន៍យថាប្រភេទកៅស៊ូ ដើម្បីត្រួតពិនិត្យខ្សែចង្វាក់ផលិតកម្មនិងទទួលសិទ្ធិចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

**៩.៤.៣-វិធានការនិងទិសដៅ**

ដើម្បីសម្រេចបាននូវទិសដៅនាឆ្នាំ២០១២ខាងមុខ សមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គម សំដៅកាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពផលិតផលកៅស៊ូធានាក្នុងការប្រកួតប្រជែងនៅលើទីផ្សារនោះ អនុវិស័យកៅស៊ូមានទិសដៅអនុវត្តការងារបន្តដូចខាងក្រោម ÷

-ការពង្រីកសេវាណែនាំបច្ចេកទេសបន្តដល់កសិករ និងការរៀបចំយន្តការធ្វើវិញ្ញាបនកម្មច្បារពូជនិងបណ្តុះបណ្តាលអ្នកធ្វើច្បារពូជ

-ការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងសំណើសុំដីសម្រាប់ធ្វើអនុស្ថានីយនៅតាមបណ្តាខេត្ត

-ការតាមដាន ការអនុវត្តផែនការកម្មវិធីវិនិយោគនៅលើដីសម្បទានសេដ្ឋកិច្ច-សង្គមកិច្ច និងវាយតម្លៃ

-ការចុះស្រង់ស្ថិតិកៅស៊ូគ្រួសារ ក្នុងគម្រោងថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១២ នៅក្នុងខេត្តគោលដៅចំនួន១១ ខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ ស្វាយរៀង ព្រៃវែង កំពត ព្រះសីហនុ កោះកុង ពោធិសាត់ និងបន្ទាយមានជ័យ

-ការចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ-ឯកជន នៅក្នុងខេត្តគោលដៅចំនួន ៤ គឺរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី និងក្រចេះ

-ការពង្រឹងសមាគមកៅស៊ូគ្រួសារទាំង៤ នៅក្នុងខេត្តកំពង់ចាម

-ទំនាក់ទំនងជាមួយដៃគូរអភិវឌ្ឍន៍ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា វិទ្យាសាស្ត្រ

-ការសិក្សាស្រាវជ្រាវព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ និងអំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុង និងក្រៅប្រទេស

-សំណើសុំមន្ត្រីមុខងារសាធារណៈ ដើម្បីបំពេញតាមជំនាញឯកទេសគ្រប់អង្គភាពក្រោមឱវាទ

-ការពង្រឹងសមត្ថភាពធ្វើតេស្តនិងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូចំនួន២០-៣០កែសប៉ាឡែតក្នុងមួយថ្ងៃ

-ការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ និងផ្តល់លិខិតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (CSR) ដល់ម្ចាស់រោងចក្រកែច្នៃកៅស៊ូ CSR ដើម្បីលើកកម្ពស់គុណភាពកៅស៊ូកម្ពុជា

-ការចុះបញ្ជិកាទទួលស្គាល់ជាផ្លូវការ និងផ្តល់លិខិតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (CSR) ដល់មន្ទីរពិសោធន៍មូលដ្ឋាន ដើម្បីទទួលសិទ្ធិចេញវិញ្ញាបនបត្រញ្ជាក់គុណភាពកៅស៊ូ

-ការពង្រឹងគុណភាពកៅស៊ូនិងការពារសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (CSR) តាមរយៈការត្រួតពិនិត្យរោងចក្រកែច្នៃកៅស៊ូ និងមន្ទីរពិសោធន៍មូលដ្ឋានយ៉ាងតិច ២ ដងក្នុងមួយឆ្នាំ

-ការពង្រឹងសមត្ថភាពការធ្វើតេស្តនិងចេញវិញ្ញាបនត្របញ្ជាក់គុណភាពកៅស៊ូ និងការពារសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទ (CSR) តាមរយៈការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក៤ដងក្នុងមួយឆ្នាំ

-ពង្រឹងសមត្ថភាពកាធ្វើតេស្តនិងការទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ ចំពោះកៅស៊ូ TSRs ដោយ

សមាគមកៅស៊ូអន្តរជាតិ (IRA) តាមរយៈការចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍ (Round Robin Crosscheck) ២ដង ក្នុងមួយឆ្នាំ

-ចូលរួមនិងសហការជាមួយដៃគូ ឬបណ្តាញមន្ទីរពិសោធន៍ថាប្រភេទកៅស៊ូអន្តរជាតិ និងគំរោងការអភិវឌ្ឍន៍គុណភាពកៅស៊ូ

-តាមដាននិងស្រង់ទិន្នន័យគ្រប់ចំការពិសោធន៍និងរៀបចំបង្កើតចំការពិសោធន៍ដីលើកូនកៅស៊ូធ្វើអាជីវកម្ម និងពិធីសារពិសោធន៍ និងបង្កើតចំការពិសោធន៍ដីលើកូន កៅស៊ូដាំលើដីខ្សត់ជីជាតិ

-ចូលរួមជាមួយអ្នកបច្ចេកទេសមកពីសាកលវិទ្យាល័យ Nagoya, សាកលវិទ្យាល័យ Kyushu ប្រទេសជប៉ុន និងសាកវិទ្យាល័យ Hawaii ដើម្បីតាមដានទិន្នន័យនិងថែទាំឧបករណ៍ Sapflow, Flux Tower

-បំពាក់ឧបករណ៍ឧតុនិយមដល់ស្ថានីយឧតុនិយមថ្មី ក្រោមកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Kyushu ប្រទេសជប៉ុន និងចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលផ្សេងៗ និងរៀបចំប្រធានបទសំនួរចម្លើយ ដើម្បីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍

-ជំរុញចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន ដើម្បីធ្វើជាស្នូលក្នុងការជួយទ្រទ្រង់ដល់ចម្ការកៅស៊ូគ្រួសារ

-ចុះពិនិត្យស្ថានភាពបណ្តាចម្ការកៅស៊ូកសិឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារនៅទូទាំងប្រទេស ដើម្បីប្រមូលទិន្នន័យ និងវាយតម្លៃ និងបន្តចុះស្រង់ទិន្នន័យរោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូដែលមានស្រាប់និងបង្កើតថ្មី។

## ៥.៥- លទ្ធផលការងារុក្ខកម្ម

### ៥.៥.១-លទ្ធផល

### ៥.៥.១.១- ការប្រមូលចំណូលពីវិស័យព្រៃឈើ

បានប្រមូលចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៦០.៨៦៦.៤៩១.៨៦៦៛០០ ក្នុងនោះ ចំណូលពីថ្លៃសួយ សារផល អនុផលព្រៃឈើចំនួន ៣៣.០៧១.២១១.១៨៤៛០០ ចំណូលពីការផាកពិន័យនិងលក់ដោយដេញថ្លៃឈើដែលបានមកពីការបង្រ្កាបបទល្មើសចំនួន២៧.៦៥០.៧៦៤.១៧២៛០០ ចំណូលថ្លៃសួយសារសត្វគ្រប់ប្រភេទចំនួន ១២០.១៦៤.០១០៛០០ និងចំណូលពីការជួលអចលនទ្រព្យចំនួន២៤.៣៩២.៥០០៛០០។

### ៥.៥.១.២- ការគ្រប់គ្រងទីជម្រាល និងវាយតម្លៃគម្របព្រៃឈើ

-បានរៀបចំបោះពុម្ពសៀវភៅមេប្រមូលគម្របព្រៃឈើឆ្នាំ២០១០ ជាភាសាជាតិនិងភាសាអង់គ្លេសចំនួន៣.០០០ក្បាល

-វាយតម្លៃការប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និង២០១០ នៅទូទាំងប្រទេស និងវាយតម្លៃការប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និង២០១០ ក្នុងព្រៃសហគមន៍ចំនួន៨៨ ក្នុងខេត្តចំនួន ១៦

-ចូលរួមប្រជុំពិភាក្សាជាមួយដៃគូសហប្រតិបត្តិការជប៉ុនស្តីពី គម្រោងប្រព័ន្ធតាមដានការប្រែប្រួលគម្របព្រៃឈើ REL / MRV តាមគោលការណ៍ Cambodia REDD Road Map

-ផលិតផែនទីគម្របព្រៃឈើឆ្នាំ២០១០ ដើម្បីប្រើប្រាស់ក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន១៤ ផ្នែករដ្ឋបាលព្រៃឈើចំនួន៨ និងសង្កាត់រដ្ឋបាលព្រៃឈើចំនួន១៣

-សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវព្រៃឈើប្រទេសជប៉ុនជាលទ្ធផលយើង ទទួលបានទូវរូបភាពផ្កាយរណប Spot 4 និង Spot 5 ឆ្នាំ២០០៣និង២០០៦ និង រូបភាពផ្កាយរណប Landsat ឆ្នាំ ១៩៩២ ១៩៩៨ ២០០១ និង ២០០២សម្រាប់ប្រើប្រាស់ក្នុងវិស័យព្រៃឈើនិងគម្រោង REDD នៅកម្ពុជា។

### ៥.៥.១.៣- ការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេស

-បានបញ្ជូនសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍បានចំនួន២៥កន្លែង មានផ្ទៃដីសរុប២៦.៤៥៨ហត ដូចជាខេត្តកំពង់ធំចំនួន១២កន្លែង កោះកុងចំនួន០១កន្លែង មណ្ឌលគីរីចំនួន០៤កន្លែង កំពង់ស្ពឺចំនួន០២កន្លែង ព្រះសីហនុចំនួន០១កន្លែង ស្ទឹងត្រែងចំនួន០២កន្លែង កំពង់ចាមចំនួន០១កន្លែង និងក្រចេះចំនួន០២កន្លែង

-កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ បានចំនួន៣៦កន្លែងនៅក្នុងខេត្តមួយចំនួនដូចជា រតនគិរីចំនួន១៤កន្លែង ក្រចេះចំនួន០៦កន្លែង កំពតចំនួន០៩កន្លែង កែបចំនួន០១កន្លែង និងតាកែវចំនួន០៦កន្លែង

-បានសម្របសម្រួលចុះពិនិត្យនិងកំណត់តំបន់សក្តានុពលសម្រាប់បង្កើតសហគមន៍ព្រៃឈើបានចំនួន១៧៥កន្លែង លើផ្ទៃដីសរុប ១៣៩.៦៤៥,៣៤ហត ក្នុងខេត្តចំនួន២០

-បានចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើចំនួន១០២កន្លែង លើផ្ទៃដី៤០.៣៩៥ហត ក្នុងខេត្តចំនួន១៣

-បានបោះពុម្ពសៀវភៅស្ថិតិសហគមន៍ព្រៃឈើកម្ពុជាឆ្នាំ២០១១ ចំនួន១០.០០០ក្បាល

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ បានចំនួន៥១កន្លែង លើផ្ទៃដី១៣.៨៩៥ហត ក្នុងខេត្តពោធិសាត់ចំនួន៣៨កន្លែង ខេត្តឧត្តរមានជ័យចំនួន០២កន្លែង ខេត្តកំពតចំនួន០១កន្លែង និងខេត្តតាកែវចំនួន០៦កន្លែង។

-បានរៀបចំនូវ÷ ១) សេចក្តីព្រាងច្បាប់ស្តីពីសត្វព្រៃ និងជីវចម្រុះ និង ២) សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតតំបន់ព្រៃបៃតងជានិច្ចក្នុងទីទំនាបក្នុងខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ និងស្ទឹងត្រែង

-បានប្រជុំឆ្លងផ្ទៃក្នុងរដ្ឋបាលព្រៃឈើនូវ÷ ១)សេចក្តីព្រាងអនុក្រឹត្យស្តីពីសំលៀកបំពាក់ ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ២)សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ៣) សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ និង៤)ការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ

-បានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវ÷ ១)សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិនិងសត្វព្រៃ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និង២)សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់និយតកម្មប្រភពទឹក ការពារដីជម្រាល និងអភិរក្សជីវចម្រុះតំបន់ជួរភ្នំក្រវាញភាគខាងត្បូងខេត្តកោះកុង។

## ៥.៥.១.៤- ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

-បានបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃនិងបទល្មើសកាប់រានដីព្រៃទន្ទ្រានដីព្រៃសរុបចំនួន១.៧៩០ករណី កើនឡើងចំនួន២៨៣ករណីធៀបទៅនឹងឆ្នាំ២០១០ ដែលមានចំនួន១.៥០៧ករណី

-វត្ថុតាងបទល្មើសព្រៃឈើ សត្វព្រៃបានចាប់ឃាត់ និងដកហូតរួមមាន÷ ឈើហ៊ុបមូល-ជ្រុងចម្រុះប្រភេទ ៨១៤ម$^{៣}$៧៣៦ ឈើអារ២.៧០៣ម$^{៣}$៧០៤ ឈើគ្រាក់គ្រញូង៥១៩ម$^{៣}$០៥៩ និង៨៥.៩២៦គក្រនិង១៧ដុំ គល់បេង០១គល់ ពកបេង៤៩០គក្រ គល់គ្រញូង០ម$^{៣}$៤២៧ កូនឈើ១.៨១៥ដើម ខ្លឹមច័ន្ទនិក្រស្នា៩៣,១០គក្រ ប្រេងម្រះព្រៅភ្នំ៤២៨គក្រ ជន្លង់ម្រេច៩៩៥ដើម បង្គោលគ្រាក់៦៥ដើម បង្គោលស្នាច់៦៣០ដើម សសរ៤៧ដើម ទ្វារតម្លើងរួច០២វង់ អុស ១៥២,៧៥ស្ទែរ ធ្យូង២០.២២១គក្រ ឫស្សី១.២០០ដើម ម្សៅវល្លិ៍រមៀត៥៥គក្រ ជ័ររ៉ុង២១៨គក្រ កំទេចកិប៩,២០គក្រ សត្វព្រៃចម្រុះប្រភេទ៤.១៧៣ក្បាលនិង១.១២៨,១០គ.ក្រ សំណាកសត្វព្រៃ០៧ប្រភេទនិង២២,៧គក្រ រថយន្ត ១.១២២គ្រឿង ត្រាក់ទ័រ០៤គ្រឿង អេស្កាវ៉ាទ័រ០៣គ្រឿង ប៊ុលឌូហ្សែរ០១គ្រឿង គោយន្ត៣០គ្រឿង ម៉ូតូ១៨៥គ្រឿង ទូក-កាណូត៣១គ្រឿង ឡូរី០៧គ្រឿង រ៉ឺម៉កសណ្តោង៦៧គ្រឿង រទេះគោ៣៣គ្រឿង រទេះកង់ឡាន៣៨គ្រឿង រណារយន្ត៦៣គ្រឿងគោ៤៦ក្បាល ម៉ាស៊ីនផ្សេងៗ ៨១គ្រឿង និងសម្ភារៈផ្សេងៗទៀត ព្រមទាំងដីព្រៃ៩៧ហ.ត៥០៩

-បានចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិសរុបចំនួន១១១.៨៣៧ហតនិងដកហូតដីព្រៃ ដែលបានកាប់រានសរុបចំនួន១៥.៨២៧ហ.ត ក្នុងនោះចេញដីកាដកហូតចំនួន១៣ដីកាស្មើនឹង១២.០៧៥ហត និងដកហូតពុំមានដីកាចំនួន៣.៧៥២ហត

-ចុះស្រង់ស្ថិតិរណារយន្តចំនួន២៧៣គ្រឿងនិងដកហូតរណារយន្តបានចំនួន៣៣៧គ្រឿង។

### ៥.៥.១.៥- ការងារដាំដើមឈើនិងស្តារព្រៃឈើ

### ក- ការងារដាំដើមឈើនិងបណ្តុះកូនឈើ

*១-រដ្ឋបាលព្រៃឈើ*

ការដាំដើមឈើនិងបណ្តុះកូនឈើនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន០៧របស់អនុវិស័យរដ្ឋបាលព្រៃឈើទទួលបានលទ្ធផលរួមមាន÷ បណ្តុះកូនឈើបានចំនួន១.៩០៥.០០០ដើមគ្រប់ផែនការ និងធ្វើការដាំដុះនៅតាមទីតាំងនីមួយៗបានចំនួន៥៣០ហ.តលើផែនការចំនួន៨០០ហ.ត។

*២-ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច*

មានក្រុមហ៊ុនចំនួន៣៦ធ្វើសកម្មភាពការងារឈូសឆាយដីព្រៃបណ្តុះកូនឈើ និងធ្វើការដាំដំណាំកៅស៊ូនិងដាំឈើព្រៃ រួមមានលទ្ធផលដូចជា÷ ឈូសឆាយដីព្រៃបានចំនួន១៦.៥១១ហ.ត បណ្តុះកូនឈើបានចំនួន២២.២១១.១៥០ដើម និងការដាំកូនឈើនិងកូនកៅស៊ូបានចំនួន៣.៥៩០ហ.ត។

*៣-ផ្នែកឯកជនខ្នាតតូច/គ្រួសារនិងអង្គការក្រៅរដ្ឋាភិបាល* ក្នុងនោះ បណ្តុះកូនឈើបានចំនួន៦២៩.០០០ដើម និងដាំដុះបានចំនួន៣១៤,៥០ហ.ត។

*៤- ពិធីបុណ្យរុក្ខទិវា ៩ កក្កដា ២០១១*

### ៤.១- ការប្រារព្ធពិធីបុណ្យរុក្ខទិវាថ្នាក់ជាតិ

ពិធីបុណ្យរុក្ខទិវាថ្នាក់ជាតិ ៩កក្កដា២០១១ត្រូវបានប្រារព្ធធ្វើនៅតំបន់ភ្នំសែនហាន ភូមិអូរម្នាក់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត លើផ្ទៃដីទំហំ២៥ហត ក្រោមព្រះរាជាធិបតីភាពរបស់ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

### ៤.២- ការប្រារព្ធពិធីបុណ្យរុក្ខទិវាថ្នាក់ខេត្ត រាជធានី

ការប្រារព្ធពិធីបុណ្យរុក្ខទិវាថ្នាក់ខេត្ត រាជធានី ត្រូវបានធ្វើនៅខេត្ត រាជធានី ដោយមានការអញ្ជើញចូលរួមពីគណៈអភិបាលជាអធិបតីភាពដោយបានដាំដុះដូចជា លក្ខណៈជាចម្ការចំនួន៤២,៥ហតស្មើនឹង៨៥.៧៨៦ដើម និងលក្ខណៈរាយប៉ាយចំនួន៨៥.៧៨៦ដើម។

### ខ.ការបណ្តុះកូនឈើសម្រាប់ចែកចាយ

*១-រដ្ឋបាលព្រៃឈើ* ក្នុងនោះ បណ្តុះកូនឈើចំនួន៣.៤១៨.៦៧២ដើម ចែកចាយកូនឈើបានចំនួន២.២៤៦.១៩៧ដើម និងកូនឈើសល់ស្តុកក្នុងថ្នាលចំនួន ១.៣១៨.៧១៧ដើម។

*២-វិស័យឯកជន* ក្នុងនោះ កូនឈើបណ្តុះលក់ចែកចាយ៣.៨៨៤.០០០ដើម។

### គ- ការអភិវឌ្ឍធនធានសេនេទិចព្រៃឈើ

*១-កូននៃប្រភេទឈើ* Acacia Hybrid ក្នុងនោះ បានដាំសាកល្បង និងដាំកូនស្តុក(Clonestock)នៅទីតាំងថ្នាលបណ្តុះចំនួន៣កន្លែង និងបានដាំជាចម្ការប្រមាណ៣.៥០០ហត នៅតាមបណ្តាស្ថានីយរដ្ឋនិងមានចំនួន៧.០០០ហត នៅតាមចម្ការក្រុមហ៊ុនឯកជន ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តកំពត ព្រះសីហនុ កោះកុង និងកំពង់ធំ។

*២-កូននៃប្រភេទឈើ* Eucalypt K7 ក្នុងនោះ ដាំសាកល្បងនៅស្ថានីយមានការសហការជាមួយក្រុមហ៊ុនOJIចំនួនដាំជាចម្ការប្រមាណ១.០០០ហតជាលក្ខណៈគ្រួសារក្នុងខេត្តបន្ទាយមានជ័យនិងបាត់ដំបង និងការរកឃើញថាដំណុះពូជឈើនេះមានកើតជំងឺរួញស្លឹកនៅខេត្តបន្ទាយមានជ័យ។

*៣-ចម្ការពូជឈើ* ដូចជាចម្ការពូជឈើចំនួន១៤ប្រភេទស្ថិតនៅទីតាំងទាំង១១ខណ្ឌរដ្ឋបាលព្រៃឈើ មានផ្ទៃដីចំនួន ១.៨៤៤,៨០ហ.ត។

### ឃ- ការរៀបចំសួនអាពាហ៍ពិពាហ៍នៅតាមសង្កាត់រដ្ឋបាលព្រៃឈើ:

o សង្កាត់រដ្ឋបាលព្រៃឈើបានរៀបចំសួនអាពាហ៍ពិពាហ៍បានចំនួន២៨ទីតាំងស្មើនឹងផ្ទៃដីទំហំ ៣៤៩,៣៤៥ហត

០ សង្កាត់រដ្ឋបាលព្រៃឈើថ្មគ្រែបានទទួលគូសាមីភរិយាទើបរៀបការរួចចំនួន០៣គូ ។

## ៥.៥.១.៦-ការងារសហប្រតិបត្តិការអន្តរជាតិ

-ការងារឥណទានកាបូនព្រៃឈើនិងការប្រែប្រួលអាកាសធាតុ មន្ត្រីរដ្ឋបាលព្រៃឈើខេត្តសៀមរាបចំនួន១០រូប បានទទួលនូវចំណេះដឹងស្តីពីវិធីសាស្ត្រធ្វើសារពើភ័ណ្ឌព្រៃឈើសម្រាប់គម្រោងឥណទានកាបូន

-រៀបចំផែនការសកម្មភាពរយៈពេល៣០ឆ្នាំរបស់គម្រោងឥណទានកាបោនព្រៃឈើនៅខេត្តឧត្តរមានជ័យនិងបាន រៀបចំលិខិតឆ្លើយតបជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីករណីសំណើសុំជួយត្រួតពិនិត្យចុងក្រោយលើខ្លឹម សារសេចក្តីព្រាងឯកសារកម្មវិធីការបន្សាំ នឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គឆ្នាំ២០១១-២០១៥

-គ្រួសារសហគមន៍គម្រូ ១០ គ្រួសារត្រូវបានជ្រើសរើសសម្រាប់ធ្វើឡជីវឧស្ម័ន

-បានរៀបចំសេចក្តីព្រាងលិខិតស្តីពីការផ្តល់ព័ត៌មានអំពីមន្ត្រីទំនាក់ទំនងថ្នាក់ជាតិផ្នែកព្រៃឈើ (National Focal Point for Forest) សម្រាប់សម្របសម្រួលការងារជាមួយ United Nation Forum on Forests (UNFF)

-បច្ចុប្បន្នរដ្ឋបាលព្រៃឈើមានកម្មវិធីនិងគម្រោង REDD ក្នុងនោះ គម្រោងនិងកម្មវិធីចំនួន០៦ បាននឹងកំពុង ដំណើរការ ហើយគម្រោងចំនួន០១ នឹងចាប់ដំណើរការក្នុងពេលឆាប់ៗនេះ ថវិកាបឋមសម្រាប់ដំណើរការកម្មវិធីនិង គម្រោង REDD នេះ មានចំនួនប្រហែល២០លានដុល្លារ។

## ៥.៥.១.៧-ការអភិវឌ្ឍឧស្សាហកម្ម និងពាណិជ្ជកម្មឈើ

### ក- ការងារឧស្សាហកម្មឈើ

*១-ការពិនិត្យឯកសារ* ដូចជាបានពិនិត្យនិងផ្តល់មតិលើសំណើសុំបង្កើត សុំពន្យារសុពលភាព រោងម៉ាស៊ីន រោងសិប្ប កម្មអារ-កែច្នៃឈើ និងឃ្លាំង ស្តុកផលិតផលឈើគ្រប់ប្រភេទបានចំនួន៣៦សំណើ។

*២-ការងាររៀបចំលិខិតអនុញ្ញាត*

-បានរៀបចំលិខិតផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំការពិនិត្យសម្រេចលើការអនុញ្ញាតបង្កើត ឬពន្យារសុពលភាពរោងចក្រ រោងសិប្បកម្មអារ-កែច្នៃឈើ ការស្នើសុំបន្ថែមគ្រឿងចក្រជូនអតិថិជនបានចំនួន ៣០សំណើ

-រៀបចំលិខិតទៅខណ្ឌរដ្ឋបាលព្រៃឈើកណ្តាលស្តីពី ការចាត់វិធានការផ្អាកសកម្មភាពរោងម៉ាស៊ីន អារ កែច្នៃឈើ របស់ក្រុមហ៊ុន លាង ស៊្រុនហេង អ៊ិនវេសមេន

-រៀបចំលិខិតឆ្លើយតបទៅខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ស្តីពីការស្នើសុំការឯកភាពក្នុងការផ្តល់ និងបន្តសុពល ភាពលិខិតអនុញ្ញាតរោងសិប្បកម្មកែច្នៃប្រភេទតូច និងរោងសន្និធិ

-រៀបចំលិខិតទៅខណ្ឌរដ្ឋបាលព្រៃឈើ រតនគីរី ស្តីពីការដាក់វិធានការពង្រឹងការងារគ្រប់គ្រងដី សម្បទាន សេដ្ឋកិច្ច និងរោងម៉ាស៊ីនអារ-កែច្នៃឈើ

-រៀបចំលិខិតជម្រាបទៅខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ ស្តីពីការកំណត់អត្រាកែច្នៃឈើហ៊ុបមូល ទៅជាវីនៀរ រួច ផលិតជាក្តារបន្ទះរបស់ក្រុមហ៊ុនសុខ សម្រេច ខេត្តក្រចេះ

-រៀបចំលិខិតជម្រាបទៅខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង ស្តីពីការកំណត់អត្រាកែច្នៃកួនឈើអង្កត់ផ្ចិតទំហំ១៥-៣០ សង់ទីម៉ែត្រ ទៅជាឈើអាររបស់រោងម៉ាស៊ីនអារកែច្នៃឈើក្រុមហ៊ុន G G World ខេត្តស្ទឹងត្រែង

-រៀបចំលិខិតជម្រាបទៅខណ្ឌរដ្ឋបាលព្រៃឈើកណ្តាល កំពង់ចាម ស្ទឹងត្រែង កំពង់ឆ្នាំង និងមណ្ឌលគីរី លើករណី សំណើសុំគំរូលិខិតអនុញ្ញាតបង្កើតរោងសិប្បកម្មកែច្នៃនិងរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ។

*៣-ការងារផ្តល់លិខិតអនុញ្ញាតបង្កើតរោងចក្រ រោងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើ*

រដ្ឋបាលព្រៃឈើបានផ្តល់លិខិតស្នើសុំប្រកាសអនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រុម ហ៊ុនបង្កើតរោងម៉ាស៊ីនអារ-កែច្នៃឈើបានចំនួន ១៤លិខិត ។

*៤-ការងារផ្តល់លិខិតអនុញ្ញាតពន្យារសុពលភាពរោងចក្រនិងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ*

បានទទួលប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឲ្យក្រុមហ៊ុនពន្យារសុពលភាពរោង

ម៉ាស៊ីនអារ-កែច្នៃឈើបានចំនួន១០។

*៥-ការងារផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញ*

បានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផលអនុផលព្រៃឈើនាំចេញចំនួន២៣៦ច្បាប់។

**១- ការងារពាណិជ្ជកម្មនាំចេញនាំចូល**

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំនួន១៦ក្រុមហ៊ុន (MDS, Angkor Plywood, Green Island, Angkor Sugar, DTC, Pheapimex, Great Field Cambodia, Decowood, North-East, Wood Innovation, Grand Land, Di Duk Cambodia, Khen Chan Norak Cambidia, Tong Min, Green Rich Group, Hillco Corporation) មានបរិមាណឈើកែច្នៃសរុបចំនួន២៧.៧៩៩ម$^{3}$៥៧៩៤ និងឈើចំការ (ចំណិតឈើ) ចំនួន ៦៨.០០០ តោន

-បានពិនិត្យនិងផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលចំនួន០២ក្រុមហ៊ុន មានបរិមាណឈើមូលនិងឈើអារចំនួន៣០០ម$^{3}$

-បានពន្យាសុពលភាពគោលការណ៍អាជ្ញាប័ណ្ណនាំចេញ ចំនួន០៤ក្រុមហ៊ុន (Brightway Furniture, Angkor Sugar, Green Island, Phu Mady)

-បានពិនិត្យនិងផ្តល់ការអនុញ្ញាតពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំនួន០១ក្រុមហ៊ុន (GG World) មានបរិមាណឈើកែច្នៃចំនួន ២៥០ម$^{3}$០០៤

-បានពិនិត្យនិងផ្តល់ការអនុញ្ញាតលើសំណើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចេញចំនួន១៣ ក្រុមហ៊ុន (ឌីខ្វូដ,គង់ ហេង តាណេ:,អ៊ុយ សុខុម អ៊ឹមផត អិចផត,ងួន តុងហួរ, ឆៃ ជីងហ៊ាង, ខេន ច័ន្ទណូរ៉ក្សរស៊ីសាមគ្គី២០០០,ភូរីជាម៉ា,មាន សុខជាត្រេឌីង, HSIANG CHENG PEANICH, ផេន តាអេង ខេមបូឌា, ថាញ់ ហ៉ារ ខេម៉ាហ្គ្រា អ៊ិនវេសមេនគ្រុប)

-បានពិនិត្យនិងផ្តល់ការអនុញ្ញាតលើសំណើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចូលចំនួន០១ក្រុមហ៊ុន(ហ្គាម៉ារ៉ាយហាបហ្វា)។

**៥.៥.១.៨- ការអភិរក្សសត្វព្រៃ**

-ទីជម្រករបស់សត្វព្រៃត្រូវបានការពារនិងអភិរក្សបានល្អ (បង្កើតសម្រាប់អភិរក្សដោយព្រះរាជាណាចក្រកម្ពុជា)

-សព្វព្រៃគ្រប់ប្រភេទត្រូវបានអភិរក្សបានគង់វង់ និងកម្មវិធីអភិឌ្ឍនផ្សារភ្ជាប់នឹងការអភិរក្សត្រូវបានអនុវត្តនៅតាមបណ្តាភូមិក្នុងនិងជុំវិញតំបន់ព្រៃការពារនិងតំបន់អភិរក្ស (តាមរយៈបង្កើតជាតំបន់អេកូទេសចរណ៍)

-ប្រជាពលរដ្ឋយល់ដឹងច្រើនលើកិច្ចការអភិរក្សសត្វព្រៃនិងព្រៃឈើតាមរយៈការអប់រំ ផ្សព្វផ្សាយផ្សេងៗ

-បង្កើតការយកចិត្តទុកដាក់លើការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជា សហគមន៍អភិវឌ្ឍនិងម្ចាស់ជំនួយនានាលើពិភពលោកទាំងថវិកានិងបច្ចេកទេស

-ក្រុមការងារអនុវត្តគម្រោងបានធ្វើការកត់ត្រានូវក្រុមប្រភេទសត្វស្លាបជិតផុតពូជប្រភេទកម្រនិងប្រភេទមានដោយបង្គួរ

-ទិន្នន័យសា្វក្តាមមេ-បាពូជ និងកូនសា្វក្តាមនៅតាមកសិដ្ឋាននីមួយៗមានចំនួនសរុប៨៥.៩៤៦ក្បាល និងបាននាំចេញសា្វជិទង់ចំនួន៦.១៥២ក្បាល។

**៥.៥.១.៩- ការស្រាវជ្រាវនិងបណ្តុះបណ្តាល**

-*ការងារបណ្តុះបណ្តាល* ដូចជាបានផ្តល់វគ្គបណ្តុះបណ្តាលចំនួន២៥វគ្គ ដោយមានសិក្ខាកាមចូលរួមចំនួន ៨៣០នាក់ ។

*-ការសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍*

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ បាននិងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការចំនួន ១៦ និងបានបើកវគ្គបណ្តុះបណ្តាលចំនួន២២វគ្គ មានអ្នកចូលរួមចំនួន៧៧៥នាក់ ក្នុងនោះមានមន្ត្រីរដ្ឋបាលព្រៃឈើចូលរួមចំនួន ២៤១នាក់ សមាជិកសហគមន៍និងប្រជាជនចំនួន៥៣៤នាក់។

*-សមភាគីសហការជាមួយដៃគូអភិវឌ្ឍន៍នានា*

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ បាននិងកំពុងចូលរួមជាសមភាគីជាមួយដៃគូអភិវឌ្ឍន៍នានាចំនួន០៣។

*-ការងារស្រាវជ្រាវដោយប្រើប្រាស់ថវិកាជាតិ*

ការងារស្រាវជ្រាវគម្រោងស្តារព្រៃឈើឡើងវិញ ក្រោយអាជីវកម្មនៅតំបន់បាក់ស្នាសម្រាប់ឆ្នាំ២០១១ លទ្ធផលសម្រេចបាន÷

-ប្រមូលទិញគ្រាប់ពូជបេងនិងបណ្តុះកូនឈើបានចំនួន៥.០០០ដើម និងដាំកូនឈើបានចំនួន ០៣ហត

-ផ្តល់វគ្គបណ្តុះបណ្តាលស្តីពី រុក្ខវប្បកម្មដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងសហគមន៍ព្រៃឈើចំនួន ០១វគ្គ ដែលមានអ្នកចូលរួមចំនួន ៧៥នាក់ (ស្ត្រី០៥នាក់) នៅទីរួមខេត្តសៀមរាប។

*-ការងារលើកគម្រោងបណ្តុះបណ្តាលនិងស្រាវជ្រាវ*

វិទ្យាស្ថានស្រាវជ្រាវ បាននិងកំពុងរៀបចំសំណើគម្រោងចំនួន០៤ ក្នុងនោះ÷ កំពុងរៀបចំគម្រោងសំណើការសិក្សាស្រាវជ្រាវបច្ចេកទេសស្តារព្រៃរេចរឹល គម្រោងរៀបចំចងក្រងឯកសារនិងព្រឹត្តប័ត្រស្រាវជ្រាវព្រៃឈើកម្ពុជា រៀបចំគម្រោងសំណើសាងសង់អគារស្រាវជ្រាវព្រៃឈើនិងរៀបចំគម្រោងសំណើប្រមូល និងសំណាកឈើសម្រាប់ដាក់តាំងបង្ហាញ។

### ៥.៥.១.១០- ការសង្គ្រោះសត្វព្រៃ

ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម ថែរក្សាសត្វព្រៃគ្រប់ប្រភេទ កសាងហេដ្ឋារចនាសម្ព័ន្ធឧទ្យានសួនសត្វ ដើម្បីសង្គ្រោះ និងអភិរក្សសត្វព្រៃក្រៅតំបន់។

### ៥.៥.១.១១- ការងាយស្រួល

-មានការចូលរួម និងគាំទ្រយ៉ាងសកម្មពីកងយោធពលខេមរភូមិន្ទនគរបាល អាជ្ញាធរដែនដី អង្គភាពពាក់ព័ន្ធ អង្គការអន្តរជាតិ ដែលជាដៃគូអភិវឌ្ឍន៍ និងពីប្រជាពលរដ្ឋគ្រប់ទិសទី

-មានច្បាប់ស្តីពីព្រៃឈើ គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីព្រៃឈើច្បាស់លាស់ និងបទបញ្ញាជាច្រើនរបស់រាជរដ្ឋាភិបាលសម្រាប់ជាមូលដ្ឋានពង្រឹងការគ្រប់គ្រង និងអនុវត្តច្បាប់ក្នុងវិស័យព្រៃឈើទូទាំងប្រទេស

-មានការផ្តួចផ្តើមចង្អុលបង្ហាញ និងគាំទ្រយ៉ាងពេញទំហឹងពីថ្នាក់ដឹកនាំជាតិគ្រប់ស្ថាប័ន ជាពិសេសពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់ និងឯកឧត្តមរដ្ឋមន្ត្រីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មន្ត្រីរដ្ឋបាលព្រៃឈើភាគច្រើនមានសមត្ថភាពជំនាញ ស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួនឲ្យសម្រេចជោគជ័យ

-មានក្រុមការងារបច្ចេកទេសស្តីពី កំណែទម្រង់ព្រៃឈើនិងបរិស្ថានជាយន្តការសម្រាប់សម្របសម្រួលផ្តល់ជំនួយសហប្រតិបត្តិការ និងជាវេទិកាពិគ្រោះយោបល់របស់គ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ ផ្នែករដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល...។

### ៥.៥.១.១២- ការលំបាកនិងភាពប្រឈម

ទន្ទឹមនឹងវឌ្ឍនភាពដែលរដ្ឋបាលព្រៃឈើសម្រេចបាន ក៏នៅមានការលំបាក និងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ÷

-ខ្វះខាតធនធានមនុស្ស និងការលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលព្រៃឈើឲ្យទៅបំរើការងារនៅតំបន់ដាច់ស្រយាល

-ខ្វះខាតថវិកា សម្ភារៈនិងមធ្យោបាយសម្រាប់ដំណើរការវិស័យព្រៃឈើឲ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា

-មន្ត្រីរាជការមួយចំនួនខ្វះសមត្ថភាព មិនទាន់មានវិន័យនិងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញភារកិច្ចនៅឡើយ

-ជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការប្រមូលផលឈើ ដឹកជញ្ជូន និងកាប់រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិក្រោមរូបភាពផ្សេងៗ

-កិច្ចសហការនិងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាននិងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការត្រួតពិនិត្យបង្ក្រាបបទល្មើសព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនដីព្រៃឈើតែងជួបប្រទះការលំបាក យឺតយ៉ាវ និងមានវិវាទ ជាមួយជនល្មើស ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួចទៀតផង

-ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងជិតតំបន់ព្រៃឈើនៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុកនៅមានការធូររលុងពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

**៩.៩.២. វាយតម្លៃនិងសន្និដ្ឋាន**

-សុំអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល ដើម្បីផ្តល់នូវកញ្ចប់ថវិកា សម្ភារៈ មធ្យោបាយសម្រាប់ដំណើរការការងារនៅតាមខណ្ឌ-ផ្នែករដ្ឋបាលព្រៃឈើតាមអណត្តិការងារនិងធនធានមនុស្សបន្ថែមឲ្យបានសមស្របតាមតម្រូវការចាំបាច់នៃការងាររបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន

-សុំអន្តរាគមន៍ទៅក្រសួងមហាផ្ទៃឲ្យណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ពង្រឹងការគ្រប់គ្រងស្ថិតិប្រជាជន និងការសាងសង់លំនៅដ្ឋានអនាធិបតេយ្យរបស់ជនចំណាកស្រុកនៅក្នុងតំបន់ព្រៃឈើ។

**៩.៩.៣. វិធានការនិងទិសដៅ**

ដើម្បីសម្រេចគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ឆ្នាំ២០១២នេះ រដ្ឋបាលព្រៃឈើបានលើកវិធានការ ងផែនការសកម្មភាពសម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ដូចខាងក្រោម÷

-ពង្រឹងសាមគ្គីភាព ក្រមសីលធម៌ វិន័យ ការចាត់តាំង ភាពស្មោះត្រង់ និងឆន្ទៈក្នុងការបំពេញការងារ

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង១.០០០ គីឡូម៉ែត្រ

-បន្តរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ នៅគ្រប់កំរិតនៃរដ្ឋបាលព្រៃឈើដោយធ្វើការសិក្សាសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ និងរៀបចំព្រៃគុបដេញថ្លៃសម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើក្នុងស្រុក រួមទាំងព្រៃគុបក្នុងតំបន់អាងទំនប់វារីអគ្គិសនីនានាដូចជា វារីអគ្គិសនី ឬស្សីជ្រុំ សេសាន ២ តាតៃ...។ល។

-បន្តពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ញា លិខិតបទដ្ឋាន ពាក់ព័ន្ធនិងវិស័យព្រៃឈើ (ច្បាប់ស្តីពីព្រៃឈើ បទបញ្ជាលេខ០១-០២សជណ និងអនុសាសន៍**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាត ទប់ស្កាត់ និងបង្ក្រាបបទល្មើសឱ្យបានទាន់ពេលវេលា

-គ្រប់គ្រងនិងពង្រឹងការងារប្រមូលចំណូលពីព្រៃឈើនៅតាមបណ្តាដីសម្បទានសេដ្ឋកិច្ច ដែលត្រូវឈូសឆាយសំអាតដីព្រៃ ដោយប្រមូលផលអនុផលព្រៃឈើ ដែលឈូសឆាយ បានមកបង់ថ្លៃសួយសារ បុព្វលាភ រួចកែច្នៃ ប្រើប្រាស់ឲ្យអស់លទ្ធភាព

-ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះវត្ថុតាងបទល្មើសព្រៃឈើ ដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ ពិន័យអន្តរការណ៍រួច

-បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធីដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-ផ្តល់ការលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋាន រួមទាំងវិស័យឯកជនចូលរួមដាំដុះដើមឈើបង្កើតជាចម្ការព្រៃដាំ ដែលផ្តល់ផលប្រយោជន៍ច្រើនយ៉ាង ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់នៅក្នុងតំបន់ព្រៃរេចរឹល តាមរយៈបង្កើនការដាំដុះព្រៃឈើ ការចែកកូនឈើជូនប្រជាពលរដ្ឋសម្រាប់ដាំតាមគេហដ្ឋាន តាមទីសាធារណៈ វត្តអារាម រៀបចំប្រារព្ធបុណ្យរុក្ខទិវា៩កក្កដាទូទាំងប្រទេស រៀបចំបង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ ថ្នាលបណ្តុះកូនឈើ សួនដាំឈើអនុស្សាវរីយ៍ សួនអាពាហ៍ពិពាហ៍ និង បន្តអភិវឌ្ឍគុណភាពសេណេទិចពូជ និង បច្ចេកទេសដាំដុះឱ្យកាន់តែមានប្រសិទ្ធភាព...។ល។

-បង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃការពារតាមរយៈការរៀបចំផែនការគ្រប់គ្រង និងធ្វើការអភិវឌ្ឍសេវាកម្មបរិស្ថាន រួមទាំងទេសចរណ៍ធម្មជាតិ និងឥណទានកាបូនព្រៃឈើ ដើម្បីបង្កើតការងារនិងប្រភពចំណូលបន្ថែមជូនប្រជាជន និង

ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោកក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនឡើងកំដៅនៃភពផែនដី

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាលពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធតាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងរៀបចំវគ្គបណ្តុះបណ្តាលចាំបាច់នានា រួមទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រព្រៃឈើ (GIS) និងបំពាក់សម្ភារដល់អង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋាន ឱ្យមានលទ្ធភាពផលិតផែនទីប្រើប្រាស់ដោយខ្លួនឯង

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយព្រៃឈើ

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាពស្រាវជ្រាវ បង្កើតតំបន់ឬស្ថានីយស្រាវជ្រាវព្រៃឈើ-សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍ដែលមានស្រាប់ និងស្វែងរកដៃគូថ្មីៗទៀតស្របតាមតម្រូវការអភិវឌ្ឍរបស់ សង្គមជាតិ និងអន្តរជាតិ

-បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្ម ដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃ និងថែរក្សា ការពារចម្ការព្រៃពូជ និងប្រមូលពូជឈើ

-បន្តកសាងហេដ្ឋារចនាសម្ព័ន្ធ ការិយាល័យ កន្លែងស្នាក់អាស្រ័យ រៀបចំធនធានមនុស្ស និងលិខិតបទដ្ឋានក្រោមច្បាប់ដើម្បីអនុវត្តរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើថ្មីតាមអនុក្រឹត្យលេខ១៨៨អនក្រ ចុះថ្ងៃទី១៤-១១-២០០៨ និងធ្វើបច្ចុប្បន្នភាពសេចក្តីព្រាងអនុក្រឹត្យស្តីពី សម្លៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ច និង ភាគីពាក់ព័ន្ធនានា ជាពិសេស អ្នកសារព័ត៌មាន និងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងតំបន់ និងជាមួយប្រទេសជិតខាងក៏នឹងត្រូវបានយកចិត្តទុកដាក់ពង្រឹងពង្រីកជាប្រចាំតាមរយៈកិច្ចសហការទ្វេភាគី និង ការចូលរួមអនុវត្តកម្មវិធីតំបន់ ឬអន្តរជាតិដូចជា FLEG, ASEAN-WEN ...។ល។

## ៥.៦- ការងារជលផល (ឧបសម្ព័ន្ធទី១៦-១៨)

### ៥.៦.១- លទ្ធផល

#### ៥.៦.១.១. អាជីវកម្មនេសាទ

**ក- អាជីវកម្មនេសាទទឹកសាប:** ការធ្វើអាជីវកម្មនេសាទទឹកសាបសរុបបានចំនួន ៤៤៥.០០០តោនក្នុងនោះ÷

-អាជីវកម្មឡូត៍នេសាទ-នេសាទសិប្បកម្មរដូវនេសាទឆ្នាំ២០១០-២០១១ អនុវត្តបាន១៣០.០០០តោន ស្មើ១០០% នៃផែនការ១៣០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៥.០០០តោន

-នេសាទគ្រួសារក្នុងដែននេសាទឆ្នាំ២០១១ អនុវត្តបាន១៨០.០០០តោន ស្មើ១០៥,៨៨%នៃផែនការ ១៧០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង២០.០០០តោន

-នេសាទគ្រួសារក្នុងវាលស្រែឆ្នាំ២០១១ អនុវត្តបាន១៣៥.០០០តោន ស្មើ៩០%នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១៥.០០០តោន។

**ខ- អាជីវកម្មនេសាទសមុទ្រ**

ការធ្វើអាជីវកម្មនេសាទសមុទ្រឆ្នាំ២០១១ អនុវត្តបាន៩១.០០០តោន ស្មើ១១៣,៧៥% នៃផែនការ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៦.០០០តោន។

#### ៥.៦.១.២. ការអភិវឌ្ឍន៍វារីវប្បកម្ម

-ការចិញ្ចឹមត្រី បង្កាឆ្នាំ២០១១ អនុវត្តបាន៧២.០០០តោន ស្មើ១២០% នៃផែនការ៦០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១២.០០០តោន ឬកំណើន២០% ប្រចាំឆ្នាំ

-ការចិញ្ចឹមក្របើឆ្នាំ២០១១ អនុវត្តបាន២៣០.០០០ក្បាល ស្មើ១១៥% នៃផែនការ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៥៣.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជឆ្នាំ២០១១ អនុវត្តបាន១៣០.០០០.០០០ក្បាល ស្មើ១៦២,៥០% នៃផែនការ៨០.០០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១៩.៥៦០.០០០ក្បាល។

**៥.៦.១.៣. ការកែច្នៃផលនេសាទ**

-ការកែច្នៃផលនេសាទទឹកសាបឆ្នាំ២០១១ អនុវត្តបាន៤៥.០០០តោន ស្មើ៧៥% នៃផែនការ ៦០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ២.០០០តោន។

-ការកែច្នៃផលនេសាទសមុទ្រឆ្នាំ២០១១ អនុវត្តបាន៦.១០០តោន ស្មើ១០១,៦៧% នៃផែនការ៦.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៥០០តោន។

-ការផលិតទឹកត្រីឆ្នាំ២០១១ អនុវត្តបាន៤០.០០០.០០០លីត្រ ស្មើ៨០% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៥.០០០.០០០លីត្រ។

**៥.៦.១.៤. ការនាំចេញផលនេសាទ**

-ការនាំចេញផលនេសាទស្រស់និងកែច្នៃគ្រប់ប្រភេទឆ្នាំ២០១១ អនុវត្តបាន២៦.០០០តោន ស្មើ៧៤,២៩% នៃផែនការ៣៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៩.០០០តោន។

**៥.៦.១.៥. ការងារអភិវឌ្ឍន៍សហគមន៍នេសាទ**

-នៅក្នុងឆ្នាំ២០១១នេះ ពុំមានការរៀបចំសហគមន៍នេសាទបន្ថែមថ្មីទេ។ ក្នុងចំណោមសហគមន៍នេសាទចំនួន ៤៦៩ ដែលបានបង្កើតឡើងហើយ មានសហគមន៍នេសាទចំនួន២៦៧ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ រនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទនិងសហគមន៍នេសាទចំនួន៥៧ ត្រូវបានរៀបចំសំណុំឯកសាររួចរាល់ ហើយ ហើយបានផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទដើម្បីស្នើសុំចុះបញ្ជីបន្ថែមទៀត។

-លើសពីនេះ ការរៀបចំបំពេញបែបបទឯកសារសហគមន៍នេសាទ ដែលមិនទាន់បានចុះបញ្ជីនៅតែបន្តជំរុញអនុវត្តជាបន្តបន្ទាប់ ក្នុងនោះសកម្មភាពពាក់ព័ន្ធរួមមានការបោះឆ្នោតជ្រើសរើសគណៈកម្មការដែលផុតអាណត្តិ ការសម្របសម្រួលរៀបចំនិងកែសម្រួលលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ការសម្របសម្រួលចុះឈ្មោះ សមាជិកសហគមន៍នេសាទការរៀបចំធ្វើផែនទីសហគមន៍នេសាទនិងរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាដើម។ ជាក់ស្តែងសហគមន៍នេសាទចំនួន០៥ (ខេត្តកំពតចំនួន០២និងខេត្តកែបចំនួន០៣)ត្រូវបានរៀបចំបោះឆ្នោត រៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងឡើងវិញនិងបញ្ចប់ការធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឧបត្ថម្ភដោយ Danida។

**៥.៦.១.៦. ការងារអភិរក្សជលផល**

សកម្មភាពអភិរក្សជលផលត្រូវបានរៀបចំទាំងនៅទឹកសាបនិងសមុទ្ររួមមាន÷

-ការអភិរក្សផ្កាថ្ម ស្មៅសមុទ្របានចំនួន៣.៣០០ហត តាមតំបន់ឆ្នេនិងកោះនានា ដាំព្រៃលិចទឹក និងព្រៃកោងកាងចំនួន១៤០ហត

-ការអភិរក្សផ្សោតនៅខេត្តក្រចេះនិងខេត្តស្ទឹងត្រែងដែលធ្វើឱ្យចំនួនផ្សោតស្លាប់ថយចុះពី៩ក្បាលក្នុងឆ្នាំ២០០៦ មកនៅត្រឹម២ក្បាលក្នុងឆ្នាំ២០១១

-បានធ្វើការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃដែនជម្រកជលផល ប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់និងមុខងារនៃកន្លែងអភិរក្សចំនួន១០លើក ដោយមានអ្នកពាក់ព័ន្ធចូលរួមចំនួន ២.៥០០នាក់

-លែងកូនត្រីនិងកូនបង្គងបានចំនួន៤.៦00.000 លានកូន និងត្រីមេពូជ១៣៧តោន។

**៥.៦.១.៧. ការការពារប្រភពធនធានជលផល**

បទល្មើសនេសាទប្រចាំឆ្នាំ២០១១ អនុវត្តបាន៤.៤៦៩ករណី ក្នុងនោះ (ទឹកសាប៤.៣២៧ករណី សមុទ្រ១៤២

ករណី) ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៣.៦១០ករណី (ទឹកសាបថយចុះ៧០០ករណីនិងសមុទ្រថយចុះ២.៨៨០ករណី) ក្នុងនោះរួមមាន÷

| | |
|---|---|
| -ពិន័យ | ២៩៨ករណី |
| -បញ្ជូនទៅតុលាការ | ១៤០ករណី |
| -បំផ្លាញវត្ថុតាងនិងរឹមអូសបណ្តោះអាសន្នចំនួន | ៤.០៣១ករណី |
| -ជាប់ពន្ធនាគារ | ១១៤នាក់ |
| -ទឹកប្រាក់ពិន័យ និងលក់វត្ថុតាងចំនួន | ១៦២.៧៨៤.៥៥០រៀល |

### ៥.៦.១.៨. ការងារផ្សព្វផ្សាយ

-ចំពោះការផលិតឯកសារនិងការផ្សព្វផ្សាយ បានខិតខំជំរុញដល់រាជធានី ខេត្តទូទាំងប្រទេសឱ្យដាក់តាំងរូបភាព ប៉ាណូរូបភាពផ្សព្វផ្សាយនៅតាមទីប្រជុំជននានា អំពីការហាមឃាត់ប្រព្រឹត្តបទល្មើសនេសាទនិងការចូលរួមអភិរក្សប្រភព ធនធានជលផល។ ក្រៅពីនេះ មានបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដល់សមាជិកសហគមន៍ អាជ្ញាធរដែនដី និងកងកំលាំងប្រដាប់អាវុធលើប្រធានបទការអភិវឌ្ឍន៍វារីវប្បកម្ម ការអភិរក្សធនធានជលផល ការកែច្នៃ ក្រោយការប្រមូលផល។ល។

-ដោយឡែកការផ្សព្វផ្សាយច្បាប់ស្តីពីជលផលអនុវត្តបានចំនួន៨០វគ្គ ដែលមានអ្នកពាក់ពន្ធ័ចូលរួមចំនួន២.១៣៥នាក់ ក្នុងនោះស្រីចំនួន១.១៣០នាក់។

### ៥.៦.១.៩. ការងារស្រាវជ្រាវនិងសហប្រតិបត្តិការអន្តរជាតិ

ការងារស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា DANIDA, JICA, MRC, ADB, FAO, AIDA, CI, World Fish Center ជាដើម។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។

### ៥.៦.១.១០. ការងាររៀបចំច្បាប់និងលិខិតបទដ្ឋាននានា

ក្នុងឆ្នាំ២០១១នេះ មានលិខិតបទដ្ឋានក្រោមច្បាប់ចំនួន៣០ ត្រូវបានរៀបចំឡើង ក្នុងនោះមួយចំនួនត្រូវបាន អនុម័ត និងមួយចំនួនទៀតនៅជាសេចក្តីព្រាង ។

### ៥.៦.១.១១. ការងារហិរញ្ញវត្ថុ

ប្រាក់ចំណូលពីគ្រប់ខេត្ត ក្រុងប្រមូលបាន៧.៤១៨.៧៤៣.៥៥០រៀល ក្នុងនោះមានប្រាក់ចំណូលពី÷

| | |
|---|---|
| - ថ្លៃឈ្នួលឡូត៍នេសាទ | ៤.៧៨៨.៦៣០.០០០រៀល |
| - ប្រាក់ធានាស្តាពរ | ១.៦២១.៥០០.០០០រៀល |
| - ថ្លៃឈ្នួលដែននេសាទសមុទ្រ | ៦៣០.៨៨៦.៥០០រៀល |
| - ប្រាក់ពិន័យនិងលក់វត្ថុតាង | ១៦២.៧៨៤.៥៥០រៀល |
| - បំណុលឆ្នាំចាស់ | ១២៣.៧៤០.០០០រៀល |
| - ចំណូលផ្សេងៗ÷ | |
| + រដ្ឋបាលជលផល (ឈ្នួលអាគារ រោងចក្រ) | ២៤.៦២៣.២០០រៀល |
| + រាជធានី ខេត្ត | ៦៦.៥៧៩.៣០០រៀល |

### ៥.៦.២- វាយតម្លៃនិងសន្និដ្ឋាន

ដើម្បីការគ្រប់គ្រងធនធានជលផលមានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយនិរន្តរភាព គឺអាស្រ័យលើការចូលរួម ទទួលខុសត្រូវរបស់មន្ត្រីជំនាញ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និងអ្នកនេសាទផងដែរ។ ដោយឡែក សកម្មភាពថែរក្សា ការពារប្រភពធនធានជលផលត្រូវមានមធ្យោបាយ សម្ភារៈ ថវិកា និងប្រេងឥន្ធនៈគ្រប់គ្រាន់ ដើម្បីធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីជលផលនិងសារៈសំខាន់នៃធនធានជលផលដល់អ្នកនេសាទក៏ដូចជាសហគមន៍នេសាទនិងប្រជាពលរដ្ឋទូទៅ។

បញ្ហាជាគន្លឹះគឺស្ថិតនៅត្រង់កិច្ចសហការជួយទប់ស្កាត់បទល្មើសរបស់អាជ្ញាធរដែនដី និងសមត្ថកិច្ចគ្រប់លំដាប់ ថ្នាក់និងជាពិសេសបំផុតស្មារតីទទួលខុសត្រូវខ្ពស់និងស្នេហាវិជ្ជាជីវៈរបស់មន្ត្រីរដ្ឋបាលជលផលគ្រប់ថ្នាក់ ក្នុងការតស៊ូការពារធនធានជលផលឱ្យបានគង់វង្សសម្រាប់ទុកឱ្យកូនចៅជំនាន់ក្រោយៗទៀត។ សំណូមពរដូចខាងក្រោម÷

-ស្នើសុំជ្រើសរើសមន្ត្រីបច្ចេកទេសជលផលចំនួន៥០នាក់ ដើម្បីជំនួសមន្ត្រីចូលនិវត្តន៍អស់ចំនួន១១០នាក់ និងមួយចំនួនទៀតផ្ទេរក្របខណ្ឌចេញពីរដ្ឋបាលជលផល

-បង្កើនថវិកា សម្ភារៈ ប្រេងឥន្ធនៈ សម្រាប់ពង្រឹងការងារសហគមន៍នេសាទ ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស ការផ្សព្វផ្សាយ និងការបង្ក្រាប បទល្មើសជលផលឱ្យមានប្រសិទ្ធភាព

-សំណើសុំថវិកាសម្រាប់សាងសង់អគារអធិការដ្ឋាន ខណ្ឌ និងផ្នែករដ្ឋបាលជលផល និងសម្រាប់ទិញ នាវាត្រួតពិនិត្យបង្ក្រាបបទល្មើសជលផលនៅដែនសមុទ្រ

-ជួយអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុញ្ញាតឲ្យរដ្ឋបាលជលផល បានដកថវិកាចំណូលពីវិស័យជលផលស្របតាមមាត្រា១៤ នៃច្បាប់ស្តីពីជលផល ដើម្បីបម្រើការអភិវឌ្ឍន៍វិស័យជលផល ក្នុងន័យធានានិរន្តរភាពធនធានជលផលនិងបង្កើន ជីវភាពប្រជាពលរដ្ឋតាម រយៈការបង្កើនផលត្រីឡើងវិញ ។

### ៩.៦.៣. វិធានការ

-ខិតខំបន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ***"ធ្វើឲ្យទីណាមានទឹក ទីនោះមាន ត្រីឡើងវិញ"***

-បន្តការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលឲ្យកាន់តែប្រសើរឡើង តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងវែងទាំងក្នុងនិងក្រៅប្រទេស ដោយរួមទាំងអ្នកនេសាទ សហគមន៍ នេសាទ និងអ្នកចិញ្ចឹមត្រីផង

-បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិដើម្បីជំរុញការងារអភិវឌ្ឍន៍វារីវប្បកម្មនិង ការគ្រប់គ្រងធនធានជលផល

-បន្តលែងប្រភេទពូជត្រីនិងបង្កងក្នុងស្រុកចូលតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកមច្ឆជាតិបំរើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ

-បន្តផលិតឯកសារបច្ចេកទេស ការផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល

-បន្តបង្កើនការងារបណ្តុះបណ្តាលដល់មន្ត្រីរាជការនិងកសិករចិញ្ចឹមត្រី ផលិតកូនត្រីពូជ ដើម្បីពង្រីកសកម្មភាពផ្សព្វផ្សាយវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-ជំរុញការរៀបចំឯកសារ និងលិខិតពាក់ព័ន្ធរបស់សហគមន៍នេសាទ ដើម្បីចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យបានច្រើនថែមទៀត

-ជំរុញការសម្របសម្រួលជាមួយអាជ្ញាធរដែនដីពាក់ព័ន្ធដើម្បីទទួលបានការគាំទ្រលើការងាររៀបចំឯកសារសហគមន៍នេសាទឱ្យបានលឿន ជាពិសេសការចុះហត្ថលេខាទទួលស្គាល់ផែនទីសហគមន៍នេសាទ

-ខិតខំបង្កើនសកម្មភាពត្រួតពិនិត្យ និងលុបបំបាត់បទល្មើសជលផលតាមបណ្តាខេត្តនិងការពារឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត

-ជំរុញការអភិវឌ្ឍន៍សមាគមន៍អ្នកកែច្នៃជលផលឲ្យកាន់តែល្អប្រសើរទាំងបរិមាណនិងគុណភាព

-បង្កើនការយល់ដឹងនិងសមត្ថភាពរបស់អ្នកកែច្នៃឲ្យកាន់តែល្អប្រសើរឡើងលើការអនុវត្តការធ្វើអនាម័យ ល្អ និងការអនុវត្តការផលិតល្អក្នុងខ្សែសង្វាក់ផលិតកម្មកែច្នៃជលផល

-រៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សនិងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

## ៩.៧- ការងារសេវាកម្មនិងការគាំទ្រ

### ៩.៧.១-ការងារគោលនយោបាយផែនការ និងវិនិយោគ

បទ់ណ្ឌខាងលើជាគន្លឹះសំខាន់នៃការងារដំណោះស្រាយការលំបាកដែលរាំងស្ទះនានា ហើយទាមទារឱ្យមានការត្រួតពិនិ

ត្យតាមដាន និងវាយតម្លៃច្បាស់លាស់ ទើបមានមូលដ្ឋានគ្រឹះ ដើម្បីធ្វើការសម្រេចចិត្តកែលម្អ ក្នុងការគ្រប់គ្រងនិងដឹកនាំបានល្អ។ សភាពការណ៍ និងលទ្ធផលតាមផ្នែកនីមួយៗ នៃការងារបម្រើសេវាកម្មនេះ មានដូចខាងក្រោម ÷

## ក- ការងារផែនការគោលនយោបាយ

### ក.១-ការងារគោលនយោបាយយុទ្ធសាស្ត្រ

-បន្តតាមដានការអនុវត្តនិងរបាយការណ៍ជឿនលឿន នៃលទ្ធផលសម្រេចបាន ចំពោះការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកំពស់ការអភិវឌ្ឍវិស័យកសិកម្ម

-រៀបចំផែនការសកម្មភាព ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

-រៀបចំផែនកសាងផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-ណែនាំតម្រង់ទិស និងជំរុញតាមដានការអនុវត្ត ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទតាមកម្មវិធី និងអនុកម្មវិធីស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០០៩-២០១៣

-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធីប្រចាំឆ្នាំ (Program Budgeting) នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ជំរុញការកសាងគម្រោងតាមទម្រង់ P3 និង P4 ដោយផ្អែកតាមកម្មវិធី អនុកម្មវិធីរបស់អនុវិស័យនីមួយៗ

-ពិនិត្យកែលំអ និងណែនាំតម្រង់ទិសចំពោះការលើកគំរោង P3 និង P4 ដោយកំណត់ឱ្យបានច្បាស់លាស់ នូវគោលដៅលទ្ធផលចុងក្រោយ សូចនាករ និងធនធានដែលមាន

-ពិនិត្យនិងវាយតម្លៃលទ្ធផលសម្រេចបាន ដោយផ្អែកលើសូចនាករដែលកំណត់ និងលើកទិសដៅអនុវត្តបន្ត

-សម្រួសម្រួលតាមដានត្រួតពិនិត្យ និងវាយតំលៃល្បឿននៃការអនុវត្តផែនការ និងកម្មវិធីនានា ដើម្បីលើកជាសំណើតម្រង់ទិសនៅឆ្នាំខាងមុខ

### ក.២-ការងារវិនិយោគសាធារណៈនិងជំនួយអភិវឌ្ឍន៍ផ្លូវការ

#### ក.២.១-ការងារវិនិយោគសាធារណៈ

នៅក្នុងឆ្នាំ២០១១ បានរៀបចំស្នើសុំគម្រោងវិនិយោគសាធារណៈ ២០១២ -២០១៤ សម្រាប់វិស័យកសិកម្ម និងបានដាក់ស្នើទៅក្រសួងផែនការមានទាំងអស់៣៧គម្រោង ក្នុងនោះ÷

-គម្រោងស្នើសុំថ្មី (Planned-Project) មានចំនួន ៣១គម្រោង មានថវិកាសរុបចំនួន ២៨,៤០០,០០០ ដុល្លារអាមេរិក ក្នុងនោះ គម្រោងវិនិយោគជាទុន (Investmet project) មាន ០៥គម្រោង និងគម្រោងជំនួយបច្ចេកទេស (Technical asstance project) ២៦ គម្រោង។

-គម្រោងកំពុងដំណើរការ (On-going Project) មានចំនួន០៦ គម្រោងមានថវិកាសរុបចំនួន ១៦,៦៩៨,០០០ ដុល្លាអាមេរិក។

#### ក.២.២-ការងារផែនការថវិកាតាមកម្មវិធី

នៅឆ្នាំ២០១១ និង២០១២ បានទទួលថវិកាតាមកម្មវិធី ដែលជាថវិការដ្ឋ និងត្រូវបានអនុម័ត ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុប ៣២.០៧៨.៨០០.០០០ រៀល ក្នុងនោះ ÷

**១-<u>គម្រោងថវិកាតាមកម្មវិធីនៅឆ្នាំ ២០១១</u> ( ១៤.៤៩១.៤០០.០០០ )**

**ក-<u>កម្មវិធីទី១ :</u>** មានទឹកប្រាក់ចំនួន ៧.០៣៥.៤០០.០០០ រៀល

**ខ-<u>កម្មវិធីទី២ :</u>** មានទឹកប្រាក់ចំនួន ៤៨៨.០០០.០០០ រៀល

**គ-<u>កម្មវិធីទី៣ :</u>** មានទឹកប្រាក់ចំនួន ៥៤៩.០០០.០០០ រៀល

ឃ-<u>កម្មវិធីទី៤</u> : មានទឹកប្រាក់ចំនួន ១.៩៧២.០០០.០០០ រៀល

ង-<u>កម្មវិធីទី៥ :</u> មានទឹកប្រាក់ចំនួន ៤.៤៤៧.០០០.០០០ រៀល

**២-<u>គម្រោងថវិកាតាមកម្មវិធីនៅឆ្នាំ២០១២</u> ( ១៧.៥៨៧.៤០០.០០០ )**

ក-<u>កម្មវិធីទី១ :</u> មានទឹកប្រាក់ចំនួន ៨.៤៧០.៤០០.០០០ រៀល

ខ-<u>កម្មវិធីទី២ :</u> មានទឹកប្រាក់ចំនួន ៤៨៨.០០០.០០០ រៀល

គ-<u>កម្មវិធីទី៣ :</u> មានទឹកប្រាក់ចំនួន ៦១០.០០០.០០០ រៀល

ឃ-<u>កម្មវិធីទី៤ :</u> មានទឹកប្រាក់ចំនួន ៣.៥៧២.០០០.០០០ រៀល

ង-<u>កម្មវិធីទី៥ :</u> មានទឹកប្រាក់ចំនួន ៤.៤៤៧.០០០.០០០ រៀល

### ក-៣-ការងារវិនិយោគឯកជន

គិតមកដល់ខែមករា ឆ្នាំ២០១២ នេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ គោលការណ៍វិនិយោគជូន ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសរុបចំនួន ១១៨ក្រុមហ៊ុន លើផ្ទៃដីផលិតកម្មអាជីវកម្មសរុបចំនួន ១.២២១.០៤៤ ហត ស្ថិតនៅខេត្តចំនួន១៧ ក្នុងនោះមានក្រុមហ៊ុនក្នុងស្រុកចំនួន៤១ ក្រុមហ៊ុន លើផ្ទៃដីចំនួន ៦២៨.៧៩៣ហតដាំដុះបានចំនួន៦៥.០៧៩ហត និងក្រុមហ៊ុនមកពីបរទេសសរុបចំនួន ៧៧ ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ៥៩២.២៥១ ហត ដាំដុះបានចំនួន៩៥.៥៩០ ហត ។ប្រភេទដំណាំដែលបានដាំដុះរួមមានកៅស៊ូ ឈើ ដូងប្រេង ចន្ទី ដំឡូងមី និងចិញ្ចឹមសត្វ។

ក្រុមហ៊ុនមកពីបរទេសទាំងចំនួន៧៧ក្រុមហ៊ុនមានមកពី÷ ប្រទេសវៀតណាមចំនួន២៩ ក្រុមហ៊ុនលើផ្ទៃដីចំនួន ២១៦.១៤៨ហត ប្រទេសចិនចំនួន ២៤ក្រុមហ៊ុន លើផ្ទៃដីចំនួន ១៩២.៩៥៤ហត ប្រទេសឥណ្ឌាចំនួន០៣ក្រុមហ៊ុន លើផ្ទៃដីចំនួន ១៧.៧២៧ហត ក្រុមហ៊ុនមកពីប្រទេសកូរ៉េចំនួន ០៦ក្រុមហ៊ុន លើផ្ទៃដីចំនួន ៤៤.៣៥២ហត ប្រទេសម៉ាឡេស៊ីចំនួន០២ក្រុមហ៊ុនលើផ្ទៃដីចំនួន១៥.៧៥៥ហត ប្រទេសថៃឡង់ចំនួន០៥ក្រុមហ៊ុនលើផ្ទៃដីចំនួន ៣៨.៨៣៦ហត អូស្ត្រាលីចំនួន ០១ក្រុមហ៊ុនលើផ្ទៃដីចំនួន ៨.៩៧៧ហត ប្រទេសសិង្ហបូរីចំនួន០១ ក្រុមហ៊ុន លើផ្ទៃដីចំនួន ៨.០០០ហត ប្រទេសអ៊ីស្រាអែលចំនួន០១ក្រុមហ៊ុនលើផ្ទៃដីចំនួន ២.៤០៩ហត ប្រទេសស៊ុយអ៊ែត០១ក្រុមហ៊ុនលើផ្ទៃដីចំនួន៥.៥២៥ហត មកពីប្រទេសអាមេរិកចំនួន ០៣ ក្រុមហ៊ុន លើផ្ទៃដីចំនួន២៦.៤០៣ ហត និងមកពីប្រទេសរុស្សីចំនួន ០១ក្រុមហ៊ុន លើផ្ទៃដីចំនួន ១៥.១៦៥ ហត ។

ក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលបានសម្រេចលុបគោលការណ៍ និងកិច្ចសន្យាវិនិយោគសរុបចំនួន ១២ក្រុមហ៊ុន លើផ្ទៃដីចំនួន ៤៨.៦៥៧ ហត។

## ខ. ការងារសម្របសម្រួល តាមដាន និងវាយតម្លៃគម្រោង

ដោយអនុលោមទៅតាមតួនាទីនិងភារកិច្ចការងារសម្របសម្រួល តាមដាន និងវាយតម្លៃគម្រោងបានអនុវត្តនូវរាល់សកម្មភាពការងារដែលទាក់ទងទៅនឹងការតាមដានថវិកាតាមកម្មវិធី ការសម្របសម្រួលគម្រោងដែលប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ដោយទទួលបានលទ្ធផលដូចខាងក្រោម ÷

### ខ.១ ការតាមដាននិងវាយតម្លៃថវិកាតាមកម្មវិធី

- បានចុះតាមដាននិងវាយតម្លៃនៅតាមអង្គភាពថ្នាក់កណ្តាលបានចំនួន ០៩ អង្គភាព
- បានសហការជាមួយអង្គភាពជំនាញចុះតាមដានការអនុវត្តថវិកាតាមកម្មវិធីនៅទីវាល បានចំនួន ៩លើក
- បានរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការតាមដាននិងវាយតម្លៃការអនុវត្តថវិកាតាមកម្មវិធី តាមទម្រង់ M2
- បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីសកម្មភាពប្រចាំឆ្នាំ តាមទម្រង់តារាង ១៥ “ខ”

### ខ.២ ការតាមដាននិងវាយតម្លៃគម្រោងរបស់អង្គការក្រៅរដ្ឋាភិបាល

- បានសហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិចុះតាមដានការអនុវត្តគម្រោងរបស់អង្គការក្រៅ រដ្ឋាភិបាលបានចំនួន ០៨ រួមមាន អង្គការ AFSC, GRET, FIDR, WHH/GAA, CI, ADDA, New Humanity, CEDAC

**១.៣ ការសម្របសម្រួលគម្រោងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍**

- គម្រោងជំនួយបច្ចេកទេស ADB-Grant . 0133-CAM/Component1: PFMRDs

បានសហការនិងរៀបចំបើកសិក្ខាសាលាចំនួន០៣លើកនៅខេត្តបាត់ដំបងនិងខេត្តសៀមរាប ក្នុងគោលដៅលើកកំពស់ និងពង្រឹងសមត្ថភាពមន្ត្រីតាមអង្គភាពជំនាញ ដែលពាក់ព័ន្ធនិងកែលំអប្រសិទ្ធភាពការងារ ជាពិសេសលើការងារអនុវត្តថវិកាតាមកម្មវិធី។

**១.៤ ការសម្របសម្រួលការងាររៀបចំបង្កើតផែនទីបង្ហាញផ្លូវរបស់សុខដុមនីយកម្មនៃកម្មវិធីក្រោមយុទ្ធសាស្ត្រសម្រាប់វិសយកសិកម្មនិងទឹក**

- ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹកបានជ្រើសរើសទីប្រឹក្សាជាតិនិងអន្តរជាតិ ដើម្បីរៀបចំបង្កើតផែនការអនុវត្តកម្មវិធីទាំងប្រាំនៃយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក។

- បានសម្របសម្រួលនិងសហការជាមួយទីប្រឹក្សាជាតិនិងអន្តរជាតិក្នុងកិច្ចពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ទាក់ទងទៅនឹងកិច្ចដំណើរការនិងការអនុវត្តអភិក្រមផ្អែកលើកម្មវិធី (PBAs)

ជារួមការអនុវត្តសកម្មភាពការងារសម្របសម្រួលតាមដាននិងវាយតម្លៃកន្លងមកនេះ ឃើញថា ទទួលបានលទ្ធផលជាវិជ្ជមានទាំងលើការងារសម្របសម្រួលគម្រោង ទាំងលើការងារតាមដាននិងវាយតម្លៃថវិកាតាមកម្មវិធី។ ទន្ទឹមនឹងនោះបន្តការងារសម្របសម្រួលគម្រោងជាមួយដៃគូអភិវឌ្ឍន៍និងអង្គការជាតិនិងអន្តរជាតិ និងការងារតាមដាននិងវាយតម្លៃថវិកាតាមកម្មវិធី ដើម្បីឲ្យឆ្លើយតបទៅនឹងដំណើរការកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ជាពិសេសបន្តការងារសម្របសម្រួលការៀបចំបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក។

## គ-ការងារស្ថិតិ

ជារួមការងារស្ថិតិកសិកម្មត្រូវបានពង្រឹង និងបន្តបង្កើនសមត្ថភាពធនធានមនុស្ស ជំនាញបច្ចេកទេស និងវិធីសាស្ត្រនៃការធ្វើអង្កេត ជំរឿន និងវិភាគ។ ផ្នែកស្ថិតិកសិកម្មជាសេនាធិការមានយន្តការនៃ ការដឹកនាំគ្រប់គ្រង ប្រមូល វិភាគ ចងក្រង និងចែកចាយនៃទិន្នន័យស្ថិតិកសិកម្ម។ លទ្ធផលសម្រេចបានតាមផ្នែកមានដូចខាងក្រោម÷

### គ.១- ផ្នែកតាមដានបូកសរុប និងវិភាគទិន្នន័យ

-ការប្រមូលព័ត៌មាននិងរបាយការណ៍តាមបណ្តានាយកដ្ឋានក្រោមឳវាទក្រសួង និងតាមបណ្តារាជធានី ខេត្ត ដែលពាក់ពន្ធ័ការងារប្រព័ន្ធទិន្នន័យស្ថិតិកសិកម្ម

-តាមដានការងារបង្កបង្កើនផលដំណាំកសិកម្ម (ដំណាំស្រូវរដូវវស្សានិងរដូវប្រាំង ដំណាំផ្សេងៗនិងដំណាំអចិន្ត្រៃយ៍ ដើមី្បធ្វើការវាយតម្លៃលើផ្ទៃដីដាំដុះ ទិន្នផល បរិមាណផលប្រចាំឆ្នាំ

-តាមដានពិនិត្យ វាយតម្លៃ វិភាគ និងធ្វើរបាយការណ៍ជាប្រចាំស្តីពី ល្បឿនបង្កបង្កើនផលស្រូវរដូវវស្សា និងរដូវប្រាំង និងដំណាំរួមផ្សំឆ្នាំ២០១១-២០១២ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-វិភាគនិងបកស្រាយលើទិន្នន័យ ដែលបានបញ្ចូលក្នុងប្រព័ន្ធអេឡិចត្រូនិចនិងផ្ទៀងផ្ទាត់ លើផ្ទៃដី ទិន្នផល បរិ-មាណផល ដែលបានប្រមូលតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-ពិនិត្យវាយតម្លៃ និងសិក្សាវិភាគទិន្នន័យ ដែលបានបញ្ចប់ការដាំដុះដំណាំរដូវវស្សា និងប្រាំង ដើមី្បធ្វើការវាយតម្លៃ ប៉ាន់ស្មានតុល្យភាពស្បៀងប្រចាំឆ្នាំតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-តាមដានទឹកភ្លៀងនិងគ្រោះធម្មជាតិ (រាំងស្ងួត ទឹកជំនន់ សត្វល្អិត) នៅតាមបណ្តារាជធានីខេត្តនិងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបាន ដើមី្បធ្វើការកែច្នៃនិងវិភាគសកម្មភាពការងារបង្កបង្កើនផលដំណាំកសិកម្មរដូវវស្សានិងរដូវប្រាំង។

សកម្មភាពនិងលទ្ធផលការងារនេះ បានផលិតចេញជារបាយការណ៍កសិកម្មរៀងរាល់សប្តាហ៍ ផ្ញើជូនខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រចាំឆ្នាំ និងរបាយការណ៍ពិសេសដោយឡែកមួយចំនួនទៀត ដូចជារបាយការណ៍ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សៀវភៅស្ថិតិកសិកម្មប្រចាំឆ្នាំ។ល។

### គ.២- ផ្នែករៀបចំវិធីសាស្ត្រអង្កេតដំណាំ

-ធ្វើការជ្រើសរើសចំនួនភូមិ ចំនួនគ្រួសារ និងចំនួនសំណាកគំរូតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស ដើម្បីសម្រាប់ដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំងឆ្នាំ២០១១-២០១២

-ធ្វើទម្រង់បញ្ជីសំណួរថ្នាក់ភូមិ សម្រាប់ការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំង

-ធ្វើបញ្ជីឈ្មោះគ្រួសារដាំដំណាំស្រូវក្នុងភូមិ ដែលត្រូវធ្វើការជ្រើសរើសចៃដន្យសំណាកគំរូ បញ្ជីសំណួរអង្កេតស្ទង់ទិន្នផលដំណាំស្រូវ និងស្លាកកំណត់ត្រាដំណើរការធ្វើអង្កេតស្ទង់

-ធ្វើការជ្រើសរើសគ្រួសារចៃដន្យតាមប្រព័ន្ធអេឡិត្រូនិច ដើម្បីអនុវត្តការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំងប្រចាំឆ្នាំ២០១១-២០១២ តាមបណ្តារាជធានី ខេត្ត

-ធ្វើការសាកល្បងលើសំណាកគំរូតាមប្រភេទស្រូវ (ស្រាល កណ្តាល និងធ្ងន់) នៅមូលដ្ឋានស្រុក ភូមិ និងគ្រួសារ និងដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំងឆ្នាំ២០១១-២០១២

-ដំណើរការធ្វើអង្កេតស្ទង់ទិន្នផលដំណាំអចិន្ត្រៃយ៍ឆ្នាំ២០១១

-បង្កើតនិងកែច្នៃទម្រង់សម្រាប់ធ្វើការអង្កេតក្នុងប្រព័ន្ធអេឡិត្រូនិច ដើម្បីងាយស្រួលក្នុងការបញ្ចូល និងវិភាគទិន្នន័យ

-បែងចែកទិន្នន័យមួយចំនួនទៅតាមលំដាប់បណ្តារាជធានី ខេត្ត ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធពត៌មានស្ថិតិថ្នាក់ជាតិ

- ទទួលអនុវត្តនូវគម្រោងប្រព័ន្ធព័ត៌មានដីកសិកម្ម ក្រោមគម្រោងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន ឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលជប៉ុន

- សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ដើម្បីសិក្សាស្រាវជ្រាវនូវវិធីសាស្ត្រ សម្រាប់ការគិតគូរគណនាកំណើនរបស់វិស័យកសិកម្ម GDP ប្រចាំឆ្នាំ

- សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) អង្គការ FAO និងការស្វែងរកថវិកាពី ដៃគូអភិវឌ្ឍ ដើម្បីដំណើរការធ្វើជំរឿនកសិកម្មនៅឆ្នាំ២០១៣។

ជារួមសមត្ថភាពនៃការធ្វើអង្កេតស្ទង់ទិន្នផលស្ថិតិកសិកម្ម ដោយមានការជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល បានជំរុញឱ្យដំណើរការងារនេះ មានការរីកចម្រើនបន្ថែមនូវការអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ បានមួយកម្រិត តែទោះជាយ៉ាងណាក្តី ក៏ការធ្វើអង្កេតស្ទង់ដំណាំកសិកម្ម នៅមានការសេសសល់ការងារជាច្រើនទៀត ដែលមិនបានធ្វើដោយកត្តាផ្សេងៗ ដូចជាខ្វះខាតថវិកា និងធនធានមនុស្សនៅមានកម្រិតនៅឡើយ។

## ឃ-ការងារទីផ្សារកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់ គឺត្រូវធ្វើការអភិវឌ្ឍនៅក្នុងវិស័យកសិកម្មឱ្យបានលឿនដោយសារប្រទេសកម្ពុជាមានប្រជាជនភាគច្រើនជាកសិករ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកពាក់ព័ន្ធបានកំណត់ថា ការផ្តល់ព័ត៌មានទីផ្សារកសិផលជាអាទិភាពដ៏ចម្បងដែលនឹងនាំទៅដល់ការអភិវឌ្ឍបណ្តាញទីផ្សារ និងឈានទៅដល់ការធ្វើឱ្យប្រសើរឡើងវិស័យកសិកម្មនៅកម្ពុជា។

ការិយាល័យទីផ្សារកសិកម្ម នៃនាយកដ្ឋានផែនការ និងស្ថិតិ បានខិតខំបំពេញការផ្នែកទីផ្សារ កសិកម្មដោយផ្តល់នូវសេវាសំខាន់ៗពីរ គឺសេវាព័ត៌មានទីផ្សារកសិផល និងការអភិវឌ្ឍទីផ្សារកសិកម្ម ដើម្បីឱ្យអ្នកពាក់ព័ន្ធមានលទ្ធភាពទទួលបានព័ត៌មានទីផ្សារ ប្រមូល និងវិភាគព័ត៌មានត្រឹមត្រូវ ទាន់ពេល និងជាប់ជាប្រចាំ។ សេវាព័ត៌មានទីផ្សារកសិកម្មនឹងជួយធ្វើឱ្យជីវភាពប្រជាកសិករបានប្រសើរឡើង និងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងចូលរួមកាត់បន្ថយភាពក្រីក្រ។

### ឃ.១- ផ្នែកសេវាព័ត៌មានទីផ្សារកសិកម្ម:

ក្នុងឆ្នាំ២០១១ ការិយាល័យទីផ្សារ សម្រេចបានការងាររបស់ខ្លួនស្របតាមសារាចររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីផ្សព្វផ្សាយព័ត៌មានទីផ្សារកសិផលឱ្យដល់មូលដ្ឋានភូមិ-ឃុំ ដោយបានពង្រីកសេវាកម្មពី១៤ ទៅ ២៤ រាជធានី ខេត្ត។ សេវាព័ត៌មានទីផ្សារកសិផលនេះ ត្រូវបានធ្វើការ ផ្សព្វផ្សាយតាមរយៈ ១). ស្ថានីយ៍វិទ្យុចំនួន៩ និងទូរទស្សន៍ចំនួន១ ២). ព្រឹត្តិបត្រប្រចាំខែ ដែលបាន ចែកជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាក់ព័ន្ធផ្សេងទៀត អង្គការជាតិ និងអន្តរជាតិ ៣). គេហទំព័រ (www. agriculturalmarketinformation.org.kh) និង ៤). ផ្ញើសារជាអក្សរ (SMS)។ ការងារ

ទីផ្សារកសិកម្មបានសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្ម និងជនបទ អង្គការស្បៀង និងកសិកម្ម (FAO) ប្រចាំកម្ពុជា និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក បានផលិត ព្រឹត្តិបត្រតាមដានព័ត៌មានតម្លៃប្រចាំខែ និងព្រឹត្តិបត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រចាំត្រីមាស។

## ឃ.២- ផ្នែកអភិវឌ្ឍន៍ទីផ្សារ

ការងារទីផ្សារកសិកម្មបានបើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយសេវាព័ត៌មានកសិកម្មដូចតទៅ÷

- រៀបចំកិច្ចប្រជុំរវាងអាជីវករ និងកសិករបានចំនួន៣៦វគ្គ អ្នកចូលរួមសរុប៥៤១នាក់ ស្ត្រី២៤៧នាក់
- រៀបចំកិច្ចប្រជុំអាជីវករបានចំនួន ៣៨វគ្គ មានអ្នកចូលរួមសរុបចំនួន៣៩១នាក់ ស្ត្រី២៦៤នាក់
- បានបណ្តុះបណ្តាលស្តីពីសាលារៀនទីផ្សារកសិករចំនួន ២វគ្គ មានអ្នកចូលរួមសរុបចំនួន ៥០នាក់ ស្ត្រី១៨នាក់
- បានបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពដល់មន្ត្រីផ្នែកទីផ្សារកសិកម្មទូទាំង ២៤ រាជធានី ខេត្តបាន ចំនួន ៣វគ្គ មានអ្នកចូលរួមសរុបចំនួន ១១៨នាក់ ស្ត្រី៣៥នាក់។

ដូចឆ្នាំមុនៗដែរ ការិយាល័យទីផ្សារកសិកម្ម បានបំពេញការងារទទួលបានជោគជ័យដូចផែនការគ្រោងទុក។ ជាពិសេសអាជីវករ និងកសិករមានចំណាប់អារម្មណ៍ចំពោះសេវាព័ត៌មានទីផ្សារកសិផល ដែល ជួយឲ្យអាជីវករ-កសិករទទួលបានចំណូលខ្ពស់ជាងមុន និងមានបណ្តាញទីផ្សារធំទូលាយ។

## ង-ការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- ចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍គម្រោង របស់អង្គការ CRS ចាប់ពីថ្ងៃទី១០-១២ ខែកុម្ភៈ ឆ្នាំ២០១១ នៅខេត្តស្វាយរៀង

- ពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងលើគម្រោងវិនិយោគ÷

  - ដីសម្បទានសេដ្ឋកិច្ចវិនិយោគដាំដំណាំកៅស៊ូនិងដំណាំកសិ-ឧស្សាហកម្ម
  - គម្រោងសិក្សាស្រាវជ្រាវនិងធ្វើអាជីវកម្មរ៉ែមាសនៅតំបន់អូរខ្វិកខ្លក់ឃុំក្បាលដំរីស្រុកសំបូរ និងស្រុកចិត្របូរីនៃខេត្តក្រចេះ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីផែនការបរិស្ថានជាតិ ២០១១-២០១៥ រៀបចំដោយក្រសួងបរិស្ថាន

- ចូលរួមសិក្ខាសាលាស្តីពី " The Green Growth Policy Tools Training Workshop for Low Carbon Development in Cambodia " ដែលបានរៀបចំដោយស្ថានទូតអង់គ្លេសសហការជាមួយក្រសួងបរិស្ថានកម្ពុជា។

- ចូលរួមសិក្ខាសាលាស្តីពី "បរិស្ថានអណ្តូងរ៉ែ" រៀបចំដោយក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សហការជាមួយសាជីវកម្មជាតិប្រេងកាត ឧស្ម័ន និងលោហៈ នៃប្រទេសជប៉ុន

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយចំណេះដឹងស្តីពី ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រៀបចំដោយអង្គភាពគាំទ្រគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ច- វាយតម្លៃនិងសន្និដ្ឋាន

ជារួមការងារផែនការ និងស្ថិតិ គឺជាសេនាធិការឱ្យក្រសួងក្នុងផ្នែកការងារគោលនយោបាយយុទ្ធសាស្ត្រ ផែនការសេដ្ឋកិច្ច និងវិនិយោគ។ ការងារវិភាគគោលនយោបាយយុទ្ធសាស្ត្រ និងការកសាងកម្មវិធី និងគម្រោងការងារនានា ជាបញ្ហាគន្លឹះ ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យ។ កន្លងមកក្នុងឆ្នាំ ២០១១ ការងារក្នុងផ្នែកនេះ សម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំកន្លងមក និងតាមផែនការដែលបានគ្រោងទុក។ ក៏ប៉ុន្តែជាមួយនឹងការខិតខំនេះ យើងក៏ជួបការប្រឈមនិងបញ្ហាខ្លះៗ ដូចជា កង្វះធនធានមនុស្ស ដែលមានសមត្ថភាពបរិប្ូរណ៍ និងមធ្យោបាយសម្ភារធ្វើការ ដែលទាំងអស់នេះទាមទារឱ្យមានការ ជួយគាំទ្រពីអ្នកពាក់ព័ន្ធ ដើម្បីជំរុញឱ្យការងារនេះ កាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត។

## ឆ- វិធានការ

-ជំរុញបន្តអនុវត្តផែនការសកម្មភាព ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០០៩-២០១៣ ជូនភ្ជាប់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនិងយុទ្ធសាស្ត្រដ៏ទៃទៀត និងយុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងយុទ្ធសាស្ត្រកសិកម្មនិងទឹក

-ជំរុញការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការគាំទ្រការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-ជំរុញរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៣-២០១៧

-សិក្សាលទ្ធភាពនៃការរៀបចំកសាងផែនការមេ សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មរយៈពេល និងវែង ២០១២-២០៣៥

-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធី (Program Budgeting) នៃក្របខណ្ឌផែនការយុទ្ធសាស្ត្រ (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ទុនវិនិយោគរបស់រដ្ឋ ឱ្យចំទិសដៅអាទិភាព និងមានប្រសិទ្ធភាពខ្ពស់

-បន្តកិច្ចសហការជាមួយស្ថាប័ន និងអង្គភាពពាក់ពន្ធ័ពិនិត្យដោះស្រាយទំនាស់ផ្សេងៗ ក្នុងតំបន់វិនិយោគសប្បទានដីសេដ្ឋកិច្ច ដែលមានគោលការណ៍ និងចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តជំរុញឱ្យក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច គោរពតាមកិច្ចសន្យាផែនការមេនិងការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តធ្វើបច្ចុប្បន្នភាពលើការរៀបចំ ចងក្រង ប្រមូលពត៌មាន និងទិន្នន័យគម្រោង ដែលផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងត្រៀមលក្ខណៈចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

-ជំរុញការរៀបចំ និងបន្តយន្តការតាមដានល្បឿនការងារបង្កបង្កើនផលឆ្នាំ២០១១ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស និងពង្រឹងសមត្ថភាពត្រួតពិនិត្យ លើការងារស្ថិតិកសិកម្មពីថ្នាក់កណ្តាលដល់មូលដ្ឋាន ដើម្បីសម្រួលដល់ការប្រមូលបញ្ចូល វិភាគ និងចងក្រងទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ

-ជំរុញយន្តការការធ្វើអង្កេតស្ទង់ទិន្នផលដំណាំស្រូវ អង្កេតដំណាំផ្សេងៗ ដំណាំអចិន្ត្រៃយ៍ និងការប្រមូលទិន្នន័យប្រព័ន្ធពត៌មាន ស្ថិតិកសិកម្ម ដើម្បីឱ្យប្រព័ន្ធស្ថិតិកសិកម្មមានតម្លាភាព និងនិរន្តរភាព

-បង្កើនសមត្ថភាពបច្ចេកទេស ក្នុងការប្រមូល កែច្នៃ និងផ្ទៀងផ្ទាត់ទិន្នន័យ ស្ថិតិឱ្យមានតម្លាភាព និងប្រសិទ្ធិភាពល្អប្រសើរ សម្រាប់អ្នកប្រើប្រាស់ស្រាវជ្រាវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ

-ខិតខំស្វះស្វែងរកថវិកាពីដៃគូអភិវឌ្ឍនានា និងបន្តសហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ និងអង្គការ FAO ដើម្បីអនុវត្តគម្រោងធ្វើអង្កេត និងជំរឿនកសិកម្មនាឆ្នាំខាងមុខ

-បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មរាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្មឱ្យកាន់តែល្អប្រសើរឡើង ដើម្បីចងក្រងព្រឹត្តិប័ត្រប្រចាំខែ ប្រចាំឆ្នាំ ជាមូលដ្ឋានសម្រាប់ផ្សព្វផ្សាយបន្តដល់ប្រជាកសិករនៅតាមជនបទ

-ពង្រឹងគុណភាពការប្រមូលព័ត៌មានតម្លៃកសិផលនិងធ្វើឱ្យមានភាពជឿជាក់ និងធានាឱ្យបានថាព័ត៌មានទីផ្សារកសិផលនឹងទៅដល់កសិករនៅថ្នាក់ភូមិឃុំ

-បន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ និងបោះពុម្ពខិត្តប័ណ្ណ និងពិនិត្យតាមដានការប្រមូលព័ត៌មានថ្លៃទីផ្សារនៅតាមរាជធានី ខេត្ត និងសិក្សាបញ្ហាទីផ្សារ ដែលធ្វើឱ្យមានឥទ្ធិពលដល់ការប្រែប្រួលតម្លៃរបស់ផលិតផល។

### ៥.៧.២-ការងារសហប្រតិបត្តិការអន្តរជាតិ

### ៥.៧.២.១-លទ្ធផល

ការងារសហប្រតិបត្តិការអន្តរជាតិ ដែលជាសេនាធិការផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួល និងទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍនានា ក្នុងក្របខណ្ឌសហប្រតិបត្តិការទ្វេភាគី ពហុភាគី អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងការអនុវត្តគម្រោងអភិវឌ្ឍវិស័យកសិកម្ម។

នៅឆ្នាំ២០១១កន្លងទៅនេះ ដោយប្រកាន់ភ្ជាប់នូវភារកិច្ចខាងលើ និងដោយមានការគាំទ្រ ព្រមទាំងការ ណែនាំតម្រង់ទិសពីថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានបានអនុវត្តការងារ និងទទួលបានលទ្ធផលដូចតទៅ:

-មុខការលើលិខិតចូល ២៤៦៧ ច្បាប់ ព្រមទាំងរៀបចំ និងបញ្ជូនលិខិតចេញ ១៣០៩ ច្បាប់

-សម្របសម្រួលរៀបចំ និងបំពេញបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីចំនួន ៤០១ នាក់ ចូលរួមប្រជុំ សិក្ខា សាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សានៅបរទេសចំនួន ៣៥ ប្រទេស ក្នុងនោះពាក់ព័ន្ធនឹង កិច្ចសហការជាមួយអង្គការអន្តរជាតិចំនួន ៩៨ នាក់ កិច្ចការអាស៊ានចំនួន ៦៣ នាក់ និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីចំនួន ២៤០ នាក់

-រៀបចំឯកសារ និងសម្របសម្រួលការជួបសម្តែងការគួរសម និងពិភាក្សាការងាររវាងថ្នាក់ដឹកនាំ ជាមួយឯកអគ្គរដ្ឋទូតតំណាងប្រទេស និងដៃគូអភិវឌ្ឍន៍នានាចំនួន ១៣ លើក

-តាក់តែង ចងក្រង និងពិនិត្យឯកសារជូនថ្នាក់ដឹកនាំចរចា សម្រេច និងចុះហត្ថលេខាលើអនុស្សា រណៈនៃការយោគយល់គ្នា (MoU) ចំនួន ២ កិច្ចព្រមព្រៀងជាមួយអង្គការ និងដៃគូរអភិវឌ្ឍន៍ចំនួន១២ លិខិតប្តូរសារចំនួន ៣ និងកំណត់ហេតុនៃកិច្ចពិភាក្សា (Record of Discussion)។

## ក- កិច្ចការអាស៊ានកសិកម្ម

- បានសម្របសម្រួលស្នើសុំគោលការណ៍ និងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំចំនួន ៣ គឺ ៖
  - កិច្ចប្រជុំលើកទី ១៩ នៃក្រុមការងារជលផលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ
  - កិច្ចប្រជុំលើកទី ១៨ នៃក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មអាស៊ាន
  - កិច្ចប្រជុំពិសេសលើកទី ៣២ នៃឧត្តមមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន និងកិច្ចប្រជុំពិសេសលើកទី ១០ នៃឧត្តមមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានបូក ៣។
- បានសម្របសម្រួលរៀបចំបែបបទបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមបំពេញបេសកកម្មក្រៅប្រទេសពាក់ព័ន្ធនឹងការងារអាស៊ាន ចំនួន ២៨ លើក សរុបចំនួន ៥៥ នាក់
- បានសម្របសម្រួលការចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ានបូកបីចំនួន៣

| ល.រ | ប្រភេទឯកសារសហប្រតិបត្តិការ | កាលបរិច្ឆេទ | ហត្ថលេខី |
|---|---|---|---|
| អនុស្សារណៈនៃការយោគយល់គ្នា (MoU) | | | |
| ១ | រវាង សមាជិកប្រទេសអាស៊ាន និងអង្គការ សុខភាពសត្វពិភពលោក (OIE) ស្តីពីប្រព័ន្ធ ផ្តល់ព័ត៌មានសុខភាពសត្វថ្នាក់តំបន់ | ៧ តុលា ២០១១ | ឯ.ឧ. ច័ន្ទ តុងអ៊ីវ |
| កិច្ចព្រមព្រៀង | | | |
| ១ | ការត្រៀមបម្រុងអង្ករសម្រាប់គ្រាអាសន្នរបស់ អាស៊ានបូកបី (APTERR) | ៧ តុលា ២០១១ | ឯ.ឧ. ច័ន្ទ តុងអ៊ីវ |
| ២ | កិច្ចសហប្រតិបត្តិការលើវិស័យព្រៃឈើរវាង អាស៊ាន និងសាធារណរដ្ឋកូរ៉េ (AFoCo) | ១៨ វិច្ឆិកា ២០១១ | ឯ.ឧ. ហោ ណាំហុង |

## ខ- ការងារកសិ- ពាណិជ្ជកម្មពិភពលោក

-បានសម្របសម្រួលបំពេញខ្លឹមសារនៃបញ្ជីសំនួរស្តីពីអាជ្ញាប័ណ្ណនាំចូល ជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានបញ្ជូនលទ្ធផលសរុបទៅក្រសួងពាណិជ្ជកម្ម

-បានសម្របសម្រួលកិច្ចប្រជុំចំនួន ៤ លើក ដើម្បីពិភាក្សាសេចក្តីព្រាងជំពូក I III និង IV នៃរបាយការណ៍ ស្តីពីការត្រួតពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្មរបស់កម្ពុជា ដែលចងក្រងដោយអ្នកជំនាញ ការរបស់លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក និងបានបញ្ជូនលទ្ធផលកែសម្រួលទៅក្រសួងពាណិជ្ជកម្ម

-បានសម្របសម្រួលរៀបចំកិច្ចប្រជុំស្តីពីការសម្រួល និងធ្វើបច្ចុប្បន្នភាពអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

-បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ លើក ស្តីពីនីតិវិធីនៃការរៀបចំសេចក្តីជូនដំណឹងក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ។

## គ-ការងារអង្គការជាតិនិងអន្តរជាតិ

-បានរៀបចំលិខិតសុំចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងសហប្រតិបត្តិការរវាងក្រសួងជាមួយអង្គការ FAO OXFAM AUSTRALIA, VSF-CICDA ADDA ADRA FIDR CI ចំនួន ៩ គម្រោង

-បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពគម្រោងរបស់អង្គការចំនួន១០ក្នុងនោះមានអង្គការ WCS, CI, GRET, CRS, FIDR, ADDA, NEW HUMANITY, WHH, CMC និង RPRP នៅខេត្តរតនគីរី ស្វាយរៀង កំពង់ឆ្នាំង បាត់ដំបង និងសៀមរាប។

**តារាង-គម្រោងដែលបានចុះកិច្ចព្រមព្រៀងនៅឆ្នាំ២០១១**

| ល.រ | ឈ្មោះអង្គការ | ឈ្មោះគម្រោង | រយៈពេលអនុវត្ត | ថវិកា |
|---|---|---|---|---|
| ១ | អង្គការមូលនិធិអភិរក្សអន្តរជាតិ - CI | ការការពារកន្លែងអភិរក្សជលផលព្រៃលិចទឹក និងអភិរក្សជីវចម្រុះ | ០១-០១-២០១១ ៣១-១២-២០១៣ | ២៩០.០០០ ដុល្លារអាមេរិក |
| ២ | អង្គការ ADDA | គម្រោងបង្កើនសិទ្ធិអំណាចដល់ស្ត្រី ជំហានទី ២ | ០១-០៣-២០១១ ២៨-០២-២០១៤ | ៦៤៦.៨៦៥ ដុល្លារអាមេរិក |
| ៣ | អង្គការ ADRA | គម្រោងពង្រឹងសមត្ថភាព និង បង្កើនជីវភាពសហគមន៍តាមរយៈកសិកម្ម | ០១-០៧-២០១១ ៣០-០៦-២០១៤ | ៤៦២.៨០១ ដុល្លារអាមេរិក |
| ៤ | អង្គការអ្នកក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន - AVSF-CICDA | គម្រោងគាំទ្រសន្តិសុខស្បៀងពីសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានដល់ក្រុមដែលងាយរងគ្រោះបំផុតនៅតំបន់ជនបទ | ២២-០២-២០១០ ២១-០២-២០១៣ | ១.៤៤៤.៦០០ អឺរ៉ូ |
| ៥ | មូលនិធិសម្រាប់ការអភិវឌ្ឍ និងជំនួយសង្គ្រោះ អន្តរជាតិ - FIDR | សន្តិសុខស្បៀង និងអាហារូបត្ថម្ភ FNSP II | ០១-០៤-២០១១ ៣១-០៣-២០១៦ | ៧០៣.០០០ ដុល្លារអាមេរិក |
| ៦ | អង្គការអុកស្វាមអូស្ត្រាលី | ការអភិវឌ្ឍន៍សហគមន៍ | ៣០-០១-២០១១ ៣១-០១-២០១៤ | ៤.៩៥១.៣៧២ ដុល្លារអាមេរិក |
| ៧ | អង្គការ FAO | ការកសាងសមត្ថភាពគ្រប់គ្រង និងការពារការរាលត្បាតសត្វល្អិតចង្រៃ (Pink Mealy Bug) លើដំឡូងមីនៅមហាអនុតំបន់ទន្លេមេគង្គ | ខែកុម្ភៈ ឆ្នាំ២០១១ ខែធ្នូ ឆ្នាំ២០១២ | ៤៩១.០០០ ដុល្លារអាមេរិក |
| | | ការអភិវឌ្ឍសមត្ថភាព ដើម្បីកាត់បន្ថយការបាត់បង់ក្រោយពេល | ខែមករា ឆ្នាំ២០១១ ខែធ្នូ ឆ្នាំ២០១២ | ៤៥១.០០០ ដុល្លារអាមេរិក |

| | | | | |
|---|---|---|---|---|
| | | ប្រមូលផលនៃដំណាំសាកវប្បកម្ម នៅមហាអនុតំបន់ទន្លេមេគង្គ | | |
| | | ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដើម្បីសម្រេចបាននូវសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និងភាពម្ចាស់ការលើខ្លួនឯង សម្រាប់ប្រជាពលរដ្ឋក្រីក្រនៅក្រុង ភ្នំពេញ | ខែមេសា ឆ្នាំ២០១១ ខែមេសា ឆ្នាំ២០១៤ | ១.៣៣៩.០០០ ដុល្លារអាមេរិក |

## ឃ- ការងារសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី

-បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំ ចូលរួមទទួលជួបឯកអគ្គរដ្ឋទូត ហើយធ្វើកំណត់ហេតុ និងសម្រង់ព័ត៌មាន ចំនួន ១៣ លើក ក្នុងនោះមានជាមួយចិន ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន ដាណឺម៉ាក អូស្ត្រាលី សាធារណរដ្ឋកូរ៉េ បង់ក្លាដេស ជប៉ុន គុយបា ឥណ្ឌា សាធារណរដ្ឋប្រជាមានិតប្រជាធិតេយ្យកូរ៉េ អ៊ីស្រាអែល និងថៃ

-បានចុះត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយ បណ្តាប្រទេសដៃគូ ដូចជាវៀតណាម ចិន សាធារណរដ្ឋកូរ៉េ និងជប៉ុន នៅខេត្តសៀមរាប កំពង់ធំ រតនគិរី ព្រះវិហារ និងស្វាយរៀង

-បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគម្រោងតាមប្រព័ន្ធទិន្នន័យ (Database)

-បានសម្របសម្រួលការចុះហត្ថលេខាសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាមិត្តនិងដៃគូរអភិវឌ្ឍន៍ ÷

| ល.រ | ប្រភេទឯកសារ | ប្រទេស | ថវិកា |
|---|---|---|---|
| **អនុស្សារណៈនៃការយោគយល់គ្នា (MoU)** | | | |
| ១ | ការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយ សាជីវកម្មធនាគារអភិវឌ្ឍន៍ចិន | សាធារណរដ្ឋប្រជាមានិតចិន | |
| **កំណត់ហេតុនៃកិច្ចពិភាក្សា** | | | |
| ១ | ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋកូរ៉េ ស្តីពីគម្រោងរៀបចំផែនការមេ ដើម្បីបង្កើតភ្នាក់ងារសម្របសម្រួល មានជំនាញក្នុងការជំរុញវិនិយោគលើវិស័យកសិកម្ម | សាធារណរដ្ឋកូរ៉េ | ១ លានដុល្លារ |
| **លិខិតប្តូរសារ** | | | |
| ១ | គម្រោងសាងសង់មន្ទីរពិសោធន៍ កសិកម្មកម្ពុជា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណ រដ្ឋប្រជាមានិតចិន | សាធារណរដ្ឋប្រជាមានិត | |
| ២ | ការផ្តល់អំណោយសម្ភារកសិកម្ម រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជា មានិតចិន | សាធារណរដ្ឋប្រជាមានិតចិន | ៣.០០០.០០០ យ៉ន់ |
| ៣ | វគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចនិងចត្តាឡីស័កនៃផលិតផលកសិកម្ម (រុក្ខជាតិ) រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន | សាធារណរដ្ឋប្រជាមានិតចិន | ៣.៥០០.០០០ យ៉ន់ |
| **គម្រោងដែលបានចុះហត្ថលេខា** | | | |
| ១ | ការអនុវត្ត និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប (ជំហានទី២) | ជប៉ុន | ៤.០០០.០០០ ដុល្លារអាមេរិក |
| ២ | ការសម្របសម្រួលអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រកាត់ | ជប៉ុន | ២.០០០.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| | បន្ថយការបំភាយឧស្ម័នពីការរិចរិល និងការកាប់បំផ្លាញព្រៃឈើ | | អាមេរិក |
| ៣ | សន្តិសុខស្បៀងសម្រាប់កសិករគ្មានបុព្វសិទ្ធិ | ជប៉ុន | ៣.២៨៦.៧៥១,១២ ដុល្លារអាមេរិក |

## ៩.៧.២.២- ការវាយតម្លៃនិងសន្និដ្ឋាន

ក្នុងភារកិច្ចជាអង្គភាពសម្របសម្រួលនិងទំនាក់ទំនង ថ្នាក់ដឹកនាំនិងមន្ត្រីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់អនុវត្ត ព្រមទាំងដោះស្រាយយ៉ាងអស់លទ្ធភាព ដែលជាហេតុធ្វើឲ្យសម្រេចបានស្នាដៃ និងលទ្ធផលល្អជាច្រើន គួរឲ្យកត់សម្គាល់ខាងលើ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១១ កន្លងមកនេះ ក្រសួងបានចុះកិច្ចព្រមព្រៀងអនុវត្តអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងក្របខណ្ឌទ្វេភាគី-ពហុភាគីនិងអាស៊ាន គម្រោង អនុស្សារណៈនៃការយោគយល់គ្នា និងពិធីសារនានា។

ទន្ទឹមនឹងនោះ ការងារនេះបានជួបប្រទះបញ្ហាជាច្រើនក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ពិសេសគឺការគ្រប់គ្រងនិងសម្របសម្រួលសកម្មភាពដែលដំណើរការក្រោមឥណទានជំនួយនៅមានកម្រិត។ ដូចនេះ ដើម្បីអនុវត្តភារកិច្ចនេះឱ្យបានរលូន និងមានប្រសិទ្ធិភាពខ្ពស់ សូមឱ្យមានកិច្ចសហការគាំទ្រពីអង្គភាពពាក់ព័ន្ធនិងមានការលើកទឹកចិត្តលើការងារនេះ។

## ៩.៧.២.៣- វិធានការ

នៅក្នុងឆ្នាំ២០១២ ការងារសហប្រតិបត្តិការអន្តរជាតិនឹងសហការជាមួយអង្គភាពជំនាញ រៀបចំកិច្ចប្រជុំក្រុមការងារអាស៊ានចំនួន៣នៅខេត្តសៀមរាបតី ÷

-កិច្ចប្រជុំលើកទី៥ នៃបណ្តាញការងារព្រៃឈើសង្គមអាស៊ាន ភ្ជាប់ជាមួយនិងសន្និសីទលើកទី២នៃបណ្តាញការងារព្រៃឈើសង្គមអាស៊ាន នៅថ្ងៃទី ១១-១៥ ខែមិថុនា ឆ្នាំ២០១២

-កិច្ចប្រជុំលើកទី៣២ នៃក្រុមប្រឹក្សាត្រៀមបម្រុងសន្តិសុខស្បៀងអាស៊ានភ្ជាប់ជាមួយនិងវេទិកាពាណិជ្ជកម្មស្រូវអង្ករ នៅថ្ងៃទី១៩-២២ ខែមិថុនា ឆ្នាំ២០១២

-កិច្ចប្រជុំលើកទី៩ នៃក្រុមការងារអ្នកជំនាញសាយតេស្តអាស៊ាននៅថ្ងៃទី០៦-៨ ខែ វិច្ឆិកា ឆ្នាំ២០១២។

-បន្តការយកចិត្តទុកដាក់ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រទេសជាមិត្តនានា ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម សំដៅរួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងជំរុញបង្កើនផលិតកម្មស្រូវ និងនាំចេញ អង្កររបស់រាជរដ្ឋាភិបាល

-បន្តកិច្ចសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ពិនិត្យ តាមដាន និងវាយតម្លៃ លើការអនុវត្តខ្លឹមសារអនុសារណៈ ពិធីសារ អនុសញ្ញា និងកិច្ចព្រមព្រៀងផ្សេងៗ ដែលចុះហត្ថលេខារួចហើយ។

## ៩.៧.៣-ការងារកិច្ចការរដ្ឋបាល

## ៩.៧.៣.១- លទ្ធផល

ឆ្នាំ២០១១នេះ ដោយអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងទិសដៅការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញតួនាទីយ៉ាងសកម្មលើការងារៀបចំនិងចរាចរឯកសារផ្សព្វផ្សាយច្បាប់គោលការណ៍ផ្សេងៗ÷

### ក- ផ្នែករៀបចំ និងចរាចរឯកសារ

ក.១- ផ្នែកទទួលលិខិតចូល

- ទទួលពីស្ថាប័ននានា សរុបចំនួន២ ៣៥៥ច្បាប់
- ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន២ ៤៥៥ច្បាប់
- ទទួលពីរាជធានី ខេត្ត សរុបចំនួន ៦៩៩ច្បាប់

### ខ- ផ្នែកចុះលិខិតចេញ

-បញ្ជូនទៅក្រសួងស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទខេត្ត ក្រុង សរុបចំនួន ៤.៩៤០ ច្បាប់

-សេចក្ដីសម្រេច និងប្រកាស សរុបចំនួន ៣៨៥ ច្បាប់

-ថតចម្លង និងបែងចែងតាមអង្គភាពក្រោមឱវាទ សរុបចំនួន ២៧០ ច្បាប់

-បញ្ជូនលិខិតបទដ្ឋានចុះក្នុងរាជកិច្ច សរុបចំនួន ០៦ ច្បាប់

### គ-ការងារសន្តិសុខអនុវត្តនល្អប្រសើរដូចជា

-ភ្ញៀវមកពីអង្គភាពក្រោមឱវាទ សរុបចំនួន ២.៨១២ នាក់

-ភ្ញៀវមកពីអន្តរក្រសួង សរុបចំនួន ២៥៥ នាក់

-ភ្ញៀវមកពី រាជធានី ខេត្ត សរុបចំនួន ២៥៨ នាក់

-ភ្ញៀវជាអតិថិជន សរុបចំនួន ១.៧៤៩ នាក់

-ភ្ញៀវអន្តរជាតិ សរុបចំនួន ៤៦០ នាក់

### ៥.៧.៣.២- វាយតម្លៃ និងសំណើ

ជារួមការងារកិច្ចការរដ្ឋបាល បានប្រព្រឹត្តទៅយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាពល្អប្រសើរ។

### ៥.៧.៣.៣- វិធាន

- បណ្ដុះបណ្ដាលធនធានមនុស្ស ទាំងផ្នែករដ្ឋបាល ផ្នែកជំនាញ និងភាសាបរទេស

-បន្តពង្រឹងប្រសិទ្ធភាពការងាររដ្ឋបាល និងការងារគ្រប់គ្រង និងបែងចែកបញ្ជូនលិខិតស្នាមតាមបែបបទរដ្ឋបាលឱ្យបានទាន់ពេលវេលា។

### ៥.៧.៤-ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ ២០១១ នេះ ការងារនីតិកម្មកសិកម្ម បានផ្ដោតលើសកម្មភាពដូចខាងក្រោម ÷

-ពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្ម តាមរយៈការត្រួតពិនិត្យនៅពេលនាំចូលចែកចាយនិងតាមដានត្រួតពិនិត្យជាប្រចាំ ដល់សកម្មភាពធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារកសិកម្មនៅគ្រប់មូលដ្ឋានរាជធានី ខេត្ត

-ពង្រឹងយន្តការគ្រប់គ្រងសម្ភារកសិកម្មនីតិកម្មកសិកម្មរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្ត ច្បាប់ ការលើកកំពស់ប្រសិទ្ធភាពការគ្រប់គ្រង និងអនុវត្តកម្មវិធីផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានរាជធានី ខេត្ត នូវការយល់ ដឹងផ្នែក បច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

### ៥.៧.៤.១-លទ្ធផល

### ក-ការងារអាជីវកម្មសម្ភារកសិកម្ម

-ការផ្ដល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មមានចំនួន ៦៨ក្រុមហ៊ុន

-ការផ្ដល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មមានចំនួន ១២៣ក្រុមហ៊ុនសរុប ១.៨០៤មុខ ប្រមូលប្រាក់ចំណូលកម្រៃសេវាកម្មចុះបញ្ជិកាសម្ភារកសិកម្មនិងបង់ចូលថវិការដ្ឋបានចំនួន ២៧០.៦០០.០០០៛ (ពីរយចិតសិបលានប្រាំមួយរយពាន់រៀល)

-ការផ្ដល់លិខិតអញ្ញាតឱ្យនាំចូលសម្ភារកសិកម្មមានចំនួន ១១៧ ក្រុមហ៊ុន ត្រូវជា ១៤៧ករណីនាំចូល÷

- ជីកសិកម្មចំនួនៈ ៥០៣.៩១១,៦តោន ៣៣៤,៩០គីឡូ ១០.៤០០បាវ ៤០០លីត្រ ៥០ដប
- ថ្នាំកសិកម្មៈ ៥.៥៩៨,០២តោន ៣.៦៤០,៥០គីឡូក្រាម ៥៣.៨៨៣លីត្រ ០៧កំប៉ុង
- ចំណីសត្វៈ ៤០៥.៦៤៧តោន
- បសុឱសថៈ ៨០០.៩៣៩តោន ៩៦១.១២៥ត.ក្រ ៨០៣,៨០លីត្រ
- ពូជដំណាំៈ ១.៩០៨តោន ១.០០០ត.ក្រ ១៧០.០០០គ្រាប់
- បរិក្ខាបសុពេទ្យៈ ០៥មុខ

-វត្ថុធាតុដើមសម្រាប់ផលិតស្រាបៀរៈ ៨៦០មុខ

-ការផ្តល់លិខិតអញ្ញាតឱ្យនាំចេញសម្ភារកសិកម្មរបស់ក្រុមហ៊ុននាំចេញជីផូស្វាត៩.០០០តោន។

**ខ-ការងារនីតិកម្មកសិកម្មនិងផ្សព្វផ្សាយច្បាប់កសិកម្ម÷**

ឆ្នាំ២០១១នេះ ការសិក្សានិងអភិវឌ្ឍបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្មដូចជា÷

-ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រមលេខនស/រកម/០១១២/០០៥ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១២

-សំណើសុំចូលជាសមាជិកភាគីនៃអនុសញ្ញា Rotterdam ស្តីពី "នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន

-ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ" ត្រូវបានយល់ព្រមដោយរាជរដ្ឋាភិបាល និងកំពុងឆ្លងនីតិវិធីក្នុងការ បញ្ជូនស្នើសុំការផ្តល់សច្ចាប័នដោយស្ថាប័នរដ្ឋសភា

-សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជិកាថ្នាំកសិកម្ម និងសេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជិកាជីកសិកម្ម

-សេចក្តីណែនាំស្តីពីព័ត៌មានបង្ហាញផ្លូវនិងកាតព្វកិច្ចពាណិជ្ជករសម្ភារកសិកម្ម កំពុងដាក់ឆ្លងការពិនិត្យសម្រេច និងនីតិវិធីណែនាំសម្រាប់អនុវត្តក្នុងប្រតិបត្តិការត្រួតពិនិត្យសម្ភារកសិកម្មដែលនាំចូលនិងផ្គត់ផ្គង់ចែកចាយ និងនីតិវិធីសម្រាប់អនុវត្តក្នុងប្រតិបត្តិការត្រួតពិនិត្យនិងអនុវត្តច្បាប់ ចំពោះគ្រឹះស្ថានធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម (ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈលិខិតលេខ ៨៤៨៦ កសក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១)

-សៀវភៅណែនាំអំពីការគ្រប់គ្រងសមាសភាពចង្រៃនិងកូនសៀវភៅសម្រាប់មន្ត្រីអធិការកិច្ច និងឯកសារបរិយាយប័ណ្ណ និងប័ណ្ណផ្សព្វផ្សាយផ្សេងទៀតពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម (ឧបត្ថម្ភដោយគម្រោង QCAM/JICA-MAFF)។

**គ-ការងារផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម ÷**

-ធ្វើការផ្សព្វផ្សាយស្តីពី ***"យុទ្ធនាការជាតិលុបបំបាត់ថ្នាំកសិកម្មហាមឃាត់"*** ក្រោមកម្មវិធីសហប្រតិបត្តិការបច្ចេកទេស (QCAM/JICA-MAFF) នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងកំពង់ចាម

-ចូលរួមជាវាគ្មិនស្តីពី ***"យុទ្ធនាការជាតិលុបបំបាត់ថ្នាំកសិកម្មហាមឃាត់"*** នៅទូរទស្សន៍ជាតិកម្ពុជា

-បានធ្វើការចុះផ្សាយឈុតអប់រំស្តីពីសុវត្ថិភាពក្នុងការទិញនិងប្រើប្រាស់ថ្នាំកសិកម្មតាមរយៈទូរទស្សន៍ជាតិកម្ពុជា

-ចុះផ្សព្វផ្សាយណែនាំនិងបណ្តុះបណ្តាលដល់កសិករនៅស្រុកបវេល អំពីការជ្រើសរើសនិងវិធីសាស្ត្រនៃការប្រើប្រាស់ថ្នាំកសិកម្មនិងជីកសិកម្ម

-ចូលរួមជាគ្រូឧទ្ទេសនាមក្នុងវគ្គអប់រំសមត្ថភាពវិជ្ជាជីវដល់អាជីវករលក់ដុំ លក់រាយសម្ភារកសិកម្ម១៤ខេត្ត (ខេត្តពោធិសាត់ ព្រៃវែង កំពត ស្វាយរៀង កំពង់ស្ពឺ កណ្តាល តាកែវ បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ កំពង់ចាម ប៉ៃលិន សៀមរាប និងកំពង់ឆ្នាំងសរុបចំនួន ៣១ វគ្គដែលមានអាជីវករចូលរួមសរុបចំនួន២.៩២២នាក់

-សហការជាមួយវេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពី ការផ្សព្វផ្សាយណែនាំការលុបបំបាត់ថ្នាំកសិកម្មហាមឃាត់ និងការកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម នៅស្រុកព្រះស្តេចខេត្តព្រៃវែង។

**ឃ-ការងារវិវាទកសិកម្មនិងស្រាវជ្រាវ ÷**

-ការត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មក្រុមហ៊ុន ដែលមានលិខិតអនុញ្ញាតនាំចូលឆ្នាំ២០១១មានចំនួន៨៥ក្រុមហ៊ុនបាននាំចូល ១១៥ករណី ក្នុងនោះ ÷

- ក្រុមហ៊ុនបានធ្វើប្រតិវេទន៍មានចំនួន ៨៤ក្រុមហ៊ុន បាននាំចូល៥០ករណី
- ក្រុមហ៊ុនមិនបានធ្វើប្រតិវេទន៍មានចំនួន ២៣ក្រុមហ៊ុន បាននាំចូល ២៤ករណី
- ក្រុមហ៊ុនមិនទាន់ធ្វើការនាំចូលចំនួន១២ក្រុមហ៊ុន (១២ករណី)
- ក្រុមហ៊ុនមិនសហការចំនួន០៣ក្រុមហ៊ុន (០៣ករណី)

- ក្រុមហ៊ុនដែលមិនអាចទំនាក់ទំនងដើម្បីត្រួតពិនិត្យបានចំនួន០៧ក្រុមហ៊ុន (១៨ ករណី) និងក្រុមហ៊ុនដែលមិនទាន់បានធ្វើការត្រួតពិនិត្យចំនួន០៧ក្រុមហ៊ុន (០៨ ករណី)។

-បានសម្រេចចេញលិខិតព្រមានចំនួន ៣០ក្រុមហ៊ុន និង១៣ក្រុមហ៊ុនទៀតក្រសួងបានសម្រេចធ្វើការណែនាំ និងកែកំហុស និងដាក់វិធានការទណ្ឌកម្មលើក្រុមហ៊ុនចំនួន២៧ក្រុមហ៊ុនបន្ថែមទៀត ដែលបានធ្វើការនាំចូលមិនបានប្រកាសប្រតិវេទន៍និងមិនអាចធ្វើការទំនាក់ទំនងដើម្បីចុះត្រួតពិនិត្យ

-ការតាមដាន ត្រួតពិនិត្យសកម្មភាពធ្វើអាជីវកម្ម លក់ចែកចាយសម្ភារកសិកម្មក្នុងរាជធានី ខេត្ត ត្រួតពិនិត្យសកម្មភាពធ្វើអាជីវកម្មសម្ភារកសិកម្ម និងពង្រឹងការអនុវត្តច្បាប់ដោយបានដឹកនាំអនុវត្តការងារការិយាល័យ នីតិកម្មកសិកម្ម ខេត្តពោធិសាត់ កំពង់ឆ្នាំង ស្វាយរៀង ព្រៃវែង សៀមរាប បន្ទាយមានជ័យ តាកែវ កំពង់ចាម កំពង់ធំ បាត់ដំបង និងប៉ៃលិនទទួលបានលទ្ធផលដូចខាងក្រោម ÷

- បានធ្វើកិច្ចសន្យាកែតម្រូវចំពោះក្រុមហ៊ុននាំចូលសម្ភារកសិកម្មចំនួន៨ករណី ដើម្បីធ្វើការតម្រង់ទិសឱ្យក្រុមហ៊ុនកែតម្រូវកំហុសនិងបំពេញនូវលក្ខខណ្ឌច្បាប់និងលក្ខខណ្ឌបច្ចេកទេសឱ្យបានត្រឹមត្រូវតាមនីតិវិធី
- ត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសម្ភារកសិកម្មបានចំនួន៤៥១ដេប៉ូ ដោយបានចាត់វិធានការធ្វើកិច្ចសន្យាកែតម្រូវ ចំនួន ៦៩ ករណី និងស្នើសុំមន្ទីរកសិកម្ម ចេញលិខិតព្រមានចំនួន ៣០ ករណី
- បានស្នើសុំសម្រេចចេញលិខិតព្រមានលុបចោលបញ្ជិកានិងដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មមួយចំនួន

### ង- ការងារនីតិកម្មកសិកម្មរាជធានី ខេត្ត ÷

-ការគ្រប់គ្រងមូលដ្ឋានអាជីវកម្មសម្ភារកសិកម្ម នៅមូលដ្ឋានអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មគ្រប់រាជធានី ខេត្ត មានចំនួន៣.៦៥២ កន្លែងក្នុងនោះ មានលិខិតអនុញ្ញាតចំនួន៣.១៤៣កន្លែងត្រូវជា៨៦% (ឆ្នាំ២០១០ មាន ៨០%) និងគ្មានលិខិតអនុញ្ញាតចំនួន៥០៩កន្លែងត្រូវជា ១៤% (ឆ្នាំ២០១០ មាន ២០%)។

-សកម្មភាពត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារកសិកម្ម បានត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសរុបចំនួន ៧៦៥លើក ត្រូវជា ៣.៦៦៨ដេប៉ូ និងបានចាត់វិធានការចំពោះបទល្មើស ដែលប្រព្រឹត្តដោយម្ចាស់មូលដ្ឋានអាជីវកម្ម ដូចជាស្នើឱ្យមន្ទីរកសិកម្មខេត្តចេញលិខិតព្រមានចំនួន៣០ករណី ទន្ទឹមនឹងនោះមន្ទីរបានសម្រេចចេញលិខិតព្រមានចំនួន២៦ករណី បានធ្វើកិច្ចសន្យាកែតម្រូវចំនួន ៥៤៦ ករណី និងបញ្ជូនសំណុំរឿងទៅតុលាការចំនួន ០៤ករណី។

-សកម្មភាពផ្សព្វផ្សាយអប់រំការយល់ដឹងអំពី សម្ភារកសិកម្មបានអនុវត្តកម្មវិធីផ្សព្វផ្សាយនិងធ្វើការណែនាំផ្ទាល់ដល់អាជីវករចំនួន ៣៦៤ លើក គ្របដណ្តប់ លើ ឃុំចំនួន ៤៣១ ឃុំ និង ១០៨ ស្រុក និង មានអ្នកចូលរួមសរុបចំនួន ១០.៧៣០ នាក់។

### ច- ចំណូលនិងថវិកា

-ថវិកាចំណូល បានពីកម្រៃសេវាកម្មចុះបញ្ជិកាសម្ភារកសិកម្ម រួមមាន ២៧០.៦០០.០០០ រៀល

-ថវិកាដៃគូអភិវឌ្ឍន៍កម្មវិធី [JICA] CBQCAM/JICA/MAFF សរុបចំនួន ៨២៥.០១៦, ៥៥ USD

## ៥.៧.៤.២- វាយតម្លៃនិងសំណើ

ទោះជាភាពខ្វះខាតក្នុងការគ្រប់គ្រងសម្ភារកសិកម្ម នៅតែមានសេសសល់នៅឡើយ ប៉ុន្តែភាពជឿនលឿន ចំពោះមុខបានធ្វើឱ្យមានការប្រែប្រួលច្រើនក្នុងការគ្រប់គ្រងសម្ភារកសិកម្មបច្ចុប្បន្ន ដែលបាន បង្ហាញនូវការខិតខំដ៏ សកម្មរបស់អង្គភាពនីតិកម្ម កសិកម្មកន្លងមកក្នុងការជំនះលើរាល់ឧបសគ្គ និងភាពខ្វះខាត។ លទ្ធផលនេះនឹងបង្កនូវភាពសុទិដ្ឋិនិយមសម្រាប់អង្គភាព ឱ្យបន្តបេសកកម្មរបស់ខ្លួនទៅមុខទៀតរហូតទទួលបានជោគជ័យស្របតាមទិសដៅកំណត់។

## ៥.៧.៤.៣- វិធានការ

-សិក្សារៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងអនុវត្តកម្មវិធីផ្សព្វផ្សាយច្បាប់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

-ជំរុញឆ្លងការពិភាក្សានិងសម្រេចលើសេចក្តីព្រាងប្រកាសស្តីពី "នីតិវិធីនិងការតម្រូវបមាណីយសម្រាប់កិច្ចបញ្ជិកាជីកសិកម្ម" និងជំរុញឆ្លងការពិភាក្សានិងសម្រេចលើសេចក្តីព្រាងប្រកាសស្តីពី"នីតិវិធីនិងការតម្រូវបមាណីយសម្រាប់កិច្ចបញ្ជិកា ថ្នាំកសិកម្ម"

-ជំរុញការពិនិត្យសម្រេចលើសេចក្តីណែនាំស្តីពី "ព័ត៌មានបង្ហាញផ្លូវនិងកាតព្វកិច្ចពាណិជ្ជករសម្ភារកសិកម្ម" ដើម្បីសម្រួលដល់អតិថិជនដែលស្នើសុំធ្វើអាជីវកម្ម ចុះបញ្ជិកា និងនាំចូលសម្ភារកសិកម្ម ស្របតាមផែនការសកម្មភាពអនុវត្តគោលនយោបាយជម្រុញផលិតកម្មស្រូវនិងការនាំចេញអង្ករ

-ជំរុញដំណើរការឆ្លងសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុញ្ញា Rotterdam ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

-ជំរុញការអនុវត្តកម្មវិធីតាមដាន ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ចំពោះសកម្មភាពអាជីវកម្ម ការនាំចូល ការផលិត ការផ្គត់ផ្គង់ចែកចាយ និងមូលដ្ឋានធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មនៅរាជធានី ខេត្ត គោលដៅនិងទូទាំងប្រទេស និងជំរុញការអនុវត្តកម្មវិធីវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករលក់ដុំលក់រាយសម្ភារកសិកម្ម នៅបណ្តារាជធានី ខេត្តគោលដៅ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាពក្នុងការធ្វើអាជីវកម្មសម្ភារកសិកម្ម

-បន្តការពង្រឹងសមត្ថភាពរបស់នាយកដ្ឋាននីតិកម្មកសិកម្ម លើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍ វិភាគគុណភាព ជីកសិកម្ម លើកកម្ពស់ប្រសិទ្ធភាពការងារបម្រើសេវាកម្មអាជីវកម្មសម្ភារកសិកម្ម និង អភិវឌ្ឍន៍សមត្ថភាពមន្ត្រីតាមមុខជំនាញ

-បន្តការពង្រឹងសមត្ថភាពអង្គភាពនីតិកម្មកសិកម្មរាជធានី ខេត្ត ក្នុងការបំពេញសមត្ថកិច្ចគ្រប់គ្រងសម្ភារកសិកម្ម តាមរយៈការចុះដឹកនាំ ហ្វឹកហាត់ការងារដល់មន្ត្រីជំនាញដោយផ្ទាល់នៅមូលដ្ឋាន

-បន្តការស្វែងរកដៃគូរអភិវឌ្ឍន៍ ដើម្បីទ្រទ្រង់ដំណើរការរបស់អង្គភាព ក៏ដូចជាបន្តអនុវត្តគម្រោងជំនួយដែលមានស្រាប់ ឬកំពុងដំណើរការក្នុងក្របខណ្ឌពង្រឹងសមត្ថភាពរបស់ អង្គភាពនីតិកម្មកសិកម្ម។

## ៥.៧.៥-ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង

### ៥.៧.៥.១-លទ្ធផល

### ក- ការងារអធិការកិច្ច

-ចុះស្រាវជ្រាវនិងដោះស្រាយបណ្តឹងនិងករណីធ្វើអ្វីខុសច្បាប់នៅស្រុកប្រាសាទសំបូរ សណ្តាន់ ខេត្តកំពង់ធំ។

-ចុះត្រួតពិនិត្យការអនុវត្តគោលការណ៍ថ្មីៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យផលិតកម្មនិងបសុព្យាបាល នៅខេត្តកំពង់ស្ពឺនិងរាជធានីភ្នំពេញ និងស្រាវជ្រាវករណីបាតុភាពកន្លែងសាងសង់ទូកនេសាទ (អ៊ូទូក) និងការដឹកនាំគ្រប់គ្រងនៅខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ

-ចុះផ្ទៀងផ្ទាត់ការអនុវត្តគោលការណ៍ ជាពិសេសលិខិតលេខ៦០៥កសកចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ នៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម ព្រៃវែង ស្វាយរៀង និងតាកែវ

-ចុះត្រួតពិនិត្យការធ្វើអាជីវកម្មឡូត៍នេសាទនិងបទល្មើសនេសាទ នៅខេត្តកណ្តាល កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ

-ចុះត្រួតពិនិត្យលើការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទ ដូចជាខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី កំពង់ធំ សៀមរាប ព្រះវិហារ កំពង់ឆ្នាំង ពោធិសាត់ និងបាត់ដំបង និងស្រាវជ្រាវលើការងារគ្រប់គ្រងផលិតកម្មនិងបសុព្យាបាលនៅខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ពោធិសាត់ ព្រៃវែង សៀមរាប និងព្រះសីហនុ។

-ចុះត្រួតពិនិត្យនិងស្រាវជ្រាវជាក់ស្តែងនូវបញ្ហាដីទាំង០៥កន្លែងដែលមន្ទីរកសិកម្មខេត្តបាត់ដំបង ស្នើសុំលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

-សម្របសម្រួលជាមួយអាជ្ញាធរខេត្តស្វាយរៀងពាក់ព័ន្ធដីសម្បទានសេដ្ឋកិច្ចនិងស្ថានីយដាំឈើក្រសាំងនិងត្រួតពិនិត្យការធ្វើអាជីវកម្មឡូត៍នេសាទ នៅខេត្តកណ្តាលនិងរាជធានីភ្នំពេញ និងពិនិត្យរៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងអង្គភាពនានា។

## ១- លទ្ធផលការងារ

-ការងារផលិតកម្មនិងបសុព្យាបាលនិងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសអាជីវកម្មចលនាសត្វ ត្រូវជំរុញការងារត្រួតពិនិត្យនិងទប់ស្កាត់ឱ្យបាននូវការលួចនាំជ្រូកពីប្រទេសជិតខាង ជាពិសេសត្រូវយកចិត្តទុកដាក់តាមដានសត្វដែលយកមកបង្ខាំងទុកស្ថានីយចត្តាឡីស័កឱ្យបានជិតដល់ជៀសវាងសត្វស្លាប់ដោយគ្មានមូលហេតុ និងខ្វះការទទួលខុសត្រូវ

-ការងារកសិកម្ម ផលិតកម្មនិងបសុព្យាបាលខេត្តកណ្តាល ត្រូវបញ្ឈប់ការចេញលិខិត អនុញ្ញាតឱ្យដឹកជញ្ជូនជ្រូក និងវិញ្ញាបនបត្រអនាម័យសត្វការបន្លំសត្វនាំចូលដោយខុសច្បាប់

-ធ្វើការណែនាំដល់ខណ្ឌរដ្ឋបាលជលផលកំពង់ធំនិងបាត់ដំបង អំពីការប្រើប្រាស់ឧបករណ៍នេសាទ លបបណ លបឡុក លបរ៉ាវមិនសមស្រប ហើយមិនមានចែងក្នុងប្រកាសស្តីពីការកំណត់ឧបករណ៍ នេសាទដែលបានធ្វើនេសាទនៅតំបន់ លបបណ លបរ៉ាវ។ ត្រូវពិនិត្យមើលនូវឧបករណ៍នេសាទទាំងនោះថា ត្រឹមត្រូវ តាមច្បាប់និងលិខិតបទដ្ឋានដែរឬទេ មុននឹងស្នើសុំគោលការណ៍សម្រេចពីរដ្ឋបាលជលផលថ្នាក់កណ្តាល ចៀសវាងការសម្រេចពីថ្នាក់លើទៅហើយឧបករណ៍នេសាទមានលក្ខណៈមិនសមស្រប ហើយត្រូវត្រួតពិនិត្យការអនុវត្តឱ្យបានត្រឹមត្រូវតាមការអនុញ្ញាត។

-ចាត់វិធានការដល់បណ្តាខណ្ឌរដ្ឋបាលជលផលជុំវិញបឹងទន្លេសាបនិងអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ឱ្យរុះរើរបាំងព្រួលនិងបង្គោលឡូត៍នេសាទទាំងអស់ឱ្យបានមុនរដូវបិទនេសាទ។

-តាមរយៈលិខិតលេខ៦៣៤៣កសក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ក្រសួងសម្រេចឱ្យរដ្ឋបាលជលផលពិនិត្យការអនុវត្តគោលការណ៍ និងបញ្ឈប់ការចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុន ចាន់ ធូមានជ័យ អ៊ឹមផត អ៊ិចផត ដឹកជញ្ជូនត្រីឆ្មៀបកាត់ក្បាលពីប្រទេសវៀតណាមចូលមកប្រទេសកម្ពុជាទៀត។ ទន្ទឹមនេះ ត្រូវធ្វើការផ្សព្វផ្សាយឱ្យដល់សង្កាត់ផ្នែកខណ្ឌរដ្ឋបាលជលផលទាំងអស់ធ្វើការត្រួតពិនិត្យឱ្យបានម៉ឺនម៉ាត់ចាប់ពីថ្ងៃនេះតទៅ និងចាត់វិធានការត្រួតពិនិត្យឱ្យបានតឹងរឹងរាល់ការនាំចូល និងនាំឆ្លងកាត់ផលិតផលជលផលពីប្រទេសដែលមានគោលការណ៍អនុញ្ញាតពីក្រសួង ចៀសវាងការបន្លំនាំចូលត្រីឆ្មៀបកាត់ក្បាល និងត្រីឆ្ពោ ដោយខុសច្បាប់។

## ២- វិធានការ

-បន្តពង្រឹងសមត្ថភាពមន្ត្រីក្រោមឱវាទឱ្យខិតខំរៀនសូត្រនូវបទពិសោធន៍ល្អៗ ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព និងក្តាប់សភាពការណ៍ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តការងារ

-ត្រួតពិនិត្យស្រាវជ្រាវការងារដឹកនាំគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានី ខេត្ត ដោយផ្តោតលើការងារប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិឱ្យស្របតាមគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញ និងវិស័យផលិតកម្មនិងបសុព្យាបាល

-ត្រួតពិនិត្យលើការទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទគ្រប់ប្រភេទ នៅរដូវបិទនិងបើកនេសាទ ព្រមទាំងការងារដឹកនាំរបស់អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល

-ត្រួតពិនិត្យលើសកម្មភាពទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់សមត្ថកិច្ចរដ្ឋបាលព្រៃឈើ

-ត្រួតពិនិត្យការអនុវត្តរបស់មន្ត្រីផលិតកម្មនិងបសុព្យាបាល លើការងារនាំសត្វជ្រូកនិងគោក្របីឆ្លងកាត់

-ត្រួតពិនិត្យលើការងារគ្រប់គ្រងនិងទប់ស្កាត់ការនាំចូលបមាណីនិងសម្ភារកសិកម្ម ដែលលក់លើទីផ្សារដោយខុសច្បាប់តាមបណ្តាលរាជធានី ខេត្ត និងប្រតិបត្តិការងារផ្សេងៗដែលក្រសួងផ្តល់ឱ្យ។

## ខ- សវនកម្មផ្ទៃក្នុង

### ១. ការងារចុះធ្វើសវនកម្មផ្ទៃក្នុង

-ការងារសវនកម្មផ្ទៃក្នុងបានបន្តចុះធ្វើសវនកម្មនៅរដ្ឋបាលព្រៃឈើ ចុះត្រួតពិនិត្យឡើងវិញនូវការណែនាំអនុវត្តអនុសាសន៍ នៃការធ្វើសវនកម្មផ្ទៃក្នុងនៅមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ និងប៉ៃលិន

-ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ២០១១ អង្គភាពថ្នាក់កណ្តាល គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរកសិកម្មរាជធានី-ខេត្ត

-ចុះធ្វើសវនកម្មតាមអង្គភាពខាងលើ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងអាជ្ញាធរសវនកម្មជាតិជាបន្តបន្ទាប់និងទាន់ពេលវេលា។

## ២. ការងាយស្រួលនិងការលំបាក

### ២.១. ការងាយស្រួល

-តាមរយៈសារាចរណែនាំលេខ០១សរ.ណន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ លេខ១២សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួងស្ថាប័ននិងសហគ្រាសសាធារណៈនិងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួង ដែលតែងតែណែនាំនិងផ្តល់អនុសាសន៍ល្អៗ ដល់ការងារសវនកម្មផ្ទៃក្នុង

-មន្ត្រីមានការរីកចម្រើចំណេះដឹងជាងមុន ដោយសារមានការបណ្តុះបណ្តាលជាបន្តបន្ទាប់

-មន្ត្រីមានការមានសមត្ថភាព មានសាមគ្គីភាពផ្ទៃក្នុង និងទទួលខុសត្រូវក្នុងការងារ ។

### ២.២. ការលំបាក

-មន្ត្រីមិនទាន់មានជំនាញសវនកម្មគ្រប់គ្រាន់និងមិនទាន់មានបទពិសោធពេញលេញដែលទាមទារត្រូវធ្វើការស្វែងយល់និងទទួលការបណ្តុះបណ្តាលបន្ថែមទៀតទាំងជំនាញសវនកម្មនិងផ្នែកភាសាអង់គ្លេស

-សម្ភារការិយាល័យពុំទាន់មានគ្រប់គ្រាន់និងផ្តល់ឲទាន់ពេលវេលាតាមតម្រូវការនិងទំហំការងារ

-ការកំណត់រយៈពេលឲចុះបេសកកម្មមានរយៈពេលខ្លីពេកមិនសមស្របនឹងទំហំការងារដែលត្រូវអនុវត្ត

-ប្រាក់បេសកកម្មបើកផ្តល់មិនទាន់ពេលវេលា

-អង្គភាពរងសវនកម្មមួយចំនួនមិនបានផ្ញើរបាយការណ៍សកម្មភាពការងារ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសនីមួយៗនៃឆ្នាំរាយការណ៍ បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងរបាយការណ៍កែលម្អមកនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីជាមូលដ្ឋានតាមដាននិងជួយផ្តល់យោបល់ទាន់ពេលវេលា ។

### ២.៣. ទិសដៅអនុវត្ត

-បន្តស្វែងយល់លិខិតបទដ្ឋានច្បាប់និងប្រមូលព័ត៌មានដែលពាក់ព័ន្ធការងារសវនកម្ម

-ពង្រឹងការអនុវត្តភារកិច្ចសវនកម្មតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជានិងអនុក្រឹត្យលេខ៤០អនក្រ.បកចុះថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០០៥របស់រាជរដ្ឋាភិបាលកម្ពុជា

-បន្តចូលរួមវគ្គបណ្តុះបណ្តាលនានាដែលរៀបចំឡើងដោយក្រុមប្រឹក្សាកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ២០១២ដែលបានអនុម័តនិងតាមបញ្ជារបស់ថ្នាក់ដឹកនាំក្រសួង និងបន្តតាមដានការកែលម្អអង្គភាពរងសវនកម្ម

-ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសវនកម្មជាតិនិងសវនកម្មផ្ទៃក្នុងតាមស្ថាប័ននានា

-បន្តសហការជាមួយក្រុមជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី ADB នៃគម្រោង PFMRDP Component 2 (Public Financial Management for Rural Development)។

### ៥.៧.៦-ការងារស្រាវជ្រាវកសិកម្ម

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាមានមន្ត្រី-និយោជិតសរុបចំនួន ១៥៦នាក់ (មន្ត្រីរាជការចំនួន៨៦នាក់) ក្នុងនោះមាននារីចំនួន៤០នាក់។ អនុវត្តតាមតួនាទីនិងភារកិច្ចរបស់ខ្លួន ជាពិសេសដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេចបាននូវគោលនយោបាយចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ២០១១នេះ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានបន្តការខិតខំប្រឹងប្រែងអនុវត្តយ៉ាងសស្រាក់សស្រាំលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ (១)ការអភិវឌ្ឍន៍ពូជដំណាំផ្សេងៗ រួមមានស្រូវ ពោត សណ្តែក ដំឡូងមី បន្លែ ឈើហូបផ្លែ ដំណាំលម្អ (២)ការគ្រប់គ្រងជីជាតិដី និងសារធាតុចិញ្ចឹម (៣)ការអភិវឌ្ឍន៍បច្ចេកទេសដាំដុះនិងប្រព័ន្ធកសិកម្ម (៤)ការការពារដំណាំពីការបំផ្លាញរបស់កត្តាចង្រៃផ្សេងៗមានដូចជា សត្វល្អិតចង្រៃស្មៅនិងជំងឺ (៥)ការអភិវឌ្ឍន៍បច្ចេកទេសមុននិងក្រោយពេលប្រមូលផល (៦)ការវិភាគសេដ្ឋកិច្ចសង្គមពាក់ព័ន្ធវិស័យកសិកម្ម និង (៧)ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសនិងព័ត៌មានកសិកម្ម។ ទន្ទឹមនឹងនេះ បាន

ប្រារព្ធពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវកម្រងឯកសារបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ ក្រោមអធិបតីភាព របស់ **ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សមិទ្ធផលការងារស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ របស់វិទ្យាស្ថានចែកចេញជា៦ផ្នែកធំៗ ដែលសរុបទាំងអស់មានចំនួន២៧ចំណុចដូចខាងក្រោម÷

## ក. ការងារអភិរក្ស

**-ពូជដំណាំៈ** បានបន្តការអភិរក្សពូជស្រូវចំនួន២៥៩៥បញ្ជីកនិងដំណាំផ្សេងៗចំនួន១៥ប្រភេទ មានចំនួនសរុប៣៧៤សំណាក។ ទន្ទឹមនឹងនេះ បានធ្វើយុវកម្មពូជស្រូវ២០៧៥បញ្ជីកនិងម្ទេស៣៥សំណាក បានធ្វើយុវកម្មដើម្បីធានានូវគុណភាព ដំណុះគ្រាប់និងតម្រូវការលើការងារពិសោធន៍ស្រាវជ្រាវ។

**-សម្ពហកម្មសត្វល្អិតៈ** បានបន្តថែរក្សានិងធ្វើការប្រមូលសត្វល្អិតបន្ថែមលើដំណាំស្រូវចំនួន៥ប្រភេទ (ទ្រីបជញ្ជក់ស្លឹក ខ្យងស្រូវពណ៌មាស ដង្កូវមូរស្លឹក ចៃស្រូវ និងដង្កូវរុយ) លើដំណាំសណ្តែកបាយចំនួន៤ប្រភេទ (ដង្កូវស៊ីរូងផ្លែ ដង្កូវរុយ ដង្កូវហ្វូងនិងស្រឹងម្ទូល) លើដំណាំពោតចំនួន៣ប្រភេទ (ចៃពោត ដង្កូវស៊ីរូងផ្លែពោតនិងដង្កូវស៊ីរូងដើមពោត) លើដំណាំឪឡឹកចំនួន២ប្រភេទ (ចៃកប្បាសនិងដង្កូវផែនទី) លើដំណាំស្វាយចំនួន៦ប្រភេទ (ដង្កូវស៊ីរូងដើមនិងឬស រុយចោះផ្លែ ស្តែលស្វាយ ដង្កូវស៊ីរូងមែក ក្រាស្វាយ និងចៃស្វាយពណ៌ខ្មៅ) និងលើដំណាំប៉េងប៉ោះចំនួន២ប្រភេទ (ដង្កូវហ្វូងនិងចៃពណ៌ខ្មៅ)។

## ខ. ការអភិវឌ្ឍន៍និងជ្រើសរើសពូជដំណាំ

-បានធ្វើការបង្កាត់និងបង្កាត់ត្រឡប់ ដើម្បីអភិវឌ្ឍពូជស្រូវសំខាន់ៗចំនួន១០ពូជឲ្យមានភាពធន់ទ្រាំនឹងរាំងស្ងួត ទឹកជំនន់ ធន់ទ្រាំនឹងមមាចត្នោត ដើមដងរឹងមិនងាយដួល ធន់នឹងកំដៅនិងគុណភាពល្អបានចំនួន៣០បង្កាត់ ព្រមទាំងដាំជ្រើសរើសស្រឡាយស្រូវក្នុងជំនាន់ផ្សេងៗបានចំនួនជាង២០០ស្រឡាយ។

-បានធ្វើពិសោធន៍ជ្រើសរើសស្រឡាយស្រូវនិងដំណាំផ្សេងៗទៀត ជាង១២០០ស្រឡាយ និងបានជ្រើសរើស (១) ស្រឡាយស្រូវស្រាលពី ៨០-១០០ថ្ងៃបានចំនួន ១៥ស្រឡាយ (២)ស្រឡាយស្រូវធន់ទ្រាំនឹងរាំងស្ងួតបាន ២៥ស្រឡាយ (៣) ស្រឡាយស្រូវធន់នឹងទឹកជំនន់បាន១០ស្រឡាយ (៤) ស្រឡាយស្រូវក្រអូបបាន២០ស្រឡាយ និង(៥) ស្រឡាយស្រូវមានទិន្នផលខ្ពស់បានចំនួនជាង៣០ស្រឡាយ និងស្រឡាយស្រូវធន់ទ្រាំមធ្យមទៅនឹងមមាចត្នោតបាន២ស្រឡាយសម្រាប់ ធ្វើការងារពិសោធន៍បន្តទៀត។

## គ. ការបង្កើនផលិតភាពដំណាំ

**-តាមរយៈលទ្ធផលស្រែបង្ហាញចំនួន១១កន្លែងនៅខេត្តស្ទឹងត្រែងនិងមណ្ឌលគិរីបង្ហាញថាៈ** (១)ការប្រើប្រាស់ពូជស្រូវបញ្ចេញដោយវិទ្យាស្ថាន ទិន្នផលស្រូវដាំដុះតាមទម្លាប់កសិករកើនពី៣,២៨ត/ហ.តទៅ៤,១១ត/ហ.ត និង (២) ការប្រើប្រាស់បង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវបានកើនរហូតដល់៥,៤៣ត/ហ.ត។ ក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ (២០០៨-២០១១) លទ្ធផលនៃស្រែបង្ហាញចំនួន៦៤កន្លែងក្នុងខេត្តកំពង់ចាម សៀមរាប ស្ទឹងត្រែងនិងមណ្ឌលគិរី បានបញ្ជាក់ថាៈ (១)ការជំនួសពូជស្រូវកសិករដោយពូជស្រូវវិទ្យាស្ថានបង្កើននូវទិន្នផលចំនួន០,៨ត/ហ.ត (២) ការអនុវត្តន៍តាមបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវបានបង្កើននូវទិន្នផលពី២,១៧ត/ហ.តទៅ៤,១១ត/ហ.ត គឺជិតពីរដងនៃទម្លាប់របស់កសិករដូចមានបង្ហាញក្នុងក្រាហ្វិចខាងក្រោមៈ




· តាមរយៈការធ្វើពិសោធន៍ចំនួន២នៅក្នុងវិទ្យាស្ថានបានបង្ហាញថាដង្កូវផែនទីបំផ្លាញធ្ងន់ធ្ងរក្នុងដំណាក់កាលកូនប៉េងប៉ោះ រីឯដង្កូវហ្វូងបំផ្លាញនៅដំណាក់កាលលូតលាស់រហូតដល់ដំណាក់កាលទុំនិងដង្កូវស៊ីរូងផ្លែបំផ្លាញខ្លាំង នៅដំណាក់កាលក្តិបរហូតដល់

ទុំ។ ចំពោះដំងឺខ្មោចស្លឹកបំផ្លាញតិចតួចត្រឹមតែ២៥%នៅដំណាក់កាលលូតលាស់។ ដោយឡែកការបំផ្លាញដោយដង្កូវស៊ីរូង ផ្លែមានប្រហែល៦០%នៅដំណាក់កាលក្តិប ប៉ុន្តែក្រោយពេលបាញ់ថ្នាំពុលជីវសាស្ត្រប្រភេទ Bacillus Thuringiensis បានបង្ហាញថាកម្រិតបំផ្លាញបានថយចុះ និងគ្មានវត្តមានដង្កូវ ផ្លែរងការបំផ្លាញនៅពេលប្រមូលផល និងទិន្នផលសរុបបានកើនឡើងប្រមាណ២ត/ហ.ត។

**-ប្រសិទ្ធភាពនៃការប្រើជី NPK និងគម្របដីលើដំណាំសណ្តែកបាយដាំដុះបន្ទាប់ពីស្រូវរដូវវស្សា :** ការប្រើប្រាស់ចម្បើងគ្របដីក្នុងកម្រិត៥តោន/ហ.ត បានបង្កើនអត្រាដំណុះគ្រាប់ប្រមាណជា៦៧%ជាមួយនឹងកំណើនទិន្នផលគ្រាប់ប្រមាណ៤៣% គឺពី៥២០គ.ក្រ/ហ.ត (មិនគ្របដី)ទៅ៧៤៣គ.ក្រ/ហ.ត (គ្របដីដោយចំបើង)។ ចំណែកឯការប្រើប្រាស់ជី NPK ក្នុងកម្រិត៩០-៦០-៣០គ./ហ.ត បានធ្វើឲ្យទិន្នផលកើនឡើងប្រមាណជា២ដង បើធៀបជាមួយមិនដាក់ជីដូចមានបង្ហាញ ក្នុងក្រាហ្វិចខាងក្រោមៈ




**-ឥទ្ធិពលរយៈពេលវែងនៃអន្តរកម្មរវាងជី NPK និងជីសរីរាង្គផ្សេងៗគ្នាទៅលើជីជាតិដីនិងស្រូវក្រអូបសែនពិដោរៈ** ការប្រើប្រាស់ជីគីមី (៥០:២៣:៣០) តែឯងនៅតែរក្សាបាននូវកំណើនទិន្នផលគ្រាប់ស្រូវក្នុងរយៈពេល១១ដំណាំកន្លងមក។ ចំណែកឯការដាក់ជីលាមកគោ៥ត/ហ.ត រួមផ្សំជាមួយជីគីមី NPK នៅតែរក្សាបាននូវស្ថេរភាពទិន្នផលល្អប្រសើរ ដោយទទួលទិន្នផលជាមធ្យម៣,៥ត/ហ.ត។ ការបន្ថែមសារធាតុកែប្រែដី (១ត/ហ.តកំបោរ) បានបង្កើននូវប្រសិទ្ធភាពនៃការប្រើប្រាស់ជីគីមីបន្ថែមទៀត ដែលទិន្នផលជាមធ្យមគឺ៣,១៣ត/ហ.ត។

**-ការតាមដានដំណើរបំលែងអាសូតក្នុងស្រទាប់ដីនិងទឹកៈ** អាសូតនៅក្នុងស្រទាប់ដី បន្ទាប់ពីមានការប្រើប្រាស់ជីអ៊ុយរ៉េត្រូវបានបំលែងជាទម្រង់ពីរគឺ $NO_3^-$ និង $NH_4^+$។ រយៈពេល១ថ្ងៃក្រោយមកអាសូតក្នុងទម្រង់ទាំងពីរមានការកើនឡើង០,៣ម.ក្រ/លីត្រ។ វត្តមានអាសូតបានបន្តកើនឡើងនៅថ្ងៃបន្ទាប់ហើយខ្ពស់បំផុត០,៦ម.ក្រ/លីត្រ បន្ទាប់ពីមានការប្រើប្រាស់អាសូត៣ថ្ងៃក្នុងពេលដែល $NO_3^-$ ថយចុះស្មើសូន្យនៅថ្ងៃទី២បន្ទាប់ពីមានការបំប៉នអ៊ុយរ៉េ។ ទោះជាយ៉ាងណាក្តី ប្រសិទ្ធភាពនៃជីអាសូតមានការប្រែប្រួលខ្លាំងទៅតាមរបបទឹកក្នុងស្រែ (ដីស្ងួតឬលិចទឹកច្រើន) ហើយទិន្នផលស្រូវក៏អាចប្រែប្រួលទៅតាមលក្ខខណ្ឌនេះដែរ។

## ឃ. ពិពិធកម្មនិងការអង្កេត

**-ការធ្វើពិពិធកម្មដំណាំសណ្តែកក្រោយពេលប្រមូលផលស្រូវនិងប្រព័ន្ធកសិកម្មគម្រូ (Model Farm):** តាមរយៈលទ្ធផលនៃការស្រាវជ្រាវនៅខេត្តតាកែវបានបង្ហាញថា ការដាំដុះដំណាំសណ្តែកក្រោយពេលប្រមូលផលស្រូវបានបង្កើនប្រាក់ចំណូលបន្ថែមនិងបានជួយបង្កើនជីជាតិដីស្រែ ប៉ុន្តែកសិករត្រូវធ្វើការថែទាំនិងស្រោចស្រពដំណាំឲ្យបានល្អ។ ការអនុវត្តន៍នូវប្រព័ន្ធកសិកម្មគម្រូគឺជាប្រព័ន្ធមួយដែលល្អនិងសមស្របសម្រាប់អនុវត្ត ពីព្រោះបានបង្កើនប្រាក់ចំណូលផ្តល់នូវស្ថេរភាពខាងចំណីអាហារនិងបរិស្ថានល្អ។ ការអនុវត្តន៍ប្រព័ន្ធកសិកម្មគំរូត្រូវការថវិកា ក្នុងការជីកឬស្តារស្រះរក្សាទឹកនិងទិញម៉ាស៊ីនបូមទឹកសម្រាប់ស្រោចស្រពដំណាំ។

**-បង្កើបច្ចេកទេសដាំដុះដំណាំសណ្តែកបាយបន្ទាប់ពីស្រូវវស្សា** ៖ តាមរយៈលទ្ធផលនៃការស្រាវជ្រាវនៅខេត្តតាកែវ កំពត និងកំពង់ធំ សរុបចំនួន១៨ពិសោធន៍បានបង្ហាញថា ការដាំដុះសណ្តែកបាយបន្ទាប់ពីដំណាំស្រូវ ដោយប្រើប្រាស់បច្ចេកវិទ្យារបស់វិទ្យាស្ថាន បានធ្វើឱ្យសណ្តែកបាយផ្តល់ទិន្នផលជាមធ្យម៧៨៧គ.ក្រ/ហ.ត គឺកើនឡើងទ្វេរដងធៀបនឹងបច្ចេកវិទ្យាតាមទម្លាប់កសិករនិងទទួលបានប្រាក់ចំណេញក៏កើនឡើងទ្វេរដងផងដែរ។ ទន្ទឹមនឹងនេះ តាមរយៈកិច្ចសម្ភាសន៍កសិករចំនួន១០៩នាក់បានបង្ហាញថា ពួកគាត់ទាំងអស់គ្នាមានការពេញចិត្តក្នុងការដាំដុះដំណាំសណ្តែកបាយ បន្ទាប់ពីដំណាំស្រូវវស្សាដោយប្រើប្រាស់បច្ចេកវិទ្យារបស់វិទ្យាស្ថាន។

**-ការកាត់បន្ថយការបាត់បង់ផលស្រូវក្នុងពេលទុកដាក់** ៖ តាមរយៈការពិភាក្សាក្រុមកសិករ ដែលបានចូលរួមធ្វើការងារពិសោធន៍និងបណ្តុះបណ្តាលពីវិទ្យាស្ថានអំពីការទុកដាក់ស្រូវពូជបានបង្ហាញថា វិធីសាស្ត្រដែលល្អនិងពេញនិយមជាងគេ គឺការប្រើប្រាស់ដែលមានថង់ប្លាស្ទិកខាងក្នុង ព្រោះវាធ្វើឱ្យគ្រាប់ពូជមានអត្រាដំណុះខ្ពស់ អាចការពារបានច្រើនពីការបំផ្លាញរបស់សត្វកណ្តុរនិងចាប និងមានតម្លៃសមរម្យ ដែលកសិករអាចមានលទ្ធភាពប្រើប្រាស់បាន។

**-ខ្សែសង្វាក់ផ្គត់ផ្គង់បន្លែ** ៖ តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ខេត្តកណ្តាលគឺជាខេត្ត ដែលមានសក្តានុពលសម្រាប់ដំណាំបន្លែពិសេសគឺពពួកបន្លែយកស្លឹក ផ្ទុយពីស្ថានភាពដាំដុះបន្លែក្នុងខេត្តកំពត ដែលបន្លែភាគច្រើនគឺបាននាំចូលពីប្រទេសវៀតណាម។ ចំពោះរាជធានីភ្នំពេញមានការហូរចូលបន្លែពីប្រទេសវៀតណាម ដូចគ្នានិងបន្លែក្នុងស្រុកមកពីបណ្តាខេត្តមួយចំនួន ប៉ុន្តែខេត្តដែលគួរកត់សម្គាល់ជាងគេគឺខេត្តកណ្តាល (បន្លែយកស្លឹក)។ ចំពោះខ្សែសង្វាក់ផ្គត់ផ្គង់នៃទីផ្សារបន្លែគឺ អាស្រ័យទៅលើអ្នកប្រមូលទិញនិងឈ្មួញកណ្តាល (ក្នុងតំបន់និងក្រៅតំបន់) ដោយផ្អែកលើការប្រកួតប្រជែងតម្លៃ គុណភាព បរិមាណ រដូវកាល និងបន្លែនាំចូលព្រមទាំងការលក់ទៅដល់ដៃអ្នកប្រើប្រាស់ចុងក្រោយ។ សរុបមកទោះជាខេត្តកណ្តាលមានឱកាសទីផ្សារអំណោយផល ប៉ុន្តែក៏ត្រូវការពង្រីកបរិមាណផ្គត់ផ្គង់បន្ថែមហើយ ចំណុចជាយុទ្ធសាស្ត្រទីផ្សារសំខាន់គឺការបង្កើនវិធីសាស្ត្រផលិត។ ម្យ៉ាងវិញទៀតកសិករនៅតែត្រូវការការគាំទ្រផ្នែកបច្ចេកទេសលើបណ្តាញព័ត៌មានទីផ្សារនិងយុទ្ធសាស្ត្រទីផ្សារផ្សេងៗ រួមទាំងការកែលម្អបច្ចេកទេសដាំដុះ ប្រមូលផល ការវិចខ្ចប់ ទុកដាក់និងការដឹកជញ្ជូនប្រកបដោយសុវត្ថិភាព។

## ង. មន្ទីរពិសោធន៍

**-មន្ទីរពិសោធន៍ជីវបច្ចេកវិទ្យា**៖ បានរៀបចំបំពាក់បំពេញនូវឧបករណ៍និងសារធាតុវិភាគសម្រាប់ធ្វើការកំណត់ពន្ធុដោយប្រើសារធាតុសម្គាល់ជាជំនួយ (Marker Assisted Selection)។

**-មន្ទីរពិសោធន៍គុណភាពអង្ករ**៖ បានរៀបចំបំពាក់បំពេញនូវឧបករណ៍និងសារធាតុវិភាគ។

**-មន្ទីរពិសោធន៍វិភាគដីនិងទឹក**៖ បានបន្តអភិវឌ្ឍមន្ទីរពិសោធន៍វិភាគគីមី តាមរយៈការកែប្រែប្រព័ន្ធផលិតទឹកស្អាតឱ្យមានលក្ខណៈប្រសើរឡើងដើម្បីធានានូវសុក្រិតភាពនៃការវិភាគគីមី។ ឧបករណ៍វិភាគនិងសម្ភារបរិក្ខារបន្ថែមមន្ទីរពិសោធន៍ក៏ត្រូវបានបំពាក់បន្ថែមសំដៅឱ្យការវិភាគគីមីកាន់តែមានប្រសិទ្ធភាពខ្ពស់។ បានអភិវឌ្ឍទេពកោសល្យការងារគ្រប់គ្រងមន្ទីរពិសោធន៍វិភាគគីមីរួមមាន Quality Assurance និង Quality Control និងវិធីសាស្ត្រវិភាគដីមានដូចជា វាយនភាពដី ម៉ាស់មាឌដី កម្រិតសំណើមដីស្រែ កាបោនសរីរាង្គ សារធាតុសរីរាង្គក្នុងដី អាសូត (N) អាម៉ូញ៉ូម ($NH_4^+$) នីត្រាត ($NO_3^-$) ផូស្វ័រ (P) ប៉ូតាស្យូម (K) pH និង EC របស់ដី។ តាមរយៈការអភិវឌ្ឍន៍ទេពកោសល្យទាំងពីរផ្នែកខាងលើមន្ទីរពិសោធន៍បានវិភាគសំណាកដីនិងទឹករាប់រយសំណាករបស់គម្រោងស្រាវជ្រាវនានារបស់វិទ្យាស្ថាន។

**-មន្ទីរពិសោធន៍រុក្ខរោគសាស្ត្រ**៖ បានពង្រឹងមន្ទីរពិសោធន៍រុក្ខរោគសាស្ត្រឱ្យមានសមត្ថភាពធ្វើរោគវិនិច្ឆ័យនិងកំណត់បាននូវភ្នាក់ងារបង្កជំងឺរបស់ពពួកផ្សិតលើដំណាំកសិកម្ម។ ចំពោះជំងឺដែលបង្កដោយពួកបាក់តេរីនិងវីរុស អាចធ្វើរោគវិនិច្ឆ័យបាន ប៉ុន្តែពុំទាន់អាចកំណត់រកភ្នាក់ងារបង្កជំងឺបាននៅឡើយ ដោយសារពុំទាន់មានឧបករណ៍ជំនួយសម្រាប់វិភាគមើលពីភ្នាក់ងារ ឱ្យមានភាពច្បាស់លាស់។ បានធ្វើការបណ្តុះរកភ្នាក់ងារបង្ករោគ ដែលប្រមូលបាននៅក្នុងវិទ្យាស្ថានលើដំណាំស្រូវ (៤ប្រភេទ) សណ្តែកបាយ (២ប្រភេទ) សណ្តែកដី (២ប្រភេទ) ប៉េងប៉ោះ(៤ប្រភេទ) និងពោត (១ប្រភេទ)។

**-មន្ទីរពិសោធន៍តិណជាតិសាស្ត្រ:** បានប្រមូលស្មៅលើដំណាំស្រូវចំនួន១០ប្រភេទដើម្បីអភិរក្សទុកសម្រាប់ការងារសិក្សាស្រាវជ្រាវ។

## ច. ការផ្សព្វផ្សាយ បណ្តុះបណ្តាល និងសហប្រតិបត្តិការ

**-តាមរយៈកិច្ចប្រជុំក្រៅប្រទេស:** បានធ្វើបង្ហាញនូវលទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានទៅដល់អ្នកវិទ្យាសាស្ត្រពាក់ព័ន្ធបានចំនួន១៣លើក។

**-តាមរយៈការបោះពុម្ពនិងចែកចាយ:** បានសរសេរអត្ថបទវិទ្យាសាស្ត្រអំពី លទ្ធផលការងារស្រាវជ្រាវនិងបោះពុម្ពតាមរយៈទស្សនាវដ្ដីវិទ្យាសាស្ត្រនិងសៀវភៅសន្និសីទបានចំនួន១អត្ថបទ។

**-តាមរយៈអត្ថបទបច្ចេកទេស:** បានរៀបចំព្រឹត្តិបត្រព័ត៌មានកសិករ អត្ថបទបច្ចេកទេសនិងបោះពុម្ពសរុបចំនួន៧៧.៨៧០ច្បាប់ ព្រមទាំងរៀបចំបដាពាក់ព័ន្ធពូជស្រូវសំខាន់ៗចំនួន១០ពូជ ក្រុមដីសំខាន់ៗនិងឯកសារនានាសរុបចំនួន៥.៥៦៥ផ្ទាំង។ បានធ្វើការបែងចែកសៀវភៅកម្រងឯកសារអំពីក្សេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជា ការកំណត់ក្រុមដីស្រែលក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន១០ពូជ វិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវសរុបចំនួន៣៣.៥៥៣ច្បាប់ សៀវភៅបង្កបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវចំនួន១០.២២០ច្បាប់ បដាប្រភេទជីគីមី បរិមាណនិងពេលវេលាបាចជីសម្រាប់ពូជស្រូវ១០ពូជតាមក្រុមដីណែនាំដោយវិទ្យាស្ថាន ព្រមទាំងប្រូហ្វីលក្រុមដីសំខាន់ៗចំនួន៤.៧២០ផ្ទាំង របាយការណ៍ប្រចាំឆ្នាំរបស់វិទ្យាស្ថាន២០០៦-២០០៩ចំនួន៦៤១ច្បាប់។ បានធ្វើការបែងចែកសៀវភៅដំណាំស្រូវ (សៀវភៅសម្រាប់ការអនុវត្តជាក់ស្ដែងក្នុងការគ្រប់គ្រងសារធាតុចិញ្ចឹម) បានចំនួន៣០០ច្បាប់ សៀវភៅព្រឹត្តិបត្រព័ត៌មានកសិករចំនួន៤១៧៦ច្បាប់ សៀវភៅស្ដីពីការគ្រប់គ្រងជីជាតិដីចំនួន១៤០៨ច្បាប់ សៀវភៅស្ដីពីពូជស្រូវនិងបច្ចេកទេសដាំដុះចំនួន១៤០៨ច្បាប់និងសៀវភៅស្ដីពីពូជស្រូវសំខាន់ៗចំនួន១០ពូជចំនួន៣០០ច្បាប់ ព្រមទាំងព្រឹត្តិបត្រព័ត៌មានកសិករចំនួន១៦១៦សន្លឹក ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក សាលាឃុំនិងអ្នកពាក់ព័ន្ធជាពិសេសដល់កសិករ។

**-តាមរយៈគេហទំព័រ www.cardi.org.kh និង www.crkb.org.kh:** ក្នុងរយៈពេលមួយឆ្នាំនេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន៩១.២០០នាក់ ដោយគិតជាមធ្យមមានប្រមាណ២៥០នាក់/ថ្ងៃ ដែលក្នុងនោះក្នុងប្រទេសកម្ពុជាចំនួន៥១% សហរដ្ឋអាមេរិកចំនួន១៣% អូស្ត្រាលីចំនួន៦% ជប៉ុនចំនួន៥% ប្រទេសផ្សេងៗទៀត (១០៧ ប្រទេស) ចំនួន២៥%។

**-តាមរយៈទិវាស្រែបង្ហាញនិងបណ្តុះបណ្តាលកសិករ:** បានធ្វើទិវាស្រែបង្ហាញចំនួន១៧កន្លែង ដែលមានមន្ត្រីបច្ចេក-ទេសមន្ត្រីផ្សព្វផ្សាយនិងកសិករចូលរួមចំនួន១០០០នាក់ ព្រមទាំងបានបណ្តុះបណ្តាលកសិករចំនួន១០លើកដែលមានកសិករចូលរួមចំនួន២៥៦នាក់។

**-តាមរយៈការចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុនិងទូរទស្សន៍:** បានផ្ដល់បទសម្ភាសន៍ដល់ទូរទស្សន៍បាយ័នចំនួន០១ដងចូលរួមនៅទូរទស្សន៍ជាតិកម្ពុជាក្នុងវេទិកាតុមូលចំនួន០២ដង និងចូលរួមក្នុងគណៈកម្មការវាយតម្លៃក្នុងវេទិកាស្វែងយល់អំពីកសិកម្មចំនួន០៤ដង ចូលរួមជាវាគ្មិននៅវិទ្យុមាតុភូមិយើង FM១០១.២៥ ចំនួន០៧ដង ផ្ដល់បទសម្ភាសន៍ដល់វិទ្យុជាតិកម្ពុជាចំនួន០១ដងនិងវិទ្យុ ABC អូស្ត្រាលីជាភាសាខ្មែរចំនួន០៦ដង។

**-តាមរយៈសារណា:** បានដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្របានចំនួន១០នាក់ដែលក្នុងនោះ០២នាក់មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានិង០៨នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

**-ការងារបណ្តុះបណ្តាល:** បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន៩វគ្គដែលមានអ្នកចូលរួមសរុបចំនួន៣៩៤នាក់។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន១០លើកដែលមានមន្ត្រីវិទ្យាស្ថានទៅចូលរួមសរុបចំនួន២៤នាក់និងក្រៅប្រទេសចំនួន២៩លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន៣៩នាក់។

-**ការងារសហប្រតិបត្តិការៈ** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ទីរកសិកម្មរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេស CAVAC, ACIAR, UQ, CSIRO, DPINSW, IRRI, RDA, KOICA, KOPIA, FAO, DAI, IAS, University of Tokyo, YAAS ជាដើមបានល្អខ្ជាប់ខ្ជួន។

## ឆ- វាយតម្លៃនិងសំណើ

ក្នុងឆ្នាំ២០១១នេះថ្នាក់ដឹកនាំនិងមន្ត្រី-និយោជិតទាំងអស់បានខិតខំប្រឹងប្រែងដឹកនាំនិងបំពេញភារកិច្ចដើម្បីកសាងនិងអភិវឌ្ឍន៍វិទ្យាស្ថានដោយស្មារតីយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់ស្របតាមវិធានការ ដែលបានលើកឡើងក្នុងឆ្នាំ២០១០។ សមិទ្ធផលសំខាន់ៗមានជាអាទិ៍ (១)វិទ្យាស្ថានបានធ្វើពិសោធន៍ចំនួន៩០ប្រភេទ ដែលមានចំនួនពិសោធន៍សរុប៤៣៧កន្លែងនិងបានធ្វើអង្កេតចំនួន៨ប្រភេទមានចំនួន២៧៣៨កម្រងសំណួរ និងបានពិភាក្សាជាក្រុមចំនួន៧លើកមានអ្នកចូលរួមសរុប២០០នាក់ (២) បានប្រារព្ធទិវាស្រែបង្ហាញចំនួន១៧កន្លែងមានអ្នកចូលរួមចំនួន១០០០នាក់ និងបានបណ្តុះបណ្តាលកសិករចំនួន១០វគ្គមានអ្នកចូលរួមចំនួន២៨៦នាក់ រួមទាំងមន្ត្រីបច្ចេកទេសនិងមន្ត្រីផ្សព្វផ្សាយខេត្ត (៣)បានរៀបចំព្រឹត្តិបត្រព័ត៌មានកសិករ អត្ថបទបច្ចេកទេសបានចំនួន១០ប្រភេទនិងបោះពុម្ពសរុបចំនួន៣៧.៨៧០ច្បាប់ ដោយបានបែងចែកសៀវភៅឯកសារនានាសរុបចំនួន៤៨.៥៣០ច្បាប់ និងបដាអំពីក្រុមដីនិងកម្រិតជីសម្រាប់ដំណាំស្រូវចំនួន៥.៥៦៣ផ្ទាំងជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្តការិយាល័យកសិកម្មស្រុក សាលាឃុំនិងអ្នកពាក់ព័ន្ធដើម្បីចូលរួមអនុវត្តចតុកោណរបស់រាជរដ្ឋាភិបាល និងជាពិសេសគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ (៤)បានបង្កើតនិងជ្រើសរើសបាននូវស្រឡាយស្រូវមួយចំនួនដែលចាំបាច់សម្រាប់ធ្វើពិសោធន៍បន្ត និង(៥)បញ្ជាក់នូវបច្ចេកទេសបង្កើនផលិតភាពដំណាំមួយចំនួនដូចមានរៀបរាប់ខាងលើ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រី-និយោជិតទាំងអស់ព្រមទាំង ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណនិងគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល និងក៏ដូចជាផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានមានសំណូមពរសំខាន់ៗចំនួនបីគឺ (១) សំណើឲ្យមានការបង្កើនថវិការាជរដ្ឋាភិបាលសម្រាប់វិស័យស្រាវជ្រាវនិងបន្តជម្រុញឲ្យប្រទេសផ្តល់ជំនួយពង្រឹងស្ថាប័នស្រាវជ្រាវជាតិបន្ថែមទៀត ជាពិសេសផ្នែកហិរញ្ញវត្ថុនិងធនធានមនុស្សសម្រាប់ការងារគ្រប់គ្រងប្រតិបត្តិការ របស់វិទ្យាស្ថាន (២)សំណើជួយគាំទ្រដល់បច្ចេកទេសអភិវឌ្ឍន៍ដោយវិទ្យាស្ថាននិងប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវបច្ចេកទេសបរទេសជាពិសេសពូជដំណាំនិង (៣)សំណើសុំផ្តល់នូវធនធានមនុស្សប្រកបដោយគុណភាពបន្ថែមទៀត ដោយសារមន្ត្រីវិទ្យាស្ថានមួយចំនួនបានចូលនិវត្តន៍ជាបន្តបន្ទាប់។

## ជ- វិធានការ

ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តការជាមួយដៃគូអភិវឌ្ឍន៍ អង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ មន្ទីរកសិកម្មរាជធានី ខេត្ត អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានាដើម្បី (១)បន្តអភិវឌ្ឍពូជដំណាំកសិកម្ម ដែលមានសក្តានុពលទិន្នផលខ្ពស់ហើយប្រកបដោយគុណភាពល្អប្រពៃធន់ទ្រាំទៅនឹងទឹកជំនន់ គ្រោះរាំងស្ងួត ជាតិប្រៃនិងកំដៅពូជស្រូវអាយុកាលខ្លីជាង១០០ថ្ងៃនិងបន្តធ្វើការស្រាវជ្រាវដោយប្រើវិធីសាស្ត្រសមគ្នាប្រកបដោយសុវត្ថិភាពនិងមាននិរន្តរភាពដើម្បីជួយកសិករក្នុងការការពារការបាត់បង់ទិន្នផលដំណាំនិងប្រាក់ចំណេញ (២)បន្តស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកទេសនៃប្រព័ន្ធគ្រប់គ្រងជីជាតិដី សារធាតុចិញ្ចឹមប្រកបដោយលក្ខណៈសេដ្ឋកិច្ចនិងនិរន្តរភាពខ្ពស់ ដើម្បីជួយប្រជាកសិករក្នុងការបង្កើននិងធ្វើឲ្យមានស្ថេរភាពទិន្នផលដំណាំនៅក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាប តំបន់ស្រោចស្រពនិងតំបន់ខ្ពង់រាបតាមរយៈការធ្វើឲ្យកាន់តែប្រសើរឡើងនូវចំណេះដឹងលើផ្នែកគ្រប់គ្រងដីនិងសារធាតុចិញ្ចឹមរបស់ដំណាំ (៣)បន្តសិក្សារកលទ្ធភាពបង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្ម ក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាបនិងតំបន់ខ្ពង់រាបនៃប្រព័ន្ធផលិតកម្មដំណាំកសិកម្ម (៤)បន្តស្រាវជ្រាវដើម្បីអភិវឌ្ឍន៍សមត្ថភាពវិភាគក្នុងមន្ទីរពិសោធន៍ផ្នែកវិភាគដី ទឹក រុក្ខជាតិ ជំងឺ រុក្ខវិទ្យា និងជាលិកាវប្បកម្ម (៥)បន្តពង្រឹងនិងជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាទៅដល់កសិករនិងអ្នកពាក់ព័ន្ធនានាតាមរយៈការ

បោះពុម្ពផ្សាយគេហទំព័រ កាសែត វិទ្យុនិងទូរទស្សន៍និង (៦)លើកកម្ពស់សមត្ថភាពរបស់មន្ត្រី និយោជិតតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សានិងកិច្ចប្រជុំផ្សេងៗទាំងក្នុងប្រទេសនិងក្រៅប្រទេស។

### ៩.៧.៧- ការងារកសិ-ឧស្សាហកម្ម

## ក- ការងារអនុវត្តគម្រោង

បានអនុវត្តគម្រោងតាមកម្មវិធី កម្មវិធីទី២ "ជម្រុញការចូលទីផ្សារនៃផលិតផលកសិកម្ម" ដែលមានអនុកម្មវិធីចំនួន ០៣ ចំណាយថវិកាសរុបចំនួន ៣២៧.៣៣៩.០០រៀល រួមមាន ÷

-អនុកម្មវិធីទី១ សកម្មភាពស្តីពី "បណ្តុះបណ្តាលកសិករអំពី ការកែច្នៃ និងផ្ស៊ំចំណីសត្វ" បណ្តុះបណ្តាលកសិករក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០នាក់ ចំណាយថវិកាអស់ ១១០.៨៤២.០០០រៀល

-អនុកម្មវិធីទី៤ សកម្មភាពស្តីពី "ការលើកកម្ពស់ស្តង់ដារគុណភាព សុវត្ថិភាពនៃផលិតផលកសិកម្ម" បណ្តុះបណ្តាលកសិករក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០នាក់ ចំណាយថវិកាអស់ ១០៩.៦១៨.០០០រៀល

-អនុកម្មវិធីទី៥ សកម្មភាពស្តីពី "បណ្តុះបណ្តាលកសិករអំពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា" បណ្តុះបណ្តាលកសិករក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៩០នាក់ ចំណាយថវិកាអស់ ១០៦.៨៧៩.០០០រៀល។

## ខ- ការងារនិតិកម្ម

-បានត្រៀមរៀបចំតាក់តែងសេចក្តីព្រាងប្រកាសស្តីពី ការគ្រប់គ្រងនិងប្រមូលទិន្នន័យស្ថិតិសហគ្រាសធុនតូចនិងមធ្យមវិស័យកសិកម្ម

-បានទំនាក់ទំនង និងសហការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីទទួលបានជំនាញការមកជួយរៀបចំយន្តការអនុវត្តអនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា

-បាននឹងកំពុងរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី គុណភាព សុវត្ថិភាពផលិតផលកសិកម្ម។

## គ- ការងារដីសម្បទានសេដ្ឋកិច្ច

-ទទួលបានរបាយការណ៍ស្តីពី ការពិនិត្យសកម្មភាពការងាររបស់ក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តស្ទឹងត្រែង សៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ ក្រចេះ កំពត កំពង់ចាម ព្រះសីហនុ និងឧត្តរមានជ័យ

-បានចូលរួមសហការជាមួយមន្ត្រី និងថ្នាក់ដឹកនាំក្រសួងកសិកម្ម ចុះត្រួតពិនិត្យវាយតម្លៃការអនុវត្តន៍របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ រតនៈគីរី ស្ទឹងត្រែង មណ្ឌលគីរី ក្រចេះ កំពង់ចាម ស្វាយរៀង បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ និងកំពង់ស្ពឺ។ បន្ទាប់មកបានចូលរួមប្រជុំឆ្លងរបាយការណ៍ស្តីពី លទ្ធផលនៃការចុះត្រួតពិនិត្យវាយតម្លៃការអនុវត្តន៍របស់បណ្តាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងនេះ

-បានចូលរួមសហការជាមួយមន្ត្រី និងថ្នាក់ដឹកនាំក្រសួងកសិកម្ម ចុះត្រួតពិនិត្យវាយតម្លៃការអនុវត្តន៍របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តកំពង់ធំ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ រតនៈគីរី ស្ទឹងត្រែង មណ្ឌលគីរី ក្រចេះ កំពង់ចាម បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រះសីហនុ និងខេត្តកោះកុង។

## ឃ- ការងារសហប្រតិបត្តិការអន្តជាតិ

ក្នុងឆ្នាំ ២០១១ នាយកដ្ឋានកសិឧស្សាហកម្មបានបន្តធ្វើការសហការជាមួយដៃគូរអភិវឌ្ឍន៍នានាដូចជា ÷

-អង្គការ FAO បានសហការលើការរៀបចំផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិឧស្សាហកម្ម រយៈពេល០៥ឆ្នាំ (២០១០-២០១៥) ដោយបានរៀបចំជា Road Map សម្រាប់សកម្មភាពលម្អិតរយៈពេល០២ឆ្នាំ និងបានបញ្ចប់ចេញជាសេចក្តីព្រាងចុងក្រោយដាក់ជូនអង្គការ FAO

-អង្គការ UNIDO បានសហការលើការងារស្រាវជ្រាវការបាត់បង់ក្រោយពេលប្រមូលផល នៃផលិផលកសិកម្មនៅតាមបណ្តាលខេត្តសំខាន់ៗដូចជា ខេត្តបាត់ដំបង កំពង់ចាម ប៉ៃលិន បន្ទាយមានជ័យ និងខេត្តកំពង់ធំ

-បានការគាំទ្រគម្រោងហិរញ្ញប្បទានពីប្រទេសចិនស្តីពី ការបង្កើតមន្ទីរពិសោធន៍ផលិតផលកសិកម្ម

-បានកំពុងត្រៀមសហការជាមួយអង្គការ AFD និង GIZ ដើម្បីលើកគម្រោង Partnership Farming in Cambodia

ដោយផ្អែកលើមូលដ្ឋាន នៃអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា

-បានកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ស្តីពី គំនិតផ្តួចផ្តើមក្នុងការវិនិយោគវិស័យកសិកម្មនិងកសិឧស្សាហកម្ម នៅកម្ពុជារវាងថ្នាក់ដឹកនាំនាយកដ្ឋានកសិឧស្សាហកម្មនិងអ្នកវិនិយោទុនជប៉ុន។

## ង. វិធានការ

-កែទម្រង់រចនាសម្ព័ន្ធក្នុងនាយកដ្ឋាន ដោយបង្កើតការិយាល័យថ្មីមួយបន្ថែមទៀតផ្តោតលើបច្ចេកវិទ្យាក្រោយពេលប្រមូលផល វេចខ្ចប់ និងរក្សាទុក

-បង្កើនសកម្មភាពនិងពង្រឹងសមត្ថភាពមន្ត្រីជំនាញនិងមន្ទីរកសិកម្មខេត្តនានា ដើម្បីឱ្យមន្ត្រីតាមមូលដ្ឋានធ្វើសកម្មភាពតាមតួនាទីរបស់ខ្លួន ពិសេសលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃដំណើការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនដីសម្បទាន សេដ្ឋកិច្ច ទូទាំងព្រះរាជាណាចក្រកម្ពុជា

-ជំរុញនិងបង្កើនកិច្ចសហប្រតិបត្តិការជាមួយសប្បុរសជន អង្គការអន្តរជាតិ ស្ថាប័នឯកជន ដើម្បីស្វែងរកការគាំទ្រទាំងថវិការនិងបច្ចេកទេស។

### ៩.៧.៤- ការងារយេនឌ័រ

## ក. ការបណ្តុះបណ្តាល

-**បណ្តុះបណ្តាលក្នុងប្រទេស** ការបណ្តុះបណ្តាលរយៈពេលខ្លីមានចំនួន ១៨នាក់ ជានារីមានចំនួន ០២នាក់ក្នុងនោះមានមន្ត្រីវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ចំនួន ០១នាក់ និងវគ្គវិក្រឹត្យការមន្ត្រីមធ្យមចំនួន ០២នាក់ ។

-**បណ្តុះបណ្តាលក្រៅប្រទេស** ថ្នាក់បណ្ឌិតមានចំនួន ០២នាក់ជានារីចំនួន ០១នាក់ថ្នាក់អនុបណ្ឌិត មាន ០៨នាក់ ជានារីមានចំនួន ០៤នាក់ និងការបណ្តុះបណ្តាលរយៈពេលខ្លីមានចំនួន ២៣៩នាក់ ក្នុង នោះជានារីមានចំនួន ៤៨នាក់ ។

## ខ.ការងារទំនាក់ទំនង និងសហប្រតិបត្តិការ (អន្តរក្រសួង) ÷

-បានចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយកូនសៀវភៅស្ថិតិយេនឌ័រ(ស្ត្រីនិងបុរស) នៅកម្ពុជាឆ្នាំ២០១១ នៅក្រសួងផែនការ

-បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ អំពីទស្សនៈយេនឌ័រទៅក្នុការអភិវឌ្ឍន៍គោល នយោបាយ ស្តីពីបច្ចេកវិទ្យា គមនាគមន៍ ព័តិមានវិទ្យា នៅវិទ្យាស្ថានបើកទូលាយ

-បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការចែករំលែកចំណេះដឹងពាក់ពន្ធ័និងការបញ្ជ្រាបយេនឌ័រ នៅក្នុងវិស័យធនធានទឹកចម្រុះនៅទីរួមខេត្តកំពង់ចាម (ក្រសួងធនធានទឹក)

-បានចូលរួមក្នុងកិច្ចប្រជុំក្រុមតូចនៃក្រុមការងារបច្ចេកទេសយេនឌ័រជាមួយក្រសួងកិច្ចការនារី

- បានទទួលជួបជាមួយក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ី (ADB)ដែលចុះមកសិក្សាលើកទី៣ ប្រទេសគឺ÷

-១កម្ពុជា ២- ហ្វីលីពីន ៣- ប្រទេសកាហ្សាក់ស្តង់ ក្នុងគោលបំណងស្វែងយល់ពីការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម

-បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារ សាធារណៈដំណាក់កាលទី២ ឆ្នាំ២០១១-២០១៣(រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ)

-បានចូលរួមកិច្ចពិភាក្សាលើការរៀបចំគណៈកម្មការសាខាសមាគមនារីកម្ពុជាសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងស្ថាប័ននៅទីស្នាក់ការកណ្តាលនៃសសហគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍

-បានចូលរួមសិក្ខាសាលាជាច្រើនលើកជាមួយគម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២(PGM2) នៅខេត្ត កំពង់ចាម

-បានចូលរួមធ្វើបទបង្ហាញ ស្តីពីការលប់បំបាត់ភាពក្រីក្រតាមរយៈការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ជូនសាមជិកព្រឹទ្ធសភានិងសមាជិកសភា កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១(ដែលមានអ្នកចូលរួមប្រមាណ ជា១០០នាក់)នៅក្នុងបណ្ណាល័យព្រឹទ្ធសភាព

-បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយដីធ្លី និងយេនឌ័រសម្រាប់ដាក់បញ្ចូលក្នុងសេចក្តីព្រាងសៀវភៅសដីធ្លី (ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់)

-បានចូលរួមជាគណៈកម្មការបច្ចេកទេសក្នុងពិធីតាំងពិព័រណ៍ ដើម្បីបង្ហាញពីលទ្ធផលកសិកម្ម និង ម្ហូបអាហារ សុវត្ថិភាពដែលផលិតឡើងដោយស្នាដៃកសិករខ្មែរផ្ទាល់ ឧបត្ថម្ភអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា

-បានចូលរួមជាប្រតិភូគ.ជ.ក.ស ចុះបំពេញបេសកម្ម នៅខេត្តកែប ដើម្បីតាមដាន វាយតម្លៃការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-បានចូលរួមពិភាក្សាលើសកម្មភាពរួមចំណែកលើកកម្ពស់ស្ថានភាពស្ត្រី ដែលមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅក្រសួងកិច្ចការនារី

-បានចូលរួមក្នុងកិច្ចប្រជុំពិនិត្យរបាយការណ៍លើកទី១ "លើការតាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ ២០០៩-២០១២ និងអនុសាសន៍"

-បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ " ស្តីពីការបូកសរុបលទ្ធផលការងារបញ្ជ្រាបយេនឌ័រតាមក្រសួង-ស្ថាប័ន និងលើកទិសដៅអនុវត្តបន្តឆ្នាំ ២០១២ " និងទស្សនកិច្ចសិក្សា ដើម្បីដកបទពិសោធន៍ការបញ្ជ្រាបយេនឌ័ររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅខេត្តមណ្ឌលគិរី(ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១)

-បានចូលរួមជាកិត្តិយសក្នុងពិធីប្រកាសទទួលស្គាល់ជាផ្លូវការសមាសភាពគណៈកម្មការសាខាសមាគមន៍នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅក្រសួងព័ត៌មាន(ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១)។

## គ.ការងារសង្គម

-កាលពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ លោកជំទាវ ***សុខ កែវ ច័ន្ទ សារុន*** បានដឹកនាំគណៈប្រតិភូជាមន្ត្រីរាជការក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ២៤២ នាក់ ក្នុងនោះស្ត្រី ១៣៦ នាក់ រួមជាមួយសិស្ស និងមន្ត្រីមូលដ្ឋានមួយចំនួនទៀត ចុះជួយច្រូតស្រូវ ប្រជាកសិករនៅភូមិកាច់ត្រែក ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ បានចំនួនជាង ៦ហត។

-ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១១ លោកជំទាវ ***សុខ កែវ ច័ន្ទ សារុន*** បានដឹកនាំគណៈប្រតិភូជាមន្ត្រីរាជការក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ២១៣ នាក់ ក្នុងនោះស្ត្រី ៨៣ នាក់ រួមជាមួយសិស្ស និងមន្ត្រីមូលដ្ឋានមួយចំនួនទៀត ចុះជួយច្រូតស្រូវ ប្រជាកសិករនៅភូមិពាក់បង្អោង ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ សរុបបានចំនួន ២១ ស្រែ ជារបស់ប្រជាជនចំនួន ២៧ គ្រួសារ ដែលគិតជាផ្ទៃដីបានប្រមាណជាង ៨ ហត (ម្ចាស់ស្រែប្រជាកសិករពិការ ចាស់ជរា និងស្ត្រីមេម៉ាយ)។ ទន្ទឹមនឹងនោះ (អំណោយទាំងអស់នេះជាថវិកាផ្ទាល់របស់លោកជំទាវ ***សុខ កែវ ច័ន្ទ សារុន***)។

-កាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកឧត្តមបណ្ឌិត ***ច័ន្ទ សារុន*** និងលោកជំទាវ ***សុខ កែវ ច័ន្ទ សារុន*** បានប្រារព្ធទិវាកុមារ អបអរសាទរការចូលឆ្នាំជាសកល ឆ្នាំ ២០១២ ដោយបានអញ្ជើញកុមារា កុមារី ចៅប្រុស ចៅស្រី ដែលជាកូនចៅមន្ត្រីរាជការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ៣១៥ នាក់ មកសំណេះសំណាលធ្វើពិធីឱ្យពួកគេបានចូលរួមច្រៀង រាំ បន្ទាប់មកឯកឧត្តម និងលោកជំទាវក៏បានប្រគល់កញ្ចប់អនុស្សាវរីយ៍ដ៏ធំមួយកញ្ចប់ដែលមាន÷ មី ទឹកក្រូច នំ ព្រមទាំងថវិកាចំនួន ២៥.០០០ រៀល ក្នុងម្នាក់ៗ។

## ឃ. វាយតម្លៃនិងសន្និដ្ឋាន

បច្ចុប្បន្នក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងដំណើរការអនុវត្តកិច្ចការរបស់ខ្លួនឆ្ពោះទៅរកសមភាពយេនឌ័រ ដោយផ្តោតគោលដៅទៅលើស្ត្រី និងបុរស ជាពិសេសទៅលើស្ត្រី ក្នុងន័យធ្វើយ៉ាងណាឱ្យមានតុល្យភាព នៃការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយសមធម៌ និងក្នុងន័យចូលរួមបង្កើនផលិតភាព និង ពិពិធភាវូបនីយកម្មកសិកម្ម ដើម្បីចូលរួមការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមទិសដៅអភិវឌ្ឍន៍ សហសវត្សរ៍ នៅកម្ពុជា។

## ង. វិធានការ

-បន្តអនុវត្តព្រះរាជានុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរព្រះប្រធានកិត្តិយស

នៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី ការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនិងនារី ភេទ (CEDAW) និងឯកសារដែលពាក់ព័ន្ធបានទូលំទូលាយក្នុងវិស័យកសិកម្ម

-បន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង១៣ចំណុចរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

-បន្តអនុវត្តទិសដៅទាំង៤ នៃគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជាបយេនឌ័រក្នុងវិស័យកសិកម្មឱ្យទទួលបានលទ្ធផលល្អតាមផែនការកំណត់។

## ៥.៨- ធនធានមនុស្ស និងថវិកា

### ៥.៨.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

### ក. លទ្ធផលៈ

ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពការងារ ប្រកបដោយសមធម៌ និងជាគោលដៅចម្បងក្នុងការលើកស្ទួយសមត្ថភាពធនធានមនុស្សស្របតាមជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីរួមចំណែកលើកស្ទួយការអភិវឌ្ឍប្រទេស ដែលជាជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សមានជាអាទិ៍÷ ការងារគ្រប់គ្រងមន្ត្រីរាជការ ការងាររៀបចំមន្ត្រីកាន់មុខតំណែង ការងាររៀបចំស្នើសុំគ្រឿងឥស្សរិយយស ការងាររៀបចំបៀវត្ស ប្រាក់ធានារ៉ាប់រងសង្គម ការងាររៀបចំតម្លើងកាំបៀវត្ស ការងាររៀបចំដាក់មន្ត្រីគ្រប់អាយុឱ្យចូលនិវត្តន៍ និងការងារបណ្តុះបណ្តាលឱ្យស្របទៅតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាននានា ។

បច្ចុប្បន្នដំណើរការផលិតកម្មកសិកម្ម បាននិងកំពុងវិវឌ្ឍតាមរបត់នៃទីផ្សារសេរីដូចនេះ រចនាសម្ព័ន្ធតួនាទី និងភារកិច្ចនៃអង្គភាពនីមួយៗ ចាំបាច់ត្រូវតែកែលម្អឱ្យសមស្របតាមសភាពការណ៍ជាក់ស្តែង។ វិស័យកសិកម្មអាចអភិវឌ្ឍន៍ទៅបានគឺតម្រូវឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ និងមានធនធានមនុស្សដែលមានសមត្ថភាពសមស្រប នៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៨៧៨នាក់ ជានារីចំនួន១.១៦២នាក់ ស្មើនឹង១៦,៨៩% ក្នុងនោះ ÷

-អង្គភាពថ្នាក់កណ្តាលមានចំនួន៤.១៥៦នាក់ ជានារីមានចំនួន៦៦៧នាក់ ស្មើនឹង១៦,០៤%

-អង្គភាពថ្នាក់រាជធានី ខេត្ត មានចំនួន ២.៧២២នាក់ ជានារីមានចំនួន៤៩៥នាក់ ស្មើនឹង១៨,១៨%

-បានតែងតាំងតម្លើងឋានៈនិងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន២៩៩នាក់ ជានារីចំនួន៣១នាក់

-បានលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌមានចំនួន៦៣នាក់ ក្នុងនោះ បោះបង់ការងារមានចំនួន១៩នាក់ សុំលាឈប់ពីការងារចំនួន២៧នាក់ និងមរណភាពចំនួន១៧នាក់

-បានផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួង០៦នាក់ ផ្ទេរចូលក្រសួង០៥នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួង មានចំនួន៨០នាក់

-បានចេញលិខិតអនុញ្ញាតច្បាប់សម្រាកការងារមានចំនួន២០នាក់ ក្នុងនោះ ច្បាប់សម្រាកប្រចាំឆ្នាំមាន ចំនួន១៤នាក់ ច្បាប់ព្យាបាលជំងឺមានចំនួន០៥នាក់ និងច្បាប់សម្រាកមាតុភាព មានចំនួន០៦នាក់

-ក្នុងឆ្នាំ២០១១ ក្រសួងបានប្រឡងជ្រើសរើសក្របខណ្ឌថ្មីបានចំនួន១៣៤នាក់ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងបានបែងចែកមន្ត្រីក្របខណ្ឌថ្មី ឱ្យទៅបំរើការងារនៅតាមអង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត

-បានពិនិត្យកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសារប្រចាំឆ្នាំរបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មី តាមប្រព័ន្ធព័ត៌មានវិទ្យា

-បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ៧១នាក់ និងចេញប្រកាសឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន២៦នាក់

-បានចេញលិខិតផ្ទេរកូនកំព្រាចំនួន ០២នាក់ ទៅក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា

-បានចេញប្រកាសដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងបាត់បង់សប្បទាវិជ្ជាជីវៈ ចំនួន២២៩នាក់

-បានចេញប្រកាស ស្តីពីការអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាមានចំនួន១៩៤នាក់ និងពលករអណ្តែតមានចំនួន៨៧១នាក់

-បានបានចេញប្រកាសតម្លើងមួយថ្នាក់តាមកំរិតសញ្ញាបត្រដល់មន្ត្រីរាជការចំនួន៣២នាក់ និងបានចេញប្រកាសតម្លើងថ្នាក់ប្រចាំឆ្នាំ២០១១ ជូនមន្ត្រីរាជការកសិកម្មចំនួន២.២៨៣នាក់

-ក្រសួងបានបញ្ជូនមន្ត្រីចូលរួមបណ្តុះបណ្តាលបានចំនួន២៦៧នាក់ ក្នុងនោះការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីមានចំនួន១៨នាក់ និងនៅក្រៅប្រទេសថ្នាក់បណ្ឌិតមានចំនួន០២នាក់ ថ្នាក់អនុបណ្ឌិតមាន០៨នាក់ និងរយៈពេលខ្លីចំនួន២៣៩នាក់ ដោយឡែកមន្ត្រីរាជការ ជានារីមានចំនួន៥៦នាក់

-បានធ្វើសំណើសុំផ្តល់គ្រឿងឥស្សរិយយស ជូនដល់មន្ត្រីកសិកម្មបានចំនួន១៩៣១នាក់ ក្នុងនោះស្រី២៧២នាក់ចាប់ពីមេដាយការងារសំរិទ្ធ រហូតដល់មេដាយព្រះរាជាណាចក្រថ្នាក់មហាសេរីវឌ្ឍន៍

-បានចេញប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ និងចេញប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះនាយកដ្ឋាន និងវិទ្យាស្ថាន នៃអគ្គនាយកដ្ឋានកៅស៊ូ

-បានចេញប្រកាសស្តីពី ការបង្កើតវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ និងចេញប្រកាសលេខ១៤៩ប្រក.កសក.ប ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រកាសលេខ ៥០៩ប្រក.កសក.ប ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ

-បានចេញប្រកាសស្តីពី ការបង្កើតការិយាល័យកសិកម្មក្រុងព្រៃវែងចំណុះមន្ទីរកសិកម្មខេត្តព្រៃវែង។

## ខ. វាយតម្លៃនិងសំណើះ

ថ្វីបើមានការខិតខំប្រឹងប្រែង និងដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងយ៉ាងនេះក្តី ក៏ការអនុវត្តនភារកិច្ចទាំងនោះ តែងជួបប្រទះនូវការលំបាក ស្មុគស្មាញជាច្រើនទៀតដូចជា÷

-ការបញ្ជូនឯកសារសម្រាប់តាំងស៊ប់ ពីអង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្តមួយចំនួនមានការយឺតយ៉ាវ និងការបញ្ជូនសំណុំឯកសារអំពីស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការ សម្រាប់បញ្ចូលក្នុងតារាងបៀវត្សប្រចាំខែនៅតែយឺត នាំឱ្យការបញ្ជូនឯកសារទៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលមានភាពអូសបន្លាយ ដែលបានប៉ះពាល់ដល់ការបើកផ្តល់បៀវត្សប្រចាំខែរបស់អង្គភាពក្រោមឱវាទក្រសួង

-រាល់ការបញ្ជូនឯកសារចាត់មន្ត្រីឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស នៅតែមិនទាន់បានអនុវត្តត្រឹមត្រូវតាមការណែនាំរបស់ក្រសួង ពោលគឺឯកសារផ្ញើមកនៅពុំទាន់បានគ្រប់គ្រាន់ និងមានការយឺតយ៉ាវមកមិនទាន់ពេលវេលាកំណត់

-រាល់ការបញ្ជូនឯកសារស្នើសុំមេដាយការងារជូនមន្ត្រីរាជការ នៅតាមបណ្តាអង្គភាពនានាចំណុះក្រសួងគឺនៅមានការយឺតយ៉ាវមិនទាន់ពេលវេលាកំណត់ ទោះបីមានការក្រើនរំលឹកក៏ដោយ ហើយក៏ពុំបានអនុវត្តទៅតាមគោលការណ៍១០% របស់រាជរដ្ឋាភិបាលជាហេតុនាំឱ្យមានការលំបាកក្នុងការអនុវត្តការងារ ។

## គ. វិធានការះ

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងគោលការណ៍ លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំ អំពីការងារគ្រប់មន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែង ក្នុងការគ្រប់គ្រងធនធាន មនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកំរិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង ដើម្បីជាឯកសារសម្រាប់ក្រសួងប្រើប្រាស់

-បន្តរៀបចំសម្របសម្រួលការងារកសាងគោលការណ៍ លិខិតបទដ្ឋាន សេចក្តីសម្រេចនិងប្រកាសជូនអង្គភាព

ពាក់ព័ន្ធសម្រាប់ពង្រឹងលើការងារបណ្តុះបណ្តាលធនធានមនុស្ស ដោយលើកគម្រោងបញ្ជូនមន្ត្រីរាជការទៅសិក្សារយៈពេលវែង មធ្យម ខ្លីនៅក្នុងនិងក្រៅប្រទេស តាមជំនាញឱ្យបានច្រើន

-រៀបចំឯកសារដាក់មន្ត្រីឱ្យចូលនិវត្តន៍ឱ្យបានទាន់ពេលវេលា និងបន្តការងារដែលនៅសេសសល់

-ពិនិត្យ និងកែលំអលើការងាររៀបចំរចនាសម្ព័ន្ធ សេចក្តីព្រាងប្រកាស ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទក្រសួង

-ជំរុញការអនុវត្តគម្រោងថវិកាតាមកម្មវិធីលើការរៀបចំភារកិច្ចរបស់មណ្ឌលកសិកម្មឃុំ សង្កាត់ដែលបានអនុម័តក្នុងឆ្នាំ២០១១ សម្រាប់ឆ្នាំ២០១២

-ចុះត្រួតពិនិត្យជាក់ស្តែងការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងពលករអណ្តែតនៅតាមអង្គភាពថ្នាក់កណ្តាល និងរាជធានី ខេត្ត

-រៀបចំកសាងផែនការសំខាន់ៗមានជាអាទិ៍ៈ ផែនការក្របខណ្ឌ ផែនការជ្រើសរើសពលករអណ្តែត ផែនការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងផែនការថវិកាតាមកម្មវិធី និងមិនមែនកម្មវិធី។

### ៩.៨.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ

### ៩.៨.២.១. សាកលវិទ្យាល័យភូមិន្ទកសិកម្ម

១. លទ្ធផល

ក. ស្ថិតិនិស្សិត

ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាកលវិទ្យាល័យ២០១០-២០១៥ និងក្រោមការដឹកនាំតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៣ សម្រេចបាននូវលទ្ធផលការងារសំខាន់ៗជាច្រើន ជាពិសេសការងារអប់រំបណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ការងារផ្សព្វផ្សាយ និងការងារសហប្រតិបត្តិការជាតិនិងអន្តរជាតិ។

ក្នុងឆ្នាំ២០១១នេះ មាននិស្សិតសរុបចំនួន៤.៨២១នាក់ ក្នុងនោះនារី៩៥៣នាក់ កំពុងសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្មលើមហាវិទ្យាល័យ៨ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លីដែលបណ្តុះបណ្តាលថ្នាក់បរិញ្ញា និងនៅសាលាក្រោយឧត្តមដែលទទួលបន្ទុកបណ្តុះបណ្តាលថ្នាក់បរិញ្ញាជាន់ខ្ពស់និងបណ្ឌិត។

យោងតាមក្រាហ្វិកខាងក្រោមនេះបង្ហាញឲ្យឃើញថា ចំនួននិស្សិតចូលសិក្សាក្នុងឆ្នាំទី១ មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំគួរកត់សម្គាល់ ជាពិសេសក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ មានកំណើនទ្វេដង។




ចាប់តាំងពីបើកទ្វារសារជាថ្មីនាឆ្នាំ១៩៨៥ មកដល់ឆ្នាំ២០១១នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានរួមចំណែកបណ្តុះបណ្តាលនិស្សិតឲ្យបញ្ចប់ការសិក្សាដោយជោគជ័យលើវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងវិស័យពាក់ព័ន្ធផ្សេងៗ សរុបបានចំនួន៥ ៧២៧នាក់ (នារី៨៩៨នាក់ស្មើនឹង១៥.៦៨%) ដែលបែងចែកជាថ្នាក់បណ្ឌិតចំនួន៨នាក់ (នារី១នាក់)

បរិញ្ញាជាន់ខ្ពស់ចំនួន៦១៤នាក់ (នារី៨៦នាក់) បរិញ្ញាចំនួន៤៦០៣នាក់ (នារី៧៥៣នាក់) និងថ្នាក់បរិញ្ញារងចំនួន៥០៦ នាក់ (នារី៥៨នាក់)។ ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់និងបរិញ្ញា បែងចែកតាមជំនាញផ្សេងៗមានបង្ហាញជូនក្នុងក្រាហ្វិកខាងក្រោម ។

ស្ថិតិនិស្សិតបរិញ្ញាជាន់ខ្ពស់បញ្ចប់ការសិក្សពី ស.វ.ភ.ក (គិតត្រឹមឆ្នាំ ២០១១)




១: វិទ្យាសាស្ត្រកសិកម្ម ២: វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ ៣: ផលិតកម្មនិងសុខុមាលភាពសត្វ
៤: ធនធានធម្មជាតិកើតវិញបាន ៥: វារីវប្បកម្ម និងបរិស្ថាន ៦: ការគ្រប់គ្រងធនធានមនុស្ស
៧: អភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្ម ៨: ការគ្រប់គ្រងចម្រុះសម្រាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទ

## ខ. សហប្រតិបត្តិការជាតិនិងអន្តរជាតិ

ដើម្បីពង្រឹងសមត្ថភាពសាកលវិទ្យាល័យឲ្យកាន់តែរឹងមាំ និងជាពិសេសដើម្បីឈានទៅដល់បទដ្ឋានអន្តរជាតិ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ខ្ពស់ជាចម្បងលើកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ។ ជារួមកិច្ចសហប្រតិបត្តិការអន្តរជាតិ បានផ្តល់ឱកាសដល់សាកលវិទ្យាល័យគៀងគរបានមូលនិធិផ្សេងៗសម្រាប់ដំណើរការការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ការផ្លាស់ប្តូរនិស្សិតនិងសាស្ត្រាចារ្យទៅវិញទៅមកជាមួយសាកលវិទ្យាល័យដៃគូ ការធ្វើកម្មសិក្សារបស់និស្សិតនិងសាស្ត្រាចារ្យក្នុងនិងក្រៅប្រទេស ការផ្តល់អាហារូបករណ៍ ការផ្សព្វផ្សាយបច្ចេកទេសដល់កសិករ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ក្នុងឆ្នាំ២០១១នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានបង្កើតកិច្ចសហប្រតិបត្តិការថ្មីបានចំនួន៩ដៃគូ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម បន្ថែមពីលើដៃគូដែលមានស្រាប់នាពេលកន្លងមក។

**បញ្ជីឈ្មោះដៃគូសហប្រតិបត្តិការជាតិនិងអន្តរជាតិថ្មីក្នុងឆ្នាំ ២០១១**

| N. | Institution | Country | Ongoing activities |
|---|---|---|---|
| 1 | University of Paul Sabatier-TOULOUSE III | France | Collaborate in TECHNO project , Erasmus Mundus program |
| 2 | The University of CALIFORNIA, Davis Campus | USA | HORT Script project, safe vegetable |
| 3 | Anttel Cambodia Co., Ltd | Vietnam | AVIRA provide 416 licenses (3-U) Suite Within 9 months |
| 4 | Ederswalde University for Sustainable Development | Germany | Academic exchange |
| 5 | Chonbuk National University | Korea | Academic Exchange |
| 6 | Champasack University | Lao P.D.R | Joint study program |
| 7 | Saint Paul Institute | Cambodia | RUA provide technical support |
| 8 | Chea Sim University of Kamchaymear | Cambodia | Academic exchange and joint project on climate change adaptation |
| 9 | Fintrac, Inc | USA | Support for full time MSc program on Natural Resources Management |

## គ. អាហារូបករណ៍និស្សិត

ក្នុងនាមជាគ្រឹះស្ថានសាធារណរដ្ឋបាល សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរកអាហារូបករណ៍ផ្សេងៗ និងផ្តល់អាហារូបករណ៍ទាំងនោះដល់និស្សិត ជាពិសេសនិស្សិតពូកែ និស្សិតក្រីក្រ និងនិស្សិតមកពីតំបន់ដាច់ស្រយាល។ ដោយឡែកក្នុងឆ្នាំសិក្សា២០១១-១២នេះ រាជរដ្ឋាភិបាលសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងដៃគូ

អភិវឌ្ឍន៍នានាបានផ្តល់អាហារូបករណ៍ដល់និស្សិត សរុបមានចំនួន ១.១៤៥នាក់ ដូចមានបែងចែងក្នុងតារាងខាងក្រោមៈ

| អាហារូបករណ៍ | ចំនួនសរុប |
|---|---|
| អាហារូបករណ៍ សវភក ផ្តល់ជូនប្រមុខថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា | ៦៦ នាក់ |
| អាហារូបករណ៍ សវភក ផ្តល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៩៤ នាក់ |
| អាហារូបករណ៍ សវភក ផ្តល់ជូនកូន ប្អូន និង ក្មួយ របស់មន្ត្រីរាជការ សវភក ដែលជួបការលំបាក (អាហារូបករណ៍តាមអត្រា%) | ១២១ នាក់ |
| អាហារូបករណ៍ទទួលពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអបរំ យុវជន និងកីឡា | ៦៥៥ នាក់ |
| អាហារូបករណ៍ទទួលពីធនាគារពិភពលោក (ថ្លៃសិក្សានិងប្រាក់ឧបត្ថម្ភ៧០ USD/ខែ. នាក់) | ១៤២ នាក់ |
| អាហារូបករណ៍ RUA-JICF-JINNAI ជប៉ុន (និស្សិតទទួលបាន ៦៣៩USD/ឆ្នាំ. នាក់) | ៥២ នាក់ |
| អាហារូបករណ៍ USDA សម្រាប់ការសិក្សាថ្នាក់បណ្ឌិត អំពីជំងឺផ្កាសាយបក្សី | ៥ នាក់ |
| អាហារូករណ៍ HARVEST éUSAID សម្រាប់ការសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ ជំនាញគ្រប់គ្រងធនធានធម្មជាតិ | ១០ នាក់ |
| **សរុប** | ១.១៤៥ នាក់ |

## ឃ. ការស្រាវជ្រាវនិងផ្សព្វផ្សាយ

ដោយមានកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូជាតិនិងអន្តរជាតិ ក្នុងឆ្នាំ២០១១នេះមន្ត្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មបានចូលរួមអនុវត្តគម្រោងស្រាវជ្រាវ និងគម្រោងអភិវឌ្ឍន៍ចំនួន២៧គម្រោង ដែលមានប្រភេទគម្រោង ប្រភព និងថវិកាគម្រោងរួម ដូចខាងក្រោមៈ

| លរ | ប្រភេទគម្រោង | ប្រភព | ថវិការួម | លរ | ប្រភេទគម្រោង | ប្រភព | ថវិការួម |
|---|---|---|---|---|---|---|---|
| ១ | កសិកម្មសមស្រប | JICA | 67,669,298 ô | ១៥ | ស្រាវជ្រាវស្រូវ | IRRI | 4,000 $ |
| ២ | អប់រំផ្សព្វផ្សាយកសិកម្ម | CIDA | 29,950 Ca$ | ១៦ | ពូជនិងហ្វូងសត្វ | FAO | 42,446 $ |
| ៣ | សហការបណ្តុះបណ្តាល *MSc* | *Belg.* | 534,895 € | ១៧ | ប៉ារ៉ាស៊ីតសត្វ | Belg | 65,000 € |
| ៤ | ពង្រឹងសមត្ថភាពកសិក-បម្រែបម្រួលអាកាសធាតុ | MoE/ UNDP | 300,000 $ | ១៨ | បម្រែបម្រួលអាកាសធាតុ *(ToT)* | Japan | 5,300 $ |
| ៥ | ពង្រឹងសមត្ថភាពបសុពេទ្យ | USDA | 51,000 $ | ១៩ | គុណភាពសាច់ | Norway | 3,000 $ |
| ៦ | ចំណីគោ | Sweden | 3,000 $ | ២០ | ចំណីគោ | CARF | 18,326 $ |
| ៧ | *EURASIA II* | EC | | ២១ | ចំណីគោ - បំប៉ន | ACIAR | 621,652Au $ |
| ៨ | *Techno* | EC | | ២២ | សិប្បកម្មផ្តៅ | WWF | 14,500 $ |
| ៩ | គ្រប់គ្រងធនធានធម្មជាតិ | USAID | 53,000$ | ២៣ | ការអនុវត្តន៍ទីវាល | LI | 3,800 $ |
| ១០ | ស្មៅចម្រៃនិងទិន្នផលស្រូវ | ACIAR | 30,000$ | ២៤ | វារីវប្បកម្ម | CARF | 17,660 $ |
| ១១ | ប៉ារាស៊ីតដំណាំ | CARF | 27,280 | ២៥ | បន្លែសុវត្ថភាព | USAID | 50,000 $ |
| ១២ | ផលិតកម្មបន្លែ | ACIAR | | ២៦ | ស្រាផ្លែឈើត្រូពិក | CARF | 17,386 $ |
| ១៣ | បង្កើនផលិតកម្មស្រូវ | ACIAR | | ២៧ | កែឆ្នៃអាហារ-ស្រា | JICA | 45,465,000 ô |
| ១៤ | អភិវឌ្ឍន៍កសិកម្មកម្ពុជា | SANREM | | | | | |

### ង. ការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស

សាកលវិទ្យាល័យបានធ្វើការអភិវឌ្ឍន៍ធនធានសាស្ត្រាចារ្យ ដោយបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលចំនួន១៣វគ្គ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងទស្សនកិច្ចសិក្សាចំនួន ១៦ដង។ ក្រៅពីនេះមន្ត្រី និងបុគ្គលិកចំនួន ១៥រូបកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង៩រូបថ្នាក់បណ្ឌិតនៅក្រៅប្រទេស។ បន្ថែមពីលើនេះ សាកលវិទ្យាល័យបានបញ្ជូននិស្សិតចំនួន៤៤រូបទៅធ្វើកម្មសិក្សាទៅប្រទេសអ៊ីស្រាអែល ចូលរួមវគ្គសិក្សាខ្លី វែង នៅសហរដ្ឋអាមេរិក ជប៉ុន ម៉ាឡេស៊ី និងប្រទេសវៀតណាម។

### ច. សន្និសីទវិទ្យាសាស្ត្រ

ក្នុងឆ្នាំ២០១១នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានសហការជាមួយដៃគូជាតិ និងអន្តរជាតិ រៀបចំវេទិកាវិទ្យាសាស្ត្រសំខាន់ៗនៅក្នុងសាកលវិទ្យាល័យបានចំនួន៣លើក ដូចខាងក្រោមៈ

-ប្រារព្ធធ្វើសន្និសីទវិទ្យាសាស្ត្រអន្តរជាតិលើកទី២ ស្តីអំពី International Conference on Environmental and Agricultural Development

-រៀបចំ Lectures and Capacity Building Seminar on Environmental Service, Sustainable Land Use and Natural Resources Management, Community of Agricultural Production

-រៀបចំ Summer School on Comprehensive Land Policy in Cambodia: Framework and Precondition for balanced Spatial Planning and Development

### ២.សន្និដ្ឋាននិងការវាយតម្លៃ

ជារួមអាស្រ័យដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ថ្នាក់ដឹកនាំក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងជាពិសេសការខិតខំប្រឹងប្រែងផ្ទាល់របស់ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ បុគ្គលិក និងកម្មករ ពេលនេះសាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលនូវទំនុកចិត្តខ្ពស់ពីសំណាក់និស្សិតនិងអាណាព្យាបាល ហើយដែលធ្វើឲ្យកំណើននិស្សិត ចូលសិក្សាមានការកើនឡើងជាលំដាប់ ។ សាកលវិទ្យាល័យបានយកចិត្តទុកដាក់ជាសំខាន់លើការអប់រំប្រកប ដោយគុណភាពនិងផ្សារភ្ជាប់ជាមួយសេចក្តីត្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននិងទៅអនាគត ដោយយកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិជាកត្តាចំបង ។

អ្វីដែលសាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបានមកដល់ពេលនេះ គ្រាន់តែជាភាពជោគជ័យមួយផ្នែកប៉ុណ្ណោះបើប្រៀបធៀបនឹងសេចក្តីត្រូវការអភិវឌ្ឍន៍ដ៏ធំធេងរបស់សាកលវិទ្យាល័យ។ ដូចនេះ សាកលវិទ្យាល័យនៅមានផ្លូវវែងឆ្ងាយបន្តទៀត ក្នុងការកសាងធនធានសាស្ត្រាចារ្យឲ្យបានរឹងមាំនិងគ្រប់ចំនួន កសាងហេដ្ឋារចនាសម្ព័ន្ធអាគារសិក្សា បន្ទប់ពិសោធន៍ សម្ភារពិសោធន៍ស្រាវជ្រាវ ស្ថានីយ៍អនុវត្តជាក់ស្តែង និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ជីវិតសិក្សារបស់និស្សិតចាំបាច់ជាច្រើនទៀតដូចជា អាហារដ្ឋានទំនើប បណ្ណាល័យនិងបណ្ណាគារទំនើប ពហុកីឡដ្ឋាន អន្តេវាសិកដ្ឋាន និងមណ្ឌលសិល្បៈកំសាន្តជាដើម។

## ៥.៨.២.២ សាលាជាតិកសិកម្មព្រែកលៀប

### ១.លទ្ធផល

### ក. ការងារគ្រប់គ្រងសាស្ត្រាចារ្យ

ក្នុងការងារបណ្តុះបណ្តាលនាឆ្នាំ២០១១នេះ សាលាជាតិបានយកចិត្តទុកដាក់ជ្រើសរើសសាស្ត្រាចារ្យដែល មានបទពិសោធន៍ និងមានជំនាញតាមមុខវិជ្ជាច្បាស់លាស់ ហើយតម្រូវឲ្យមានកិច្ចសន្យាបង្រៀនជាមូលដ្ឋានក្នុងការ ពង្រឹងគុណភាពបង្រៀន។

បច្ចុប្បន្នសាលាជាតិមានសាស្ត្រាចារ្យចំនួន១៨៤នាក់ (នារី៣៨នាក់) ដោយមន្ត្រីសាលាជាតិទទួលភារកិច្ចបន្ថែមជាសាស្ត្រាចារ្យមានចំនួន១០៨នាក់ (នារី២៨នាក់) និងសាស្ត្រាចារ្យមកពីក្រៅមានចំនួន៧៦នាក់ (នារី១០នាក់)។




## ខ. ការងារគ្រប់គ្រងនិស្សិត

ឆ្នាំសិក្សា២០១១-២០១២ សាលាជាតិកសិកម្មព្រែកលៀប មាននិស្សិតសរុបចំនួនសរុបចំនួន១.៥៤៥នាក់ (នារី ៤៨៧នាក់) ដែលមាននិស្សិតថ្នាក់បរិញ្ញារង៣៦១នាក់ (នារី១២៤នាក់) និស្សិតបរិញ្ញា ១.១៨៤ នាក់ (នារី៣៦៣នាក់)




## គ. ការងារបញ្ចប់ការសិក្សារបស់និស្សិត







## ឃ. សហប្រតិបត្តិការនិងអន្តរជាតិ

បច្ចុប្បន្ននេះ ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងស្រុក សាលាជាតិកសិកម្មព្រែកលៀបបាននិងកំពុងបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយគម្រោងកម្មវិធី SRFI ប្រទេសកាណាដា លើការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយបង្គោលសម្រាប់គម្រោងការចិញ្ចឹមត្រីចំរុះក្នុងស្រែក្នុងខេត្តតាកែវ ប៉ុន្តែត្រូវបញ្ចប់គម្រោងក្នុងខែតុលាឆ្នាំ២០១១។

២- វាយតម្លៃនិងសន្និដ្ឋាន

ទោះបីមានការលំបាកនិងចំណុចខ្វះខាតជាច្រើនយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងរយៈពេល ការបន្ថែម ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រនិយមជាតិ និងអន្តរជាតិ គឺសាលាជាតិត្រូវការពេលវេលាវែងបន្តទៀតក្នុងការអភិវឌ្ឍន៍។ ក្នុងរយៈពេលខ្លីនេះ ហើយថែមទាំងជួបការនូវលំបាកជាសត្យានុម័តផ្សេងៗជាច្រើន ទាំងក្នុងបរិស្ថានខាងក្នុង ក៏ដូចជាបរិស្ថានប្រកួតប្រជែងខាងក្រៅ សាលាជាតិសម្រេចបាននូវសមិទ្ធផលជាជំហានដំបូងយ៉ាងច្រើន សម្រាប់ធ្វើជាមូលដ្ឋានក្នុងការឈានទៅសម្រេចបេសកកម្ម និងគោលដៅរបស់សាលាជាតិ។

៣- វិធានការ

-ការពង្រឹងបទបញ្ជាផ្ទៃក្នុង កែលម្អកម្មវិធីសិក្សា និងខ្លឹមសារមេរៀន

-ការងារបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀន ការងារទាក់ទង និងតភ្ជាប់កិច្ចសហការជាមួយអន្តរជាតិ

-អនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីរយៈពេលវែងឬមធ្យម (៣-៥ឆ្នាំ) សម្រាប់ជាទិសដៅអនុវត្ត។

## ៤.៨.២.៣ សាលាជាតិកសិកម្មកំពង់ចាម

១-លទ្ធផល

### ក. សមត្ថភាពមន្ត្រីសេវាកម្មផ្នែករដ្ឋបាល ផ្នែកបច្ចេកទេសនិងសាស្ត្រាចារ្យ

-មន្ត្រីក្របខ័ណ្ឌសារុបនៅសជកកចមាន ៤៣ ស្រី ០៨និងមន្ត្រីជាប់កិច្ចសន្យាពលករអណ្តែតសារុបមាន២៤នាក់

-សាស្ត្រាចារ្យសារុបនៅសជកកចមានៈ ២០៦គ្រូចរន្តមាន១៤៣នាក់ក្នុងនោះគ្រូរបស់សាលាមាន ៣៨នាក់

-សមត្ថភាពសាស្ត្រាចារ្យបំពេញការងារកម្រិតបណ្ឌិតចំនួន៩នាក់កម្រិតបរិញ្ញាជាន់ខ្ពស់ ៤៨នាក់ បរិញ្ញាបត្រ៧០នាក់ និងបរិញ្ញាបត្ររង ១៦នាក់

-មន្ត្រីផ្នែករដ្ឋបាលចំនួន២នាក់បានចូលប្រជុំនិងសិក្សាពីការគ្រប់គ្រងបុគ្គលិកនិងកិច្ចការរដ្ឋបាលតាមប្រព័ន្ធIT (ក្រសួងអប់រំ) និងសុំមន្ត្រីក្របខ័ណ្ឌបន្ថែមចំនួន១១នាក់ពីក្រសួងកសិកម្ម

-សំណើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា១០នាក់និងពលករអណ្តែត១៤នាក់ និងបំប៉នមន្ត្រីជាប់កិច្ចសន្យាលើជំនាញកិច្ចការរដ្ឋបាលនិងការគ្រប់គ្រង

### ខ. ការលើកម្ពស់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម

-ឆ្នាំ២០១១និស្សិតបរិញ្ញាប័ត្ររងជំនាន់ទី១៥ចំនួន១៨១ត្រូវបានប្រឡងបញ្ចប់ហើយ និងនិស្សិតថ្នាក់បរិញ្ញាប័ត្រចំនួន១៩៣នាក់ត្រូវបានការពារសារណាបទបញ្ចប់ហើយដែរ

-កិច្ចពង្រឹងការបណ្តុះបណ្តាល ការចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលរបស់និស្សិត ការលើកកំពស់របស់យុវជនដើម្បីពាណិជ្ជកម្មអាស៊ាន

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកិច្ចព្រមព្រៀងវិស័យកសិកម្ម-ភូតតាមអនាម័យរបស់អង្គការីទៀ និងផ្សព្វផ្សាយស្តីពីគោលការគ្រឹះរបស់ចលនាកាកបាតក្រហមកម្ពុជា និងទស្សនកិច្ចសិក្សាស្តីពីការចិញ្ចឹមនាងនិងដាំមននៅសៀមរាប

### គ. សកម្មភាពកម្មសិក្សានិងអភិវឌ្ឍន៍កម្មវិធីសិក្សា

-និស្សិតគ្រប់ដេប៉ាតឺម៉ង់ជំនាញទាំងអស់បានចុះធ្វើកម្មសិក្សាដើម្បីពង្រឹងការសិក្សាបន្ទាប់ ពីបាន សិក្សាផ្នែកទ្រឹស្តីនៅចុងបញ្ចប់នៃឆមាសនីមួយៗនៃឆ្នាំសិក្សា និងនិស្សិតបានធ្វើរបាយការណ៍ស្តីពីការចុះកម្មសិក្សារយៈពេលខ្លីនិងបានកសាងឯកសារទុកក្នុងបណ្ណាល័យ

-រៀបចំគណៈកម្មការពិនិត្យគុណភាពនិងកែលម្អវិធីសាស្ត្រអប់រំបណ្តុះបណ្តាល និងបង្កើតឱ្យមានបទអន្តរាគមន៍ស្តីពីបច្ចេកទេសកសិកម្មដោយវាគ្មិនឯកទេស ដើម្បីធ្វើបទបង្ហាញ និងការសម្របសម្រួលឱ្យនិស្សិតបានចុះសិក្សាអនុវត្តន៍

-បង្កើតគណៈកម្មការដើម្បីរៀបចំអភិវឌ្ឍន៍កម្មវិធីសិក្សាដោយមានការចូលរួមយោបល់ពីសាស្ត្រាចារ្យក្នុងនិងខាងក្រៅ និងកែលម្អគោលការណ៍នៃការអប់រំបណ្តុះបណ្តាលតាមរយៈកាត់បន្ថយមុខវិជ្ជាមិនចាំបាច់ និងបន្ថែមមុខវិជ្ជាមានប្រយោជន៍សម្រាប់ការងារសង្គមនិងសេដ្ឋកិច្ច

-បង្កើនចំនួនម៉ោងចុះកម្មសិក្សានិងអនុវត្តបានច្រើននិងជំរុញឱ្យនិស្សិតចេះសរសេររបាយការណ៍និងចងក្រងសារណាបទបញ្ចប់ការសិក្សា គោលការណ៍ចងក្រងសារណាបទនិងរបាយការណ៍បញ្ចប់ការសិក្សា

### ឃ. ការលើកកម្ពស់គុណភាពគោរពវិន័យនិងបទបញ្ជាផ្ទៃក្នុង

-រៀបចំតាក់តែងកែលម្អខ្លឹមសារបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងអន្តេវាសិកដ្ឋាន និងចំពោះនិស្សិត-សាស្ត្រាចារ្យ

-រៀបចំតាក់តែងកែលម្អខ្លឹមសារបទបញ្ជាផ្ទៃក្នុងសម្រាប់អនុវត្តន៍បណ្ណាល័យនិងមន្ទីរពិសោធន៍

-សរសេរលើប៉ាន់ណូផ្សព្វផ្សាយពីបទវិន័យផ្សេងៗដែលតម្រូវឱ្យអនុវត្តន៍ក្នុងសាលា និងលើកផ្លាកសរសេរពាក្យដាស់តឿនដល់យុវជនអំពីផលវិបាកនិងអន្តរាយក្នុងការប្រើប្រាស់គ្រឿងញៀនជាដើម។

### ង. ការងារកែលម្អហេដ្ឋារចនាសម្ព័ន្ធរបរិន្តនិងបំពាក់ទព្វសម្ភារៈ

-ជួសជុលកែលម្អការិយាល័យនានា ក្នុងអាគាររដ្ឋបាលថ្មីនិងបំពាក់សម្ភារៈ អាគារសិក្សា ដេប៉ាតឺម៉ង់ដំណាំកៅស៊ូ និងដាក់បង្កាន់ដៃថ្មី និងច្រកចាស់-បើកច្រកធ្វើទ្វាថ្មី១៩៤,២ម

-រៀបការ៉ូឡានៅទីធ្លាខាងមុខសាលាទំហំ៩១០,២ម (តាមសំណូមពរសាលាខេត្ត) និងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកសិកម្មទំហំ៤៤០ម២

-រៀបចំកែលម្អនិងពង្រីកទីធ្លានៃបរិវេណមុខអាគារសិក្សា២៣៦,២ម ប្រព័ន្ធទឹកនិងកែលម្អសួនក្នុងបរិវេណសាលាឱ្យបានល្អ និងចាក់សាបរៀបចំផ្លូវកន្សែងខាងក្រោយអាគាររដ្ឋបាលថ្មី៩៦,២ម

-រៀបចំនិងចាក់បេតុងធ្វើផ្លូវខាងមុខអាគារដេប៉ាតឺម៉ង់សេដ្ឋកិច្ចកសិកម្ម៤១៦,២ម

-ការងារនៅលើដី១០ហត ស្ថានីយថ្មពេជ្រដូចជា ដំណើរការអាគារទំហំ៤៦ម x៩ម សម្រាប់ការងារស្ថានីយ៍ សង់របងការពារសុវត្ថិភាព

-ការងារបំពាក់ទព្វសម្ភារៈនិងបរិក្ខាដូចជា កុំព្យូទ័រចំនួន ០៥គ្រឿង បំពាក់ម៉ាស៊ីនបោះពុម្ពចំនួន០៥គ្រឿង បំពាក់ម៉ាស៊ីនថតចម្លង០១គ្រឿង បំពាក់តុការិយាល័យ០២កៅអីជើងដែក៥០តុ២៥ក្តាខៀន១០ដល់ដេប៉ាតឺម៉ង់ជំនាញបំពាក់ទូរឯកសារ០៣ ម៉ាស៊ីនកាត់ស្មៅ០១គ្រឿង និងសម្ភារៈមួយចំនួនទៀតសម្រាប់ប្រើប្រាស់។

### ច. ការលើកកម្ពស់ផ្ទេរបច្ចេកវិជ្ជានិងការបណ្តុះបណ្តាលកសិករកម្ម

កម្មវិធីនេះត្រូវបានសហការជាមួយមូលដ្ឋានភូមិឃុំក្នុងខេត្តកំពង់ចាម ដើម្បីគាំទ្រគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានតាមរយៈជំនួយឧបត្ថម្ភមូលនិធិអង្គការ ខោណីខោ ការបណ្តុះបណ្តាលកសិករត្រូវបានរៀបចំកម្មវិធីបើកវគ្គខ្លី លើមុខជំនាញដូចជា ការរៀបចំប្រព័ន្ធកសិកម្មចំរុះ ការចិញ្ចឹមត្រីក្នុងថង់ប្លាស្ទិច ការធ្វើជីកំប៉ុស្តគោក កំប៉ុស្តទឹក ការដាំដំណាំផ្សិត ការដាំដំណាំបន្លែ ការចិញ្ចឹមជ្រូក ការចិញ្ចឹមមេមាន់ ការសាងសង់ចង្ក្រានកែច្នៃធ្វើស្កត្នោត និងការតម្លើងឡជីវឧស្ម័ន។

ការងារកាត់បន្ថយភាពក្រីក្រតាមរយៈផ្ទេរបច្ចេកវិជ្ជាជូនដល់កសិករនៅស្រុកស្ទឹងត្រង់ ការឧបត្ថម្ភចំណេះដឹងជូនដល់កសិករសម្រាប់លើកកម្ពស់ជីវភាពតាមរយៈដូចជា កម្មវិធីឥណទានពូជស្រូវ កម្មវិធីឥណទានពូជជ្រូកមេ កម្មវិធីឥណទានពូជគោមេ កម្មវិធីឡជីវឧស្ម័ន កម្មវិធីចិញ្ចឹមត្រីជាលក្ខណៈគ្រួសារនៅស្រុកពញាក្រែក (ឃុំកក់) កម្មវិធីបណ្តុះបណ្តាលកសិករលើដំណាំបន្លែប៉េងប៉ោះ ត្រសក់ សណ្តែកកួរ ឪឡឹក កម្មវិធីធ្វើស្រែបង្ហាញលើដំណាំស្រូវប.វ.ស និងកម្មវិធីបណ្តុះបណ្តាលកសិករធ្វើជីធម្មជាតិ (ជីកំប៉ុស្តទឹក,គោកថ្នាំធម្មជាតិកំចាត់សត្វល្អិត) នៅស្រុកត្រាំកក់ (ឃុំញ៉ែងញ៉ង) កម្មវិធីដាំដំណាំបន្លែ កម្មវិធីឥណទានពូជជ្រូកមេ កម្មវិធីឥណទានពូជគោមេ កម្មវិធីឥណទានប្រាក់សន្សំ កម្មវិធីដំណាំស្មៅចំណីសត្វគោ កម្មវិធីសន្សំជីធម្មជាតិនិងការធ្វើរោងជីកំប៉ុស្ត។

### ឆ. ការងារពង្រឹងកិច្ចសហប្រតិបត្តិការអន្តជាតិនិងការស្វែងរកដៃគូរអភិវឌ្ឍន៍

- **កិច្ចសហការជាមួយ ACIAR (CARF-CAVAC)** ACIAR ផ្តល់មូលនិធិសម្រាប់គម្រោងពិសោធន៍ស្រាវជ្រាវលើប្រសិទ្ធភាពដំណាំស្រូវនៅប្រទេសកម្ពុជា (ស្រុកស្ទឹងត្រង់ សន្ទុក បារាយណ៍ និងក្រុងស្ទឹងសែន)
- **កិច្ចសហការជាមួយ OISCA-International (ជប៉ុន)** OISCA ផ្តល់អាហារូបករណ៍សម្រាប់មន្ត្រីនិងនិស្សិតសជកកចបណ្តុះបណ្តាលលើជំនាញកសិកម្មរយៈពេល១ឆ្នាំ

- **កិច្ចសហការជាមួយ Del PHE (U.K )** Del PHE (U.K )បានផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវពីការចិញ្ចឹមសត្វ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅតំបន់ជនបទនិងក្រីក្រ
- **កិច្ចសហការជាមួយ MEKARN** MEKARN ផ្តល់មូលនិធិសម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស និងការងារពិសោធន៍ស្រាវជ្រាវលើដំណាំចំណីសត្វ និងបានផ្តល់សម្ភារៈបរិក្ខាពិសោធន៍សម្រាប់ចំណីសត្វ
- **កិច្ចសហការជាមួយសាកលវិទ្យាល័យ Tokyo University**

-បានសហការជាមួយទៀយៀនិវរសិតយលើកម្មវិធីផ្លាស់ប្តូរបទពិសោធន៍រវាងនិស្សិតកម្ពុជា និងនិស្សិតជប៉ុន

-និស្សិតជប៉ុនចំនួន១០នាក់ដឹកនាំដោយសាស្ត្រាចារ្យជប៉ុន២រូប បានមកធ្វើទស្សនកិច្ចសិក្សានៅសជកកចរយៈពេល ១ថ្ងៃរួមសហការជាមួយគ្រូនិងនិស្សិត**សជកកច**ចំនួន ១៨នាក់។

- **កិច្ចសហការជាមួយ FCM (FederationofCanadianMunicipalities)**

-បានសហការជាមួយធជិតាមរយៈកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន (LED )

-នៅខែកុម្ភៈ ឆ្នាំ២០១២ ខាងមុខគជណេព្យនិងគ្រោងធ្វើ MOU ជាមួយសាកលវិទ្យាល័យ Fraser Valley University ស្តីពីការផ្លាស់ប្តូរបទពិសោធន៍រវាង KCNSA និង UFV ។

- **កិច្ចសហការជាមួយសាលាជាមទ្រីអន្តរជាតិ (Palm Tree School International)** នៅពេលថ្មីៗកន្លងមកនេះ សជកកចធ្វើពិធីចុះ MOU ជាមួយសាលាជាមទ្រីអន្តរជាតិ ដើម្បីសហការអភិវឌ្ឍន៍លើ

ផ្នែកភាសារបរទេស

- **កិច្ចសហការជាមួយអង្គការ Cel.Agrid** បានសហការជាមួយ Cel.Agrid ដើម្បីផ្តល់នូវនិស្សិតបានចុះសិក្សាអនុវត្តជាក់ស្តែងលើការចិញ្ចឹមសត្វ និងការរៀបចំធ្វើចំណីសត្វតាមគោលការណ៍ធម្មជាតិ។
- **កិច្ចសហការជាមួយអង្គការ CEDAC**

-តាមរយៈកម្មវិធី Prolinova អង្គការ CEDAC បានផ្តល់ឱកាសឱ្យសាស្ត្រាចារ្យនិងនិស្សិត បានសិក្សាស្វែងយល់ពីការធ្វើកសិកម្មតាមគោលការណ៍ធម្មជាតិនិងបង្ហិកសាស្ត្រាចារ្យដែលបានចូលរួមពីការស្វែងយល់ពីគំនិតផ្តួចផ្តើមថ្មីៗ

- CEDAC បានផ្តល់ឯកសារទស្សនាវដ្តីសម្រាប់បណ្ណាល័យសាលាជារៀងរាល់ខែ និងឱ្យគ្រូសាលាបានចូលរួមសិក្ខាសាលាស្តីពីការផ្តួចផ្តើមគំនិតថ្មីៗ

-CEDAC បានផ្តល់វាគ្មិនសម្រាប់ធ្វើបទឧទ្ទេសនាមស្តីពីបទពិសោធន៍ការធ្វើកសិកម្មតាមបែបធម្មជាតិនិងកសិកម្មសរីរាង្គ

## ជ. ការងារពិសោធន៍ស្រាវជ្រាវនិងការផ្សព្វផ្សាយ

-មានគម្រោងពិសោធន៍ចំនួន១១ត្រូវបានដំណើរការនៅក្នុងឆ្នាំ២០១១កន្លងមកនេះដូចជា÷ (១)សិក្សាពិសោធន៍លើដំណាំស្រូវដោយប្រើជីសរីរាង្គនិងជីគីមីលើក្រុមដីស្រុកកំពង់សៀម (២)សិក្សាពិសោធន៍លើការបង្កាត់និងចិញ្ចឹមកង្កែបដោយប្រើចំណីផ្សំស្រេចនិងចំណីធម្មជាតិ (៣)សិក្សាពិសោធន៍លើដំណាំសណ្តែកសៀង ៤ប្រភេទនៅស្រុកចំការលើ (៤)សិក្សាពិសោធន៍ពិធីរៀបចំប្រព័ន្ធកសិកម្មចំរុះនៅភូមិនាងទើកស្រុកតំបែរ (៥) សិក្សាពិសោធន៍លើការចិញ្ចឹមជ្រូកសាច់ពូជកូនកាត់ចំនួន១០ក្បាលនៅសជកកច (៦) សិក្សាពិសោធន៍លើការចិញ្ចឹមជ្រូកមេដោយប្រើចំណី៩៦៣០របស់គ្រីនហ្វីត (៧) សិក្សាពិសោធន៍លើការរៀបចំកសិដ្ឋានពហុប្រយោជន៍លក្ខណៈគ្រួសារនៅស្ទឹងត្រង់ (៨) សិក្សាពិសោធន៍លើការប្រើជីធម្មជាតិ, លាមកគោ, លើដំណាំឪឡឹក, ត្រសក់នៅឃុំកក់ (៨) សិក្សាពិសោធន៍លើការប្រើថ្នាំធម្មជាតិ៣ប្រភេទសម្រាប់កំចាត់សត្វល្អិតបំផ្លាញដំណាំនៅឃុំកក់ (១០) សិក្សាពិសោធន៍លើការប្រើជីកំប៉ុស្តស្រស់លើដំណាំម្រះនៅកំពង់សៀម (១១)សិក្សាពិសោធន៍លើការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារនៅក្នុងឃុំញ៉ៀងញ៉ង់នៅស្រុកត្រាំកក់។

-បានធ្វើសិក្ខាសាលា ដើម្បីផ្សព្វផ្សាយពីការដាំដំណាំស្រូវតាមគោលការណ៍ធម្មជាតិមានកសិករ ក្រុមប្រឹក្សាឃុំ និស្សិត៤០នាក់ និងសិក្ខាសាលាដើម្បីផ្សព្វផ្សាយបច្ចេកទេសដាំដំណាំចំណីសត្វ (ដាំស្មៅ) តាមគោលការណ៍ ធម្មជាតិមានមេឃុំនិស្សិតចំនួន៤៨នាក់បានចូលរួម

-បានធ្វើការផ្សព្វផ្សាយពីបច្ចេកទេសធ្វើជីកំប៉ុស្តនិងការធ្វើរោងជីសន្សំជីធម្មជាតិដល់កសិករ១៤គ្រួសារនៅស្រុកស្ទឹងត្រង់ និងផ្សព្វផ្សាយពីការធ្វើឥណទានជ្រូកពូជ, ឥណទានប្រាក់សន្សំនៅក្នុងឃុំញ៉ៀងញ៉ង់នៅស្រុកត្រាំកក់

-បានធ្វើសិក្ខាសាលានៅឃុំពាមកោះស្នាស្ដីពីការធ្វើដំណាំស្រូវតាមប.វ.ស ដែលមានកសិករ ក្រុមប្រឹក្សាឃុំប្រមាណ ២០០នាក់ចូលរួម

-បោះពុម្ពឯកសារផ្សព្វផ្សាយស្ដីពី ការធ្វើដំណាំស្រូវតាមគោលការណ៍ធម្មជាតិរបស់ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកសិកម្ម និងការធ្វើស្រែបង្ហាញសម្រាប់កសិករគំរូចំនួន៥០នាក់ (នៅក្នុងខេត្តកំពង់ធំ)។

**២. វាយតម្លៃនិងសំណើ**

កិច្ចដំណើរការសកម្មភាពការងារនៅក្នុងឆ្នាំ២០១១នេះ បានប្រព្រឹត្តទៅមានលក្ខណៈជាប្រក្រតីគ្មានអ្វីគួរឱ្យកត់សម្គាល់ទេក្នុងនោះ÷

-មន្ត្រីរាជការ សាស្ត្រាចារ្យបានបំពេញការងារដោយមានស្មារតីយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់

-សតិអារម្មណ៍របស់មន្ត្រី សាស្ត្រាចារ្យរបស់សជកកចមានភាពប្រក្រតីនិងស្ងប់ស្ងាត់ល្អ

-ឆ្នាំ២០១១នេះ មន្ត្រីរាជការ សាស្ត្រាចារ្យមានការខិតខំបង្កើននិងពង្រឹងសមត្ថភាពបានច្រើនជាងឆ្នាំ កន្លងទៅ

-អង្គភាពបានប្រកាន់យកវប្បធម៌ចែករំលែក និងសាមគ្គីភាពផ្ទៃក្នុងការទទួលខុសត្រូវមិនប្រកាន់ឋានៈតួនាទី

-ការដោះស្រាយបាតុភាពផ្សេងៗត្រូវបានអនុវត្តក្រោមរូបភាពឈ្នះ,ឈ្នះនិងការយោគយល់គ្នា

-បញ្ហាធំៗត្រូវបានដោះស្រាយតាមរយៈអង្គុយជជែកគ្នាដោយសន្តិវិធីនិងហេតុផលច្បាស់លាស់

-ពីមួយឆ្នាំទៅមួយឆ្នាំសាលាជាតិកសិកម្មកំពង់ចាមមានការផ្លាស់ប្ដូរប្រែប្រួលជាបន្តបន្ទាប់ក្នុងនោះ ចំណុចដែលលេចធ្លោមានៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ធនធានសម្ភារៈ កិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ និងគុណភាពអប់រំបណ្ដុះបណ្ដាលត្រូវបានបង្កើននិងទាំងបរិមាណទាំងគុណភាព។

-នៅពេលអនាគតដ៏ខ្លីខាងមុខនេះ សាលាជាតិកសិកម្មកំពង់ចាមនិងក្លាយជាអង្គភាពបណ្ដុះបណ្ដាលមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់លើការអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងក្របខ័ណ្ឌបង្កើនអ្នកបច្ចេកទេសសម្រាប់បម្រើនិងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

## ៥.៤.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ

**១. លទ្ធផល**

**ក. ការងារចំណូល**

ក្នុងឆ្នាំ២០១១ ការប្រមូលចំណូលចូលថវិកាជាតិសម្រេចបានចំនួន ១៤៨.១៨៦.០៨៦.០២០រៀល ដែលមានប្រមាណ ១៤៦ % នៃផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន១០១ ៣៧៩.០០០.០០០រៀល។ ក្នុងនោះ ÷

១-ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋសម្រេចបាន៤២.៦៩៥.៧០៤.៥៧០រៀល ដែលមានប្រមាណ១៣៧% នៃផែនការចំនួន ៣១.២៦១.០០០.០០០រៀល

២-ចំណូលផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា ប្រមូលបានចំនួន៤.២៥៦.៨០៨.៥០៧រៀល ស្មើនឹង ១១៤%នៃផែនការដែលមានចំនួន៣.៧១៨.០០០.០០០រៀល

៣-ចំណូលបានមកពីការផាកពិន័យ និងដាក់ទណ្ឌកម្មចំនួន២៧.៨៧៤.៥៤៨.៧២២រៀលស្មើនឹង ៣៤៨៤% នៃផែនការចំនួន ៨០០.០០០.០០០រៀល។

**ខ. ការងារចំណាយ**

ការអនុវត្តនិងគ្រប់គ្រងថវិកាប្រចាំឆ្នាំ២០១១ សម្រេចបានប្រមាណ ៨៩,៨០% នៃថវិកាកែតម្រូវ។ ការចំណាយថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានញែកដាច់ពីគ្នារវាងថវិកាតាមកម្មវិធី និងថវិកាមិនមែនតាមកម្មវិធី ដូច្នេះយើងអាចវិភាគខ្ទង់ចំណាយថវិកានីមួយៗដូចខាងក្រោម :

**- ថវិកាមិនមែនកម្មវិធី÷**

ការចំណាយលើការងាររដ្ឋបាលប្រចាំថ្ងៃ និងការអនុវត្តប្រចាំឆ្នាំ អនុវត្តបានប្រមាណ៤៥.៧៩០.១៤៥.៦៨០រៀល ស្មើនឹង៩១,៦៦%នៃថវិកាកែតម្រូវចំនួន៤៩.៩៥៦.៥០០.០០០រៀល។ ការចំណាយតាមជំពូកនីមួយៗមានដូចខាងក្រោម:

**ជំពូក ៦០**: ការទិញអនុវត្តជាក់ស្ដែងបានចំនួន ១១.៩៨០.៦២២.០៨៨រៀល ស្មើនឹង ៩៧,១៧%នៃថវិកាកែ

តម្រូវដែលមានត្រឹមតែចំនួន ១២.៣៣០.០០០.០០០រៀល

**ជំពូក ៦១**: សេវាខាងក្រៅអនុវត្តជាក់ស្តែងបានចំនួន ១.៤៩២.៨២០.៦៥៦រៀល ស្មើនឹង៧៤,០៩%នៃថវិកាកែតម្រូវដែលមានចំនួន ២.០១៥.០០០.០០០រៀល

**ជំពូក ៦២**: សេវាក្រៅផ្សេងៗអនុវត្តជាក់ស្តែងបានចំនួន ៣.៥០៨.៦២៧.៩២៥រៀលស្មើនឹង ៨៦,៩០%នៃថវិកាកែតម្រូវដែលមានចំនួន ៤.០៣៧.៥០០.០០០រៀល

**ជំពូក ៦៣**: ពន្ធនិងអាករ អនុវត្តជាក់ស្តែងបានចំនួន ១៤៣.៧០២.០០០រៀល ស្មើនឹង ៥៩,៨៨%នៃថវិកាកែតម្រូវដែលមានចំនួន ២៤០.០០០.០០០រៀល

**ជំពូក ៦៤**: បន្ទុកបុគ្គលិកអនុវត្តជាក់ស្តែងបានចំនួន ២១.៣១២.១៧៣.២៥៦រៀល ស្មើនឹង ៩១,៥៩%នៃថវិកាកែតម្រូវដែលមានចំនួន២៣.២៧១.០០០.០០០រៀល

**ជំពូក ៦៥**: ឧបត្ថម្ភធននិងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន៧.៣៥២.១៩៩.៧៥៥រៀលស្មើនឹង ៩១,១៨% នៃថវិកាកែតម្រូវដែលមានចំនួន ៨.០៦៣.០០០.០០០រៀល។

- **ថវិកាតាមកម្មវិធី÷**

ការចំណាយថវិកាសំដៅសម្រេចឲ្យបានគោលបំណង គោលដៅ និងលទ្ធផលរំពឹងទុករបស់វិស័យនិមួយៗដែលបានកំណត់ពីដើមឆ្នាំ២០១១នេះ ការប្រើប្រាស់ថវិកាតាមកម្មវិធីមានលក្ខណៈល្អប្រសើរច្រើនធៀបនឹងឆ្នាំ២០១០ ជាក់ស្តែងក្រសួងអនុវត្តបានចំនួន១២.៩៨៧.៧៩០.៧៤០រៀល ដែលមានប្រមាណ៨៣,៤១% នៃថវិកាកែតម្រូវចំនួនប្រមាណ ១៤.៤៩១.៤០០.០០០រៀល។ ការចំណាយតាមជំពូកនីមួយៗមានដូចខាងក្រោម ÷

**ជំពូក ៦០**: ការទិញអនុវត្តជាក់ស្តែងបានចំនួន ៤.០៨៩.៨៨២.១៧៥រៀល ស្មើនឹង ៨៧,៤៤%នៃថវិកាកែតម្រូវដែលមានចំនួន ៤.៦៧៧.៣០០.០០០រៀល

**ជំពូក ៦១**: សេវាខាងក្រៅអនុវត្តជាក់ស្តែងបានចំនួន ៣.៩៧០.៤០០.៣៤០រៀល ស្មើនឹង ៧៥,៤១%នៃថវិកាកែតម្រូវដែលមានចំនួន ៥.២៦៤.៩០០.០០០រៀល

**ជំពូក ៦២**: សេវាក្រៅផ្សេងៗអនុវត្តជាក់ស្តែងបានចំនួន៣.៩៩៧.៥០៨.២២៥រៀល ស្មើនឹង ៨៨,៤៦%នៃថវិកាកែតម្រូវដែលមានចំនួន ៤.៥១៩.២០០.០០០រៀល

**ជំពូក ៦៥**: ឧបត្ថម្ភធន និងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន៣០.០០០.០០០ រៀល ស្មើនឹង ១០០%នៃថវិកាកែតម្រូវដែលមានចំនួន៣០.០០០.០០០រៀល។




## គ. ការងារផ្គត់ផ្គង់អង្គភាពក្រោមឱវាទ

ប្រេងឥន្ធនៈគតិជាទឹកប្រាក់សរុបចំនួនៈ **១.៥៨៩.៦៤៤.៣០០៖០០**

| | | |
|---|---|---|
| +ប្រេងម៉ាស៊ូត | មានទឹកប្រាក់ ចំនួន | ១.៥៨៩.៦៤៤.៣០០៖០០ |
| +ប្រេងសាំង | មានទឹកប្រាក់ចំនួនៈ | ១៩១.១០០.០០០៖០០ |

| | | |
|---|---|---|
| សម្ភារការិយាល័យ | មានទឹកប្រាក់ចំនួន | ៤២៨.៦២១.០០០៖០០ |
| សម្ភារបរិក្ខារនិងសង្ហារឹម | មានទឹកប្រាក់ចំនួន | ៧០៨.៩២១.០០០៖០០ |
| ឯកសណ្ឋាន | មានទឹកប្រាក់ចំនួន | ២៤៨.៩៩២.០០០៖០០ |
| សម្ភារនិងបរិក្ខារពិសោធន៍ | មានទឹកប្រាក់ចំនួន | ៤.៧៩៨.៩៦៧.៣០០៖០០ |

**ឃ. ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

-បានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទ២០១០នៅបណ្តាគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាលរួមមាន វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប

-បានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះរៀបចំដើម្បីកំណត់ទុនគ្រាដំបូងនៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប

-បានចុះពិនិត្យផ្ទៀងផ្ទាត់ជាក់ស្តែង និងប្រកាសផ្ទេរនូវទ្រព្យសម្បត្តិរបស់ចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរីប្រគល់ជូនក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីធីតដើម្បីគ្រប់គ្រងនិងបន្តធ្វើការស្តារនិងអភិវឌ្ឍ

-បានសហការជាមួយក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីធីត ចុះធ្វើការបញ្ជាក់ផ្ទៃដីចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរីដែលក្រុមហ៊ុនកាន់កាប់និងធ្វើការរុករកដីជំហានទី៤ បន្តទៀត

-បានរៀបចំលិខិតជំរុញឱ្យក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីធីត បង់ថ្លៃឈ្នួលចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរីសម្រាប់ឆ្នាំ២០១១

-បានរៀបចំលិខិតបំភ្លឺជូនទៅគណៈកម្មការសិទ្ធិមនុស្សកម្ពុជា ស្តីពីករណីបណ្តឹងរបស់លោកស្រី**ធឹង សុវណ្ណ** ដែលបានអះអាងថាជាម្ចាស់ចម្ការកៅស៊ូក្រុមទី៩ នៃសាខាក្រុមសាមគ្គីឬគ្រួសារក្នុង សង្កាត់កាចាញក្រុងបានលុង ខេត្តរតនគិរី

-បានធ្វើលិខិតជម្រាបជូនអគ្គនាយកដ្ឋានកៅស៊ូ ករណីសុំផ្ទេរដីការកោះរបស់សាលាឧទ្ធរណ៍ពីបញ្ហាដីចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរីដែលកន្លងមកតំណាងដោយក្រុមហ៊ុន **តាយ សេង** អាហ៎រណ នីហ៎រណ និងសំណង់ជូនក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីធីតវិញ

-បានចុះជំរុញ ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌឆ្នាំ២០០៩ របស់សាលាជាតិកសិកម្មព្រែកលៀប សាកលវិទ្យាល័យភូមិន្ទកសិកម្មមន្ទីរកសិកម្មរាជធានីភ្នំពេញ ខេត្តក្រចេះ មណ្ឌលគិរី កំពង់ធំកំពង់ស្ពឺសៀមរាប ព្រះវិហារ តាកែវ កំពត កោះកុង បាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ

-បានចុះពិនិត្យ និងផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១០ របស់មន្ទីរកសិកម្មខេត្តកណ្តាល កំពង់ឆ្នាំង បាត់ដំបង ស្ទឹងត្រែង កែប ពោធិ៍សាត់ និងព្រៃវែង

-ចូលរួមជួយរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១០ នៅមន្ទីរកសិកម្ម ខេត្តកំពង់ស្ពឺ

-បានចុះពិនិត្យជាក់ស្តែងដី ០១កន្លែងរបស់មន្ទីរកសិកម្មខេត្តពោធិ៍សាត់ ដែលរដ្ឋបាលជលផលស្នើសុំសម្រាប់រៀបចំកសិដ្ឋានផលិតកូនត្រីពូជផ្នែករដ្ឋបាលជលផលរាំងទិល

- បានចុះពិនិត្យជាក់ស្តែងដី០១កន្លែងរបស់មន្ទីរកសិកម្មខេត្តព្រះវិហារ ដែលរដ្ឋបាលព្រៃឈើស្នើសុំសម្រាប់សាងសង់អគារខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ

-បានចុះពិនិត្យជាក់ស្តែងនិងប្រកាសផ្ទេរដី០១កន្លែងទំហំ០៥ហត ស្ថិតនៅភូមិអូរម៉ាល់ សង្កាត់ អូរម៉ាល់ក្រុងបាត់ដំបង ខេត្តបាត់ដំបង របស់មន្ទីរកសិកម្មខេត្តបាត់ដំបង ជូនរដ្ឋបាលជលផល

-ចុះពិនិត្យជាក់ស្តែងនូវដីចំនួន ០៣ហត ស្ថិតនៅភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាងខេត្តកណ្តាល របស់រដ្ឋបាលជលផលដែលត្រូវផ្ទេរជូនមន្ទីរកសិកម្មខេត្តកណ្តាល

-ចូលរួមត្រួតពិនិត្យ ស្រាវជ្រាវជាក់ស្តែងនូវដីចំនួន ៥០ហត ស្ថិតនៅឃុំឈ្វាំង ស្រុកពញាឮរបស់មន្ទីរកសិកម្មខេត្តកណ្តាល

-ចុះពិនិត្យ និងស្រាវជ្រាវជាក់ស្តែងដីចម្ការម្រេចចំនួន ៧,២០ហត របស់មន្ទីរកសិកម្មខេត្តកោះកុង ដែលប្រជាជនចូលកាន់កាប់

-បានចុះពិនិត្យ និងផ្ទៀងផ្ទាត់ជាក់ស្តែងនូវផ្ទៃដីដែលលំអៀងពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅស្ថានីយ៍អនុវត្តភូមិទឹកចេញ ឃុំជីរោទ៍២ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-បានធ្វើសេចក្តីសម្រេចបង្កើតគណៈកម្មការចុះពិនិត្យស្រាវជ្រាវនិងវាស់វែងកំណត់ឡើងវិញនូវផ្ទៃដីរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-ចុះពិនិត្យនិងកំណត់តម្លៃដីធ្លី និងអគាររបស់អធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ អធិការដ្ឋានរដ្ឋបាល ព្រៃឈើខាងត្បូងបឹងទន្លេសាប និងអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប

-បានចុះពិនិត្យ និងវាយតម្លៃគុណភាពបច្ចេកទេសនូវទ្រព្យសម្បត្តិចាស់ ខូចទ្រុឌទ្រោមប្រើប្រាស់លែងកើតរបស់មន្ទីរកសិកម្មខេត្តបាត់ដំបង និងព្រះវិហារដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

-បានចុះពិនិត្យវាយតម្លៃជាក់ស្តែងនិងអនុវត្តនីតិវិធីហិរញ្ញវត្ថុក្នុងការស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវទ្រព្យសម្បត្តិចាស់ខូចទ្រុឌទ្រោមប្រើប្រាស់លែងកើតរបស់អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ អគ្គាធិការដ្ឋាន នាយកដ្ឋាននីតិកម្មកសិកម្ម នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានផែនការនិងស្ថិតិ អគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង និងមន្ទីរកសិកម្មខេត្តកោះកុង

-បានចុះពិនិត្យ តាមដាន និងប្រគល់ ទទួលការដោះដូរឃ្លាំងការិយាល័យកសិកម្មស្រុកអូរាំងឪរបស់មន្ទីរកសិកម្មខេត្តកំពង់ចាម

-បានចូលរួមប្រជុំ និងពិនិត្យទ្រព្យសម្បត្តិរបស់គម្រោងកម្មវិធីចិញ្ចឹមសត្វគ្រួសារកម្ពុជា-សហគមន៍ អ៊ឺរ៉ុបដែលបានបញ្ចប់គម្រោង ត្រូវប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានចូលរួមប្រជុំ ពិនិត្យ ប្រគល់ទទួល និងប្រកាសផ្ទេរអចលទ្រព្យ និងចលនទ្រព្យរបស់គម្រោង ECOSORN ដែលបានបញ្ចប់គម្រោង ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពពាក់ព័ន្ធ

- ចូលរួមប្រជុំនិងពិនិត្យទ្រព្យសម្បត្តិរបស់គម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម 2022-CAM (SF)2023CAM និង CAMIP-CIDA ដែលបានបញ្ចប់គម្រោង ត្រូវប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានចុះពិនិត្យ និងប្រគល់ ទទួលរោងចក្របង្កកជលផល II ក្រុងព្រះសីហនុ ផ្ទេរពីក្រុមហ៊ុន លាង ហេងត្រេឌីង ជូនរដ្ឋបាលជលផល

-ចុះពិនិត្យនិងរៀបចំកំណត់ហេតុប្រគល់ ទទួលថវិកា និងទ្រព្យសម្បត្តិរដ្ឋ ដើម្បីបញ្ឈប់បញ្ជីចាស់ និងបើកបញ្ជីថ្មីសម្រាប់ការផ្ទេរចូលកាន់តំណែងរបស់នាយកសាលាជាតិកសិកម្មព្រែកលៀប ប្រធានមន្ទីរកសិកម្មខេត្តសៀមរាប ប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម និងប្រធានមន្ទីរកសិកម្មខេត្តមណ្ឌលគិរី និងចូលរួមចុះត្រួតពិនិត្យបទល្មើសព្រៃឈើនៅខេត្តមណ្ឌលគិរី។

## ង. ការងាររៀបចំនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

សម្រេចអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈដើម្បីផ្គត់ផ្គង់ទំនិញ សម្ភារបរិក្ខា ការងារសាងសង់-ជួលជុល និងសេវាកម្មផ្សេងៗ ជូនក្រសួង និងអង្គភាពនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចំនួន ៣១គម្រោង (ដេញថ្លៃ ១៥ គម្រោង ពិគ្រោះថ្លៃចំនួន ០៧ គម្រោង ស្ទង់តម្លៃចំនួន ០២គម្រោង ចរចាថ្លៃចំនួន ០៧គម្រោង)។

## ច. ចំនួនលេខគណនីធនាគារ (Bank Account NO.)

ក្នុងឆ្នាំ២០១១នេះ ចំនួនលេខគណនីធនាគារបានកើនឡើងពី២៩គណនីនៅឆ្នាំ២០១០ កើនដល់ចំនួន៣៥គណនីនៅចុងឆ្នាំ២០១១នេះ ក្នុងនោះ២០១១នេះ ក្នុងនោះ NBC: 10, FTB: 11, ACLEDA: 9, ANZ :3, CAMPU: 2 ចំនួនគណនីដែលបានកើនឡើងនោះយើងបានទទួលព័ត៌មានប្រចាំខែពីបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់

និងនេសាទ។បានផ្តល់របាយការណ៍រៀងរាល់ប្រចាំខែឆ្នាំ២០១១ ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិស្តីអំពី ស្ថានភាពប្រើប្រាស់គណនីរបស់បណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងគម្រោងនានានៅតាមប្រព័ន្ធធនាគារ ដែលបាននិងកំពុងបម្រើការងារក្នុងវិស័យកសិកម្ម។

### ជ. ប្រាក់កក់ និងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច

ប្រាក់កក់ធានាអនុវត្តកិច្ចសន្យា : ក្នុងឆ្នាំ២០១១នេះ នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុបានទទួលបង្កាន់ដៃប្រាក់កក់ចំនួន២៧ ពីក្រុមហ៊ុនចំនួន២៦ បានជូនដំណឹងទៅនាយកដ្ឋានផែនការនិងស្ថិតិ និងលេខាធិការដ្ឋានសម្បទានដីសេដ្ឋកិច្ចដើម្បីជ្រាបជាព័ត៌មាន។

## ២. វាយតម្លៃនិងសំណើ

ជារួមបានឆ្លុះបង្ហាញឱ្យឃើញថា ការខិតខំប្រឹងប្រែងអនុវត្ត កម្មវិធីកំណែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលមានក្រុមការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងដោយបណ្តុំនូវគ្រប់សមាសភាពពីអង្គភាពពាក់ព័ន្ធរបស់ក្រសួង។ ក្រុមការងារនេះ គឺជាយន្តការមួយជាអ្នកដឹកនាំ និងជំរុញការអនុវត្ត ដល់បណ្តាអង្គភាពក្រោមឱវាទក្រសួងទាំងអស់ លើការគ្រប់គ្រង ចំណូល ចំណាយ និងទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែទោះជាយ៉ាង នេះក្តីក៏នៅមានជួបការលំបាកខ្លះទៀតជាពិសេសសមត្ថភាព និងចំណេះដឹងរបស់មន្ត្រី ដែលជាអ្នកអនុវត្តថវិកាតម្រូវរត់ឱ្យទាន់កម្មវិធីកំណែទម្រង់ ដើម្បីឱ្យការគ្រប់គ្រងនិងអនុវត្តថវិកាឱ្យបានកាន់តែប្រសើរចាំបាច់ត្រូវបណ្តុះបណ្តាលបន្ថែម និងត្រូវមានការចូលរួមដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវពីថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីពាក់ព័ន្ធទាំងអស់។

## ៣. វិធានការ

- បន្តពង្រឹងការគ្រប់គ្រងប្រព័ន្ធ SERVER កុំព្យូទ័ររបស់នាយកដ្ឋាន និងកែប្រែប្រព័ន្ធ Internet ADSL ទៅជាប្រព័ន្ធ Fiber Optics លឿនរហ័ស

- ប្រឹងប្រែងពង្រីកថវិកាតាមកម្មវិធីដល់បណ្តាអង្គភាពក្រោមឱវាទ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូស ដោយសាលក្រមដីកាសម្រេចពិន័យអន្តរការណ៍ និងឈើអញ្ញាតិជន (ឈើគ្មានម្ចាស់) នៅខណ្ឌរដ្ឋបាលព្រៃឈើទូទាំងប្រទេស

-បន្តអនុវត្តផ្ទាល់នូវប្រព័ន្ធគណនេយ្យកុំព្យូទ័រពីរបៀបបញ្ចូលទិន្នន័យនិងគ្រប់គ្រងទិន្នន័យ នៅក្នុងប្រព័ន្ធកុំព្យូទ័រតែមួយ

-ត្រៀមចុះពង្រឹងការងារបញ្ជិកាគណនេយ្យ នៅតាមបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្តនិងបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-សហការជាមួយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ចុះត្រួតពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទ២០១១ នៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងបួនស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ

-បន្តសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចូលរួមកំណត់ទុនគ្រាដំបូងឲគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងបួនស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលនៅពុំទាន់បានកំណត់ទុនគ្រាដំបូងនៅឡើយ

-ត្រៀមសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បី :

- ចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើន-ថយចុះ នៅតាមមន្ទីរកសិកម្មរាជធានី-ខេត្តនិងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កំណត់ទុនគ្រាដំបូងនៅសាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម

-បន្តខិតខំប្រឹងប្រែងរៀបចំឯកសារកិច្ចលទ្ធកម្មសាធារណៈឲបានទាន់ពេលវេលាបន្ទាប់ពីទទួលបានលិខិតគោលការណ៍ធានាចំណាយរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ខិតខំរៀបចំកសាងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាន់ពេលវេលា ដោយសហការជាមួយការិយាល័យហិរញ្ញកិច្ចនិងមន្ត្រីផ្នែកជំនាញគណនេយ្យ ហិរញ្ញវត្ថុ

របស់អង្គភាពក្រោមឱវាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

-រៀបចំនិងអនុវត្តនូវគម្រោងកិច្ចលទ្ធកម្មសម្រាប់ឆ្នាំ២០១២ នៅពេលទទួលបានគោលការណ៍ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ជួយរៀបចំឲដំណើរការនូវគម្រោងនានាដែលត្រូវការថវិកាបដិភាគតាមការណែនាំរបស់ថ្នាក់ដឹកនាំ

- បន្តសហការចូលរួមកិច្ចលទ្ធកម្មគម្រោងហិរញ្ញប្បទាន ដោយធនាគារអភិវឌ្ឍន៍អាស៊ីដែលកំពុងដំណើរការនិងគម្រោងផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ

- បន្តចូលរួមអនុវត្តសកម្មភាព PFM/MAP ក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

- ស្រង់ឈ្មោះក្រុមហ៊ុនដែលបង់ប្រាក់កក់អនុវត្តកិច្ចសន្យាយឺត ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច

## ៥.៩- កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍

**គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប** (TS-PRSDP)៖

**លទ្ធផល ÷**

**-ការងារទាក់ទងនឹងការចំណាយប្រតិបត្តការអាទិភាព (POC)** ៖ បាននឹងកំពុងដំណើរការរៀបចំបែបបទនិងជ្រើសរើសមន្ត្រីសម្រាប់អនុវត្តការចំណាយប្រតិបត្តិការអាទិភាព សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប

**-ការប្រជុំ សិក្ខាសាលា និងការងារបណ្តុះបណ្តាល÷**

- មន្ត្រីចំនួន០២ រូប បានចូលរួមសិក្ខាសាលាស្តីពី Loan disbursement ចាប់ពី ថ្ងៃទី១៤-១៦ ខែកញ្ញា ឆ្នាំ២០១១ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ភ្នំពេញ
- មន្ត្រីចំនួន០១ បានចូលរួមសិក្ខាសាលាស្តីពី Loan Joint MEF/ADB/WB /JICA Monitoring and Evaluation workshop ចាប់ពីថ្ងៃទី ១៣-១៤ ខែធ្នូ ឆ្នាំ២០១១ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ភ្នំពេញ
- បានរៀបចំផែនការសកម្មភាពរយៈពេល១៥ខែ របស់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ។

**-ការងារលទ្ធកម្ម**

- បានចុះកិច្ចសន្យាលើការផ្គត់ផ្គង់រថយន្តចំនួន ១៥ គ្រឿង (Double cabin pickups) សម្រាប់ភ្នាក់ងារប្រតិបត្តិ និងភ្នាក់ងារអនុវត្តរបស់គម្រោងកាត់ បន្ថយភាពក្រីក្រនិងការអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន K (Cambodia) Co.; Ltd ដែលមានថវិកាសរុបចំនួន 362,985.00 ដុល្លារអាមេរិក (កិច្ចសន្យា លេខ០០១/២០១១/ DCU/ MAFF ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១)
- បានរៀបចំពិធីប្រគល់ទទួលរថយន្តចំនួន១៥ គ្រឿង របស់គម្រោងនាថ្ងៃទី១២ខែតុលាឆ្នាំ២០១១ និងបានបែងចែកដល់ភ្នាក់ងារប្រតិបត្តិ និងភ្នាក់ងារអនុវត្តនាថ្ងៃទី២៥ ខែតុលាឆ្នាំ ២០១១ ក្រោមអធិបតីភាពឯកឧត្តម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានចុះកិច្ចសន្យាលេខ០០៦និង០០៧ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពី សេវាកម្មអ្នកបើកបររថយន្តរបស់អង្គភាពសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍ ចំនួនពីររូប។

**-ការងារគណនេយ្យ ហិរញ្ញវត្ថុ**

ការចំណាយសរុបរបស់គម្រោងមានចំនួន 389,230.47 USD ដែលក្នុងនោះចំណាយលើប្រភេទមុខទំនិញ និងការងារប្រតិបត្តិដូចមានខាងក្រោម÷

- រថយន្ត និងម៉ូតូ : 362,985.00 USD

- ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សចំនួន 1,130.80 USD
- សេវាកម្មទីប្រឹក្សា (ទីប្រឹក្សាថ្នាក់ជាតិ) របស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមាន ចំនួន 15,300.00USD និងទីប្រឹក្សាជាតិផ្សព្វផ្សាយកសិកម្មក្នុងខេត្តគោលដៅ ចំនួន0៤ រូប មានថវិកាចំនួន 8,800.00 USD ( ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ) ។
- ការងារប្រតិបត្តិ (ថ្លៃសេវាបង្វែថវិកាចំនួន 1,014.67 USD) របស់ធនាគារអភិវឌ្ឍន៍អាស៊ីចំណាយក្នុងការបង្វែរថវិកាចំនួន 68,786.00 USD បញ្ចូលក្នុងកញ្ចប់ថវិកា (Block Grant) និងសម្រាប់ការចំណាយប្រតិបត្តិការ (Operation) មានចំនួន 391,818.00 USD របស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**-គម្រោងពង្រឹងសមត្ថភាពសម្រាប់ការត្រួតពិនិត្យបមាណីយគុណភាពសម្ភារកសិកម្ម (ជីគីមីនិងថ្នាំកសិកម្ម) QCAM Project/JICA-MAFF**

**លទ្ធផល÷**

គម្រោង QCAM គឺជាគម្រោងមួយដែលរយៈពេល៣ឆ្នាំ (មីនា ២០០៩ -មីនា ២០១២) ក្រោមកិច្ចសហការរវាង JICA (ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ គម្រោងនេះត្រូវបានអនុវត្តលើសកម្មភាព៣ជាចំបង រួមមានសកម្មភាពលើកម្ពស់ការយល់ដឹង ការពង្រឹងសម្ថភាពរបស់មន្ទីរពិសោធន៍ និងការអភិវឌ្ឍន៍ផ្នែកច្បាប់។ តំបន់គោលដៅរបស់គម្រោងគឺស្រុកកៀនស្វាយ និងស្រុកកោះធំនៃខេត្តកណ្តាល ។

**១. ការលើកកម្ពស់ការយល់ដឹង**

- ចងក្រងកូនសៀវភៅស្តីអំពីថ្នាំកសិកម្មហាមឃាត់ និងថ្នាំកសិកម្មដែលអនុញ្ញាតឲ្យប្រើប្រាស់ស្ថិតក្នុងលក្ខខ័ណ្ឌក្នុងប្រទេសកម្ពុជា

-ផលិតកម្មវិធីជជែកពិភាក្សានិងspotអប់រំដែលត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍

-រៀបចំយុទ្ធនាការថ្នាក់ជាតិក្រោមប្រធានបទស្តីអំពីការលុបបំបាត់ថ្នាំកសិកម្មហាមឃាត់ ដែលយុទ្ធនាការនេះត្រូវបានរៀបចំធ្វើឡើងក្នុងអំឡុងខែមេសា ឆ្នាំ២០១១ ដោយបានធ្វើការចាក់ផ្សាយកម្មវិធីជជែកពិភាក្សានិងspot អប់រំតាមទូរទស្សន៍ ដូចជាទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ CTN និងទូរទស្សន៍បាយ័ន។ ទន្ទឹមនឹងគ្នាផងដែរក៏មានការចែកជូនដល់មន្ទីរកសិកម្មខេត្ត/ក្រុងទាំង២៤ នូវ poster ស្តីអំពីថ្នាំកសិកម្មហាមឃាត់ចំនួន៣២៦៥សន្លឹក កូនសៀវភៅស្តីអំពីថ្នាំកសិកម្មហាមឃាត់និងថ្នាំកសិកម្មអនុញ្ញាតឲ្យប្រើប្រាស់ចំនួន២៤៨១ក្បាល បដាផ្សព្វផ្សាយចំនួន១១០ ខិតបណ្ណ័របស់គម្រោងចំនួន១២០០សន្លឹក និង DVD (ចំនួន២៤បន្ទះ) ស្តីអំពីការរបៀបប្រើប្រាស់ថ្នាំកសិកម្មឲ្យបានត្រឹមត្រូវដែលផលិតឡើងដោយអាជ្ញាធរជីនិងថ្នាំកសិកម្មរបស់ប្រទេសហ្វីលីពីន

-ចងក្រងសៀវភៅណែនាំស្តីអំពីការគ្រប់គ្រងសមាសភាពចង្រៃ និងបានបោះពុម្ពផ្សាយចំនួន៥៦០០ក្បាល

-បកប្រែខ្សែវីដេអូអប់រំអំពីរបៀបប្រើប្រាស់ថ្នាំកសិកម្មឲ្យបានត្រឹមត្រូវ ដោយទទួលបានការអនុញ្ញាតពីអាជ្ញាធរជីនិងថ្នាំកសិកម្មរបស់ប្រទេសហ្វីលីពីនដែលជាម្ចាស់ដើមផលិតខ្សែវីដេអូនេះ

-ចុះធ្វើអង្កេតក្នុងតំបន់គោលដៅ និងនៅខេត្តសៀមរាបដើម្បីធ្វើការវាយតម្លៃលើសម្ភារផ្សព្វផ្សាយ ដែលផលិតនិងផ្សព្វផ្សាយដោយគម្រោង

-ចងក្រងសៀវភៅស្តីពីការគ្រប់គ្រងសត្វល្អិតនិងជំងឺលើដំណាំ

-រៀបចំកម្មវិធីផ្លាស់ប្តូរព័ត៌មានបច្ចេកទេសស្តីពីការគ្រប់គ្រងសម្ភារកសិកម្មនៅប្រទេសហ្វីលីពីន។

**២. ការពង្រឹងសមត្ថភាពរបស់មន្ទីរពិសោធន៍**

-រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីប្រចាំមន្ទីរពិសោធន៍របស់នាយកដ្ឋានីតិកម្មកសិកម្មនិងអគ្គនាយកដ្ឋានកសិកម្មក្រោមការបណ្តុះបណ្តាលពីអ្នកជំនាញការជនជាតិហ្វីលីពីនចំនួន៤រូប

-ផ្តល់សម្ភារនិងគ្រឿងបន្លាស់សម្រាប់មន្ទីរពិសោធន៍។

**៣. ការអភិវឌ្ឍន៍ផ្នែកច្បាប់**

-ចងក្រងពង្រាងច្បាប់ស្តីពីការគ្រប់គ្រងជីនិងថ្នាំកសិកម្ម និងចងក្រងពង្រាងបទដ្ឋានគតិយុត្តិស្តីអំពីនីតិវិធីនិងបមាណីយក្នុងការចុះបញ្ជីជីនិងថ្នាំកសិកម្ម

-ចូលរួមជំរុញឲ្យមានការចងក្រងសមាគមពាណិជករសម្ភារកសិកម្មកម្ពុជា (CAMTA) និងចងក្រងពង្រាងបញ្ជីថ្មីស្តីពីឈ្មោះថ្នាំកសិកម្ម។

**៤. សកម្មភាពផ្សេងៗ**

-រៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់ជីនិងថ្នាំកសិកម្មឲ្យបានត្រឹមត្រូវ

-រៀបចំការកិច្ចវាយតម្លៃចុងក្រោយរបស់សកម្មភាពគម្រោង

**គម្រោងជំនួយបច្ចេកទេស ADB-Grant . 0133-CAM/Component1: PFMRDs**

បានសហការនិងរៀបចំបើកសិក្ខាសាលាចំនួន០៣លើកនៅខេត្តបាត់ដំបង និងខេត្តសៀមរាប ក្នុងគោលដៅលើកកំពស់ និងពង្រឹងសមត្ថភាពមន្ត្រីតាមអង្គភាពជំនាញ ដែលពាក់ព័ន្ធនិងកែលំអប្រសិទ្ធភាពការងារ ជាពិសេស លើការងារអនុវត្តថវិកា តាមកម្មវិធី។

**គម្រោងបន្សាំនឹងការប្រែលប្រួលអាកាសធាតុ សម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម (NAPA-FU) ÷**

គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្មនៅតំបន់ជនបទនៃប្រទេសកម្ពុជា) NAPA follow up គឺពង្រឹងសមត្ថភាពដើម្បីកាត់បន្ថយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឱ្យ បានប្រសើឡើង និងធានាឱ្យមាននប្រភពទឹកនៅក្នុងប្រទេសកម្ពុជា។ គម្រោងបានផ្តល់ ហិរញ្ញប្បទានឥតសំណងពី UNDP/GEF ដែលមានថវិកាសរុបចំនួន៣,០៩ លានដុល្លា អាមេរិក អនុវត្តនៅក្នុងខេត្តក្រចេះ និងខេត្តព្រះវិហារ។ ក្នុងឆ្នាំ២០១១ គម្រោងអនុវត្ត សម្រេចបាន៩៤.២៨% នៃថវិកាអនុម័តសរុប១.១៤៧.៦៧០ដុល្លា ដោយសម្រេចបាន នូវលទ្ធផលសំខាន់ៗដូចខាងក្រោម ÷

-បញ្ជ្រាបបញ្ហានៃការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងធនធាន ទឹកទៅក្នុងកម្មវិធីវិនិយោគឃុំចំនួន១៦ឃុំ បានផ្សព្វផ្សាយការយល់ដឹង អំពីការប្រែប្រួលអាកាសធាតុដល់កសិករ៧.៤៦៩គ្រួសារ ក្នុង២០២ភូមិ ៥៤ឃុំ ១០ស្រុកក្នុងខេត្តក្រចេះ និងព្រះវិហារ

-យន្តការផ្តល់ព័ត៌មានដោយសហគមន៍១៩ភូមិត្រូវបានបង្កើតឡើងនិងបាន ផ្តល់ព័ត៌មានស្តីពីជំនន់ដល់គ្រួសារងាយរងគ្រោះចំនួន៤៣៧ គ្រួសារ

-គម្រោងបានចែកធុងចម្រោះទឹកស្អាតដល់៧៣៥គ្រួសារមកពី១៤ភូមិ ២ឃុំ អណ្តូងស្នប់ចំនួន៣២កន្លែង ត្រូវបានបង្កើតឡើងដើម្បីផ្តល់ទឹក សម្រាប់ ប្រើប្រាស់ក្នុងគ្រួសារ ការស្រោចស្រពដំណាំរួមផ្សំ និងការចិញ្ចឹមសត្វ សម្រាប់៣១៤គ្រួសារ ពី១៥ភូមិ និងក្រុមកសិករប្រើប្រាស់ទឹកអណ្តូង ចំនួន១២ ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង និងថែទាំអណ្តូង។ លើសពី នេះ ស្រះសហគមន៍ (ស្រះយក្ស) ចំនួន២កន្លែងត្រូវបានជីកប្រព័ន្ធបូមទឹក ដោយថាមពលព្រះអាទិត្យចំនួន៣កន្លែងក៏កំពុងបានសាងសង់ផងដែរនិង ដំណើរការប្រើប្រាស់ក្នុងឆ្នាំ២០១២។

-សហគមន៍កសិករប្រើប្រាស់ទឹក២កន្លែងត្រូវបានបង្កើតការសិក្សាគម្រោង ប្លង់ជួសជុលប្រព័ន្ធធារាសាស្ត្រត្រូវបានបញ្ចប់ទំនប់ជាង២គ.ម ត្រូវជួស ជុលឡើងវិញរឹងការដេញថ្លៃ និងស្តារឡើងវិញប្រព័ន្ធធាសាស្ត្រដែលក្នុង នោះមានប្រឡាយ ទ្វារទឹក ទំនប់បង្ហៀរ ប្រឡាយបេតុង ស្ថានីយ៍បូម នឹង ត្រូវអនុវត្តក្នុងដើមឆ្នាំ២០១២

-កសិករ១.៦២៧គ្រួសារ បានទទួលផលពីគម្រោងតាមរយៈសកម្មភាព កសិកម្មដែលមានភាពស៊ាំនឹងការប្រែប្រួលអាកាសធាតុ ដូចជាសាលារៀនស្រែកសិករលើប្រព័ន្ធកសិកម្មចម្រុះ ប្រពលវប្បកម្មដំណាំស្រូវ កម្មវិធីបន្សុទ្ធពូជស្រូវ និងការពិសោធន៍ពូជស្រូវដែលធន់នឹងការលិចលង់ និងភាពរាំងស្ងួត ការចិញ្ចឹមត្រីក្នុងស្រះប្លាស្ទិក និងលើសពីនោះកសិករ

៣៨១ គ្រួសារទទួលបានផលពីកម្មវិធីផ្តល់វ៉ាក់សាំងសត្វ

-គម្រោងបានចងក្រងបទពិសោធន៍និងចែករំលែកបទពិសោធន៍ពីការអនុវត្ត គម្រោងដល់ថ្នាក់ តំបន់តាមរយៈប្រព័ន្ធគេហទំព័រ វិទ្យុ និងទូរទស្សន៍ និងបានរៀបចំកិច្ចប្រជុំបច្ចេកទេស ប្រជុំណែនាំគោលនយោបាយ និងសិក្ខាសាលាផ្សព្វផ្សាយបទពិសោធ គម្រោងដល់៤៨១នាក់ មកពីថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ។

## គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទក្នុងខេត្តព្រៃវែងនិងស្វាយរៀង (RPRP)

គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទក្នុងខេត្តព្រៃវែងនិងស្វាយរៀង មានគោលបំណងដើម្បីកាត់បន្ថយភាពក្រីក្រនៃគ្រួសារអ្នកក្រីក្រ ដោយមានការចូលរួមយ៉ាងសកម្ម ពីកសិករក្រីក្រ តាមរយៈការកែលំអជីវភាពរស់នៅប្រចាំថ្ងៃពង្រឹងសមត្ថភាព កម្មវិធីប្រព័ន្ធ កសិកម្ម ឱ្យមាននិរន្តរភាព និងការគ្រប់គ្រងធនធានធម្មជាតិ ការជួសជុលនិងការសាងសង់ថ្មីនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធ នឹងបង្កើនលទ្ធភាពសមស្របនូវបច្ចេកទេស សេវាកម្មនានា និងទីផ្សារសម្រាប់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចនិងសង្គម។ គម្រោងនេះ បានអនុវត្តរយៈពេលប្រាំពីរឆ្នាំនឹងបានបញ្ចប់ការអនុវត្តនៅឆ្នាំ២០១១ ដោយប្រើប្រាស់ថវិកាសរុបចំនួនប្រមាណ ១៦លានដុល្លាអាមេរិក ជាកម្ចីហិរញ្ញប្បទានពីមូលនីធិអន្តរជាតិ អភិវឌ្ឍកសិកម្ម (IFAD)។ ក្នុងរយៈពេលប្រាំពីរឆ្នាំគម្រោងបានអនុវត្តបានក្នុងខេត្តគោលដៅចំនួនពីរគឺខេត្តព្រៃវែងនិងខេត្តស្វាយរៀង ១៦ស្រុក និង១៤៨ឃុំ នឹងទទួលបានសមិទ្ធផលដូចខាងក្រោម ÷

-បានចងក្រងក្រុមកសិករក្រីក្រចំនួន១០០៨ក្រុម ដែលមានសមាជិកសរុបចំនួន ២៥.២០០គ្រួសារ គម្រោងបានផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្មនិងរៀបចំជាក្រុមទុនបង្វិលដែលមានទុនចាប់ ផ្តើមគម្រោងចំនួន២.១៤៣.៣៩០ដុល្លារអាមេរិក និងមកដល់បច្ចុប្បន្នទុននេះកើនឡើងចំនួន៣.០៩៣.០៤៣ដុល្លារអាមេរិក

-បានបណ្តុះបណ្តាលអំពីជំនាញកសិកម្ម ការចិញ្ចឹមសត្វ មុខរបរខ្នាតតូច និង ការបញ្ច្រាបយេនឌ័រ ព្រមទាំងរៀបចំធ្វើបង្ហាញដល់កសិករចំនួន ៥០.៤០០ គ្រួសារ

-បានជួសជុកផ្លូវលំជនបទចំនួន១,៩១៤គ.ម សាលារៀនសងអំពីឥដ្ឋ១៧៤បន្ទប់ ប្រព័ន្ធស្រោចស្រព៤៦៣គ.មទ្វារទឹក៨០កន្លែង និងសាងសង់ស្ពាន៣កន្លែង។

## គម្រោងលើកកំពស់ជីវភាពរស់នៅតាមជនបទខេត្តក្រចេះ ព្រះវិហារ និងរតនគីរី

### ១. លទ្ធផលនៃការអនុវត្តសកម្មភាព

**ក. ក្រុមកែលម្អជីវភាពៈ**

-កសិករក្រុមកែលម្អជីវភាពចំនួន ៣.២១១នាក់ (ស្ត្រី ១.០៤៨នាក់)

-កសិករចូលរួមវគ្គបណ្តុះបណ្តាលកសិករក្រុមកែលម្អជីវភាព និងបណ្តុះបណ្តាលរំលឹកដល់កសិករក្រុមកែលម្អជីវភាពសរុប៦.៣៤១នាក់ (ស្ត្រី ២.១៨៩នាក់)

-សាងសង់ធនាគារស្រូវបានចំនួន១៣០និងកម្មវិធីអក្ខរកម្មអ្នកចូលរួម៥២នាក់ (ស្ត្រី១២នាក់) នៅខេត្តរតនគីរី។

**ខ. ក្រុមកែលម្អប្រព័ន្ធកសិកម្មៈ**

-ការធ្វើបង្ហាញ ក្នុងនោះមានបង្ហាញដំណាំស្រូវតាមគោលការណ៍ធម្មជាតិ បន្លែ ចិញ្ចឹមមាន់ ចិញ្ចឹមទាកាប៉ា ចិញ្ចឹមជ្រូក និងចិញ្ចឹមត្រីសរុបចំនួន៤៥៧បង្ហាញ

-កសិករចូលរួមធ្វើទិវាស្រែសរុប ២.៦៥៣នាក់ (ស្ត្រី ១.០៥៥នាក់) នៅខេត្តក្រចេះនិងព្រះវិហារ។

**គ. កម្មវិធីបំពេញបន្ថែមៈ**

-អ្នកចូលរួមវគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិថ្មីចំនួន៨១នាក់ (ស្ត្រី៣នាក់)

-អ្នកចូលរួមវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញពេទ្យសត្វភូមិចាស់ចំនួន២៤នាក់ (ស្ត្រី៤នាក់) និងចូលរួមពិព័ណ៌ស្រុកចំនួន ២៤៣នាក់ (ស្ត្រី ៩៧នាក់) នៅខេត្តព្រះវិហារ

-អ្នកចូលរួមបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយភូមិចំនួន៧៤នាក់ (ស្ត្រី១៥នាក់)

-អ្នកចូលរួមសិក្ខាសាលាការផ្តល់សេវាកម្មផ្នែកឯកជន ផ្សព្វផ្សាយច្បាប់នីតិកម្មកសិកម្មចំនួន៩៨នាក់ (ស្ត្រី២៦នាក់) នៅខេត្តក្រចេះ

-ការគាំទ្ររបស់អង្គការវឌ្ឍនៈបណ្តុះបណ្តាលពីការគ្រប់គ្រងទុនបង្វិល ការចុះបញ្ជីស្នាមហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំដល់បុគ្គលិកគម្រោង និងប្រធានក្រុមកែលម្អជីវភាពសរុបចំនួន១៥១នាក់ (ស្ត្រី៦៥នាក់) នៅខេត្តក្រចេះ

-បង្ហាញស្តីពីដំណាំកសិ ឧស្សាហ៍កម្ម÷

+បណ្តុះបណ្តាលពីជំនួញទីផ្សា ផែនការជំនួញ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងទុនបង្វិលក្រុមបច្ចេក-ទេសដាំដំឡូងមី ចិញ្ចឹមជ្រូក ១៨៥នាក់ (ស្ត្រី ១០៤នាក់) នៅខេត្តក្រចេះនិងព្រះវិហារ

+ដឹកនាំកសិករធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីបច្ចេកទេសចិញ្ចឹមជ្រូកមេយកកូនចំនួន១១នាក់ (ស្ត្រី៨នាក់) សម្រាប់ខេត្តព្រះវិហារ។

**ឃ. ការគាំទ្រសេវាកម្មកសិកម្ម:**

ជារួមមានមន្ត្រីថ្នាក់ជាតិ ១៥នាក់ (ស្ត្រី៥នាក់) មន្ត្រីគាំទ្រថ្នាក់ខេត្ត ៥៧នាក់ (ស្ត្រី១៤នាក់) មន្ត្រីគាំទ្រថ្នាក់ស្រុក ៩៦នាក់ (ស្ត្រី២៧នាក់) គ្រូបង្គោល IPM ៣០នាក់ (ស្ត្រី១២នាក់) ភ្នាក់ងារផ្សព្វផ្សាយឃុំ ១៦៨នាក់ (ស្ត្រី៨៥នាក់) ក្រុមប្រឹក្សាឃុំ ៨៤នាក់ (ស្ត្រី១០នាក់) ជនបង្គោលស្ត្រីនិងកុមារឃុំ ៨៤នាក់ ភ្នាក់ងារសុខភាពសត្វភូមិ ១២០នាក់ ភ្នាក់ងារផ្សព្វផ្សាយភូមិ ៩០នាក់ (ស្ត្រី២៥នាក់) និងទីប្រឹក្សាកសិកម្ម ៦នាក់ (ស្ត្រី១នាក់)។

**ង. យេនឌ័រក្នុងវិស័យកសិកម្ម:**

-វគ្គស្តីពីការវិភាគយេនឌ័រ ដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ចំនួនអ្នកចូលរួម ៥៥នាក់ (ស្ត្រី៣៩នាក់)

-វគ្គស្តីពីគោលគំនិតយេនឌ័រ ចំនួនអ្នកចូលរួម ៧៤នាក់ (ស្ត្រី ៥១នាក់)

-វគ្គស្តីពីការប្រើប្រាស់ផ្ទាំងរូបភាពយេនឌ័រ ចំនួនអ្នកចូលរួម ៦៨នាក់ (ស្ត្រី ៤៤នាក់)

-វគ្គស្តីពីពង្រឹងសមត្ថភាព និងកសាងទំនុកចិត្តដល់បុគ្គលិកជាស្ត្រី ចំនួនអ្នកចូលរួម ៨៩នាក់ (ស្ត្រី២៣នាក់) នៅខេត្តក្រចេះនិងព្រះវិហារ

-វគ្គស្តីពីទម្រង់របាយការណ៍ ដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំចំនួនអ្នកចូលរួម ៧៩នាក់ (ស្ត្រី២៨នាក់)

-វគ្គស្តីពីជំនាញកែច្នៃម្ហូបអាហារដល់ក្រុមស្ត្រី ចំនួនអ្នកចូលរួម ១០នាក់ នៅខេត្តព្រះវិហារ

-វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការប្រើប្រាស់គោលការណ៍សហគ្រាសខ្នាតតូច និងផែនការជំនួញ អ្នកចូលរួមចំនួន ២៩នាក់ (ស្ត្រី៧នាក់) និងបណ្តុះបណ្តាលបន្តដល់ក្រុមស្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំចំនួន ១១នាក់ នៅខេត្តរតនគីរី។

**តារាង- លទ្ធផលនៃការអនុវត្តហិរញ្ញវត្ថុ**

| ប្រភពថវិកា | ថវិកាប្រចាំឆ្នាំ | ចំណាយជាក់ស្តែង | % សម្រេចបាន |
|---|---|---|---|
| IFAD | ២.៧៧៨.៥៨៨,២២ | ២.២៣៩.៣៦៦,៨៤ | ៧៩,០៦ |
| បដិភាគរដ្ឋាភិបាល | ១៧១.៤៧៧,៤៧ | ១១៦.២២២,០៨ | ៦៧,៦៨ |
| សរុប | ២.៩៥០.០៦៥,៦៩ | ២.៣៥៥.៥៨៨,៩២ | ៧៩,៨៤ |

## ២. ទិសដៅ

### ក. ការលើកកំពស់ជីវភាពរស់នៅ

-**ក្រុមកែលម្អជីវភាព LIG**÷បណ្តុះបណ្តាលសាលារៀនស្រែកសិករ២០សប្តាហ៍ក្រុមកែលម្អជីវភាព LIG និងក្រុមងាយរងគ្រោះ MVF ពង្រឹងលើទុនបង្វិលក្រុម GRF សមាគមកសិករឬសហគមន៍អភិវឌ្ឍន៍កសិកម្ម និងទស្សនៈកិច្ចកសិករក្រុមខ្សោយទៅមើលក្រុមរឹងមាំ។

-**កម្មវិធីបំពេញបន្ថែម**÷ ភ្នាក់ងារសុខភាពសត្វភូមិ ផ្សព្វផ្សាយ និងការណែនាំ និងពិព័ណថ្នាក់ស្រុក

-**ការគាំទ្រផ្នែកសេវាកម្មកសិកម្ម**÷ បណ្តុះបណ្តាលបុគ្គលិក គាំទ្រផែនការ និងការតាមដានវាយតម្លៃដល់ក្រុមប្រឹក្សាឃុំ

**- យេនឌ័រក្នុងវិស័យកសិកម្ម÷** ការបណ្តុះបណ្តាលយេនឌ័រ ការត្រួតពិនិត្យផលប៉ះពាល់យេនឌ័រ គាំទ្រការផ្សព្វផ្សាយពីអាហារូបត្ថម្ភ

**ខ. ការគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យកសិកម្ម**

ជារួមការគាំទ្រកម្មវិធីវិនិយោគខេត្ត ការគ្រប់គ្រង និងវិភាគគោលនយោបាយ សិក្សាវិភាគគោលនយោបាយ និងផ្លាស់ប្តូរបទពិសោធន៍ និងបណ្តុះបណ្តាលមន្រ្តីគម្រោង។

**គម្រោងបង្កើតផែនការមេសម្រាប់ការសម្របសម្រួលជំរុញការវិនិយោគក្នុងវិស័យកសិកម្ម** (Project for the Establishment of Mater Plan to Install Coordination Agency Specializing in Agriculture Investment Promotion)- Republic of Korea ៖

**-គម្រោងបង្កើតផែនការមេសម្រាប់ការសម្របសម្រួលជំរុញការវិនិយោគក្នុងវិស័យកសិកម្ម**

បានចាប់ផ្តើមអនុវត្តក្រោមកិច្ចសហការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ KOICA (ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ)។ គម្រោងមានថវិកាសរុបជាជំនួយឥតសំណងចំនួន១លានដុល្លាអាមេរិក អនុវត្តក្នុងរយៈពេល២០១១-២០១៣។ គម្រោងនេះអនុវត្តលើសកម្មភាពសំខាន់ៗចំនួន៣ រួមមានសកម្មភាព (១) រៀបចំផែនការ ដើម្បីបង្កើតភ្នាក់ងារសម្របសម្រួល សម្រាប់ជំរុញការវិនិយោគក្នុងវិស័យកសិកម្ម (២) សិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់លើផ្នែកនានាដែលទាក់ទងទៅនឹងការជំរុញវិនិយោគក្នុងវិស័យកសិកម្ម និង (៣) រៀបចំបើកវគ្គបណ្តុះបណ្តាលសម្រាប់ពង្រឹងសមត្ថភាពស្ថាបននិងមន្រ្តីសមភាគី ។

**ក. លទ្ធផល÷**

-បានពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួន រួមមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ

-បានជួបប្រជុំពិភាក្សាជាមួយសមភាគីកម្ពុជា (ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ) លើការងារអនុវត្តនិងគ្រប់គ្រងគម្រោង ការរៀបចំបង្កើតគណកម្មការតម្រង់ទិសគម្រោង ការរៀបចំបង្កើតក្រុមការងារបច្ចេកទេស សមភាគីគម្រោង

-បានចុះសិក្សាស្វែងយល់អំពីស្ថានភាពវិស័យកសិកម្មនៅខេត្តកំពង់ចាម និងខេត្តក្រចេះ

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការចាប់ផ្តើមអនុវត្តគម្រោង

**ខ. ទិសដៅ÷**

ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន និងមន្រ្តីសមភាគីកម្ពុជា សិក្ខាសាលាចំនួន ០២ វគ្គ នាពេលខាងមុខ និងរៀបចំរបាយការណ៍បឋមនិងសេចក្តីព្រាងរបាយការណ៍ចុងក្រោយនៃការអនុវត្តគម្រោង។

**-គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យនិងភូតគាមអនាម័យនៅក្នុងមហាអនុតំបន់មេគង្គ (Trade Facilities: Improved SPS Handing in the GMS Trade Project)-ADB**

គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យនិងភូតគាមអនាម័យនៅក្នុងមហាអនុតំបន់មេគង្គ**ចាប់ផ្តើមអនុវត្ត** ក្រោមកិច្ចសហការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ធនាគារអភិវឌ្ឍន៍អាស៊ី ។ គម្រោងនេះមានថវិកាវិនិយោគសរុបចំនួន ១១,៤ លានដុល្លាអាមេរិក ដោយអនុវត្តរយៈពេល ២០១២-២០១៦ ។ គម្រោងនេះអនុវត្តលើសកម្មភាពសំខាន់ៗមួយចំនួន រួមមានសកម្មភាព (១) ពង្រឹងកម្មវិធីអង្កេតតាមដាននិងត្រួតពិនិត្យសុខភាពសត្វ រុក្ខជាតិនិងសុវត្ថិភាពចំណីអាហារ (២) កែលម្អកិច្ចសហប្រតិបត្តិការនិងសុខដុមនីយកម្មតំបន់ និង (៣) ពង្រីកកំរិតអប់រំ ការបណ្តុះបណ្តាលអំពីអនាម័យនិងភូតគាមអនាម័យនៅតាមមហាវិទ្យាល័យ ។ ក្នុងនោះ បានរៀបចំបង្កើតគណៈកម្មការពិនិត្យនិងវាយតម្លៃឯកសារលទ្ធកម្មគម្រោង និងបាននិងកំពុងរៀបចំបង្កើតអង្គភាពអនុវត្តគម្រោង។

# ជំពូក ៣
# វាយតម្លៃនិងសន្និដ្ឋាន

## ៦-វាយតម្លៃរួម

ផ្អែកលើលទ្ធផលទទួលបានក្នុងឆ្នាំ២០១១-២០១២ កន្លងមកនេះ យើងអាចវាយតម្លៃជារួមក្នុងការអនុវត្តនារយៈពេលមួយឆ្នាំកន្លងមកនេះ ទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ ជាពិសេសជំនន់ទឹកភ្លៀងចុងរដូវវស្សា និងការខ្វះទឹកក្នុងរដូវប្រាំងកន្លងមកយ៉ាងណាក៏ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងមានការចូលរួមគ្រប់ក្រសួងស្ថាប័នអាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្មក្នុងឆ្នាំ២០១១-២០១២ មានការកើនឡើងគួរជាទីមោទនៈ។

ជាក់ស្តែងស្រូវរដូវវស្សាឆ្នាំ២០១១នេះ យើងបានដាំដុះស្រូវរដូវវស្សាលើផ្ទៃដីសរុប ២,៥០លានហត ដែលមានទិន្នផលជាមធ្យមចំនួន២,៩២ត/ហត ដោយទទួលបរិមាណផលសរុបប្រមាណ ៦,៧លានតោន និងស្រូវរដូវប្រាំងឆ្នាំ២០១១-២០១២ លើផ្ទៃដីជាង ០,៤៧លានហិកតា ដែលមានទិន្នផលជាមធ្យម ៤,៤ត/ហត ដោយទទួលបានបរិមាណផលសរុប ២,០៨លានតោន។ សរុបទាំងរដូវវស្សានិងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុប ២,៩៧លានហត ដោយទទួលបរិមាណផលសរុបប្រមាណ ៨,៧៨លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ៣,១៧ត/ហត។ ដូច្នេះតុល្យភាពស្បៀងនៅសល់ជាង ២,៧៨លានតោនអង្ករ គិតជាស្រូវជាង ៤,៣៤លានតោន លើសឆ្នាំមុន ០,៤លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំ កន្លងមកប្រមាណ ១,៣លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំណាស់។ ការស្រាវជ្រាវដំណាំស្រូវ ស្វែងរកបច្ចេកទេសមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវ បានអនុវត្តការងារពិសោធន៍ ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅតាមកសិដ្ឋាន ស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្ម និងស្រែកសិករ មានជាអាទិ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធិភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សុំពូជ និងការពិសោធន៍អំពីវិធីសាស្ត្រដាំដុះដំណាំស្រូវផ្សេងៗទៀត មានចំនួនសរុប៧០ ពិសោធន៍ការធ្វើបង្ហាញសរុបចំនួន១០០ស្រែបង្ហាញ ធ្វើទិវាស្រែសរុបចំនួន៦៩កន្លែង និងរៀបចំទស្សនៈកិច្ចសិក្សា៣៩លើក ដោយមានកសិករចូលរួមសរុប ២.៤៧០នាក់ ។

ចំពោះដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុន។ ជារួមឈានមកដល់ពេលបច្ចុប្បន្ន ការងារបង្កបង្កើនផលឆ្នាំ ២០១១-២០១២ នេះ ទទួលបានផលយ៉ាងល្អប្រសើរ។

រីឯផលិតកម្មសត្វជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍ជាវិជ្ជមានគួរកត់សម្គាល់ ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងគោ-ក្របីត្រូវបាននាំចេញទៅបរទេសមួយចំនួនផងដែរ។ បើសិនធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១១ ឃើញថាផលិតកម្មគោកើនប្រមាណ ១,១% ក្របីថយចុះ ១,៧៥%។ ការចិញ្ចឹមបក្សីពីឆ្នាំ ២០០៧ ដល់ ២០១១ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៧% គឺពី ១៥លានក្បាល ដល់ ២១,៦លានក្បាល។ ចំពោះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែផ្សេងៗ និងចំការ។ល។ កំពុងមានការរីកចំរើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សំគាល់ថា មកដល់ឆ្នាំ ២០១១ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសមានចំនួន ២១៣.១០៤ហត គឺកើនឡើង ១៧,៥% ប្រៀបធៀបទៅនឹងឆ្នាំ ២០១០ ក្នុងនោះ ការអភិវឌ្ឍវិស័យកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍គឺកើនឡើង១៨,៤៣% បើប្រៀបធៀបនឹងឆ្នាំ២០១០។

វិស័យព្រៃឈើកំពុងតែត្រូវធានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ។ មកទល់នឹងឆ្នាំ២០១១នេះ សកម្មភាពដាំឈើជាចំការសម្រេចបានសរុបចំនួន ៣៣.៥៤០ហត ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបានចំនួន ១.៨២០ហត ក្រុមហ៊ុនវិនិយោគឯកជនដាំដុះបាន

ចំនួន ៣០.៣៦៥ ហត  គ្រួសារឯកជនខ្នាតតូចដាំបាន ១.៣៥៥ហត។ ទន្ទឹមនឹងនោះ សហគមន៍ព្រៃឈើសរុបចំនួន ៥៦១ សហគមន៍ ត្រូវបានបង្កើតឡើង ហើយគ្រប់គ្រងលើផ្ទៃដីសរុបចំនួន ៤៨១.៧៧៩ហត។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង ១០% គឺពី ៤០៥ពាន់តោននៅឆ្នាំ២០១០ ដល់ ៤៤៥ពាន់តោននៅឆ្នាំ២០១១ ហើយអាជីវកម្មនេសាទសមុទ្រសម្រេចបាន ៩១ពាន់តោន កើនលើសឆ្នាំមុន ៧%។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើ សម្រេចបាន ៧២ពាន់តោន កើនបាន ២០% និងសហគមន៍នេសាទមានចំនួន ៤៦៩សហគមន៍ ដែលបានចុះបញ្ជីការធ្វអាជីវកម្មនេសាទចំនួន៣២៤សហគមន៍រួចហើយ។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្ម និងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ដូចជាការងារវិនិយោគសាធារណៈ ការរៀបចំគម្រោងជាច្រើនសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការកើនឡើងខ្លាំង ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ឱ្យកាន់តែទូលំទូលាយ កិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានរៀបចំរួចរាល់បានកាន់តែច្រើនជាលំដាប់ផងដែរ។

ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លំអិតនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋផងដែរ។

ជាសន្និដ្ឋាន កសិកម្មកម្ពុជាក្នុងឆ្នាំ២០១១-២០១២សម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយសារការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងយុទ្ធសាស្ត្រ ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ៧-ទិសដៅរួម

វិស័យកសិកម្មជាវិស័យអាទិភាព ដែលរាជរដ្ឋាភិបាលបានកំណត់ នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ តាមរចនាសម្ព័ន្ធមុំ បួននៃចតុកោណប្រទាក់ក្រឡាគ្នា។ ចតុកោណយុទ្ធសាស្ត្រទី១ ពាក់ព័ន្ធនឹងភារៈកិច្ចសំខាន់ៗ ជាស្នូលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺបន្តការលើកស្ទួយវិស័យកសិកម្ម ដែលនៅក្នុងនោះមាន ៤មុំជាចំបង (១)-ការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម (២)-កំណែទំរង់ដីធ្លីនិងបោសសំអាតមីន (៣)-កំណែទម្រង់វិស័យ នេសាទ និងជលផល (៤)-កំណែទម្រង់ព្រៃឈើ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣) ស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយផែនការយុទ្ធសាស្ត្រកសិកម្ម និងទឹក (២០០៦-២០១០) ដែលបានរៀបចំហើយនោះ ក៏បានរៀបចំ និងដាក់បញ្ចូលនូវសកម្មភាពអាទិភាពតាមផ្នែក និងអនុផ្នែក នៅក្នុងគម្រោងវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល សំដៅការស្វែងរកប្រភពទុន និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៩-២០១៣។ ដោយឡែកសម្រាប់ឆ្នាំ២០១២-២០១៣នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅរួមមួយចំនួនដូចខាងក្រោម ÷

១-ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០០៩-២០១៣ ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រដ៏ទៃទៀតរបស់រាជរដ្ឋាភិបាល ដូចជាយុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ យុទ្ធសាស្ត្រកសិកម្ម និងទឹក។ល។ ជាមួយនោះរៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យម

២-ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការគាំទ្រការអនុវត្ត យុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

៣-សិក្សាលទ្ធភាពនៃការរៀបចំកសាងផែនការមេ ដោយត្រូវរៀបចំជាផែនការសកម្មភាពលម្អិតអនុវិស័យនីមួយៗ បន្ថែមទៀត សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មសម្រាប់រយៈពេលវែង២០១៣-២០៣៨ ដើម្បីយកទៅអនុវត្តនៅក្នុងទីវាលជាក់ស្តែង។

៤-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធី (Program Budgeting) នៃផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ថវិការដ្ឋ ឱ្យចំទិសដៅអាទិភាព និងប្រសិទ្ធភាពខ្ពស់

៥-បន្តពង្រឹងដឹកនាំគ្រប់គ្រងរបស់ក្រសួង តាមរូបភាពរដ្ឋបាល ចាត់តាំងយន្តការ វិន័យច្បាប់ និងការកសាងសមត្ថភាព អភិវឌ្ឍន៍ធនធានមនុស្សទៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង ឱ្យស្របតាមដំណើការអភិវឌ្ឍន៍បច្ចុប្បន្ន។

៦-កែទម្រង់ការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ឱ្យបានសមស្របតាមរចនាសម្ព័ន្ធរបស់ក្រសួង។

៧-បង្កើនកិច្ចសហការឱ្យបានកាន់តែប្រសើរឡើង ជាមួយដៃគូរអភិវឌ្ឍន៍នានាដូចជាៈ សហគមន៍ផ្តល់ជំនួយផ្នែកឯកជន និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត

៨-បន្តពង្រឹងការគ្រប់គ្រង តម្រង់ទិសលើការវិនិយោគរបស់ផ្នែកឯកជន ក្នុងវិស័យកសិកម្ម ពិសេសលើការវិនិយោគសម្បទានដីសេដ្ឋកិច្ច និងការវិនិយោគផលិតកម្មខ្នាតតូចដទៃទៀត

៩-សហការជាមួយដៃគូអភិវឌ្ឍនានា ក្រោមក្របខ័ណ្ឌក្រុមការងារបច្ចេកទេសចំរុះ របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍដូចជា÷ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្រុមការងារបរិស្ថាន និងព្រៃឈើ ក្រុមការងារបច្ចេកទេសជលផល។ល។

១០-រៀបចំលិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រងធនធានដី ដែលមានលក្ខណៈគុណភាពអំណោយផលផលិតកម្មកសិកម្ម និងចូលរួមកសាងលិខិតបទដ្ឋានច្បាប់ ក្នុងគោលដៅគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម ព្រមទាំងការចែកចាយទិន្នន័យព័ត៌មានទាក់ទង នឹងសម្បទានដីសេដ្ឋកិច្ចជាសាធារណៈ តាមរយៈ Website របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនេះជំរុញការត្រួតពិនិត្យ និងតាមដានពីហេតុប៉ះពាល់បរិស្ថាន លើគ្រប់គម្រោងទាំងអស់ដែលពាក់ពន្ធ័វិស័យកសិកម្ម។

១១- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្មនាពេលបច្ចុប្បន្ន រួមមាន÷

-ច្បាប់ការពាររុក្ខជាតិ និងភ្នូតគាមអនាម័យ ច្បាប់ដីកសិកម្ម និងច្បាប់សហគមន៍កសិកម្ម

-រៀបចំគោលនយោបាយជាតិសម្រាប់អភិវឌ្ឍសហគមន៍កសិកម្ម

-អនុក្រឹត្យស្តីពី "ការគ្រប់គ្រងរោងជាងផលិត កែច្នៃ ដំឡើង និងរោងជាងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម"

-អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពី "ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ" និងអនុក្រឹត្យស្តីពី "បុណ្យដារលាន"

-ប្រកាសរួមស្តីពី "សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកំចាត់សមាសភាពចង្រៃ"

-ប្រកាសស្ដីពី "ការតែងតាំងនគរបាលយុត្តិធមិសម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ"

-វិសោធនកម្មប្រកាសស្ដីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់និងត្រារបស់មន្ត្រីភូតគាមអនាម័យ

១២- ជំរុញការលើកកំពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម តាមរយៈការស្តារ និងកសាង ហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឲ្យការងារពិសោធន៍ ស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្តើរៗនូវគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញ

១៣- ពង្រឹង និងពង្រីកសេវាអប់រំផ្សព្វផ្សាយបច្ចេកទេស ជូនដល់ប្រជាកសិករឲ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀត តាមរយៈការកសាងមណ្ឌលផ្សព្វផ្សាយកសិកម្មឃុំ និងដំណើរការសកម្មភាពកសាងសមត្ថភាពមូលដ្ឋាន គ្រប់រូបភាព ដូចជាការបើកសាលារៀនស្រែកសិករ ការបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ការធ្វើស្រែបង្ហាញ ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា

១៤- រៀបចំចុះបញ្ជី និងព្រងឹងសហគមន៍កសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្ម មានលក្ខណៈប្រមូលផ្តុំ ក្នុងភាពជាដៃគូរជាមួយផ្នែកឯកជននានា ដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មី និងឥណទានគ្រប់គ្រាន់សម្រាប់ការពង្រីកផលិតកម្ម ជាពិសេសដំណាំស្រូវតម្រង់ឆ្ពោះទៅកាន់ទីផ្សារនាំចេញ

១៥- ជំរុញការងារអង្កេតសិក្សា វាយតម្លៃ និងការធ្វើសារពើភ័ណ្ឌការប្រើប្រាស់ដីកសិកម្មឱ្យបាននៅទូទាំងប្រទេស ដើម្បី ទទួលបាននូវទិន្នន័យជាក់លាក់ជាធាតុចូល សម្រាប់បម្រើឱ្យការរៀបចំផែនការ អភិវឌ្ឍវិស័យកសិកម្ម ដោយអាចកំណត់បានដំបន់ដាំដុះជាក់លាក់ តម្រង់ទិសដល់ការធ្វើប្រពលវប្បកម្ម និងពិពិធភាវូបនីយកម្មកសិកម្ម ជាពិសេសនៅតាមតំបន់មានប្រភពទឹក

១៦- ពង្រឹងឡើងវិញរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យគ្រឿងយន្តកសិកម្មរាជធានី-ខេត្ត ដោយរៀបចំផែនការដាក់ឲ្យផ្នែកនេះដំណើរការបានល្អប្រសើរឡើងវិញ និងត្រូវបង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍនានា រួមទាំងវិស័យឯកជន ដើម្បីអភិវឌ្ឍយន្តូបនីយកម្មកសិកម្មនៅកម្ពុជាឲ្យមានប្រសិទ្ធភាពនិងចីរភាព

១៧- រៀបចំទិវាផ្កាជាការដាស់រំលឹកដល់គ្រប់មន្ទីរកសិកម្មរាជធានី ខេត្ត ឱ្យមានការយកចិត្តទុកដាក់ខិតខំជំរុញការងារស្រាវជ្រាវនិងអភិវឌ្ឍដំណាំលម្អ

១៨- ពង្រឹង និងពង្រីកសមត្ថភាពពិសោធន៍វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកា ដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យគ្រប់គ្រាន់ សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធ្វូបទកម្មលើផលិតផល និងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកំពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងធានាសុខភាពសាធារណៈ

១៩- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍជាតិអន្តរជាតិ និងផ្នែកឯកជនសំដៅគៀងគរជំនួយឧបត្ថម្ភគ្រប់ប្រភេទចាំបាច់សម្រាប់ការចូលរួមចំណែក ក្នុងបុព្វហេតុការស្រាវជ្រាវអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាដើម្បីលើកកំពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម

២០- បន្តនូវប្រពៃណីល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្ម ការិយាល័យកសិកម្មស្រុក ក៏ដូចជាមន្ទីរ ការិយាល័យជំនាញពាក់ព័ន្ធឱ្យបានល្អប្រសើរ ដើម្បីធ្វើយ៉ាងណាឱ្យកសិករទទួលបានបន្ថែមទៀតនូវព័ត៌មានថ្មីៗស្តីពី បច្ចេកទេសផលិតកម្មកសិកម្មទាន់សភាពការណ៍ និងមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងស្មារតីសាមគ្គីភាពទូលាយ

២១- ការកែលំអរពូជ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា-ចិន និងការបង្កាត់ពូជគោសាន់តា និងស៊ីមប្រា ដោយសិប្បនិម្មិតនៅខេត្តពោធិសាត់ ការបង្កាត់ជ្រូកពូជដោយសិប្បនិម្មិតនៅខេត្តតាកែវ ការ បង្កាត់ពូជមាន់ យេអាយ នៅខេត្តសៀមរាប ហើយផ្សព្វផ្សាយពូជបន្តដល់ខេត្តផ្សេងៗទៀត

២២- ដំណាំចំណីសត្វនៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ជាកន្លែងផ្សព្វផ្សាយពូជស្មៅ និងចែកចាយពូជទៅតាមបណ្តាខេត្តនានា និងដាំស្មៅបង្ហាញ នៅតាមខេត្ត ស្រុក ផ្សេងទៀត

២៣- បន្តការគ្រប់គ្រងកាកសំណល់សត្វ និងពង្រឹងការសាងសង់ឡ ជីវឧស្ម័ន

២៤- ពង្រឹងការ ទប់ស្កាត់នូវជម្ងឺអុតក្តាម សាទឹក បូសខ្យល់ ជំងឺជ្រូកត្រចៀកខៀវ ជំងឺផ្តាសាយបក្សី

២៥- រៀបចំសេចក្តីច្បាប់ស្តីពី ផលិតកម្មសត្វ និងសុខភាពសត្វ ប្រកាស និងលិខិតបទដ្ឋាននានា សម្រាប់បំរើវិស័យផលិតកម្មនិងបសុព្យាបាល

២៦- ជំរុញបន្ថែមការអភិវឌ្ឍន៍លើវិស័យចិញ្ចឹមសត្វគ្រប់ប្រភេទ ដោយសង្កត់លើការកែលំអពូជ ចំណីសត្វ បញ្ជ្រាបបច្ចេកវិជ្ជាទំនើបក្នុងការចិញ្ចឹមសត្វដល់ស្រទាប់កសិករ និងឡជីវឧស្ម័នក្នុងគោលដៅបង្កើនផលិតភាពសត្វទាំងបរិមាណ និងគុណភាព

២៧- ពង្រឹងពង្រីកការងារត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជម្ងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ឬពីតំបន់មួយទៅតំបន់មួយទៀត តាមរយៈបង្កើនកម្មវិធីយុទ្ធនាការចាក់ថ្នាំការពារសត្វ ជីវសុវត្ថិភាព ពង្រឹងសមត្ថភាពបន្ថែម ដល់ភ្នាក់ងារសុខភាពសត្វភូមិ និងការពិនិត្យចលនាសត្វក្នុងប្រទេស និងក្រៅប្រទេសឱ្យបានត្រឹមត្រូវ

២៨- ជំរុញការងារសុខភាពសាធារណៈ ដោយផ្តោតជាសំខាន់លើការគ្រប់គ្រងសត្តឃាតដ្ឋាន ការពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសាច់ នៅតាមសត្តឃាតដ្ឋាន និងទីផ្សារ ក្នុងទិសដៅកាត់បន្ថយ ឬលុបបំបាត់ជំងឺឆ្លងតាមរយៈសាច់ និងផលិតផលសាច់ ដើម្បីធានាសុវត្ថិភាពចំណីអាហារដល់ប្រជាពលរដ្ឋ

២៩- ផ្សព្វផ្សាយការយល់ដឹងសាធារណៈស្តីពីច្បាប់កៅស៊ូ ពង្រីកសេវាណែនាំបច្ចេកទេសបន្តដល់កសិករពាក់ព័ន្ធការរៀបចំយន្តការធ្វើវិញ្ញាបនកម្មច្បារពូជនិងបណ្តុះបណ្តាលអ្នកធ្វើច្បារពូជ តាមដានការអនុវត្តផែនការវិនិយោគនៅលើដីសម្បទានសេដ្ឋកិច្ចសង្គមកិច្ច និងវាយតម្លៃ ការចុះស្រង់ស្ថិតិកៅស៊ូគ្រួសារនៅក្នុងខេត្តគោលដៅ ព្រមទាំងពង្រឹងសមត្ថភាពសមាគមកៅស៊ូគ្រួសារឱ្យបានកាន់តែរឹងមាំ

៣០- ទំនាក់ទំនងជាមួយដៃគូរអភិវឌ្ឍន៍ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា វិទ្យាសាស្រ្ត និងខិតខំគៀងគររកប្រភពទុន ពីស្ថាប័នភ្នាក់ងារហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស

៣១- ការពង្រឹងសមត្ថភាពធ្វើតេស្តនិងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ ការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ និងផ្តល់លិខិតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (CSR) ដើម្បីលើកកម្ពស់គុណភាពកៅស៊ូកម្ពុជា ការសិក្សាស្រាវជ្រាវព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ និងអំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុង និងក្រៅប្រទេស

៣២- ជំរុញចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន ដើម្បីធ្វើជាស្នូលក្នុងការជួយទ្រទ្រង់ដល់ចម្ការកៅស៊ូគ្រួសារ ដែលស្ថិតនៅជុំវិញ

៣៣- ពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ជា បទបញ្ញត្តិ លិខិតបទដ្ឋានពាក់ព័ន្ធនិងវិស័យព្រៃឈើ (ច្បាប់ស្តីពីព្រៃឈើបទបញ្ជាលេខ០១-០២សជណនិងអនុសាសន៍របស់សម្តេចតេជោ) ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាតទប់ស្កាត់និងបង្ក្រាបបទល្មើសឱ្យបានទាន់ពេលវេលា ទន្ទឹមនឹងការពង្រឹងវិន័យការងារចំពោះមន្ត្រីមានសមត្ថកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មសាធារណៈ និងអភិបាលកិច្ចល្អនៃវិស័យព្រៃឈើ

៣៤- រៀបចំធនធានមនុស្សនិងលិខិតបទដ្ឋានក្រោមច្បាប់ ដើម្បីអនុវត្តរចនាសម្ពន្ធ័រដ្ឋបាលព្រៃឈើតាមអនុក្រឹត្យលេខ១៨៨អន.ក្រ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបន្តសហការជាមួយស្ថាប័នពាក់ពន្ធ័ និងអាជ្ញាធរដែនដីបោះបង្គោលកំណត់ព្រំប្រទល់ដែនព្រៃឈើឱ្យបានយ៉ាងតិច១.០០០គ.ម និងអនុវត្តបន្តកម្មវិធីសហគមន៍ព្រៃឈើជាតិ ដោយសហការ

ជាមួយដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរមូលដ្ឋានពាក់ពន្ធ័រៀបចំបង្កើត និងធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ ឱ្យបានយ៉ាងតិច ១០០ កន្លែង

៣៥- ជំរុញដាំព្រៃឈើសម្រាប់បម្រើដល់ពហុប្រយោជន៍ នៃសេដ្ឋកិច្ច សង្គម និងសេវាបរិស្ថានយ៉ាងតិច ១០.០០០ហត/ឆ្នាំ និងបណ្តុះកូនឈើចែកចាយជូនប្រជាពលរដ្ឋដាំឱ្យបាន១០លានដើម និងរៀបចំបុណ្យរុក្ខទិវាដាំដើមឈើ។ សហការជាមួយដៃគូអភិវឌ្ឍន៍ រៀបចំបង្កើតប្រពន្ធ័គណនេយ្យឥណទានកាបូនព្រៃឈើ (Forest Carbon Accounting System) ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើលើបញ្ហាថ្មីៗ នៃឥណទានកាបូនព្រៃឈើ

៣៦- ជំរុញការយកចិត្តទុកដាក់រៀបចំបញ្ចប់ផែនការគ្រប់គ្រងព្រៃឈើ ដោយផ្ទេរការរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិទូទាំងប្រទេស និងដំណើរការគ្រប់គ្រងព្រៃឈើនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយនិរន្តរភាព ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់គោលសំខាន់ៗ ដែលពាក់ពន្ធ័ផ្សេងទៀត

៣៧- ខិតខំបន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ** ***"ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ"*** ដោយបន្តលែងប្រភេទពូជត្រីនិងបង្កងក្នុងស្រុកចូលតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកមច្ឆជាតិបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ

៣៨- បន្តការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលឲ្យកាន់តែប្រសើរ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងវែងទាំងក្នុងនិងក្រៅប្រទេស ដោយរួមទាំងអ្នកនេសាទ សហគមន៍ នេសាទ និងអ្នកចិញ្ចឹមត្រីផង

៣៩- បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីជំរុញការងារអភិវឌ្ឍន៍វារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

៤០- បន្តផលិតឯកសារបច្ចេកទេសការផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលនិងបន្តបង្កើនការងារបណ្តុះបណ្តាលដល់មន្ត្រីរាជការនិងកសិករចិញ្ចឹមត្រី ផលិតកូនត្រីពូជ ដើម្បីពង្រីកសកម្មភាពផ្សព្វផ្សាយវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

៤១- ជំរុញការរៀបចំបង្កើតសហគមន៍នេសាទ នៅតាមបណ្តាខេត្តពាក់ព័ន្ធឱ្យបានកាន់តែច្រើនថែមទៀត

៤២- បង្កើនសកម្មភាពត្រួតពិនិត្យ និងលុបបំបាត់បទល្មើសជលផលតាមបណ្តាខេត្តនិងរៀបចំវិធានការការពារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត

៤៣- ជំរុញការអភិវឌ្ឍន៍សមាគមន៍អ្នកកែច្នៃជលផលឱ្យកាន់តែល្អប្រសើរទាំងបរិមាណនិងគុណភាព

៤៤- បង្កើនការយល់ដឹងនិងសមត្ថភាពរបស់អ្នកកែច្នៃឲ្យកាន់តែល្អប្រសើរឡើង លើការអនុវត្តការធ្វើអនាម័យល្អ និងការអនុវត្តការផលិតល្អក្នុងខ្សែសង្វាក់ផលិតកម្មកែច្នៃជលផល

៤៥- រៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សនិងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

៤៦-សម្របសម្រួលតាមដានត្រួតពិនិត្យ និងវាយតំលៃល្បឿននៃការអនុវត្តផែនការ និងកម្មវិធីនានាទាំងវិស័យ និងអនុវិស័យទាំងអស់ ដើម្បីលើកជាសំណើតំរង់ទិសនៅឆ្នាំខាងមុខ និងត្រៀមលក្ខណៈកសាងផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលវែង ២០១៣-២០៣៨

៤៧- ជំរុញល្បឿនការងារបង្កបង្កើនផលស្រូវនិងដំណាំកសិកម្មឆ្នាំ២០១២-២០១៣ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស និងពង្រឹងសមត្ថភាពត្រួតពិនិត្យលើការងារស្ថិតិកសិកម្ម ដើម្បីសម្រួលដល់ការបញ្ចូល វិភាគ និងចងក្រងទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ។ ជាពិសេសបន្តការសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្នុងការធ្វើជំរឿនស្ថិតិកសិកម្ម

៤៨- បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មទាំង ១១ រាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្ម ឱ្យកាន់តែប្រសើរឡើង និងឈានយកពត៌មានទាំង ២៤រាជធានី ខេត្ត និងបន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈ Internet ទូរទស្សន៍ វិទ្យុ និងបោះពុម្ព Leaflet, Booklet

៤៩- បន្តកិច្ចសហការជាមួយស្ថាប័ននិងអង្គភាពពាក់ពន្ធ័ និងចុះពិនិត្យស្រាវជ្រាវដោះស្រាយទំនាស់ដីរវាងប្រជាពលរដ្ឋ ជាមួយក្រុមហ៊ុនវិនិយោគឯកជន ដែលនឹងបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ និងបន្តពង្រឹងការគ្រប់គ្រងសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនវិនិយោគឯកជនទាំងអស់ ឱ្យបានកាន់តែរឹងមាំហ្មត់ចត់ត្រឹមត្រូវ នឹងឈានទៅលុបគោលការណ៍ និងកិច្ចសន្យា ចំពោះក្រុមហ៊ុនដែលអសកម្មភាពមិនគោរពតាមលក្ខខ័ណ្ឌនៃកិច្ចសន្យានិងផែនការមេ

៥០- ជំរុញរៀបចំគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច មានការអំពាវនាវដោយដាក់ឱ្យដេញថ្លៃ នូវអតីតទីតាំងសម្បទានដីសេដ្ឋកិច្ចមួយចំនួន ដែលបានលុបគោលការណ៍និងកិច្ចសន្យាកន្លងមក

៥១- ជំរុញការត្រួតពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅអង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានីខេត្ត ហើយធ្វើការស្រាវជ្រាវផ្ទៀងផ្ទាត់ និងទារបំណុល ដែលមន្ទីរកសិកម្មខេត្តអង្គភាព និងបុគ្គលនៅជំពាក់បំណុលអតីតក្រុមហ៊ុនសម្ភារៈកសិកម្ម

៥២- ជំរុញការពង្រឹកមន្ត្រីទៅធ្វើការនៅតាមខេត្ត-ក្រុង ពិសេសនៅការិយាល័យកសិកម្មថ្នាក់ស្រុកនៃមន្ទីរកសិកម្មខេត្ត-ក្រុងដាច់ស្រយ៉ាល ដើម្បីអភិវឌ្ឍន៍ពង្រឹកថ្នាក់មូលដ្ឋានឱ្យមានប្រសិទ្ធភាពខ្ពស់

៥៣- ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងរដ្ឋបាលនិងការគ្រប់គ្រង ពិសេសលិខិតបទដ្ឋាននានា និងគោលការណ៍ផ្សេងៗ ដើម្បីបម្រើឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការកែទម្រង់

៥៤- រៀបចំផែនការកម្មវិធីចុះធ្វើសវនកម្មផ្ទៃក្នុងនិងបណ្តុះបណ្តាលបច្ចេកទេសសវនកម្ម ដល់មន្ត្រីចុះធ្វើសវនកម្មតាមកម្មវិធី ដែលបានអនុម័តនិងតាមបញ្ជារបស់ថ្នាក់ដឹកនាំក្រសួង ជាពិសេសពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយអាជ្ញាធរសវនកម្មជាតិនិងសវនកម្មផ្ទៃក្នុងតាមស្ថាប័ននានា

៥៥- កែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកនៅតាមបណ្តាស្ថានីយ៍ស្រាវជ្រាវ និងបន្តអភិវឌ្ឍពូជដំណាំកសិកម្ម ដែលមានសក្តានុពលទិន្នផលខ្ពស់ ហើយប្រកបដោយគុណភាពល្អ

៥៦- ជំរុញពង្រឹងសមត្ថភាពមន្ត្រី ក៏ដូចប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និងសាលារៀនស្រែកសិករ នៅថ្នាក់ស្រុក និងមូលដ្ឋានជាពិសេសពង្រឹងការរៀបចំនិងអប់រំផ្សព្វផ្សាយ នូវសម្ភារផ្សព្វផ្សាយកសិកម្ម ដូចជា បទដ្ឋានអនុវត្តបច្ចេកវិទ្យា សៀវភៅណែនាំ វិធីសាស្ត្រផ្សព្វផ្សាយបច្ចេកទេស និងផ្ទាំងរូបភាព។ល។

៥៧- ជំរុញពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមកសិករ ទាំងការគ្រប់គ្រងការធ្វើផែនការ និងការធ្វើជំនួញនានា ជាពិសេសរៀបចំលិខិតបទដ្ឋានច្បាប់និងក្របខ័ណ្ឌយុទ្ធសាស្ត្រនានា ដើម្បីធានាការពារផលប្រយោជន៍របស់សហគមន៍អភិវឌ្ឍន៍កសិកម្មនិងកសិករ

៥៨- បន្តការអំពាវនាវ និងគៀងគរបន្ថែមទៀតពីអង្គការជាតិអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ផ្នែកហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍វិស័យកសិកម្ម

៥៩-បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាដៃគូនិងភាពជាម្ចាស់លើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យកសិកម្ម។

## ៨. វាយតម្លៃ និង សន្និដ្ឋាន

លទ្ធផលការងារក្នុងវិស័យកសិកម្មឆ្នាំ២០១១-២០១២ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន** ជាប្រមុខនិងដោយការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំក្រសួងមន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីក្រសួង ស្ថាប័នជាតិ អន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍផងនោះបានបង្ហាញឱ្យឃើញពី លទ្ធផលការងារផលិតកម្មអាជីវកម្មនិងសេវាកម្មកសិកម្ម បានទទួលការរីកចម្រើនលើគ្រប់ផ្នែក ជាពិសេសលើការងារផលិតកម្មដំណាំស្រូវ ដែលមានការកើនឡើងខ្ពស់លើសឆ្នាំមុន។ ក្នុងឆ្នាំ២០១១នេះ បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ ជាពិសេសជំនន់ទឹកភ្លៀងចុងរដូវវស្សា ចាប់ពីពាក់កណ្តាលខែតុលាដល់ពាក់កណ្តាលខែវិច្ឆិកា យ៉ាងណាក្តី ប៉ុន្តែជាក់ស្តែងស្ថានភាពផលិតកម្មកដំណាំស្រូវរដូវវស្សាឆ្នាំ២០១១នេះ ជារួមមានកម្រិតល្អទូទាំងប្រទេស។

កសិករបានដាំដុះស្រូវវស្សាលើផ្ទៃដីសរុប**២,៥០លានហត** ដែលមានទិន្នផលជាមធ្យមចំនួន**២,៩២៥/ហត** ដោយទទួលបរិមាណផលសរុបប្រមាណ**៦,៧លានតោន** និងស្រូវរដូវប្រាំងឆ្នាំ២០១១-២០១២ លើផ្ទៃដីជាង**០,៤៧លានហត** ដែលមានទិន្នផលជាមធ្យម**៤,៤៥/ហត** ដោយទទួលបានបរិមាណផលសរុប**២,០៨លានតោន**។ សរុបការដាំដុះស្រូវទាំងរដូវវស្សានិងរដូវប្រាំងអនុវត្តបានលើផ្ទៃដីសរុប**២,៩៧លានហត** ដោយទទួលបរិមាណផលសរុបប្រមាណ**៨,៧៨លានតោន**ស្រូវ ដែលមានទិន្នផលមធ្យមប្រចាំឆ្នាំ**៣,១៧៥/ហត**។ ដូច្នេះតុល្យភាពស្បៀងនៅសល់ជាង**២,៧៨លានតោនអង្ករ** គិតជាស្រូវជាង**៤,៣៤លានតោន** លើសឆ្នាំមុន ០,៤លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំ កន្លងមកប្រមាណ ១,៣លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំធេងណាស់។

តួលេខខាងលើត្រូវបានវាយតម្លៃ ពីភាពជោគជ័យនៃកំណើនផលិតផលស្រូវ ដែលបានកើនលើសក្នុងសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៩-២០១៣ ដែលបានកំណត់ថារហូតដល់ឆ្នាំ២០១៣ ទិន្នផលស្រូវនឹងបានកើនឡើងដល់៣,០០៥/ហត។ កំណើនទិន្នផលស្រូវនេះ គឺដោយសារមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ពីប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹក នាំក្រសួង មន្ត្រីរាជការក្រោមឱវាទគួបផ្សំនឹងអាកាសធាតុអំណោយផលល្អទាចុងរដូវ ព្រមទាំងប្រជាកសិករមានការយល់ដឹងក្នុងការគ្រប់គ្រងថែរក្សា ស្រែចំការ ការផ្លាស់ប្តូរបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានបរិមាណទិន្នផលខ្ពស់។

ទន្ទឹមនឹងការកើនឡើងខ្ពស់នូវបរិមាណផលស្រូវលើសពីតម្រូវការ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការគ្រប់គ្រងនិងដាំដុះព្រៃឈើ ការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូគ្រួសារនិងដំណាំកៅស៊ូឯកជន ត្រូវបានកើនឡើងគួរជាទីមោទនៈ។ រីឯការងារសេវាកម្មផ្សេងៗរួមមាន ការងារសេវាកម្មបច្ចេកទេស និងការងារសេវាកម្ម រដ្ឋបាលគ្រប់គ្រងបុគ្គលិក បណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស ការងារគោលនយោបាយផែនការហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងនិងកែលម្អប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍន៍ជាសកល។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមីនា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**